ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣

«សហគ្រាស គ្រឹះស្ថានមួយជាសហគមន៍សុខសាន្តមួយ របស់កម្មករនិយោជិតដែលពោរពេញដោយសមត្ថភាព ផលិតភាព ឥរិយាបថការងារ និងមនសិការវិជ្ជាជីវៈខ្ពស់»

ថ្ងៃព្រហស្បតិ៍ ២កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩

# មាតិកា


**អារម្ភកថា** ........ iii

**អក្សរបំព្រួញ** ........ v

**ជំពូកទី ១ សេចក្តីផ្តើម** ........ ១

**១.១- ភាពចាំបាច់នៃ ផ.យ.អ.ក.ប ២០១៩-២០២៣** ........ ១

**១.២- ចក្ខុវិស័យ** ........ ២

**១.៣- បេសកកម្ម** ........ ៣

**១.៤- គោលបំណង និងគោលដៅ** ........ ៤

**ជំពូកទី ២ ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ........ ៥

**២.១- ស្ថានភាពទូទៅនៃវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ........ ៥

២.១.១. ការផ្គត់ផ្គង់កម្លាំងពលកម្ម ........ ៥

២.១.២. តម្រូវការកម្លាំងពលកម្ម ........ ៧

២.១.៣. និន្នាការនៃតម្រូវការការងារនាពេលអនាគត ........ ១៤

២.១.៤. បញ្ហាប្រឈមនៅក្នុងទីផ្សារការងារ ........ ១៨

**២.២- សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨** ........ ២០

**២.៣- បញ្ហាប្រឈម** ........ ៣០

**ជំពូកទី ៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** ........ ៣៥

**៣.១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ** ........ ៣៥

៣.១.១. លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ........ ៣៦

៣.១.២. ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ........ ៣៨

៣.១.៣. ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ........ ៤០

៣.១.៤. ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ........ ៤១

៣.១.៥. ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ ........ ៤២

**៣.២- ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** ........ ៤៤

៣.២.១. ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........ ៤៦

៣.២.២. ពង្រីកការបណ្តុះបណ្តាលជំនាញ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ........ ៤៧

៣.២.៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........ ៤៨

៣.២.៤. លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........ ៤៩

៣.២.៥. ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍ ........ ៤៩

**៣.៣- ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស**........................................ ៥១
៣.៣.១. បង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់........................................................................ ៥២
៣.៣.២. ពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា...................................................................................................................... ៥៣
៣.៣.៣. ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជាបព័ត៌មានទីផ្សារការងារ........ ៥៤
៣.៣.៤. ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ.. ៥៥
៣.៣.៥. បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ........................................................ ៥៦
**៣.៤- ការអភិវឌ្ឍរបបសន្តិសុខសង្គម**........................................................................................ ៥៧
៣.៤.១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ........................................................ ៥៨
៣.៤.២. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព........................................................ ៥៩
៣.៤.៣. ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន........................................ ៦០
៣.៤.៤. ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ........................................................ ៦១
៣.៤.៥. អភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា........................................................ ៦១
**៣.៥- ការពង្រឹងសេវាគាំទ្រទូទៅ**........................................................................................ ៦២
៣.៥.១. ពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ............ ៦៣
៣.៥.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន........................................................................ ៦៥
៣.៥.៣. អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ........................................................................................................ ៦៦
៣.៥.៤. ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម........................................................ ៦៧
៣.៥.៥. ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ........................................ ៦៨
**ជំពូកទី ៤ ការគៀរគរប្រភពធនធានហិរញ្ញវត្ថុ**........................................................................................ ៧០
**ជំពូកទី ៥ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ**................................ ៧២
**ជំពូកទី ៦ សេចក្តីសន្និដ្ឋាន**........................................................................................ ៧៣
**ឧបសម្ព័ន្ធ ១ ÷ គំនូសបំព្រួញក្របខ័ណ្ឌនៃ ផ.យ.អ.ក.ប ២០១៩-២០២៣**........................................ ៧៥
**ឧបសម្ព័ន្ធ ២ ÷ សូចនាករស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣**.................... ៧៧
**ឧបសម្ព័ន្ធ ៣ ÷ របាយការណ៍សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨**.................................... ១០៥

# អារម្ភកថា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអនុវត្តប្រកបដោយជោគជ័យនូវអាទិភាពទាំង ៥ ដែលបានដាក់ចេញនូវក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨** កន្លងទៅនេះ។ ក្នុងនាមថ្នាក់ដឹកនាំនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ជូនចំពោះមន្ត្រីរាជការក្រោមឱវាទក្រសួងទាំងអស់ ព្រមទាំងគ្រប់ក្រសួង-ស្ថាប័ន និងដៃគូ ដែលបានរួមចំណែកខិតខំប្រឹងប្រែងយ៉ាងប្ដូរផ្ដាច់សម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរជាទីមោទនៈនេះ។

ផ្តើមចេញពីបទពិសោធន៍ក្នុងការអនុវត្តកន្លងមកនេះ ដើម្បីបន្តការអនុវត្តការងារជូនរាជរដ្ឋាភិបាលកម្ពុជា ឱ្យស្របតាមកម្មវិធីនយោបាយ និង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** របស់ រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តដាក់ចេញកាន់តែមុតស្រួច និងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់នូវ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣**។ ក្នុងការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នេះ ក្រសួងបានធ្វើអាទិភាវូបនីយកម្មនូវកម្មវិធីកំណែទម្រង់ទាំង ៥ រួមមាន ១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ២-ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៣-ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស ៤-ការអភិវឌ្ឍរបបសន្តិសុខសង្គម និង ៥-ការពង្រឹងសេវាគាំទ្រទូទៅ ដោយកំណត់នូវកម្មវិធី ចង្កោមសកម្មភាព និងសូចនាករកាន់តែសុក្រឹត និងអាចឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍របស់វិស័យទាំងមូល ស្របតាមស្ថានភាពវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងសកលលោក។

ទន្ទឹមគ្នានេះ ការដាក់ចេញនូវ **ផ.យ.អ.ក.ប ២០១៩-២០២៣** គឺដើម្បីធានាថាគ្រប់សកម្មភាពរបស់ក្រសួងមានភាពប្រទាក់ក្រឡាគ្នា សង្គតិភាពពីគ្រប់តួអង្គពាក់ព័ន្ធ និងដើម្បីធានាថាធនធានទាំងអស់របស់ក្រសួង និងដៃគូអភិវឌ្ឍន៍ត្រូវបានផ្តល់ ដោយមានទិសដៅច្បាស់លាស់ទៅដល់អាទិភាពការងារដែលបានកំណត់។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រនេះ ក៏មានគោលដៅចូលរួមអនុវត្តឱ្យសម្រេចបានជោគជ័យនូវ ក្របខ័ណ្ឌគោលនយោបាយនានា ជាអាទិ៍ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០, គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ របស់អង្គការអន្តរជាតិខាងការងារ, គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ និងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥ ដើម្បីជាមូលដ្ឋានឈានឆ្ពោះទៅសម្រេចជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅ ឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។

ជាថ្មីម្តងទៀត ក្នុងនាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះក្រុមការងារបច្ចេកទេសចងក្រង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** ដែលបានដឹកនាំសម្របសម្រួលការរៀបចំឯកសារដ៏មានសារៈសំខាន់នេះ និងសូមវាយតម្លៃខ្ពស់ចំពោះអង្គភាពពាក់ព័ន្ធគ្រប់កម្រិតរបស់ក្រសួង ដែលបានសហការគ្នាយ៉ាងស្អិតរមួត និងខិតខំប្រឹងប្រែងរួមគ្នារៀបចំនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ នេះឡើង។

ជាទីបញ្ចប់នេះ ខ្ញុំសូមបញ្ជាក់ថា ដើម្បីជោគជ័យនៃការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដូចបានកំណត់ក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងគ្រប់អង្គភាពពាក់ព័ន្ធផ្ទៃក្នុងក្រសួង ក៏ដូចជាកិច្ចសហការដ៏ស្អិតរមួតជាមួយគ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងអនុវត្តនូវបណ្តាអាទិភាពនានាដែលបានកំណត់ក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ជាពិសេស ត្រូវអនុវត្តដោយការប្រកាន់ខ្ជាប់នូវអភិក្រម ៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺ “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល** និង**វះកាត់**” និងបាវចនា ២ គឺ “**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ**” ហើយត្រូវយកផែនការយុទ្ធសាស្ត្រនេះ រៀបចំជាផែនការសកម្មភាពអនុវត្តប្រចាំឆ្នាំនៅតាមអង្គភាពប្រកបដោយការទទួលខុសត្រូវខ្ពស់ និងឆន្ទៈម្ចាស់ការ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# អក្សរបំព្រួញ

| | | |
|---|---|---|
| ក.ស.ថ.ម | : | ក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីរៀបចំដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ |
| គ.ក.ប | : | គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា |
| គ.ជ.ព | : | គណៈកម្មការជាតិប្រឆាំងពលកម្មកុមារ |
| ផ.យ.អ.ក.ប | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ផ.យ.អ.ជ | : | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| អ.ប.វ | : | អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| ទ.ជ.ម.ក | : | ទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ប.ស.ស. | : | បេឡាជាតិសន្តិសុខសង្គម |
| ផ.ស.ស | : | ផលិតផលក្នុងស្រុកសរុប |
| ស.ជ.ក | : | នាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា |
| អ.គ.ក.ប | : | អគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាក្ងដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា |
| អ.ក.ជ.ប.អ | : | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា |
| AOP | : | Annual Operation Plan |
| AQRF | : | ASEAN Qualification Reference Framework |
| BFC | : | Better Factories Cambodia |
| BSP | : | Budget Strategy Plan |
| CBT | : | Competency Based Training |
| CQF | : | Cambodia Qualification Framework |
| CTQF | : | Cambodia Trainer Qualification Framework |
| GMAP | : | Gender Mainstreaming Action Plan |
| ILO | : | International Labour Organization |
| ILO-BFC | : | International Labour Organization-Better Factory Cambodia |
| ISO | : | International Standard Organization |
| LAC | : | Labour Advisory Committee |
| MoU | : | Memorandum of Understanding |

| | | |
|---|---|---|
| MRA | : | Mutual Recognition Arrangement |
| MRS | : | Mutual Recognition Skills |
| MTOSB | : | Manpower Training and Overseas Sending Board |
| NTB | : | National Training Board |
| PB | : | Program Budgeting |
| PPP | : | Public-Private Partnerships |
| RCC | : | Recognition of Current Competencies |
| RPL | : | Recognition of Prior Learning |
| TCS | : | Teacher Competency Standard |
| TVET | : | Technical Vocational Education and Training |
| TVETMIS | : | Technical Vocational Education and Training Management Information System |
| TWG | : | Technical Working Group |
| TWG-TVET | : | Technical Working Group for Technical and Vocational Education and Training |
| WIND | : | Work Improvement in Neighborhood Development |
| WINDY | : | Work Improvement in Neighborhood Development for Youth |
| WISCON | : | Work Improvement at Small Construction Sites |
| WISE | : | Work Improvement in Small Enterprises |
| WISH | : | Work Improvement for Safe Home |

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១- ភាពចាំបាច់នៃ ផ.យ.អ.ក.ប ២០១៩-២០២៣

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំកម្ពុជាឈានទៅរកការអភិវឌ្ឍគួរជាទីមោទនៈក្នុងរយៈពេលជាង២ទសវត្សរ៍ចុងក្រោយនេះ ដោយបាននាំកម្ពុជាឈានមកដល់ដំណាក់កាលរីកចម្រើនថ្មី ទាំងក្នុងទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គម, ជាមួយការខិតខំដោយស្មារតីភ្ញាក់រលឹក និងឆន្ទៈម្ចាស់ការជាមួយការបោះជំហានដ៏មុតស្រួច និងបានប្រែក្លាយពីប្រទេសដែលធ្លាប់ត្រូវបានស្គាល់ថា គ្របដណ្តប់ដោយសង្គ្រាមស៊ីវិល, សេដ្ឋកិច្ចអន់ថយ និងញាំញីដោយភាពក្រីក្រ, មកជាប្រទេសអភិវឌ្ឍន៍ឯកទត្តជួរមុខថែមទាំងត្រូវបានប្រសិទ្ធនាមថាជា “**ខ្លាសេដ្ឋកិច្ចថ្មី**” មួយនៅអាស៊ីទៀតផង។ វឌ្ឍនភាពគួរជាទីមោទនៈបំផុតនេះបានលើកស្ទួយមុខមាត់របស់កម្ពុជានៅលើឆាកអន្តរជាតិ, ជាប្រទេសដែលមានតួនាទីយ៉ាងសកម្មដោយស្មើសិទ្ធិ និងស្មើភាព, និងជាករណីសិក្សាអំពីភាពជោគជ័យ និងគំរូឧត្តមានុវត្តមួយដោយបណ្តាប្រទេសនានានៅលើសកលលោក។

ជាក់ស្តែង, រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តដោយជោគជ័យនូវ **យុទ្ធសាស្ត្រចតុកោណ** ដើម្បី **កំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** នៅកម្ពុជា ៣ ដំណាក់កាលរួចមកហើយ ដែលបាននាំមកនូវការអភិវឌ្ឍជាច្រើន ហើយបានធ្វើឱ្យកម្ពុជាឆ្លងកាត់ដោយជោគជ័យពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីពេលថ្មីៗកន្លងទៅនេះ។ ដោយឈរលើមូលដ្ឋាននៃសមិទ្ធផលដ៏មហាធំធេងនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** ទាំង ៣ ដំណាក់កាលមកនេះ **រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា** បានបន្តដាក់ចេញកាន់តែមុតស្រួច និងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់នូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ដោយពង្រឹងបន្ថែមទៀតលើសមិទ្ធផលដែលសម្រេចបាននាអាណត្តិកន្លងមក តាមរយៈការអនុវត្តអភិក្រមទាំង៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គឺ “**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល** និង **វះកាត់**” និងបាវចនា២ គឺ “**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ**”។ ព្រមជាមួយគ្នានេះ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ក៏ជាឧបករណ៍គោលនយោបាយដ៏ស័ក្តិសិទ្ធផ្សាភ្ជាប់ជាមួយចក្ខុវិស័យ ដើម្បីសម្រេចបានជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០ ដោយកសាងជាជំហានៗ នូវសង្គមកម្ពុជាប្រកបដោយសុខសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម ការប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ

មនុស្ស សិទ្ធិការងារ និងការពង្រឹងនីតិរដ្ឋ ការកសាងជីវភាពប្រជាជនប្រកបដោយភាពសុខដុមរមនា ទាំងក្នុងសង្គមជាតិទាំងក្នុងគ្រួសារ។

ឈរលើមូលដ្ឋាននៃការវិវឌ្ឍនៃសេដ្ឋកិច្ច និងសង្គម ផលលាភប្រជាសាស្ត្រ និងចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ និងឆ្នាំ២០៥០ ជាពិសេស **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងការតម្រង់ទិសគោលនយោបាយប្រកបដោយភាពឈ្លាសវៃរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំ និងដាក់ចេញនូវ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** ដើម្បីជាមគ្គទេសក៍ចូលរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្ន។ ផ.យ.អ.ក.ប ២០១៩-២០២៣ ត្រូវបានរៀបចំឡើងដោយមានយន្តការច្បាស់លាស់ ការសិក្សា និងការពិគ្រោះយោបល់ ដោយកំណត់អំពីជម្រើសគោលនយោបាយ ផែនការសកម្មភាពដែលត្រូវអនុវត្តដោយអន្តរអង្គភាព ព្រមទាំងមានការកំណត់នូវគោលដៅ និងគោលបំណងយ៉ាងច្បាស់សម្រាប់អាណត្តិរបស់ខ្លួន។

អភិក្រមសំខាន់នៃ **ផ.យ.អ.ក.ប ២០១៩-២០២៣** គឺធានានិងលើកកម្ពស់លក្ខខណ្ឌការងារល្អប្រសើរ ពង្រឹងភាពសុខដុមរមនាទំនាក់ទំនងវិជ្ជាជីវៈ បង្កើតបរិយាកាសការងារ និងបង្កើនឱកាសការងារ និងធានាការគាំពារសង្គម ព្រមទាំងផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យស្របទៅតាមតម្រូវការទីផ្សារការងារ ដោយបង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និងគុណភាព ក្នុងនិងក្រៅប្រទេស ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការផ្តល់ជំនាញព័ត៌មានទីផ្សារការងារ កែលម្អលក្ខខណ្ឌការងារ ការលើកកម្ពស់សកម្មភាពធុរកិច្ច និងការជំរុញការវិនិយោគ។ ឯកសារផែនការយុទ្ធសាស្ត្រនេះក៏នឹងជាផែនទីចង្អុលផ្លូវសម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា ក្នុងការស្វែងរកនូវធនធានបន្ថែមសម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

## ១.២- ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺលើកកម្ពស់ជីវភាពរស់នៅ សេចក្តីថ្លៃថ្នូរ និងការគាំពារសង្គមរបស់កម្មករនិយោជិត និងទេសន្តរប្រវេសន៍ខ្មែរ, ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ, និងប្តេជ្ញាបង្កើតឱ្យបាននូវកម្លាំងពលកម្មប្រកបដោយសមត្ថភាព ផលិតភាព ឥរិយាបថការងារ និងមនសិការនិងសីលធម៌វិជ្ជាជីវៈខ្ពស់ ដែលធន់នឹងបម្រែបម្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា។

ជារួមចក្ខុវិស័យនេះ គឺសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ ជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងការបែងចែកផលនៃកំណើនប្រកបដោយសមធម៌ ស្របតាម កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, ក្របខ័ណ្ឌគោលនយោបាយនានា ជាអាទិ៍

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០, គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ២០១៧-២០២៥, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣, គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ២០១៩-២០២៣ និងផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥។

## ១.៣- បេសកកម្ម

ដើម្បីឈានទៅសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានបេសកកម្មចម្បងៗដូចជា÷

- អភិវឌ្ឍ និងអនុវត្តគោលនយោបាយ និងកសាងលិខិតបទដ្ឋាននានា ដើម្បីរួមចំណែកបង្កើនឱកាសទទួលបានការងារ និងបង្កើតការងារ ប្រកបដោយគុណភាពទាំងក្នុង និងក្រៅប្រទេសជូនប្រជាពលរដ្ឋ
- ពង្រឹង និងជំរុញការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងវិស័យការងារ ដើម្បីធានាបាននូវការគោរពសិទ្ធិការងារ និងលក្ខខណ្ឌការងារល្អប្រសើរ, និងរក្សាបាននូវភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋ
- ពង្រឹងការធ្វើអធិការកិច្ចការងារ និងការគ្រប់គ្រងស្ថិតិសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ ដោយផ្អែកលើប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្ម បច្ចេកវិទ្យាព័ត៌មានវិទ្យា និងកម្រិតហានិភ័យនៃសហគ្រាស គ្រឹះស្ថាន
- លើកកម្ពស់សុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ, ការពារទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ, និងគាំទ្រដល់ពលករទេសន្តរប្រវេសន៍ខ្មែរ
- ពង្រឹងគុណភាព និងពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើជំនាញអាទិភាព និងផ្នែកបច្ចេកទេសដែលគាំទ្រដល់ការធ្វើពិពិធកម្មឧស្សាហកម្ម និងការបង្កើតមុខរបរដោយខ្លួនឯង
- ជំរុញការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិកម្ពុជា, ស្តង់ដាជាតិសមត្ថភាព, កម្មវិធី និងឯកសារសិក្សាផ្អែកលើសមត្ថភាព និងឯកសារធ្វើតេស្តបញ្ជាក់សមត្ថភាព
- ពង្រឹងការគ្រប់គ្រង និងគាំពារកម្លាំងពលកម្មនៅក្នុង និងក្រៅប្រទេស ព្រមទាំងផ្តល់សេវារកការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយប្រសិទ្ធភាព
- ប្រមូល វិភាគ និងចងក្រងព័ត៌មានទីផ្សារការងារ ដើម្បីជាប្រភពទិន្នន័យដល់អ្នករៀបចំគោលនយោបាយ អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល និយោជក និងសាធារណជនទូទៅ

- ផ្តល់សេវាផ្នែកសន្តិសុខសង្គមប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលា ដើម្បីជួយសម្រាលការលំបាកនានានៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និងមាតុភាពជាដើម

- លើកកម្ពស់យេនឌ័រ និងកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ពង្រឹងសមត្ថភាពមន្ត្រី និងអង្គភាពក្នុងការផ្តល់សេវាសាធារណៈនានា ប្រកបដោយភាពទន់ភ្លន់ ក្រមសីលធម៌វិជ្ជាជីវៈ និងទាន់ពេលវេលាជូនប្រជាពលរដ្ឋ ជាពិសេស កម្មករនិយោជិត ស្របតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- កសាងឱ្យបាននូវប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុ ប្រកបដោយតម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យវាយតម្លៃមួយត្រឹមត្រូវ និងទៀងទាត់ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តអភិក្រមទាំង ៥ និងបាវចនាកែទម្រង់ផ្ទៃក្នុង របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**

- ជំរុញ និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ-វិស័យឯកជន (Public-Private Partnership) ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ស្របតាមបាវចនា “**កែទម្រង់ខាងក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ**” របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។

## ១.៤- គោលបំណង និងគោលដៅ

***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣*** ត្រូវបានរៀបចំឡើងដើម្បីជាមគ្គុទេសក៍ដល់អង្គភាពប្រតិបត្តិករៀបចំផែនការសកម្មភាព សូចនាករ និងគោលដៅប្រចាំឆ្នាំ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាដែលបានរកឃើញ ដោយដាក់ចេញនូវវិធានការដ៏រស់រវើកថ្មីៗបន្ថែមទៀត ដែលអាចវាស់វែង និងវាយតម្លៃបានច្បាស់លាស់។ ផែនការយុទ្ធសាស្ត្រនេះ ក៏មានគោលបំណងដើម្បីធានានូវភាពប្រទាក់ក្រឡាទៅនឹងក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិ និងកម្រិតអនុវិស័យនានាដែលមានជាធរមាន។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់នូវគោលដៅចម្បងចំនួន៥ គឺ÷ ***ទី១-*** អភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ***ទី២-***ធ្វើទំនើបកម្មការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ***ទី៣-*** រក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស ***ទី៤-*** អភិវឌ្ឍរបបសន្តិសុខសង្គម និង ***ទី៥-*** បន្តពង្រឹងសេវាគាំទ្រទូទៅក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈការពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ន។

# ជំពូកទី ២

# ក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ២.១- ស្ថានភាពទូទៅនៃវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

### ២.១.១. ការផ្គត់ផ្គង់កម្លាំងពលកម្ម

#### ក. ប្រជាជនសរុប

នៅក្នុងចន្លោះពីឆ្នាំ២០១៣ ទៅ២០១៨ ចំនួនប្រជាជនសរុបបានកើនពី ១៥,០ ទៅ ១៦,១លាននាក់ ឬកើនឡើង ២,៣% ជាមធ្យមក្នុងមួយឆ្នាំ ដែលក្នុងនោះអត្រាកំណើនរបស់មនុស្សប្រុស (២,៦%) ខ្ពស់ជាងមនុស្សស្រី (២,០%)។ ប្រជាជនដែលកើនលឿនជាងអត្រាកំណើនសរុប គឺស្ថិតនៅក្នុងក្រុមអាយុ ២៥-៣៤ឆ្នាំ, ៣៥-៤៤ឆ្នាំ និង៥៥-៦៤ឆ្នាំ។ ទន្ទឹមគ្នានេះ ចំនួនប្រជាជនអាយុ១៥-២៤ឆ្នាំ បានថយចុះ ០,២% ជាមធ្យមក្នុងមួយឆ្នាំ ដែលបណ្តាលមកពីការថយចុះនៃចំនួនមនុស្សស្រីក្នុងក្រុមអាយុនេះ ៥,៣% ក្នុងមួយឆ្នាំ។ ក្នុងចន្លោះឆ្នាំដូចគ្នានេះចំនួនប្រជាជនដែលកើនច្រើនជាងគេ គឺស្ថិតនៅក្នុងក្រុមអាយុ ២៥-៣៤ឆ្នាំ ប្រមាណជា ៩៨ពាន់នាក់ ក្នុងមួយឆ្នាំ ឬស្មើនឹង ៣៥,១% នៃចំនួនកំណើនប្រជាជនសរុប។

នៅក្នុងឆ្នាំ២០១៨ ប្រជាជនកម្ពុជាភាគច្រើនមានអាយុចាប់ពី០ទៅ ១៤ឆ្នាំ ដែលមានចំនួន ៤,៦លាននាក់ ឬស្មើនឹង ២៨,៥%នៃប្រជាជនសរុប។ ប្រមាណជា ៥០,៨%នៃប្រជាជនសរុបគឺ ជាមនុស្សស្រី និង ៤៩,២% ជាមនុស្សប្រុស។ នៅឆ្នាំ២០២៣ ចំនួនប្រជាជនសរុបនឹងកើនឡើងដល់ ១៧,១លាននាក់ ដែលក្នុងនោះប្រជាជនដែលមានអាយុពី ០ ទៅ១៤ឆ្នាំ មានចំនួន ២៧,៧%។

**តារាង ២.១÷ ចំនួនប្រជាជនសរុប តាមក្រុមអាយុ និងភេទ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| ក្រុមអាយុ | ចំនួនប្រជាជន (ពាន់នាក់) | | | | | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ(2013-2018) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | | | 2018 | | | ចំនួន (ពាន់នាក់) | | | បរិមាណភាគ (%) | | | អត្រាកំណើន (%) | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| 0-14 | 2,224 | 2,095 | 4,318 | 2,331 | 2,249 | 4,579 | 21 | 31 | 52 | 13.7 | 25.1 | 18.7 | 1.2 | 1.8 | 1.5 |
| 15-24 | 1,623 | 1,585 | 3,208 | 1,628 | 1,553 | 3,181 | 1 | -6 | -5 | 0.7 | -5.3 | -2.0 | 0.1 | -0.5 | -0.2 |
| 25-34 | 1,214 | 1,291 | 2,505 | 1,502 | 1,492 | 2,994 | 58 | 40 | 98 | 37.0 | 32.8 | 35.1 | 5.5 | 3.7 | 4.6 |
| 35-44 | 764 | 847 | 1,612 | 933 | 984 | 1,917 | 34 | 27 | 61 | 21.6 | 22.3 | 21.9 | 5.1 | 3.8 | 4.4 |
| 44-54 | 655 | 757 | 1,411 | 729 | 812 | 1,541 | 15 | 11 | 26 | 9.6 | 9.0 | 9.3 | 2.7 | 1.8 | 2.2 |
| 55-64 | 343 | 526 | 869 | 455 | 605 | 1,059 | 22 | 16 | 38 | 14.3 | 12.8 | 13.7 | 7.3 | 3.6 | 5.1 |
| 65+ | 299 | 455 | 755 | 323 | 476 | 799 | 5 | 4 | 9 | 3.1 | 3.3 | 3.2 | 1.9 | 1.1 | 1.4 |
| ប្រជាជនសរុប | 7,122 | 7,556 | 14,678 | 7,900 | 8,170 | 16,070 | 156 | 123 | 278 | 100.0 | 100.0 | 100.0 | 2.6 | 2.0 | 2.3 |

ចំណាំ÷ សម្រាប់ឆ្នាំ២០១៨ គឺផ្អែកលើទិន្នន័យនៃការព្យាករប្រជាជនកម្ពុជា២០០៨-២០៥០ របស់វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០១១

ប្រភព÷ ការប៉ាន់ស្មានដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ច ២០១៣

### ខ. ប្រជាជនស្ថិតក្នុងវ័យធ្វើការ

នៅចន្លោះពី ឆ្នាំ២០១៣-២០១៨ ក្រុមប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ (១៥-៦៤ឆ្នាំ) បានកើនឡើងពី ៩,៦លាននាក់ ទៅ ១០,៧លាននាក់ ឬ ២,៣% ជាមធ្យមក្នុងមួយឆ្នាំ ដែលក្នុងនោះ អត្រាកំណើនរបស់មនុស្សប្រុស (៣,៣%) ខ្ពស់ជាងមនុស្សស្រី (២,១%)។ ជិតពាក់កណ្ដាលនៃចំនួនកើនឡើងរបស់ប្រជាជនដែលស្ថិតក្នុងវ័យធ្វើការសរុប (៤៥,០%) គឺស្ថិតនៅក្នុងក្រុមអាយុ២៥-៣៤ឆ្នាំ (តារាង ២.២)។ នៅឆ្នាំ២០១៨ ភាគច្រើននៃប្រជាជនស្ថិតក្នុងវ័យធ្វើការមានអាយុពី១៥ទៅ៣៤ឆ្នាំ ដែលក្នុងនោះ ២៩,៧%មានអាយុពី១៥ទៅ២៤ឆ្នាំ និង ២៨,០% មានអាយុពី២៥ ទៅ៣៤ឆ្នាំ ហើយនៅក្នុងឆ្នាំ២០២៣ ចំនួនប្រជាជនស្ថិតក្នុងវ័យធ្វើការនឹងកើនដល់ប្រមាណជា ១១,៤លាននាក់ ពោលគឺកើនឡើង ១៤៤ពាន់នាក់ ក្នុងមួយឆ្នាំចន្លោះពីឆ្នាំ២០១៩-២០២៣។

**តារាង ២.២÷ ចំនួនប្រជាជនស្ថិតក្នុងវ័យធ្វើការ តាមក្រុមអាយុ និងភេទ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| ក្រុមអាយុ | ចំនួនប្រជាជន (ពាន់នាក់) | | | | | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ(2013-2018) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | | | 2018 | | | ចំនួន (ពាន់នាក់) | | | បរិមាណភាគ (%) | | | អត្រាកំណើន (%) | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| 15-24 | 1,623 | 1,585 | 3,208 | 1,628 | 1,553 | 3,181 | 1 | -6 | -5 | 0.8 | -7.4 | -2.5 | 0.1 | -0.5 | -0.2 |
| 25-34 | 1,214 | 1,291 | 2,505 | 1,502 | 1,492 | 2,994 | 58 | 40 | 98 | 44.5 | 45.7 | 45.0 | 5.5 | 3.7 | 4.6 |
| 35-44 | 764 | 847 | 1,612 | 933 | 984 | 1,917 | 34 | 27 | 61 | 26.0 | 31.1 | 28.1 | 5.1 | 3.8 | 4.4 |
| 44-54 | 655 | 757 | 1,411 | 729 | 812 | 1,541 | 15 | 11 | 26 | 11.5 | 12.6 | 12.0 | 2.7 | 1.8 | 2.2 |
| 55-64 | 343 | 526 | 869 | 455 | 605 | 1,059 | 22 | 16 | 38 | 17.2 | 17.9 | 17.5 | 7.3 | 3.6 | 5.1 |
| សរុប 15-64 | 4,599 | 5,006 | 9,604 | 5,246 | 5,446 | 10,692 | 129 | 88 | 217 | 100.0 | 100.0 | 100.0 | 3.3 | 2.1 | 2.7 |

ចំណាំ÷ សម្រាប់ឆ្នាំ២០១៨ គឺផ្អែកលើទិន្នន័យនៃការព្យាករប្រជាជនកម្ពុជា២០០៨-២០៥០ របស់វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០១១
ប្រភព÷ ការប៉ាន់ស្មានដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ច ២០១៣

### គ. កម្រិតអប់រំនៃប្រជាជនស្ថិតក្នុងវ័យធ្វើការ

នៅចន្លោះពីឆ្នាំ២០១៣-២០១៧ ការអប់រំរបស់អ្នកស្ថិតក្នុងវ័យធ្វើការបានកើនឡើងគួរឱ្យកត់សម្គាល់ដោយចំនួនអ្នកដែលទទួលបានការអប់រំកម្រិតឧត្ដមសិក្សា និងមធ្យមសិក្សាទុតិយភូមិ បានកើនឡើងទ្វេដង (តារាង ២.៣)។ ទន្ទឹមគ្នានេះ អត្រាអ្នកមានការអប់រំតិចជាងថ្នាក់បឋមសិក្សាបានថយចុះប្រមាណជា -៤,៨ពិន្ទុភាគរយ ហើយអត្រាអ្នកដែលទទួលមានការអប់រំខ្ពស់ជាងថ្នាក់មធ្យមសិក្សាទុតិយភូមិបានកើនឡើង ៦,១ពិន្ទុភាគរយ ក្នុងចន្លោះឆ្នាំដូចគ្នា។ ក្នុងរយៈពេលដូចគ្នានេះ យើងក៏សង្កេតឃើញមានការកើនឡើងនៃកម្រិតអប់រំរបស់មនុស្សស្រីនៅកម្រិតឧត្តមសិក្សា និងមធ្យមសិក្សាទុតិយភូមិ ជាមួយនឹងអត្រាខ្ពស់ជាងមនុស្សប្រុស។ ទោះបីជាមានវឌ្ឍនភាពដូចខាងលើ ភាគច្រើននៃប្រជាជនស្ថិតក្នុងវ័យធ្វើការ គឺនៅមានកម្រិតអប់រំ និងជំនាញកម្រិតទាប។ ជាក់ស្ដែងនៅឆ្នាំ២០១៧ ប្រមាណជា ៤,៣លាននាក់ ឬ ៤១,៨% មិនបានចូលរៀន ឬមិនបានបញ្ចប់ថ្នាក់បឋមសិក្សា ខណៈអ្នកទទួលបានការអប់រំ ខ្ពស់ជាងមធ្យមសិក្សាទុតិយភូមិមានចំនួន ១,៥លាននាក់ ឬ ១៤,៤% តែប៉ុណ្ណោះ។

**តារាង ២.៣ ÷ កម្រិតអប់រំរបស់ប្រជាជនស្ថិតក្នុងវ័យធ្វើការ (១៥-៦៤ឆ្នាំ) ចន្លោះឆ្នាំ២០១៣ និង២០១៧**

| កម្រិតអប់រំ | ចំនួន (ពាន់នាក់) | | | | | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2017) | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | | | 2017 | | | ចំនួន(ពាន់នាក់) | | | បរិមាណភាគ (%) | | | អត្រាកំណើន (%) | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ឧត្តមសិក្សា | 214 | 112 | 326 | 394 | 271 | 665 | 45 | 40 | 85 | 39.4 | 44.7 | 41.7 | 16.5 | 24.6 | 19.5 |
| មធ្យមសិក្សាទុតិយភូមិ | 285 | 181 | 466 | 471 | 363 | 834 | 46 | 46 | 92 | 40.7 | 51.4 | 45.3 | 13.4 | 19.0 | 15.7 |
| មធ្យមសិក្សាបឋមភូមិ | 1,030 | 749 | 1,779 | 976 | 884 | 1,860 | -13 | 34 | 20 | -11.7 | 38.1 | 10.0 | -1.3 | 4.2 | 1.1 |
| បឋមសិក្សា | 1,266 | 1,294 | 2,561 | 1,390 | 1,318 | 2,708 | 31 | 6 | 37 | 27.1 | 6.6 | 18.1 | 2.4 | 0.5 | 1.4 |
| មិនបញ្ចប់ថ្នាក់បឋមសិក្សា | 1,402 | 1,814 | 3,216 | 1,375 | 1,757 | 3,131 | -7 | -14 | -21 | -6.0 | -16.1 | -10.4 | -0.5 | -0.8 | -0.7 |
| គ្មាន ឬរៀនបានតិចតួច | 402 | 856 | 1,257 | 450 | 768 | 1,218 | 12 | -22 | -10 | 10.5 | -24.7 | -4.9 | 2.9 | -2.7 | -0.8 |
| សរុប | 4,599 | 5,006 | 9,604 | 5,056 | 5,360 | 10,416 | 114 | 89 | 203 | 100.0 | 100.0 | 100.0 | 2.4 | 1.7 | 2.0 |

ប្រភព÷ អង្កេតសង្គមសេដ្ឋកិច្ចឆ្នាំ ២០១៣ និង២០១៧

### ឃ. ប្រជាជនស្ថិតក្នុងវ័យធ្វើការតាមតំបន់

នៅចន្លោះពីឆ្នាំ២០១៣ ទៅ២០១៧ ប្រជាជនស្ថិតក្នុងវ័យធ្វើការនៅទីប្រជុំជនបានកើនឡើងពី ២,២លាននាក់ ទៅ ២,៦លាននាក់ ឬស្មើនឹង ៤,៩% ក្នុងមួយឆ្នាំ ខណៈដែលនៅជនបទបានកើនឡើងពី ៧,៤លាននាក់ ទៅ ៧,៧លាននាក់ ឬស្មើនឹង ១,១% ក្នុងមួយឆ្នាំ។ ក្នុងចន្លោះឆ្នាំដូចគ្នានេះ យើងសង្កេតឃើញចំនួនអ្នកនៅទីប្រជុំជន (៥៧,៥%) បានកើនឡើងច្រើនជាងចំនួននៅជនបទ (៤២,៥%) ប៉ុន្តែប្រមាណជា ២ភាគ៣ នៃប្រជាជនស្ថិតក្នុងវ័យធ្វើការបាននិងកំពុងរស់នៅតាមទីជនបទ។

**តារាង ២.៤ ÷ ចំនួនប្រជាជនស្ថិតក្នុងវ័យធ្វើការ តាមតំបន់ និងភេទ ចន្លោះឆ្នាំ២០១៣ និង២០១៧**

| | ចំនួន (ពាន់នាក់) | | | | | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2017) | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2013 | | | 2017 | | | ចំនួន(ពាន់នាក់) | | | អត្រាកំណើន (%) | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ទីប្រជុំជន | 1,067 | 1,147 | 2,214 | 1,283 | 1,398 | 2,681 | 54 | 63 | 117 | 4.7 | 5.1 | 4.9 |
| ជនបទ | 3,532 | 3,858 | 7,390 | 3,773 | 3,962 | 7,736 | 60 | 26 | 86 | 1.7 | 0.7 | 1.1 |
| សរុប | 4,599 | 5,006 | 9,604 | 5,056 | 5,360 | 10,416 | 114 | 89 | 203 | 2.4 | 1.7 | 2.0 |
| | បរិមាណភាគតាមជួរឈរ (%) | | | | | | | | | | | |
| ទីប្រជុំជន | 23.2 | 22.9 | 23.1 | 25.4 | 26.1 | 25.7 | 47.2 | 70.7 | 57.5 | | | |
| ជនបទ | 76.8 | 77.1 | 76.9 | 74.6 | 73.9 | 74.3 | 52.8 | 29.3 | 42.5 | | | |
| សរុប | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | 100.0 | | | |

ប្រភព÷ អង្កេតសង្គមសេដ្ឋកិច្ចឆ្នាំ ២០១៣ និង២០១៧

## ២.១.២. តម្រូវការកម្លាំងពលកម្ម

### ក. ស្ថានភាពសេដ្ឋកិច្ច និងការងារ

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណជា ៧,០% នៅក្នុងចន្លោះពីឆ្នាំ២០១៣ ទៅ២០១៨ ទោះបីស្ថានភាពសេដ្ឋកិច្ចសកលលោក មានលក្ខណៈមិនប្រាកដប្រជា ហើយប្រទេសមួយចំនួនកំពុងជួបប្រទះបញ្ហា

វិបត្តិបំណុលសាធារណៈ។ ក្នុងរយៈពេលដូចគ្នានេះ ចំនួនអ្នកមានការងារធ្វើ (១៥ឆ្នាំ+) បានកើនឡើងពី ៨,៣ លាននាក់នៅឆ្នាំ២០១៣ ទៅ ៩,៦លាននាក់ នៅឆ្នាំ២០១៨ ពោលគឺកើនឡើង ២,៩% ជាមធ្យមក្នុងមួយឆ្នាំ ដែលខ្ពស់ជាងអត្រាកំណើនរបស់ប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ (២,៧% ជាមធ្យមក្នុងមួយឆ្នាំ)។

ជាលទ្ធផល អនុបាតអ្នកមានការងារទៅនឹងប្រជាជន (១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការផ្តល់ការងារដល់ប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ ឬផ្តល់ការងារដល់អ្នកចង់ស្វែងរកការងារ រក្សាបានអត្រាថេរក្នុងរង្វង់ ៨០,៦% ក្នុងរយៈពេលដូចគ្នានេះ។ ប៉ុន្តែ អនុបាតនេះមានអត្រាខ្ពស់សម្រាប់បុរស (៨៦,៥%) ជាងស្ត្រី (៧៥,២%)។ ទន្ទឹមនឹងនេះ អត្រានិកម្មភាព (១៥ឆ្នាំ+) ស្ថិតនៅក្នុងអត្រាមួយទាបជាង ១% ប៉ុន្តែអត្រានិកម្មភាពរបស់យុវជន (១៥-២៤ឆ្នាំ) ជាពិសេសយុវជនជាបុរសមានកម្រិតខ្ពស់ជាងអត្រានិកម្មភាពទូទៅ (១៥ឆ្នាំ+)។ ក្នុងចន្លោះឆ្នាំដូចគ្នានេះ អត្រាចូលរួមកម្លាំងពលកម្ម ដែលវាស់ពីអត្រាប្រជាជនសកម្មនៅក្នុងប្រទេស បានរក្សាកម្រិតមួយថេរ និងខ្ពស់ប្រមាណជា ៨១,០% ដែលខ្ពស់ជាងអត្រាជាមធ្យមរបស់អាស៊ានប្រមាណជា ៦៨,១%។ អត្រាចូលរួមរបស់មនុស្សប្រុសខ្ពស់ជាងមនុស្សស្រីប្រមាណជា ១១,៣ពិន្ទុភាគរយ ក្នុងចន្លោះពីឆ្នាំ២០១៣-២០១៨។

**តារាង ២.៥ ៖ សូចនាករសេដ្ឋកិច្ច និងទីផ្សារការងារសំខាន់ៗ**

| | | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|
| អត្រាកំណើន ផ.ស.ស (ថ្លៃថេរឆ្នាំ២០០០)(១) | | 7.4% | 7.1% | 7.0% | 7.0% | 7.0% | 7.0% |
| ចំនួនការងារសរុប (ពាន់នាក់; ១៥ឆ្នាំ+)(២) | | 8,274 | 8,521 | 8,626 | 8,955 | 9,102 | 9,555 |
| អត្រាកំណើនការងារ(២) | | 3.6% | 3.0% | 1.2% | 3.8% | 1.6% | 5.0% |
| អត្រាចូលរួមកម្លាំងពលកម្ម (១៥ឆ្នាំ+) | សរុប | 81.0% | 80.8% | 80.9% | 81.0% | 81.0% | 81.1% |
| | ស្រី | 75.6% | 75.5% | 75.5% | 75.6% | 75.6% | 75.6% |
| | ប្រុស | 86.8% | 86.6% | 86.7% | 86.8% | 87.0% | 87.1% |
| អនុបាតអ្នកមានការងារទៅនឹងប្រជាជន(១៥ឆ្នាំ+) | សរុប | 81.8% | 80.9% | 80.1% | 80.1% | 80.1% | 80.3% |
| | ស្រី | 86.8% | 86.5% | 86.2% | 86.2% | 86.3% | 86.6% |
| | ប្រុស | 77.2% | 75.9% | 74.5% | 74.5% | 74.4% | 74.5% |
| អត្រានិកម្មភាព (១៥ឆ្នាំ+) | សរុប | 0.3% | 0.4% | 0.5% | 0.6% | 0.6% | 0.6% |
| | ស្រី | 0.2% | 0.3% | 0.4% | 0.4% | 0.4% | 0.5% |
| | ប្រុស | 0.4% | 0.5% | 0.6% | 0.7% | 0.7% | 0.7% |
| អត្រានិកម្មភាព (១៥-២៤ឆ្នាំ) | សរុប | 0.5% | 0.7% | 0.8% | 0.9% | 1.0% | 1.0% |
| | ស្រី | 0.3% | 0.5% | 0.6% | 0.6% | 0.7% | 0.7% |
| | ប្រុស | 0.6% | 0.9% | 1.0% | 1.1% | 1.2% | 1.3% |

ប្រភព៖ ធ្វើការចងក្រងពី (១)ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (២)អង្កេតសង្គមសេដ្ឋកិច្ច, និង ILOSTAT database របស់អង្គការអន្តរជាតិខាងការងារ

## ខ. ស្ថានភាពការងារតាមវិស័យ

កំណើនសេដ្ឋកិច្ចនាពេលកន្លងមក មិនត្រឹមតែធ្វើឱ្យមានការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយក៏បានជះឥទ្ធិពលទៅលើរចនាសម្ព័ន្ធទីផ្សារការងារផងដែរ។ នៅចន្លោះឆ្នាំ២០១៣-២០១៨ ផ.ស.ស របស់វិស័យកសិកម្ម

បានកើនឡើង ១,១% ក្នុងមួយឆ្នាំ ខណៈចំនួនការងារក្នុងវិស័យនេះបានថយចុះ ៣,២% ក្នុងមួយឆ្នាំ។ ជាលទ្ធផល បរិមាណភាគនៃអ្នកធ្វើការនៅក្នុងវិស័យកសិកម្មបានថយចុះពី ៤៩,៥% នៅក្នុងឆ្នាំ២០១៣ មកត្រឹម ៣៦,៤% នៅក្នុងឆ្នាំ២០១៨។ ជាមួយនឹងអត្រាកំណើន ផ.ស.ស ១០,៤% ក្នុងមួយឆ្នាំ វិស័យឧស្សាហកម្មបានបង្កើតការងារបន្ថែមសម្រាប់ប្រជាជនកម្ពុជា ប្រមាណជា ៨៩៤ពាន់នាក់ ក្នុងចន្លោះឆ្នាំដូចគ្នានេះ ហើយបរិមាណភាគនៃអ្នកធ្វើការនៅក្នុងវិស័យឧស្សាហកម្មបានកើនឡើងពី ១៩,៣% ទៅ ២៦,១%។ ទន្ទឹមនឹងនេះ ផ.ស.ស របស់វិស័យសេវាកម្មបានរក្សាកំណើនវិជ្ជមានក្នុងរង្វង់ ៧,៣% ក្នុងមួយឆ្នាំ និងបានបង្កើតការងារបន្ថែមប្រមាណ ១លាននាក់ ហើយបរិមាណភាគអ្នកមានការងារធ្វើនៅក្នុងវិស័យនេះបានកើនឡើងពី ៣១,២% ទៅ ៣៧,៥% នៅក្នុងចន្លោះពីឆ្នាំ២០១៣-២០១៨។

**តារាង ២.៦ ÷ រចនាសម្ព័ន្ធសេដ្ឋកិច្ច និងទីផ្សារការងារ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| វិស័យ | ផលិតផលក្នុងស្រុកសរុប (ថ្លៃថេរឆ្នាំ២០០០) | | | ការងារ (១៥ឆ្នាំ+) | | |
|---|---|---|---|---|---|---|
| | បរិមាណភាគ (%) | | អត្រាកំណើនក្នុងមួយឆ្នាំ (%) | បរិមាណភាគ (%) | | អត្រាកំណើនក្នុងមួយឆ្នាំ (%) |
| | 2013 | 2018 | | 2013 | 2018 | |
| កសិកម្ម | 24.2 | 18.2 | 1.1 | 49.5 | 36.4 | -3.2 |
| ឧស្សាហកម្ម | 29.9 | 34.9 | 10.4 | 19.3 | 26.1 | 9.3 |
| សេវាកម្ម | 39.0 | 39.6 | 7.3 | 31.2 | 37.5 | 6.8 |
| សរុប | 100.0 | 100.0 | 7.0 | 100.0 | 100.0 | 2.9 |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ជាលទ្ធផល យើងក៏សង្កេតឃើញមានវិសមភាពរវាងបរិមាណភាគនៃ ផ.ស.ស ទៅនឹងបរិមាណភាគនៃកម្លាំងពលកម្មតាមវិស័យដែលនេះបានឆ្លុះបញ្ចាំងពីកម្រិតខុសគ្នានៃផលិតភាពការងារ។ ជាក់ស្តែងនៅឆ្នាំ២០១៨ វិស័យកសិកម្មបានចូលរួមចំណែកក្នុង ផ.ស.ស ត្រឹមតែ ១៨,២% តែវិស័យនេះបានស្រូបយកកម្លាំងពលកម្មរហូតដល់ ៣៦,៨%។ ផ្ទុយមកវិញ វិស័យឧស្សាហកម្មដែលចូលរួមចំណែកក្នុង ផ.ស.ស ប្រមាណជា ៣៤,៩% ប្រើប្រាស់កម្លាំងពលកម្មប្រមាណជា ២៦,១% ខណៈដែលវិស័យសេវាកម្មដែលចូលរួមចំណែកក្នុង ផ.ស.ស ប្រមាណជា ៣៩,៦% បានប្រើប្រាស់កម្លាំងពលកម្ម ៣៧,៥% (តារាង ២.៦)។ នេះបានបង្ហាញថា វិស័យកសិកម្មគឺជាវិស័យដែលមានផលិតភាពទាបជាងគេ ធៀបទៅនឹងវិស័យឧស្សាហកម្ម និងសេវាកម្ម។

**តារាង ២.៧÷ ការប្រែប្រួលតម្រូវការការងារតាមអនុវិស័យ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| សកម្មភាពសេដ្ឋកិច្ច | 2013 | | 2018 | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2018) | | |
|---|---|---|---|---|---|---|---|
| | ពាន់នាក់ | % | ពាន់នាក់ | % | ចំនួន (ពាន់នាក់) | អត្រាចូលរួម(%) | អត្រាកំណើន (%) |
| កសិកម្ម | 4,097 | 49.5 | 3,480 | 36.4 | (124) | -48.2 | -3.2 |
| ដំណាំ | 3,089 | 37.3 | 2,429 | 25.4 | (132) | -51.6 | -4.7 |
| សកម្មភាពចិញ្ចឹមសត្វ | 628 | 7.6 | 738 | 7.7 | 22 | 8.6 | 3.3 |
| រុក្ខាប្រមាញ់ | 183 | 2.2 | 119 | 1.2 | (13) | -5.0 | -8.2 |
| ការនេសាទ | 198 | 2.4 | 194 | 2.0 | (1) | -0.3 | -0.4 |
| ឧស្សាហកម្ម | 1,595 | 19.3 | 2,489 | 26.1 | 179 | 69.8 | 9.3 |
| ការជីករ៉ែ | 42 | 0.5 | 26 | 0.3 | (3) | -1.3 | -9.2 |
| កម្មន្តសាលផ្នែកផលិតចំណីអាហារ និងភេសជ្ជៈ | 127 | 1.5 | 195 | 2.0 | 14 | 5.3 | 8.9 |
| កម្មន្តសាលផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង | 728 | 8.8 | 1,093 | 11.4 | 73 | 28.5 | 8.5 |
| កម្មន្តសាលផ្នែកកែច្នៃឈើ ក្រដាស និងបោះពុម្ព | 72 | 0.9 | 84 | 0.9 | 2 | 1.0 | 3.2 |
| កម្មន្តសាលផ្នែកផលិតផលជ័រកៅស៊ូ និងប្លាស្ទិក | 3 | 0.0 | 9 | 0.1 | 1 | 0.4 | 21.1 |
| កម្មន្តសាលផ្សេងៗ | 114 | 1.4 | 229 | 2.4 | 23 | 8.9 | 14.9 |
| សំណង់ | 465 | 5.6 | 853 | 8.9 | 78 | 30.3 | 12.9 |
| ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងទឹក | 43 | 0.5 | 57 | 0.6 | 3 | 1.1 | 5.7 |
| សេវាកម្ម | 2,581 | 31.2 | 3,586 | 37.5 | 201 | 78.5 | 6.8 |
| ពាណិជ្ជកម្មលក់ដុំ និងរាយ | 1,038 | 12.6 | 1,224 | 12.8 | 37 | 14.5 | 3.3 |
| ការស្នាក់នៅ និងភោជនីយដ្ឋាន | 303 | 3.7 | 453 | 4.7 | 30 | 11.7 | 8.3 |
| ការដឹកជញ្ជូន ព័ត៌មានវិទ្យា និងគមនាគមន៍ | 341 | 4.1 | 477 | 5.0 | 27 | 10.6 | 7.0 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 33 | 0.4 | 92 | 1.0 | 12 | 4.6 | 22.6 |
| រដ្ឋបាលសាធារណៈ | 255 | 3.1 | 307 | 3.2 | 10 | 4.1 | 3.8 |
| អចលនទ្រព្យ និងសេវាកម្មគាំទ្រអាជីវកម្ម | 246 | 3.0 | 483 | 5.1 | 47 | 18.5 | 14.4 |
| សេវាកម្មផ្សេងៗ | 364 | 4.4 | 494 | 5.2 | 26 | 10.1 | 6.3 |
| ចំនួនការងារសរុប | 8,274 | 100.0 | 9,555 | 100.0 | 256 | 100.0 | 2.9 |

ប្រភព÷ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧

ក្នុងចំណោមការងារដែលបានកើនឡើងបន្ថែមចំនួន ១,៣លានកន្លែង ក្នុងចន្លោះឆ្នាំ២០១៣-២០១៨ ភាគច្រើនស្ថិតនៅក្នុងវិស័យឧស្សាហកម្ម (៦៩,៨% នៃចំនួនការងារដែលបានបង្កើត) និងសេវាកម្ម (៧៨,៥%) ចំណែកការងារនៅក្នុងវិស័យកសិកម្មបានថយចុះ ៤៨,២%។ ការងារក្នុងវិស័យកសិកម្ម មានការធ្លាក់ចុះទាំងបរិមាណភាគ និងចំនួន ដែលនេះបានឆ្លុះបញ្ចាំងពីបំលាស់កម្លាំងពលកម្មពីវិស័យកសិកម្មដែលមានផលិតភាពទាប ទៅរកវិស័យទំនើបផ្សេងទៀតដែលមានផលិតភាពខ្ពស់ រួមមាន វិស័យឧស្សាហកម្ម និងសេវាកម្ម។ ជារួមចន្លោះពីឆ្នាំ២០១៣ ទៅ២០១៨ យើងបានកត់សម្គាល់និន្នាការតម្រូវការការងារតាមអនុវិស័យ (តារាងទី២.៧) ដូចខាងក្រោម÷

- អនុវិស័យដែលបង្កើតការងារច្រើនជាងគេគឺ សំណង់ (៧៨ ពាន់នាក់ ក្នុងមួយឆ្នាំ) និងទី២ វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង (៧៣ ពាន់នាក់ ក្នុងមួយឆ្នាំ)
- អនុវិស័យដែលមានអត្រាកំណើនការងារលឿន (អត្រាកំណើន ២ខ្ទង់ ក្នុងមួយឆ្នាំ) មាន÷ ហិរញ្ញវត្ថុ និងធានារ៉ាប់រង (២២,៦%) ផលិតផលជ័រកៅស៊ូ និងប្លាស្ទិក (២១,១%) កម្មន្តសាលផ្សេងៗ (១៤,៩%) អចលនទ្រព្យ និងសេវាគាំទ្រអាជីវកម្ម (១៤,៤%) និងសំណង់ (១២,៩%)
- អនុវិស័យដែលមានចំនួនការងារធ្លាក់ចុះមាន÷ ដំណាំ, រុក្ខាប្រមាញ់, ការជីករ៉ែ និងការនេសាទ

- នៅឆ្នាំ២០១៨ អនុវិស័យ ៤ ដែលមានអ្នកធ្វើការច្រើនជាងគេគឺ÷ ដំណាំ(២៥,៤%) ពាណិជ្ជកម្មលក់ដុំ និងរាយ(១២,៨%) វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង(១១,៤%) និងសំណង់(៨,៩%)។

## គ. ស្ថានភាពការងារតាមមុខរបរ

នៅក្នុងចន្លោះពីឆ្នាំ២០១៣ និង២០១៨ យើងសង្កេតឃើញមានការផ្លាស់ប្តូររចនាសម្ព័ន្ធតម្រូវការពីការងារជាកសិករ និងគ្មានជំនាញ ទៅកាន់ការងារដែលមានជំនាញមធ្យម និងខ្ពស់ ដែលក្នុងនោះ÷

- ភាគច្រើននៃការងារដែលត្រូវបានបង្កើតជា÷ កម្មករជំនាញផ្នែកសិប្បកម្ម (៥៥,២% នៃការងារសរុបដែលបង្កើត) អ្នកជំនាញផ្នែកលក់ និងសេវាកម្ម (២៧,០%) ជំនាញលេខាធិការ (២៣,៤% ) និងអ្នកបញ្ជាម៉ាស៊ីន និងផ្គុំដំឡើង (១៩,៣%)
- ការងារមានជំនាញខ្ពស់ដែលមានការកើនឡើងរួមមាន÷ អ្នកគ្រប់គ្រង អ្នកឯកទេសវិជ្ជាជីវៈ និងអ្នកបច្ចេកទេស ឬវិជ្ជាជីវៈ សរុបទាំងពីរមុខរបរនេះ បានកើនឡើង ៨,៩% នៃចំនួនការងារសរុបដែលបានបង្កើត
- ការងារដែលគ្មានជំនាញបានកើនឡើងបន្តិចបន្តួចប្រមាណជា ៣៦ពាន់នាក់ ខណៈដែលការងារជាកសិករបានធ្លាក់ចុះប្រមាណជា ៤៦១ពាន់នាក់
- មុខរបរដែលមានតម្រូវការកើនឡើងលឿន (អត្រាកើនឡើង២ខ្ទង់ក្នុងមួយឆ្នាំ) រួមមាន÷ លេខាធិការ, អ្នកបញ្ជាម៉ាស៊ីន និងផ្គុំដំឡើង និងអ្នកបច្ចេកទេស ឬវិជ្ជាជីវៈរង
- នៅឆ្នាំ២០១៨ ប្រភេទមុខរបរ ៣ ដែលមានអ្នកធ្វើការច្រើនជាងគេគឺ÷ កសិករ (៣០,៤%) កម្មករជំនាញផ្នែកសិប្បកម្ម (២១,២%) និងអ្នកជំនាញផ្នែកលក់ ឬសេវាកម្ម (១៨,១%) ។

**តារាង ២.៨ ÷ ការប្រែប្រួលតម្រូវការការងារតាមប្រភេទនៃមុខរបរ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| ប្រភេទនៃមុខរបរ | 2013 | | 2018 | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2018) | | |
|---|---|---|---|---|---|---|---|
| | ពាន់នាក់ | % | ពាន់នាក់ | % | ចំនួន (ពាន់នាក់) | អត្រាចូលរួម(%) | អត្រាកំណើន (%) |
| អ្នកគ្រប់គ្រង | 87 | 1.1 | 94 | 1.0 | 1 | 0.5 | 1.4 |
| អ្នកឯកទេសវិជ្ជាជីវៈ | 239 | 2.9 | 292 | 3.1 | 11 | 4.2 | 4.1 |
| អ្នកបច្ចេកទេស ឬវិជ្ជាជីវៈរង | 85 | 1.0 | 139 | 1.4 | 11 | 4.2 | 10.2 |
| លេខាធិការ | 240 | 2.9 | 539 | 5.6 | 60 | 23.4 | 17.6 |
| អ្នកជំនាញផ្នែកលក់ ឬសេវាកម្ម | 1,384 | 16.7 | 1,731 | 18.1 | 69 | 27.0 | 4.6 |
| កសិករ | 3,363 | 40.6 | 2,902 | 30.4 | (92) | -36.0 | -2.9 |
| កម្មករជំនាញផ្នែកសិប្បកម្ម | 1,314 | 15.9 | 2,022 | 21.2 | 142 | 55.2 | 9.0 |
| អ្នកបញ្ជាម៉ាស៊ីន និងផ្គុំដំឡើង | 301 | 3.6 | 548 | 5.7 | 49 | 19.3 | 12.7 |
| កម្មករគ្មានជំនាញ | 1,200 | 14.5 | 1,237 | 12.9 | 7 | 2.8 | 0.6 |
| មុខរបរផ្សេងៗ | 59 | 0.7 | 52 | 0.5 | (2) | -0.6 | -2.8 |
| សរុប | 8,274 | 100.0 | 9,555 | 100.0 | 256 | 100.0 | 2.9 |

ប្រភព÷ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧

## ឃ. ស្ថានភាពការងារតាមកម្រិតនៃការអប់រំ

ស្របគ្នានេះ យើងក៏បានសង្កេតឃើញការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធតម្រូវការការងារ ពីការអប់រំកម្រិតតិចតួច ឬមិនបញ្ចប់បឋមសិក្សាទៅ យ៉ាងហោចណាស់ត្រឹមកម្រិតបឋមសិក្សា ដោយសារការប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ជាក់ស្តែង នៅក្នុងចន្លោះពីឆ្នាំ២០១៣និង២០១៨÷

- ភាគច្រើននៃការងារដែលត្រូវបានបង្កើតទាមទារការអប់រំកម្រិត÷ ឧត្តមសិក្សា (៣៣,៨% នៃការងារសរុបដែលបានបង្កើត) មធ្យមសិក្សាបឋមភូមិ (២៦,៦%) បឋមសិក្សា (២៥,៩%) និងមធ្យមសិក្សាទុតិយភូមិ (២៣,៥%)
- កម្រិតអប់រំដែលបានថយចុះនៃចំនួនការងារគឺ÷ មិនបានបញ្ចប់បឋមសិក្សា (បាត់បង់ ២២ ពាន់កន្លែង ក្នុងមួយឆ្នាំ) និង គ្មាន ឬរៀនបានតិចតួច (១២ ពាន់កន្លែង ក្នុងមួយឆ្នាំ)
- កម្រិតអប់រំដែលមានតម្រូវការកើនឡើងលឿន រួមមាន÷ ឧត្តមសិក្សា (២១,៥% ក្នុងមួយឆ្នាំ) មធ្យមសិក្សាទុតិយភូមិ (១៤,១%) និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស (៩,៩%)
- នៅឆ្នាំ ២០១៨ ភាគច្រើននៃការងារទាមទារកម្រិតអប់រំកម្រិតមិនបញ្ចប់ថ្នាក់បឋមសិក្សា (២៩,៧%) និងបឋមសិក្សា (២៦,៥%)។

**តារាង ២.៩ ÷ ការប្រែប្រួលតម្រូវការការងារតាមកម្រិតនៃការអប់រំ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| កម្រិតនៃការអប់រំ | 2013 | | 2018 | | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2013-2018) | | |
|---|---|---|---|---|---|---|---|
| | ពាន់នាក់ | % | ពាន់នាក់ | % | ចំនួន (ពាន់នាក់) | អត្រាចូលរួម(%) | អត្រាកំណើន (%) |
| ឧត្តមសិក្សា | 262 | 3.2 | 695 | 7.3 | 87 | 33.8 | 21.5 |
| មធ្យមសិក្សាទុតិយភូមិ | 322 | 3.9 | 623 | 6.5 | 60 | 23.5 | 14.1 |
| មធ្យមសិក្សាបឋមភូមិ | 1314 | 15.9 | 1655 | 17.3 | 68 | 26.6 | 4.7 |
| បឋមសិក្សា | 2198 | 26.6 | 2530 | 26.5 | 66 | 25.9 | 2.9 |
| មិនបញ្ចប់ថ្នាក់បឋមសិក្សា | 2948 | 35.6 | 2836 | 29.7 | -22 | -8.7 | -0.8 |
| គ្មាន ឬរៀនបានតិចតួច | 1156 | 14.0 | 1098 | 11.5 | -12 | -4.5 | -1.0 |
| ការអប់រំបណ្តុះបណ្តាលបច្ចេកទេស (មុន និងបន្ទាប់ពីមធ្យមសិក្សាទុតិយភូមិ) | 73 | 0.9 | 118 | 1.2 | 9 | 3.5 | 9.9 |
| សរុប | 8274 | 100.0 | 9555 | 100.0 | 256 | 100.0 | 2.9 |

ប្រភព÷ ការប៉ាន់ស្មានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧

## ង. ប្រភេទនៃការងារ

ស្របជាមួយនឹងកំណើនការងារ គុណភាពនៃការងារក៏ត្រូវបានកែលម្អ ដែលបង្ហាញតាមរយៈការកើនឡើងបរិមាណភាគនៃនិយោជិតដែលទទួលប្រាក់ឈ្នួលប្រមាណជា ២,៣ពិន្ទុភាគរយ ដែលក្នុងនោះបុរសបានកើនឡើង ២,៣ពិន្ទុភាគរយ និងស្ត្រីកើនឡើង ២,២ ពិន្ទុភាគរយ។ ទន្ទឹមគ្នានេះ អ្នកដែលមានការងារជាអ្នកប្រើទុនដោយខ្លួនឯង ឬជួយការងារគ្រួសារដោយមិនទទួលប្រាក់កម្រៃក៏បានថយចុះ ០,៥ពិន្ទុភាគរយ និង ១,៨ពិន្ទុភាគរយរៀងគ្នា។ ប៉ុន្តែនៅឆ្នាំ ២០១៨ បរិមាណភាគនៃប្រភេទទាំង២ ក៏នៅមានចំនួនច្រើនប្រមាណជា ៥០,៨% ដែលក្នុងនោះស្ត្រីមានកម្រិតប្រមាណជា ៥៦,៩% និងបុរស ប្រមាណជា ៤៥%។

**តារាង ២.១០ ÷ ការប្រែប្រួលតម្រូវការការងារតាមប្រភេទការងារ ចន្លោះឆ្នាំ២០១៣ និង២០១៨**

| ប្រភេទការងារ | 2013 | | | 2018 | | | ការប្រែប្រួល 2013-2018 (ពិន្ទុភាគរយ) | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| និយោជក | 0.5% | 0.3% | 0.4% | 0.5% | 0.3% | 0.4% | 0.0 | 0.0 | 0.0 |
| និយោជិត | 52.2% | 40.6% | 46.5% | 54.5% | 42.8% | 48.8% | 2.3 | 2.2 | 2.3 |
| អ្នករកស៊ីដោយប្រើទុនខ្លួនឯង | 34.3% | 32.6% | 33.4% | 33.5% | 32.2% | 32.9% | -0.8 | -0.4 | -0.5 |
| អ្នកជួយធ្វើគ្រួសារដោយមិនទទួលប្រាក់ឈ្នួល | 13.0% | 26.5% | 19.7% | 11.5% | 24.7% | 17.9% | -1.5 | -1.8 | -1.8 |

ប្រភព÷ ILOSTAT database របស់អង្គការអន្តរជាតិខាងការងារ

## ច. ការប្រែប្រួលប្រាក់ឈ្នួល

នៅក្នុងរយៈពេលដូចគ្នា ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានកើនឡើងជាលំដាប់ ពោលកើនឡើងពី ១០០ ដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០១៤ ដល់ ១៧០ ដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០១៨ ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះកើនឡើងដល់ ១៨២ដុល្លារសហរដ្ឋអាមេរិក។ បើធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសដែលមានស្ថានភាព សេដ្ឋកិច្ច-សង្គម ប្រហាក់ប្រហែលគ្នា និងជាដៃគូប្រកួតប្រជែង ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨នេះ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាបានកើនឡើងជាលំដាប់ប្រមាណជា ១៦,៣% ជាមធ្យមក្នុងមួយឆ្នាំ ឬ កើនឡើងជិត ០២ដង ខណៈដែលប្រទេស វៀតណាម ភូមា និងបង់ក្លាដែស បានដំឡើងប្រាក់ឈ្នួលអប្បបរមារបស់ខ្លួនក្នុងអត្រាកំណើនទាប ឬមិនទៀងទាត់ (រូបភាពទី ២.១)។ កម្រិតនៃប្រាក់ឈ្នួលអប្បបរមានេះ បានដើរតួជាប្រាក់ឈ្នួលយោងសម្រាប់វិស័យកម្មន្តសាលផ្សេងទៀតក្នុងការចរចាប្រាក់ឈ្នួល។ ទន្ទឹមនឹងនេះ ចំនួនប្រាក់ឈ្នួលទូទៅក៏មានការកើនឡើងគ្រប់វិស័យ ដោយសារកំណើនការងារនៅក្នុងស្រុក និងទេសន្តរប្រវេសន៍ការងារ ទៅប្រទេសដែលមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងប្រាក់ឈ្នួលខ្ពស់ជាងកម្ពុជា។

**រូបភាព ២.១ ÷ ការវិវឌ្ឍប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជាធៀបនឹងបណ្តាប្រទេសជាដៃគូប្រកួតប្រជែងពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨**



**ឆ. ការប្រែប្រួលផលិតភាពការងារ**

ទោះបីជាកន្លងមក សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនខ្ពស់ក្នុងរង្វង់អត្រា ៧,០% តែកំណើនសេដ្ឋកិច្ចនេះបានត្រូវបានជំរុញដោយកំណើនកត្តាផលិតកម្ម ជាពិសេសកត្តាកម្លាំងពលកម្ម។ យោងតាមរបាយការណ៍ឆ្នាំ២០១៨ របស់អង្គការផលិតភាពអាស៊ី (APO) កំណើនផលិតការងារ ក្នុងចន្លោះពីឆ្នាំ២០១០-២០១៦ នេះកម្ពុជាសម្រេចបាននូវកំណើនប្រមាណជា ៤,៤% ជាមធ្យមក្នុងមួយឆ្នាំ ដែលក្នុងនោះ ៩៥% ត្រូវបានរួមចំណែកដោយកំណើនមូលធនធៀបនឹងពលកម្ម និង ៥% ដោយកំណើនផលិតភាពសរុប។ ទន្ទឹមនឹងនេះ កំណើននៃផលិតភាពនេះ ក៏ត្រូវបានជំរុញ ដោយសារការបង្វែរកម្លាំងពលកម្មចំនួនដ៏ច្រើនចេញពីវិស័យកសិកម្ម ដែលមានផលិតភាពទាប ចូលមកក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពខ្ពស់ជាង (ដូចបានបង្ហាញខាងលើ) ដែលនឹងមិនអាចរក្សាបានចីរភាពក្នុងរយៈពេលវែង។

បើប្រៀបធៀបនឹងប្រទេសសិង្ហបុរី ដែលជាប្រទេសមានផលិតភាពខ្ពស់ជាងគេនៅលើពិភពលោក នាឆ្នាំ២០១៥ ផលិតភាពកម្ពុជាក្នុងមនុស្សម្នាក់មានកម្រិតទាបជាងគេនៅក្នុងអាស៊ី ដោយមានកម្រិតត្រឹមតែ ៤,៧% ខណៈពេលដែលប្រទេសបង់ក្លាសដេសមានកម្រិត ៦,២% វៀតណាម (១០,២%) មីយ៉ាន់ម៉ា (៨,០%) ឡាវ (៨,៧%) ភីលីពីន (១៤,២%) ឥណ្ឌូនេស៊ី (១៨,៩%) ថៃ (២១,៥%) និងម៉ាឡេស៊ី (៤២,៣%)។

**ជ. ស្ថានភាពទេសន្តរប្រវេសន៍ការងារ**

ស្របជាមួយនឹងការបង្កើតការងារក្នុងប្រទេស ឱកាសការងារនៅក្រៅប្រទេស ក៏ជាប្រភពការងារមួយដ៏សំខាន់សម្រាប់កម្លាំងពលកម្មកម្ពុជា។ ចន្លោះពី ឆ្នាំ២០១៣-២០១៨ ចំនួនពលករទេសន្តរប្រវេសន៍បានកើនឡើងពីប្រមាណជា ៥០៧ ៦៦៩នាក់ ដែលក្នុងនោះទៅប្រទេសថៃមានការកើនឡើង ៤៩៤ ៧៤០នាក់ ប្រទេសជប៉ុនកើនឡើង ៦ ៨៩៥នាក់ សាធារណរដ្ឋកូរ៉េកើនឡើង ២០ ២៧២នាក់ សិង្ហបុរីកើនឡើង ៧២០នាក់ តំបន់រដ្ឋបាលពិសេសហុងកុងកើនឡើង ៥៤នាក់ អារ៉ាប៊ីសាអូឌីត កើនឡើង ១៦នាក់ និងប្រទេសម៉ាឡេស៊ីថយចុះ ១៥ ០២៨នាក់។ នៅឆ្នាំ២០១៨ បើយើងពិនិត្យទៅតាមចំនួនអ្នកធ្វើការងារនៅក្រៅប្រទេសសុរបប្រមាណ ១,២លាននាក់ ប្រមាណជា ៩២.៩% កំពុងធ្វើការ និងស្នាក់នៅប្រទេសថៃ ហើយប្រមាណជា ៧,១% ផ្សេងទៀត នៅក្នុងប្រទេសម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត ជប៉ុន សិង្ហបុរី តំបន់រដ្ឋបាលពិសេសហុងកុង និងសាធារណរដ្ឋកូរ៉េ។

**២.១.៣. និន្នាការនៃតម្រូវការការងារនាពេលអនាគត**

**ក. ការព្យាករតម្រូវការកម្លាំងពលកម្មតាមវិស័យ**

ជាមួយព្យាករណ៍អត្រាកំណើនប្រមាណជា ៧,២% ក្នុងមួយឆ្នាំក្នុងរយៈពេលមធ្យម (២០១៨-២០២១) សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងអាចបង្កើតការងារបន្ថែមប្រមាណជា ២១៦ ពាន់នាក់ ឬកើនឡើងប្រមាណជា ២,២% ក្នុងមួយឆ្នាំ ដែលធ្វើឱ្យចំនួនអ្នកមានការងារសុរបកើនឡើងដល់ប្រមាណជា ១០,២លាននាក់ នៅ



ង៉

ឆ្នាំ២០២១។ នៅក្នុងចន្លោះឆ្នាំដូចគ្នានេះ វិស័យឧស្សាហកម្មត្រូវបានព្យាករណ៍ថានឹងមានអត្រាកំណើនការងារប្រចាំឆ្នាំប្រមាណជា ៦,៧% ក្នុងមួយឆ្នាំ វិស័យសេវាកម្មនឹងកើនឡើងប្រមាណជា ៣,៣% ក្នុងមួយឆ្នាំ និងវិស័យកសិកម្មនឹងថយចុះប្រមាណជា ២,៦% ក្នុងមួយឆ្នាំ។ ការថយចុះនៃចំនួនអ្នកធ្វើការក្នុងវិស័យកសិកម្ម គឺជានិន្នាការមួយដែលត្រូវបានសង្កេតឃើញតាំងពីមួយទសវត្សរ៍មុនរួចមកហើយ។

**តារាង ២.១១÷ ការព្យាករការប្រែប្រួលសេដ្ឋកិច្ច និងការងារតាមវិស័យ ចន្លោះឆ្នាំ២០១៨-២០២១**

| | អត្រាកំណើន ២០១៨-២០២១ | | បរិមាណភាគឆ្នាំ២០២១ | |
|---|---|---|---|---|
| | ផ.ស.ស (%) | ការងារ (%) | ផ.ស.ស (%) | ការងារ (%) |
| កសិកម្ម | 1.7 | -2.6 | 15.5 | 31.5 |
| ឧស្សាហកម្ម | 10.2 | 6.7 | 37.9 | 30.3 |
| សេវាកម្ម | 7.0 | 3.3 | 39.4 | 38.2 |
| **សរុប** | 7.2 | 2.2 | 100.0 | 100.0 |

ប្រភព÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ចន្លោះពីឆ្នាំ២០១៨ ទៅ២០២១ យើងនឹងសង្កេតឃើញនូវនិន្នាការតម្រូវការកម្លាំងពលកម្មតាមអនុវិស័យដូចខាងក្រោម÷

- អនុវិស័យសេដ្ឋកិច្ចដែលនឹងបង្កើតការងារច្រើនជាងគេគឺ សំណង់ (៦៣ ៦៥៦នាក់ ក្នុងមួយឆ្នាំ) និងទី២គឺ កម្មន្តសាលផ្សេងៗ (៦០ ៨៦៩ ក្នុងមួយឆ្នាំ)។ ការកើនឡើងនៃតម្រូវការកម្លាំងពលកម្មនៅក្នុងអនុវិស័យកម្មន្តសាលផ្សេងៗ ជាសញ្ញាណនៃពិពិធកម្មនៅក្នុងសេដ្ឋកិច្ច។
- អនុវិស័យដែលនឹងមានអត្រាកំណើនការងារលឿន (អត្រាកំណើន២ខ្ទង់ ក្នុងមួយឆ្នាំ)មាន÷ កម្មន្តសាលផ្សេងៗ (២១,៦%) ផលិតផលជ័រកៅស៊ូ និងប្លាស្ទិក (១២,០%) និងហិរញ្ញវត្ថុនិងធានារ៉ាប់រង (១២,២%)។
- អនុវិស័យ ៣ ដែលនឹងមានចំនួនការងារធ្លាក់ចុះច្រើនជាងគេ÷ ដំណាំ (៧៨ ០៩១នាក់ ក្នុងមួយឆ្នាំ), រុក្ខាប្រមាញ់ (១៦ ៤៨១ នាក់), និងសេវាកម្មផ្សេងៗ (១០ ៣២៩ នាក់)។

**តារាង ២.១២÷ ការព្យាករកំណើនការងារតាមវិស័យ ចន្លោះឆ្នាំ២០១៨ និង២០២១**

| សកម្មភាពសេដ្ឋកិច្ច | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2018-2021) | | | 2021 | |
|---|---|---|---|---|---|
| | ចំនួន | អត្រាចូលរួម(%) | អត្រាកំណើន (%) | ចំនួន (ពាន់នាក់) | បរិមាណភាគ (%) |
| **កសិកម្ម** | **(88,633)** | **-40.9** | **-2.6** | **3,214** | **31.5** |
| ដំណាំ | (78,091) | -36.1 | -3.3 | 2,194 | 21.5 |
| សកម្មភាពចិញ្ចឹមសត្វ | 5,587 | 2.6 | 0.8 | 755 | 7.4 |
| រុក្ខាប្រមាញ់ | (16,481) | -7.6 | -16.4 | 69 | 0.7 |
| ការនេសាទ | 352 | 0.2 | 0.2 | 195 | 1.9 |
| **ឧស្សាហកម្ម** | **183,498** | **84.8** | **6.7** | **3,097** | **30.3** |
| ការជីករ៉ែ | (3,110) | -1.4 | -13.8 | 17 | 0.2 |
| កម្មន្តសាលផ្នែកផលិតចំណីអាហារ និងភេសជ្ជៈ | 9,807 | 4.5 | 4.8 | 224 | 2.2 |
| កម្មន្តសាលផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង | 52,527 | 24.3 | 4.6 | 1,251 | 12.3 |
| កម្មន្តសាលផ្នែកកែច្នៃឈើ ក្រដាស និងបោះពុម្ព | (6,462) | -3.0 | -8.3 | 65 | 0.6 |
| កម្មន្តសាលផ្នែកផលិតផលជ័រកៅស៊ូ និងប្លាស្ទិក | 1,174 | 0.5 | 12.0 | 12 | 0.1 |
| កម្មន្តសាលផ្សេងៗ | 60,869 | 28.1 | 21.6 | 411 | 4.0 |
| សំណង់ | 63,656 | 29.4 | 7.0 | 1,044 | 10.2 |
| ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន និងទឹក | 5,038 | 2.3 | 8.1 | 72 | 0.7 |
| **សេវាកម្ម** | **121,600** | **56.2** | **3.3** | **3,894** | **38.2** |
| ពាណិជ្ជកម្មលក់ដុំ និងរាយ | 57,058 | 26.4 | 4.5 | 1,395 | 13.7 |
| ការស្នាក់នៅ និងភោជនីយដ្ឋាន | 20,276 | 9.4 | 4.3 | 514 | 5.0 |
| ការដឹកជញ្ជូន ព័ត៌មានវិទ្យា និងគមនាគមន៍ | 13,104 | 6.1 | 2.7 | 517 | 5.1 |
| ហិរញ្ញវត្ថុ និងធានារ៉ាប់រង | 12,648 | 5.8 | 12.2 | 130 | 1.3 |
| រដ្ឋបាលសាធារណៈ | 10,242 | 4.7 | 3.2 | 337 | 3.3 |
| អចលនទ្រព្យ និងសេវាកម្មគាំទ្រអាជីវកម្ម | 18,601 | 8.6 | 3.7 | 539 | 5.3 |
| សេវាកម្មផ្សេងៗ | (10,329) | -4.8 | -2.1 | 463 | 4.5 |
| **ចំនួនការងារសរុប** | **216,465** | **100.0** | **2.2** | **10,204** | **100.0** |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧

## ខ. ការព្យាករតម្រូវការកម្លាំងពលកម្មតាមមុខរបរ

ក្នុងចន្លោះឆ្នាំពី២០១៨ ទៅ២០២១ មុខរបរដែលត្រូវបានព្យាករណ៍ថា នឹងបង្កើតការងារច្រើនជាងគេគឺ កម្មករជំនាញផ្នែកសិប្បកម្ម (កម្មករជំនាញកម្រិតមធ្យម) ប្រមាណជា ១៥២ ៥៣៥នាក់ ក្នុងមួយឆ្នាំ ឬ ៧០,៥% នៃការងារសរុបដែលនឹងត្រូវបានបង្កើត។ ភាគច្រើននៃមុខរបរប្រភេទនេះត្រូវបានបង្កើតក្នុងអនុវិស័យ កម្មន្តសាលផ្សេងៗ សំណង់ និងវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង។ អ្នកជំនាញផ្នែកលក់ និងសេវាកម្ម ត្រូវបានព្យាករណ៍ថា នឹងកើនឡើងប្រមាណជា ៦៩ ៧៨៣ នាក់ ក្នុងមួយឆ្នាំ។

ក្នុងរយៈពេលដូចគ្នានេះ ប្រភេទមុខរបរដែលត្រូវបានព្យាករថា នឹងមានកំណើនការងារលឿនគឺ លេខាធិការ ជាមួយអត្រាកំណើន ១១,៣% ជាមធ្យមក្នុងមួយឆ្នាំ អ្នកជំនាញផ្នែកសិប្បកម្មកើនឡើង ៧% និងអ្នកបញ្ជាម៉ាស៊ីន និងផ្គុំដំឡើងកើនឡើង ៥,៩%។ ការងារទាមទារជំនាញខ្ពស់ ដូចជា អ្នកគ្រប់គ្រង អ្នកឯកទេសវិជ្ជាជីវៈ និងអ្នកបច្ចេកទេស ឬវិជ្ជាជីវៈរង នឹងកើនឡើងប្រមាណជា ៤,២% នៃការងារសរុបដែលនឹងបង្កើត។ ទន្ទឹមនឹងនេះ ការងារដែលជាកសិករនឹងធ្លាក់ចុះប្រមាណជា ៤,១% ក្នុងមួយឆ្នាំ។

**តារាង ២.១៣ ÷ ការព្យាករកំណើនការងារតាមប្រភេទមុខរបរ ចន្លោះឆ្នាំ ២០១៨ និង២០២១**

| ប្រភេទនៃមុខរបរ | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2018-2021) | | | 2021 | |
|---|---|---|---|---|---|
| | ចំនួន | អត្រាចូលរួម(%) | អត្រាកំណើន (%) | ចំនួន (ពាន់នាក់) | បរិមាណភាគ (%) |
| អ្នកគ្រប់គ្រង | 499 | 0.2 | 0.5 | 95 | 0.9 |
| អ្នកឯកទេសវិជ្ជាជីវៈ | 1,318 | 0.6 | 0.4 | 296 | 2.9 |
| អ្នកបច្ចេកទេស ឬវិជ្ជាជីវៈរង | 7,269 | 3.4 | 5.0 | 160 | 1.6 |
| លេខាធិការ | 68,121 | 31.5 | 11.3 | 743 | 7.3 |
| អ្នកជំនាញផ្នែកលក់ ឬសេវាកម្ម | 69,783 | 32.2 | 3.9 | 1,940 | 19.0 |
| កសិករ | -113,171 | -52.3 | -4.1 | 2,563 | 25.1 |
| កម្មករជំនាញផ្នែកសិប្បកម្ម | 152,535 | 70.5 | 7.0 | 2,480 | 24.3 |
| អ្នកបញ្ជាម៉ាស៊ីន និងផ្គុំដំឡើង | 34,567 | 16.0 | 5.9 | 652 | 6.4 |
| កម្មករគ្មានជំនាញ | 5,545 | 2.6 | 0.4 | 1,253 | 12.3 |
| មុខរបរផ្សេងៗ | -10,002 | -4.6 | -25.3 | 22 | 0.2 |
| សរុប | 216,465 | 100.0 | 2.2 | 10,204 | 100.0 |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពីឆ្នាំ១៩៩៣-២០១៧

## គ. ការព្យាករតម្រូវការកម្លាំងពលកម្មតាមកម្រិតនៃការអប់រំ

ដូចគ្នាទៅនឹងនិន្នាការតម្រូវការកម្លាំងពលកម្មតាមប្រភេទមុខរបរ ចំនួនអ្នកមានការងារដែលមិនមានការអប់រំ ឬទទួលបានការអប់រំតិចតួច ត្រូវបានរំពឹងនឹងមានការថយចុះខ្លាំង ពោលគឺនឹងត្រូវកាត់បន្ថយ ហើយជំនួសមកវិញដោយការងារដែលទាមទារការអប់រំកម្រិតខ្ពស់ ជាពិសេស ការងារកម្រិតមធ្យមសិក្សាទុតិយភូមិ និងថ្នាក់ឧត្តមដែលត្រូវបានរំពឹងថានឹងមានកើនឡើងប្រមាណជា ១២,០% និង ១១,១% ក្នុងមួយឆ្នាំ រៀងគ្នា នៅចន្លោះពីឆ្នាំ ២០១៨ និង២០២១។ ទន្ទឹមនឹងនេះ យើងក៏សង្កេតឃើញ មានការធ្លាក់ចុះយ៉ាងលឿននៃចំនួនការងារ ដែលទាមទារការអប់រំកម្រិតទាបជាងថ្នាក់បឋមសិក្សា ដែលនេះអាចបង្កឱ្យមានបញ្ហានិកម្មភាព ដែលបណ្តាលមកពីការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច។

**តារាង ២.១៤÷ ការព្យាករកំណើនការងារតាមកម្រិតនៃការអប់រំ ចន្លោះឆ្នាំ ២០១៨ និង២០២១**

| កម្រិតនៃការអប់រំ | ការប្រែប្រួលជាមធ្យមក្នុងមួយឆ្នាំ (2018-2021) | | | 2021 | |
|---|---|---|---|---|---|
| | ចំនួន | អត្រាចូលរួម(%) | អត្រាកំណើន (%) | ចំនួន (ពាន់នាក់) | បរិមាណភាគ (%) |
| ឧត្តមសិក្សា | 93,878 | 43.4 | 12.0 | 977 | 9.6 |
| មធ្យមសិក្សាទុតិយភូមិ | 76,777 | 35.5 | 11.1 | 854 | 8.4 |
| មធ្យមសិក្សាបឋមភូមិ | 79,863 | 36.9 | 4.6 | 1,894 | 18.6 |
| បឋមសិក្សា | 41,576 | 19.2 | 1.6 | 2,655 | 26.0 |
| មិនបញ្ចប់ថ្នាក់បឋមសិក្សា | -19,951 | -9.2 | -0.7 | 2,776 | 27.2 |
| គ្មាន ឬរៀនបានតិចតួច | -58,906 | -27.2 | -5.7 | 922 | 9.0 |
| ការអប់រំបណ្តុះបណ្តាលបច្ចេកទេស (មុន និងបន្ទាប់ពីមធ្យមសិក្សាទុតិយភូមិ) | 3,228 | 1.5 | 2.7 | 127 | 1.2 |
| សរុប | 216,465 | 100.0 | 2.2 | 10,204 | 100.0 |

ប្រភព÷ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយផ្អែកលើការអង្កេតសង្គមសេដ្ឋកិច្ចពី ឆ្នាំ១៩៩៣-២០១៧

### ២.១.៤. បញ្ហាប្រឈមនៅក្នុងទីផ្សារការងារ

ដោយផ្អែកលើទិន្នន័យដែលបានបង្ហាញខាងលើ ទីផ្សារការងារកម្ពុជាកំពុងតែប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួនដូចខាងក្រោម÷

១. ប្រមាណ ៥០,៨% នៃអ្នកដែលមានការងារសរុបកំពុងតែបម្រើការងារក្នុងទម្រង់ការងារជាអ្នកប្រើទុនដោយខ្លួនឯង ឬជួយការងារគ្រួសារដោយមិនទទួលប្រាក់កម្រៃ ដែលប្រភេទការងារទាំងអស់នេះត្រូវបានចាត់ទុកជាការងារក្រៅផ្លូវការ ហើយអាចប្រឈមទៅនឹងលក្ខខណ្ឌការងារទាប។ ក្នុងន័យនេះ ការជំរុញការបង្កើតការងារសមរម្យ និងមានផលិតភាពខ្ពស់ ជាពិសេសនៅវិស័យក្រៅពីកសិកម្ម គឺជាការចាំបាច់សម្រាប់កម្ពុជា។

២. តាមរយៈការពិនិត្យ និងការវិភាគទៅលើស្ថានភាពប្រជាសាស្ត្រ ការទទួលបានការអប់រំ និងជំនាញ និងតម្រូវការជំនាញនៅផ្នែកខាងលើ យើងអាចសង្កេតឃើញថា ភាពមិនបន្សុីគ្នានៃជំនាញកំពុងតែកើតមានឡើងនៅក្នុងទីផ្សារការងារនៃប្រទេសកម្ពុជា ជាពិសេសនៅក្នុងជំនាញកម្រិតមធ្យម និងខ្ពស់។ បញ្ហានេះបានបណ្តាលឱ្យនិយោជកបាន នឹងកំពុងប្រឈមការលំបាក ក្នុងការជ្រើសរើសកម្លាំងពលកម្មដើម្បីបំពេញតាមតម្រូវការរបស់ខ្លួនដែលបណ្តាលមកពីបញ្ហាកង្វះជំនាញនៅលើទីផ្សារការងារ (skill shortages) និងគម្លាតជំនាញ (skill gaps) ដោយសារបេក្ខជនដែលមកដាក់ពាក្យខ្វះជំនាញ, គុណវុឌ្ឍ និងបទពិសោធន៍ការងារតាមតម្រូវការរបស់និយោជក។ ហេតុដូច្នេះ ការពង្រឹង និងពង្រីកការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសកម្លាំងពលកម្មដែលកំពុងធ្វើការ គឺមានសារៈសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវជំនាញនៃកម្លាំងពលកម្មកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការកម្លាំងពលកម្មជំនាញកម្រិតមធ្យម និងខ្ពស់ទាំងនៅក្នុងប្រទេស និងក្នុងតំបន់ដែលកំពុងតែមានការកើនឡើង។

៣. ទីផ្សារការងារមិនទាន់ដំណើរការល្អ ដោយសាររបាយកម្លាំងពលកម្មមិនស្មើគ្នា (រវាងទីប្រជុំជន និងជនបទ), សេវាអន្តរកម្មការងារ និងការបែងចែកព័ត៌មានមិនទាន់មានការអភិវឌ្ឍពេញលេញ និងប្រព័ន្ធព្យាករណ៍ និងប៉ាន់ស្មានទៅអនាគតអំពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងជំនាញ និងការងារមិនទាន់ត្រូវបានអភិវឌ្ឍ។ នេះបានបង្ហាញថា ការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម រួមមានការពង្រីកការផ្តល់សេវាការងារសាធារណៈ ការពង្រឹងយន្តការវេទិកាការងារ និងការតម្រង់ទិសមុនចូលទីផ្សារការងារ គឺដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវដំណើរការទីផ្សារការងារ តាមរយៈ ការធ្វើឱ្យមានតម្លាភាពរវាងការផ្គត់ផ្គង់ និងតម្រូវការនៅលើទីផ្សារការងារ និងផ្តល់ភាពងាយស្រួលឆាប់រហ័ស ក្នុងការផ្គូផ្គងរវាងអ្នកស្វែងរកការងារ និងព័ត៌មានជ្រើសរើសកម្លាំងពលកម្ម។ បន្ថែមពីលើនេះ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលដើរតួនាទីក្នុងការប្រមូល ផ្សព្វផ្សាយ វិភាគ វាយតម្លៃ និងផ្តល់ព័ត៌មានទីផ្សារឱ្យបានទៀងទាត់ទាន់ពេលវេលា និងទូលំទូលាយ រួមទាំងការងារពាក់ព័ន្ធនឹងការកែលម្អស្ថានភាពទីផ្សារការងារ នៅក្នុងវិស័យដែលត្រូវការបន្ថែមកម្លាំងពលកម្ម នឹងដើរតួកាន់តែសំខាន់ក្នុងការធានាថា ប្រជាជនដែលមានជំនាញ និងបទពិសោធន៍ការងារស្រាប់នឹងមានលទ្ធភាពទទួលបានឱកាសការងារប្រសើរជាងមុន នៅតាមបណ្តាវិស័យសេដ្ឋកិច្ចដែលមានការរីកចម្រើន។

៤. ការប្រែក្លាយកម្លាំងពលកម្មភាគច្រើននៅតែស្ថិតក្នុងវិស័យកសិកម្ម និងទទួលបានការអប់រំក្រោមថ្នាក់បឋមសិក្សា ទៅបម្រើការឱ្យវិស័យឧស្សាហកម្ម និងសេវាកម្ម ទាមទារការផ្លាស់ប្តូរសំខាន់មួយក្នុងទីផ្សារការងាររួមមានរបៀបរបបនៃការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាលជំនាញ វិន័យ ឥរិយាបថការងារ បណ្តុះទម្លាប់ជាពិសេសទំនាក់ទំនងវិជ្ជាជីវៈដែលមានភាពសុខដុម និងរឹងមាំដែលគាំទ្រដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងបែងចែកអត្ថប្រយោជន៍ដែលកើតពីកំណើនសេដ្ឋកិច្ចរវាងនិយោជិត និងនិយោជកប្រកបដោយសមធម៌។ ប៉ុន្តែ ទំនាក់ទំនងវិជ្ជាជីវៈប្រកបដោយភាពសុខដុមរមនា និងធានាភាពអាចព្យាករបានរវាងកម្មករនិយោជិត និងនិយោជកនៅមិនទាន់បានអភិវឌ្ឍពេញលេញ និងមានភាពចាស់ទុំនៅឡើយទេ។

៥. មូលដ្ឋាននៃកំណើន និងការងារតូចចង្អៀត បានឆ្លុះបញ្ចាំងពីកម្លាំងពលកម្មមានលក្ខណៈ ប្រមូលផ្តុំ និងពឹងផ្អែកទៅលើតែវិស័យមួយចំនួនតូច។ ទន្ទឹមគ្នានេះ កំណើនប្រាក់ឈ្នួលមិនសមស្រប នឹងកំណើនផលិតភាពបាននឹងកំពុងដាក់សម្ពាធលើល្បឿន នៃការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចចេញពីការពឹងផ្អែកលើឧស្សាហកម្មអតិពលកម្ម ទៅឧស្សាហកម្មដែលផ្អែកលើជំនាញ និងមានតម្លៃបន្ថែមកាន់តែខ្ពស់។ ប្រការនេះតម្រូវឱ្យមានការវិនិយោគនៅគ្រប់កម្រិតក្នុងបង្កើនផលិតភាព ដែលចាប់ពីកម្រិតថ្នាក់ជាតិ កម្រិតសហគ្រាស និងកម្រិតបុគ្គល។ ប៉ុន្តែការបង្កើនផលិតភាពការងារ ដែលប្រចាំបំផុតគឺនៅកម្រិតបុគ្គលិក ដែលនេះទាមទារទាំងការវិនិយោគទៅលើវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលក្នុងពេលធ្វើការងារ។ ប៉ុន្តែកិច្ចការដំបូងចាំបាច់បន្ទាន់ដែលចាំបាច់ត្រូវធ្វើ គឺការបង្កើតឡើងនូវផ្នត់គំនិតជាមូលដ្ឋានអំពីផលិតភាព ភាពចាំបាច់ និងសារប្រយោជន៍របស់វាក្នុងការលើកកម្ពស់ភាពប្រកួតប្រជែង ការទ្រទ្រង់កំណើនរយៈពេលវែង ការបង្កើតការងារកាន់តែល្អ និងការបន្តលទ្ធភាពដំឡើងប្រាក់ឈ្នួលកាន់តែខ្ពស់។

៦. ការលេចឡើងនូវបដិវត្តន៍ឧស្សាហកម្មទី៤.០ បាននាំឱ្យតម្រូវការជំនាញកាន់តែខ្ពស់ ដែលនេះអាចនឹងបង្កឱ្យមានបញ្ហាកង្វះជំនាញ ព្រមទាំងការជំនួសកម្លាំងមនុស្សដោយម៉ាស៊ីនស្វ័យប្រវត្តិកម្ម និងបញ្ញាសិប្បនិម្មិតដែលនេះអាចនាំឱ្យបាត់បង់ការងារ ជាពិសេសសម្រាប់កម្លាំងពលកម្មជំនាញទាប និងគ្មានជំនាញ។ ហេតុដូចនេះដើម្បីត្រៀមលក្ខណៈទប់ទល់នឹងបញ្ហាប្រឈម និងទាញប្រយោជន៍ជាអតិបរមាពីបដិវត្តន៍ឧស្សាហកម្មទី៤.០នេះ ការលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍ គឺជាការចាំបាច់ក្នុងការទាញយកផលប្រយោជន៍ ភាពរីកចម្រើននៃបច្ចេកវិទ្យា និងនវានុវត្តលើឧស្សាហកម្មដែលមានស្រាប់។

៧. ដោយសារអតុល្យភាពប្រជាសាស្ត្រ ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងតំបន់មានកម្រិតផ្សេងគ្នា កំណើនទេសន្តរប្រវេសន៍នឹងបន្តកើនឡើង ដែលអាចបណ្តាលឱ្យកើតមានឡើងការខ្វះខាតកម្លាំងពលកម្មក្នុងប្រទេសនិងការកើនឡើងប្រាក់ឈ្នួលក្នុងស្រុកលឿន។ ទន្ទឹមនឹងនិន្នាការនេះ បញ្ហាប្រឈម គឺការគ្រប់គ្រង ការពារសិទ្ធិផលប្រយោជន៍របស់ពលករទេសន្តរប្រវេសន៍ខ្មែរនៅក្រៅប្រទេស។


ឍ/

៨. តម្រូវការកាន់តែកើនឡើងក្នុងការពង្រីករបបសន្តិសុខសង្គមទៅវិស័យក្រៅផ្លូវការ ព្រមទាំងពង្រីកប្រភេទរបបសន្តិសុខ និងសង្គមដើម្បីធានាស្ថិរភាពការងារ និងចំណូលរបស់ប្រជាពលរដ្ឋ។

## ២.២- សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨

នាអាណត្តិ ២០១៤-២០១៨ កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច បើទោះជាត្រូវប្រឈមបញ្ហាធំៗជាច្រើន និងការប្រែប្រួលនៃពាណិជ្ជកម្មនៅក្នុងតំបន់ និងអន្តរជាតិក៏ដោយ។ ដោយការអនុវត្តយ៉ាងប្តូរផ្តាច់ប្រកបដោយភាពប្រយ័ត្នប្រយែងនូវ **ផ.យ.អ.ក.ប ២០១៤-២០១៨** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រេចបាននូវលទ្ធផលការងារសំខាន់ៗ ព្រមទាំងជួបប្រទះបញ្ហាប្រឈមគន្លឹះមួយចំនួនដូចខាងក្រោម÷

### ២.២.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- បានធ្វើវិសោធនកម្មបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងរៀបចំបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារឱ្យស្របតាមការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច-សង្គម និងបទដ្ឋានអន្តរជាតិ ជាពិសេសបានរៀបចំកសាងច្បាប់ស្តីពីសហជីព នៅឆ្នាំ២០១៦ និងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា នៅក្នុងឆ្នាំ ២០១៨
- បានកែសម្រួលយន្តការអធិការកិច្ចការងារ ពីការធ្វើអធិការកិច្ចការងារជាច្រើនក្រុមដាច់ដោយឡែកពីគ្នាតាមជំនាញនីមួយៗមកជាក្រុមអធិការកិច្ចការងាររួមគ្នា និងបានធ្វើអធិការកិច្ចការងារបានចំនួន ៤៤ ៧៣៩ លើក កើនឡើង ៣,៦ ដង ធៀបនឹងអាណត្តិទី៤ ព្រមទាំងដាក់កំហិតចំនួន ៤ ២៣៩ សហគ្រាស គ្រឹះស្ថាន, ផាកពិន័យចំនួន ៣០២ សហគ្រាស គ្រឹះស្ថាន និងប្តឹងទៅតុលាការចំនួន ០៩ សហគ្រាស-គ្រឹះស្ថាន
- បានបង្កើតប្រព័ន្ធគ្រប់គ្រងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត
- បានកែលម្អរបាយការណ៍អធិការកិច្ចការងារឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ តម្លាភាព និងទទួលបានការជឿទុកចិត្តពីគ្រប់ភាគីពាក់ព័ន្ធស្របតាមច្បាប់ជាធរមាន និងស្តង់ដាអន្តរជាតិ ព្រមទាំងការពង្រឹងសមត្ថភាពមន្ត្រី និងគុណភាពអធិការកិច្ចការងារតាមរយៈបន្តគាំទ្រគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) និងកិច្ចសហការជាមួយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)
- បានរៀបចំបង្កើតវិទ្យាស្ថានជាតិការងារដែលនឹងដាក់ឱ្យដំណើរការនៅឆ្នាំ ២០១៩នេះ ក្នុងគោលបំណងអភិវឌ្ឍសមត្ថភាព និងផ្តល់វិក្រឹត្យការដល់មន្ត្រីរាជការក្នុងវិស័យការងារ
- បានបន្តអនុវត្តយន្តការក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ (ក្រុមការងារទី៨) នៃគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍវិស័យឯកជន ព្រមទាំងគណៈកម្មការប្រឹក្សាការងារ (ត្រីភាគី) ដើម្បីសម្របសម្រួលទទួលយកយោបល់ស្តីអំពីលក្ខខណ្ឌការងារ និងការដោះស្រាយបញ្ហាទាក់ទងនឹងទំនាក់ទំនងវិជ្ជាជីវៈ



ង

- បានពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា (គ.ក.ប) គ្រប់ជាន់ថ្នាក់ និងអគ្គលេខាធិការដ្ឋាន គ.ក.ប ដើម្បីប្រចាំការត្រៀមខ្លួនអន្តរាគមន៍ទប់ស្កាត់ ដោះស្រាយ និងផ្សះផ្សាវិវាទ ព្រមទាំងបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី គ.ក.ប និងអាជ្ញាធរពាក់ព័ន្ធ សរុបចំនួន ៣ ៦៩៧នាក់ ស្មើនឹង ១៨ វគ្គ និងអន្តរាគមន៍ដោះស្រាយកូដកម្មចំនួន ១ ០២២ លើ ១ ០៤២ករណី (ស្មើនឹង ៩៨,១%) ដែលជាលទ្ធផល ករណីសះជាមានចំនួន ១ ០០៨ ករណី (ស្មើនឹង ៩៦,៧% នៃចំនួនកូដកម្មសរុប) ចំនួនករណីកូដកម្មដែលកើតឡើងនៅតាម សហគ្រាស គ្រឹះស្ថាន បានថយចុះជាបន្តបន្ទាប់ប្រមាណជា ៨៦,២ %ពោលគឺថយចុះពី ៣៤២ ទៅ ៤៧ ក្នុងចន្លោះឆ្នាំ២០១៤ និង២០១៨ និងអត្រាកូដកម្មដែលឈានទៅដល់ហិង្សាស្ថិតនៅក្នុងកម្រិតទាប និងគ្រប់គ្រងបានប្រមាណជា ៤,១%

- បានដោះស្រាយវិវាទការងារចំនួន ៤ ២៧២ករណី ក្នុងនោះវិវាទបុគ្គលចំនួន ១ ៤៥៣ ករណី និងវិវាទការងាររួមចំនួន ២ ៨១៩ ករណី។ ជារួម យន្តការ និងសមត្ថភាពមន្ត្រីក្នុងការដោះស្រាយវិវាទការងារត្រូវបានកែលម្អ និងមានប្រសិទ្ធភាពជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃចំនួនវិវាទការងាររួមពី ៨៧៥ មកត្រឹម ១៦៣ ករណី នៅចន្លោះឆ្នាំ ២០១៤-២០១៨ ហើយអត្រាវិវាទការងាររួមដែលសះជាកើនឡើងពី ៣៥,១% ទៅ ៦០,៧% នៅក្នុងរយៈពេលដូចគ្នានេះ

- បានបន្តអនុវត្តយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ដោយក្នុងអំឡុងឆ្នាំ ២០១៤-២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដោះស្រាយវិវាទការងាររួមចំនួន ១ ០៥២សំណុំរឿង ដែលក្នុងនោះ សំណុំរឿងចំនួន ៧៣៣ ត្រូវបានដោះស្រាយដោយចេញសេចក្តីបង្គាប់, សំណុំរឿងចំនួន ៦៧ ត្រូវបានដោះស្រាយសះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលខ្លួនឯង ហើយសំណុំរឿងចំនួន ២៥២ ត្រូវបានសះជាដោយភាគីទាំងពីរ

- បានពង្រឹងការអនុវត្តច្បាប់ស្តីពីសហជីព ដោយនៅក្នុងឆ្នាំ២០១៧ ក្រសួងបានចុះបញ្ជិកាអង្គការវិជ្ជាជីវៈចំនួន ៦៨១ គឺច្រើនជាងការចុះបញ្ជីអង្គការវិជ្ជាជីវៈសរុបក្នុងចន្លោះឆ្នាំ២០១៤-២០១៦ ដោយឡែកក្នុងឆ្នាំ ២០១៨ ចំនួននេះក៏នៅតែបន្តកើនឡើងចំនួន ៥៣៣។ ការកើនឡើងនេះបានបង្ហាញថា ការអនុវត្តសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈត្រូវបានលើកកម្ពស់ គ្មានការរឹតត្បិត ឬរើសអើងចំពោះការចូលរួមដោយសេរី និងស្មើភាពរបស់កម្មករនិយោជិតក្នុងការចូលរួមលើកកម្ពស់លក្ខខណ្ឌការងារ និងធានាបាននូវសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

- បានចេញលិខិតទទួលស្គាល់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈចំនួន ៥៥៤ និងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការវិជ្ជាជីវៈ

- បានដោះស្រាយករណីថៅកែរត់ចោលមិនទូទាត់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងៗចំនួន ៨៦ ករណី មានកម្មករនិយោជិតចំនួន ៣០ ០០៦ នាក់ ក្នុងនោះករណីដោះស្រាយក្រៅប្រព័ន្ធតុលាការចំនួន ៦៥ ករណី នីតិវិធីក្ស័យធនចំនួន ០៣ ករណី និងប្រាក់បុរេប្រទានពីរាជរដ្ឋាភិបាលចំនួន ១៨ ករណី

- បានរៀបចំពិធីចុះជួបសំណេះសំណាលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាមួយបងប្អូនកម្មករនិយោជិត ប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម

ជំនួយការ នៅតាមបណ្តារោងចក្រនានា និងចុះសាកសួរសុខទុក្ខកម្មករនិយោជិតផ្ទាល់នៅតំបន់ឧស្សាហកម្ម និង តាមរោងចក្រ សហគ្រាសទូទាំងប្រទេសចំនួន ៦១ លើក មានកម្មករនិយោជិតចំនួន ៨៧៥ ១៧៣ នាក់

- បានពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា តាមរយៈយន្តការត្រីភាគី ដោយសម្រេចកំណត់គោលការណ៍ចំនួន ៥ លក្ខណវិនិច្ឆ័យបែបសង្គមនិងបែបសេដ្ឋកិច្ចចំនួន ៧ និងកាលវិភាគក្នុងការចរចាប្រាក់ឈ្នួលអប្បបរមាច្បាស់លាស់ និងបង្កើត "ក្រុមការងារបច្ចេកទេសត្រីភាគី" ដើម្បីពិភាក្សាការងារបច្ចេកទេសលម្អិតលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច ព្រមទាំងរក្សានូវអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងបន្ថែមលើប្រាក់ឈ្នួលអប្បបរមាដែល រួមមាន ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ, ប្រាក់សោហ៊ុយធ្វើដំណើរ ឬស្នាក់នៅចំនួន ៧ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ និងប្រាក់រង្វាន់អតីតភាពការងារដែលទទួលបានចន្លោះពី ១ ទៅ ១១ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ

- បានដំឡើងប្រាក់ឈ្នួលអប្បបរមាពី ១០០ ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៤ ដល់ ១៧០ដុល្លារសហរដ្ឋអាមេរិកនៅឆ្នាំ២០១៨ សម្រាប់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតក្នុងវិស័យនេះ កើនឡើងដល់ ១៨២ ដុល្លារសហរដ្ឋអាមេរិក ប្រសិនបើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម កម្មករនិយោជិតម្នាក់អាចទទួលបានប្រាក់ឈ្នួលពី ១៩៩ ទៅ ២១០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ

- បានអនុវត្តផែនការជាតិស្តីពីកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ដោយពលកម្មកុមារចំនួន ២៧ ៥៤៩ នាក់ (ស្រី ១៤ ៦៩៩នាក់) ត្រូវបានដកហូតទប់ស្កាត់ និងសមាហរណកម្មទៅក្នុងសង្គមជាតិវិញ

- បានបង្កើតគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ និងរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋាន ព្រមទាំងពិនិត្យកាយសម្បទាជូនមន្ត្រីរាជការ សិស្ស និស្សិត កម្មករនិយោជិតខ្មែរ និងបរទេសចំនួន ១,៤លាននាក់, បញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសចំនួន ៨១៨នាក់ ផ្តល់សេវាបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារចំនួន ១០ ៣០៤ នាក់, និងពិនិត្យសុខភាពពលករខ្មែរដែលទៅធ្វើការនៅបរទេសចំនួន ៣៨ ៦៤៧នាក់

- បានជំរុញការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថានចំនួន ៦៤៤ ព្រមទាំងសហការជាមួយដៃគូពាក់ព័ន្ធរៀបចំទិវាពិភពលោក ដើម្បីសុខភាព និងសុវត្ថិភាពការងារជារៀងរាល់ឆ្នាំ

- បានពង្រឹងសមត្ថភាពមន្ត្រី និងលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារថ្នាក់ជាតិ ព្រមទាំងចូលរួមកិច្ចប្រជុំកម្រិតសកល និងរៀបចំព្រឹត្តិការណ៍ធំៗនៅកម្រិតតំបន់ចំនួន ០៣លើក។

### ២.២.២. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានដាក់ចេញ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ព្រមទាំងបង្កើតអនុគណៈកម្មការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត

- បានអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) នៅតាមគ្រឹះស្ថាន អ.ប.វ និងធ្វើការផ្ទឹង CQF ជាមួយក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF) ដោយបង្កើតគណៈកម្មការសម្របសម្រួលថ្នាក់ជាតិ (NCC) ដែលមានអនុគណៈកម្មការចំនួន ០៣ រួមមាន អនុគណៈកម្មការក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF), អនុគណៈកម្មការកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRA), និងអនុគណៈកម្មការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRS)

- បានអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពគុណវុឌ្ឍិជាតិកម្រិត ១ ២ ៣ និង ៤ សម្រាប់ ៥ វិស័យ រួមមាន សំណង់ មេកានិច ធុរកិច្ច/ព័ត៌មានវិទ្យា អគ្គិសនី និងកម្មន្តសាល សរុបចំនួន ៣៦ មុខរបរ/១០៣ គុណវុឌ្ឍិ

- បានដាក់ឱ្យអនុវត្តសាកល្បងនូវកញ្ចប់ស្តង់ដាបណ្តុះបណ្តាល CQF កម្រិត៥ ជំនាញអគ្គិសនីលើ៤មុខរបរនៅនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ និងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស

- រៀបចំគោលនយោបាយស្តីពីការវាយតម្លៃសមត្ថភាព និងការផ្តល់គុណវុឌ្ឍិក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនិង ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធវាយតម្លៃផ្អែកលើសមត្ថភាព និងការផ្តល់គុណវុឌ្ឍិសម្រាប់កម្ពុជានៅឆ្នាំ២០១៧ ដែលរួមបញ្ចូលទាំងការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន ដើម្បីជំរុញដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រការសិក្សាពេញមួយជីវិត

- បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន ០៤ រួមមាន វិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, វិស័យអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ, វិស័យមេកានិករថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា

- បានជ្រើសរើសបេក្ខជនចំនួន ៤៤ នាក់ ចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាន និងអន្តរជាតិ ដោយទទួលបានពានរង្វាន់លេខ១ ចំនួន ១ (China Skills), មេដាយសំរឹទ្ធិចំនួន ២, Medallion of Excellence ចំនួន ១, វិញ្ញាបនបត្រល្អប្រសើរចំនួន ៣, Best of the Nation ចំនួន ៣

- បានបង្កើតគណៈកម្មការអធិការកិច្ចគ្រូបច្ចេកទេសឯកទេស/ និងរៀបចំប្រកាសស្តីពីការដាក់ឱ្យអនុវត្តលក្ខណវិនិច្ឆ័យទាំង ៦ ក្នុងការធានាគុណភាពវិស័យ អ.ប.វ

- បានធ្វើការបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបច្ចេកទេសចំនួន ២២០ នាក់ លើវិក្រឹត្យការជំនាញបច្ចេកទេសចំនួន ៦៣៦ នាក់ លើវិធីសាស្ត្របង្រៀនផ្អែកលើសមត្ថភាព និង គ្រូបង្គោល (Master Trainers) ចំនួន ៣០ នាក់ លើវិធីសាស្ត្របង្រៀនផ្អែកលើសមត្ថភាពបន្ត (CBT Methodology)

- បានរៀបចំសូចនាករ និងបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ (TVETMIS) ដែលស្ថិតនៅក្នុងដំណាក់កាលប្រើប្រាស់សាកល្បង ហើយគ្រោងនឹងដាក់ឱ្យដំណើរការក្នុង ឆ្នាំ២០១៩ នេះ

- បានកំណត់យកថ្ងៃទី១៥ ខែមិថុនា ជាថ្ងៃប្រារព្ធទិវាជាតិ អ.ប.វ (TVET-DAY) ជារៀងរាល់ឆ្នាំ ព្រមទាំងតម្រង់ទិសវិជ្ជាជីវៈ អ.ប.វ ដល់សិស្សានុសិស្ស និងសាធារណជនចំនួន ១៧៨ ០២៤នាក់ ដែលបានចូលរួមវេទិកាជាតិ អ.ប.វ និងវេទិកាជាតិផ្សេងៗទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

- បានបណ្តុះបណ្តាលសិក្ខាកាម សិស្ស និស្សិតចំនួន ១៩២ ៩៧១នាក់ ដែលក្នុងនោះកម្រិតក្រោយឧត្តមចំនួន ៩៩នាក់ កម្រិតឧត្តមចំនួន ២០ ៦៦៦នាក់, កម្រិតបច្ចេកទេសជាន់ខ្ពស់/បរិញ្ញាបត្ររងចំនួន ១២ ៨២៦នាក់, កម្រិតសញ្ញាបត្ររយៈពេលវែងចំនួន ៧ ៤៩២នាក់, និងកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈចំនួន ១៥១ ៨៨៨នាក់ ហើយបើធៀបនឹងអាណត្តិទី៤ ចំនួនសិស្សនិស្សិតសរុបនេះ បានកើនឡើងប្រមាណជា ២,៣ដង ដែលនេះបានបង្ហាញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកវិសាលភាព អ.ប.វ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស

- បានបង្កើតគ្រឹះស្ថាន អ.ប.វ ថ្មីបន្ថែមចំនួន២ គឺ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ (២០១៨) និងវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាព កម្ពុជា-ចិន ខេត្តព្រះសីហនុ (២០១៧), ប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ១៣ ទៅជាវិទ្យាស្ថាន ដែលអាចធ្វើការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បរិញ្ញាបត្របច្ចេកវិទ្យា/សញ្ញាបត្រវិស្វករ, ដំឡើងកម្រិតបណ្តុះបណ្តាលមជ្ឈមណ្ឌល/សាលាចំនួន ១៥ ដែលអាចបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បរិញ្ញាបត្ររងបច្ចេកវិទ្យា។ បើគិតត្រឹមឆ្នាំ២០១៨ គ្រឹះស្ថាន អ.ប.វ មានចំនួន ១០៦ ដែលក្នុងនោះគ្រឹះស្ថានសាធារណៈចំនួន ៣៩ (ទទួលបានវិញ្ញាបនបត្រ ISO ៩០០១-២០១៥ ចំនួន ២០), គ្រឹះស្ថានឯកជនចំនួន ៤១, និងគ្រឹះស្ថានជាអង្គការ/សមាគមចំនួន ២៦

- បានសាងសង់អគារសិក្សាបន្ថែមចំនួន ០៩, អគាររោងជាងចំនួន ១៤, អគារអន្តេវាសិកដ្ឋានចំនួន ១០, ជួសជុលអគារចំនួន ២៤, ព្រមទាំងបានបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Centers of Excellence) ចំនួន ០៤ គឺស្ថិតនៅផ្នែកកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា, ផ្នែកអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ, ផ្នែករថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងផ្នែកសំណង់នៅវិទ្យាស្ថានពហុបច្ចេកទេសអង្គរ

- បានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងនៅតាម សហគ្រាស គ្រឹះស្ថានបានចំនួន ២ ០០៨ ស្មើនឹង ៩៨ ២១៨ នាក់ ដែលបានកើនឡើងប្រមាណជា ៣៦ដង, ធៀបនឹងអាណត្តិទី៤

- តាមរយៈគណៈវិស្វករកម្ពុជា បានជ្រើសរើស និងវាយតម្លៃវិស្វករឱ្យ ទទួលបានគោរមងារជាវិស្វករដំបូងចំនួន ១ ៥៦១ នាក់ ,(ស្រី ៤៧ នាក់)វិស្វករវ័យក្មេងអាស៊ានចំនួន ១១២ នាក់ (ស្រី ០៣ នាក់), វិស្វករអាស៊ានចំនួន ១៤០ នាក់ (ស្រី ០២នាក់), វិស្វករកិត្តិយសអាស៊ានចំនួន ៥៦ នាក់ (ស្រី ០២នាក់), វិស្វករកិត្តិយសជាន់ខ្ពស់អាស៊ានចំនួន ២៥ នាក់ (ស្រី ០១នាក់), Distinguished Honorary Fellow ចំនួន ០៤ នាក់ និងវិស្វករអាជីពឆ្នើមអាស៊ានចំនួន ៦៧ នាក់ក្រោមក្របខ័ណ្ឌ MRA។

**២.២.៣. ការអភិវឌ្ឍមុខរបរ និងការងារ**

- ក្រសួងបានដាក់ចេញនូវ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ដែលត្រូវបានរៀបចំឡើងឱ្យស៊ីចង្វាក់គ្នាទៅនឹង**គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥** ដែលជាលទ្ធផលនៃការអនុវត្តគោលនយោបាយនេះ ចំនួនអ្នកមានការងារធ្វើសរុប (អាយុ១៥ឆ្នាំ+) បានកើនឡើងពី ៨,៦លាននាក់នៅក្នុងឆ្នាំ ២០១៥ ទៅ ៩,៦លាននាក់នៅក្នុងឆ្នាំ ២០១៨ ពោលគឺកើនឡើងប្រមាណជា ២,៥% ជាមធ្យមក្នុងមួយឆ្នាំ។ ជាមួយនឹងកំណើនការងារវិជ្ជមាននេះ អនុបាតអ្នកមានការងារធ្វើទៅនឹងប្រជាជន (អាយុ១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការផ្តល់ការងារដល់ប្រជាជន ដែលស្ថិតនៅក្នុងវ័យធ្វើការរក្សាបាននូវអត្រាថេរក្នុងរង្វង់ប្រមាណជា ៨១% និងអត្រានិកម្មភាព(អាយុ១៥ឆ្នាំ+) ស្ថិតនៅក្នុងអត្រាទាបជាង ១% ក្នុងរយៈពេលដូចគ្នានេះ។ ទន្ទឹមនឹងនេះ គុណភាពនៃការងារក៏ត្រូវបានកែលម្អដែលបង្ហាញតាមរយៈការកើនឡើងនៃបរិមាណភាគនិយោជិតទទួលប្រាក់ឈ្នួលបានកើនពី ៤៧,៥% នៅក្នុងឆ្នាំ ២០១៥ ទៅប្រមាណជា ៤៨,៨% នៅក្នុងឆ្នាំ២០១៨

- បានពង្រីកវិសាលភាពសេវាមុខរបរ និងការងារដោយបង្កើតមជ្ឈមណ្ឌលការងារបន្ថែមចំនួន ៨ លើមជ្ឈមណ្ឌលការងារដែលមានស្រាប់ចំនួន ៥ និងមជ្ឈមណ្ឌលការងារចល័តចំនួន ១ ព្រមទាំងផ្តល់សេវាប្រឹក្សាយោបល់មុខរបរ និងការងារ និងមគ្គទេសក៍អាជីពចំនួន ៩ ៩០៨នាក់, រៀបចំវគ្គបណ្តុះបណ្តាលត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារចំនួន ២៣១ វគ្គ, រៀបចំសិក្ខាសាលាណែនាំអាជីព ការងារ និងវិជ្ជាជីវៈ តាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាកលវិទ្យាល័យចំនួន ១ ០០១ ដង ព្រមទាំងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីចំនួន ៩២ នាក់ និងរៀបចំចងក្រងឯកសារមគ្គទេសក៍ និងការប្រឹក្សាអាជីពការងារ និងវិជ្ជាជីវៈ ចំនួន ៨ ឯកសារ

- បានអភិវឌ្ឍ និងជំរុញការប្រើប្រាស់គេហទំព័រការងារសម្រាប់ផ្តល់សេវាចុះឈ្មោះអ្នកស្វែងរកការងារ និងជ្រើសរើសកម្លាំងពលកម្មដែលចំនួនចូលប្រើប្រាស់គេហទំព័របានកើនឡើងដល់ប្រមាណជា ១៧ ៨០២ ២៣៤ លើក ព្រមទាំងបង្កើតកម្មវិធីសម្រាប់រកការងារតាមស្មាតហ្វូន (NEA Job Search) ដែលមានអ្នកទាញយកមកប្រើប្រាស់សរុបចំនួន៨ ៩២៣ នាក់

- បានផ្សព្វផ្សាយពីសេវា MRC និងចុះឈ្មោះពលករចំណាកស្រុកមកពីប្រទេសថៃដែលមានបំណងចង់ស្វែងរកការងារចំនួន ២លើក ស្មើនឹង ២០ ១៨៦ នាក់

- បានពង្រឹង និងពង្រីកយន្តការ “**វេទិកាការងារ**” ដោយរៀបចំពិព័រណ៍ការងារថ្នាក់ជាតិចំនួន ៥ ដង, យុទ្ធនាការផលិតភាពជាតិចំនួន ២ ដង, ពិព័រណ៍ការងារថ្នាក់ខេត្តចំនួន ២ដង, វេទិកាផ្សព្វផ្សាយ និងចុះឈ្មោះអ្នកស្វែងរកការងារចំនួន ២៤៦ ដង, សិក្ខាសាលាជាមួយនិយោជក និងសហជីពចំនួន ៤១ ដង, ទិវាជ្រើសរើសកម្លាំងពលកម្មចំនួន ២៩៥ ដង, កិច្ចសម្ភាសន៍ការងារប្រចាំខែចំនួន ២៨ និងចូលរួមពិព័រណ៍ផ្សេងៗចំនួន ៥៣៣ ដង

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៣៥៧ ០៥១ នាក់ ព្រមទាំងផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រការងារចំនួន ៦០ លេខ និងកម្មវិធីនាទីទីផ្សារការងារ និងមុខរបរ ចំនួន២៥៤ វគ្គ

- បានធ្វើការអង្កេត ចងក្រង វិភាគ និងបោះពុម្ពផ្សាយរបាយការណ៍ស្តីពីតម្រូវការជំនាញរបស់និយោជក ក្នុងឆ្នាំ២០១៤ ២០១៥ និងឆ្នាំ២០១៧, ជំនាញសម្រាប់ពាណិជ្ជកម្ម និងពិពិធកម្មសេដ្ឋកិច្ចក្នុងវិស័យឧស្សាហកម្ម ធុនស្រាល និងកែច្នៃចំណីអាហារឆ្នាំ២០១៦, ទស្សនវិស័យការងារកម្ពុជាឆ្នាំ២០១៨, ស្ថានភាពសិស្ស និស្សិត ក្រោយបញ្ចប់ការសិក្សាឆ្នាំ២០១៦ និងឆ្នាំ២០១៨ និង Labour Market Update

- បានចុះបញ្ជីសហគ្រាស គ្រឹះស្ថានចំនួន ១២ ៧៩៦ ព្រមទាំងផ្តល់សៀវភៅការងារចំនួន ១ ១១៧ ២៥០ ក្បាល, ចុះទិដ្ឋាការចូលចំនួន ១៥៦ ៤៧៩ ទិដ្ឋាការ, ចុះទិដ្ឋាការចេញចំនួន ៣១ ៨០៣ ទិដ្ឋាការ និងប្រមូល អាករចូលរដ្ឋសរុបចំនួន ១១ ១៧២,៥ លានរៀល

- បានផ្តល់សេវារកការងារនៅក្រៅប្រទេស ជូនប្រជាពលរដ្ឋចំនួន ១,២ លាននាក់ ដែលក្នុងនោះនៅ ប្រទេសថៃចំនួន ១ ១៤៦ ៦៨៥ នាក់, ម៉ាឡេស៊ីចំនួន ៣០ ១១៣ នាក់, អារ៉ាប់ប៊ីសាអូឌីតចំនួន ១៦ នាក់, ជប៉ុន ចំនួន ៧ ៣១៣ នាក់, សិង្ហបុរីចំនួន ៨៣១ នាក់, តំបន់រដ្ឋបាលពិសេសហុងកុងចំនួន ៥៤ នាក់, និងសាធារណ រដ្ឋកូរ៉េចំនួន ៤៩ ០៩៩ នាក់

- បានធ្វើយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដោយគិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ចំនួន ៤២៦ ៨៤១ នាក់ ព្រមទាំងដោះស្រាយវិវាទផ្នែកទេសន្តរ ប្រវេសន៍ចំនួន ២៩៦ ករណី

- បានរៀបចំ និងអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៥ និង២០១៨ ដែលផ្តោតសំខាន់លើអភិបាលកិច្ចនៃទេសន្តរប្រវេសន៍ការការពារ ,និងការលើកកម្ពស់សិទ្ធិរបស់ ពលករទេសន្តរប្រវេសន៍, និងការរៀបចំទេសន្តរប្រវេសន៍ការងារដើម្បីអភិវឌ្ឍន៍

- បានធ្វើអធិការកិច្ចហត្ថពលកម្មជនបរទេសចំនួន ១២ ៩៦០ សហគ្រាស គ្រឹះស្ថាន និងពិនិត្យឃើញមាន ជនបរទេសចំនួន ៩៧ ៩៧៥ នាក់ ក្នុងនោះ ៩២,៧% មានប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ព្រម ទាំងចេញសៀវភៅការងារជនបរទេសថ្មី និងចុះទិដ្ឋាការចូលដល់ជនបរទេសចំនួន ១៩៩ ៣៩៣ នាក់ ពន្យារ សុពលភាពលើប័ណ្ណ និងសៀវភៅការងារជនបរទេសចំនួន ៨៤ ៧៣១ នាក់ និងប្រមូលអាករជនបរទេសបាន ថវិកាចំនួន ១៣៨ ៩៦៩ លានរៀល ។

### ២.២.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- បានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនៅចុង ឆ្នាំ២០០៨ ដោយនិយោជកទទួលបន្ទុកបង់ភាគទានចំនួន ០,៨% នៃប្រាក់បៀវត្សរបស់កម្មករនិយោជិត។ ជាមួយគ្នានេះ ក្រសួងបានចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ផ្នែកហានិភ័យការងារ ចំនួន ១២ ៨២៨ សហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចំនួន ១ ៤៩២ ១៤៤ នាក់ ក្នុងនោះការចុះបញ្ជីសហគ្រាស គ្រឹះស្ថានថ្មីបន្ថែមមានចំនួន ៦ ៧២១ ដែលមានកម្មករនិយោជិតចំនួន ៦៤៤ ៩៦៩ នាក់ ព្រមទាំងផ្តល់តាវកាលិកចំនួន ៨៣ ៤២៦ នាក់ គិតជាថវិកាអស់ចំនួន ៧៥,២ ប៊ីលានរៀល។ ជារួម ការកើនឡើងនៃចំនួនសហគ្រាស គ្រឹះស្ថាន ថ្មីនេះ បានបង្ហាញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការធានារ៉ាប់រងផ្នែកនេះ ដើម្បីកាត់បន្ថយហានិភ័យ និងការព្រួយបារម្ភរបស់បងប្អូនកម្មករនិយោជិតក៏ដូចជាអ្នកនៅក្នុងបន្ទុក ដោយសារគ្រោះថ្នាក់ចៃដន្យណាមួយ ដោយគិតចាប់តាំងពីពេលបងប្អូនកម្មករនិយោជិតធ្វើដំណើរចេញពីផ្ទះ សំដៅឆ្ពោះទៅកន្លែងការងារ ពេលកំពុងធ្វើការងារ និងពេលចប់ការងារធ្វើដំណើរសំដៅឆ្ពោះទៅផ្ទះវិញ

- បានដាក់អនុវត្តការធានារ៉ាប់រងផ្នែកសុខភាពនៅចុងឆ្នាំ២០១៦ ដោយភាគទានចំនួន ១,៣%នៃប្រាក់បៀវត្សត្រូវបង់ដោយនិយោជក និង១,៣% នៃប្រាក់បៀវត្សត្រូវបង់ដោយកម្មករនិយោជិត ប៉ុន្តែដើម្បីលើកស្ទួយកម្ពស់ជីវភាពរស់នៅរបស់បងប្អូនកម្មករនិយោជិត ឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលបានកំណត់ចាប់ពីខែមករា ឆ្នាំ២០១៨ ឱ្យនិយោជកទទួលបន្ទុកបង់ភាគទាននេះជំនួសកម្មករនិយោជិត ១០០%។ ជាលទ្ធផល បានចុះបញ្ជីសហគ្រាស គ្រឹះស្ថានបានចំនួន ៨ ៧៧០ ដែលមានកម្មករនិយោជិត ១,៦លាន នាក់ និងចំណាយថវិកាអស់ ១៧១ ៥២២លានរៀល ដែលនេះបានបង្ហាញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការធានារ៉ាប់រងសុខភាពនេះដល់បងប្អូនកម្មករនិយោជិត ឱ្យបានលឿនដើម្បីជួយសម្រាលបន្ទុកចំណាយលើសុខភាព

- បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលទូទាំង២៥ រាជធានី-ខេត្តចំនួន ១ ៣៣៥ (ក្នុងនោះមន្ទីរពេទ្យថ្នាក់ជាតិចំនួន ៥, មន្ទីរពេទ្យបង្អែកចំនួន ១០៩, មណ្ឌលសុខភាពចំនួន ១ ១៧៨ និងមន្ទីរពេទ្យឯកជនចំនួន ៤៣) ដើម្បីបង្កិតសេវាឱ្យកៀកដល់សមាជិក ប.ស.ស

- បានកំណត់ប្រាក់ឧបត្ថម្ភចំនួន ១២០% រយៈពេល៣ខែ ក្នុងពេលសម្រាកលំហែមាតុភាព (ចំនួន៥០% ផ្តល់ដោយនិយោជកតាមច្បាប់ស្តីពីការងារ និងចំនួន ៧០% ផ្តល់ដោយ ប.ស.ស) ហើយកម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទាំងក្នុង និងក្រៅប្រព័ន្ធ ទទួលបានគោលរបបឧបត្ថម្ភពីរាជរដ្ឋាភិបាល នៅពេលសម្រាលកូន ដោយកូនម្នាក់ទទួលបាន ៤០ម៉ឺនរៀល សម្រាលបានកូនភ្លោះពីរនាក់ទទួលបាន ៨០ម៉ឺនរៀល និងសម្រាលបានកូនភ្លោះបីនាក់ទទួលបាន ១លាន២០ ម៉ឺនរៀល។ ជាលទ្ធផល ក្នុងឆ្នាំ២០១៨ បានផ្តល់នូវ

គោលរបបឧបត្ថម្ភជូនដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធពេលសម្រាលកូនចំនួន ៦៥ ៤៨៤នាក់ កូនមានចំនួន ៦៥ ៩៦៥នាក់ ហើយចំណាយទឹកប្រាក់សរុបចំនួន ៦លាន ៦សែនដុល្លារសហរដ្ឋអាមេរិក

- បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនចំនួន ៣៦ ក្រសួង/ស្ថាប័ន ដែលមានសមាជិកសរុប ៣១២ ៣០៦នាក់ (ស្រី ៩៧ ៧០៤នាក់) ហើយជាលទ្ធផលបានទៅទទួលសេវាចំនួន ២៥ ៨៥១ ដង ដែលបានចំណាយថវិកាអស់ចំនួន ២,៥ ប៊ីលានរៀល

- ចំពោះមន្ត្រីរាជការស៊ីវិលជាស្ត្រីក៏ទទួលបានប្រាក់ខែចំនួន ១០០% រយៈពេល៣ខែ ក្នុងរយៈពេលសម្រាកលំហែមាតុភាព ព្រមទាំងទទួលបានគោលរបបឧបត្ថម្ភពេលសម្រាលកូនដែលសម្រាលបានកូនម្នាក់ទទួលបាន ៨០ម៉ឺនរៀល ហើយប្រាក់ឧបត្ថម្ភនេះនឹងកើនឡើងសមាមាត្រទៅនឹងចំនួនកូនសម្រាលបាន

- បានកំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធននិវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ។

### ២.២.៥. ការពង្រឹងអភិបាលកិច្ចល្អ

- បានចូលរួមអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋយ៉ាងយកចិត្តទុកដាក់លើកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ដោយផ្អែកលើទស្សនទាន “ការផ្សាភ្ជាប់ថវិកា ទៅនឹងគោលបំណងគោលនយោបាយ” ព្រមទាំងរៀបចំអនុវត្តថវិកាកម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

- បានពង្រឹងការគ្រប់គ្រងការអនុវត្តថវិកាកាន់តែមានប្រសិទ្ធភាព ហ្មត់ចត់ និងម៉ឺងម៉ាត់ តាមរយៈការគ្រប់គ្រងការអនុវត្តចំណាយដែលអនុលោមទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយបានអនុវត្តចំណាយក្នុងកម្រិតលំអៀង -៥% នៃផែនការថវិកាជាតិ ព្រមទាំងចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ ដោយរៀបចំអង្គភាពថវិកាចំនួន ៧ អង្គភាព (កម្រិតទី២) នៅរដ្ឋបាលកណ្តាល និង ២៥ អង្គភាពនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត

- បានអនុវត្តតាមផែនការសកម្មភាពកំណែទម្រង់ហិរញ្ញវត្ថុជំហានទី៣ របស់ខ្លួន (MAP3) ប្រចាំត្រីមាស និង អនុវត្តសម្រេចបានតាមគោលដៅសូចនាករ ដោយទទួលបានចំណាត់ថ្នាក់ខ្ពស់ពីការវាយតម្លៃរបស់គណៈកម្មការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៅឆ្នាំ២០១៧ ស្ម័គ្រចិត្តចូលរួមអនុវត្តសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

- បានខិតខំបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈ ដោយពង្រឹងយន្តការគ្រប់គ្រងការផ្តល់សេវា, ការចរាចរលិខិតឯកសារ, ការរៀបចំការិយាល័យច្រកចេញចូលតែមួយ, និងការសម្រួលការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលាជាទៀងទាត់ តាមប្រព័ន្ធធនាគារ

- បានបង្កើនចំនួនមន្ត្រីប្រមាណជា ២៦,៦% ទាំងមន្ត្រីរាជការក្របខ័ណ្ឌបច្ចេកទេស និងក្របខ័ណ្ឌរដ្ឋបាល ព្រមទាំងអភិវឌ្ឍ និងបំប៉នសមត្ថភាពមន្ត្រីរាជការស៊ីវិលបន្ថែមទាំងថ្នាក់ជាតិ និងក្រោមជាតិ តាមរយៈការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស

- បានពង្រឹងការងារចុះអធិការកិច្ច និងសវនកម្មក្នុងការតាមដានលើគ្រប់បណ្តាអង្គភាពក្រោមឱវាទក្រសួង ក្នុងការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨ និងលិខិតបទដ្ឋាននានាព្រមទាំងត្រួតពិនិត្យលើការអនុវត្តចំណូល-ចំណាយថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងដោះស្រាយវិវាទរដ្ឋបាល

- បានដាក់ចេញនូវ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ព្រមទាំងពង្រឹងសមត្ថភាពជនបង្គោលយេនឌ័រគ្រប់អង្គភាពក្រោមឱវាទក្រសួងចំនួន ៦២៥ នាក់ ហើយបានបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងថ្នាក់ដឹកនាំនិងជាមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងក្រោមជាតិដោយបរិមាណភាគនៃមន្ត្រីរាជការនិងថ្នាក់ដឹកនាំជាស្ត្រីបានកើនឡើងពី ១៨,៦% នៅឆ្នាំ២០១៤ ដល់ ២២,៩% នៅឆ្នាំ២០១៨

- បានបង្កើតគណៈកម្មការជាតិ និងលេខាធិការដ្ឋាននៃគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារដែលកម្ពុជាបានផ្តល់សច្ចាប័ន ព្រមទាំងបង្កើតក្រុមការងារអន្តរជាតិ និងលេខាធិការដ្ឋានក្រុមការងារអន្តរជាតិដើម្បីជួយសម្របសម្រួល ប្រមូល និងផ្តល់ធាតុចូល សម្រាប់ធ្វើរបាយការណ៍ឆ្លើយតបជូនអង្គការអន្តរជាតិខាងការងារ (ILO) ឱ្យបានទាន់តាមកាលកំណត់

- បានអនុម័តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការ ILO ពាក់ព័ន្ធនឹងសេរីភាពសមាគម និងផ្សព្វផ្សាយដល់គ្រប់សមាជិកនៃគណៈកម្មការជាតិនេះ ដោយស្ថិតនៅក្រោមកិច្ចសហការត្រីភាគី និងជំនួយបច្ចេកទេសពីអង្គការ ILO ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ

- បានបង្កើនវត្តមាននៅលើឆាកអន្តរជាតិតាមរយៈការចូលរួមកិច្ចប្រជុំសំខាន់ៗក្នុងតំបន់អាស៊ាន និងអឺរ៉ុប ព្រមទាំងចូលរួមអនុម័តលើឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និង លើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ សេចក្តីថ្លែងការណ៍វៀងចន្ទន៍ ស្តីពីការផ្លាស់ប្តូរការងារក្រៅប្រព័ន្ធទៅជាការងារក្នុងប្រព័ន្ធ ដើម្បីឆ្ពោះទៅរកការងារសមរម្យក្នុងក្របខ័ណ្ឌអាស៊ាន និងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការងារបៃតងដើម្បីសមធម៌ និងការរីកចម្រើនរួមរបស់អាស៊ាន

- បានបន្តចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយអង្គការ ស្ថាប័នជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក ព្រមទាំងសហការជាមួយអ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជាក្នុងការបង្កើត គណៈប្រឹក្សាភិបាលនៃកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិ "រួមគ្នាដើម្បីមុខរបរ និងការងាររបស់យុវជននៅកម្ពុជា" (Steering Committee of United Nation Joint Programme "United for Youth Employment in Cambodia") ដើម្បីលើកកម្ពស់ចំណេះដឹង និងជំនាញរបស់យុវជនកម្ពុជា។

## ២.៣- បញ្ហាប្រឈម

ជាមួយការខិតខំអនុវត្ត **ផ.យ.អ.ភ.ប ២០១៤-២០១៨** ដោយទទួលបានលទ្ធផលធំៗគួរជាទីមោទកៈ ក្រសួងក៏នៅជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ និងដោះស្រាយ រួមមាន÷

### ២.៣.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៅមានការខ្វះខាត ហើយមួយចំនួនទៀតទាមទារឱ្យធ្វើវិសោធនកម្ម ឬ កែសម្រួលដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ ស្របតាមបទដ្ឋានអន្តរជាតិ និងការវិវឌ្ឍនៃស្ថានភាព សេដ្ឋកិច្ច-សង្គម ជាពិសេសនៅវិស័យសំណង់ ឡឥដ្ឋ និងសេវាកម្សាន្ត

- ការធ្វើផែនការអធិការកិច្ចការងារ ដោយផ្អែកទៅលើការវាយតម្លៃ និងការកំណត់គោលដៅលើសហគ្រាស គ្រឹះស្ថានដែលងាយប្រឈមទៅនឹងការបំពានលក្ខខណ្ឌការងារ និងច្បាប់ មិនទាន់បានអនុវត្ត ដែលកត្តានេះទាមទារ ឱ្យមានការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យា ការកំណត់នីតិវិធីនៃការអនុវត្តការងារអធិការកិច្ច ការងារ និងការពង្រឹងសមត្ថភាពមន្ត្រីក្នុងការធ្វើផែនការអធិការកិច្ច

- ការធ្វើចំណាត់ថ្នាក់កម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាន ដែលជាកត្តាសំខាន់ក្នុងគ្រប់គ្រងអត្រា ហានិភ័យ និងជំរុញប្រសិទ្ធភាព និងគុណភាពរបស់អធិការកិច្ចនៅមិនទាន់បានអនុវត្ត

- ការយល់ដឹងរបស់ រដ្ឋបាលផ្សះផ្សាវិវាទការងារ កម្មករនិយោជិត និយោជក សហជីព អំពីច្បាប់ស្តីពីការងារ សុវត្ថិភាព និងសុខភាពការងារ ការប្រើប្រាស់កម្លាំងពលកម្មកុមារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានានៅ មានកម្រិតដែលនេះទាមទារឱ្យមានការបង្កើនការផ្សព្វផ្សាយ បើកវគ្គបណ្តុះបណ្តាល ព្រមទាំងពង្រឹងការអនុវត្ត ច្បាប់ចំពោះសហគ្រាស គ្រឹះស្ថាន ឬ បុគ្គលដែលមិនគោរពច្បាប់

- យន្តការទប់ស្កាត់បញ្ហាកូដកម្ម បាតុកម្ម និងដោះស្រាយវិវាទការងារនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់ ដែលទាមទារឱ្យមាន ការកែសម្រួលបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយនឹងនីតិវិធីដោះស្រាយវិវាទការងារ ការរៀបចំ សេចក្តីណែនាំអំពីខ្លឹមសារពាក់ព័ន្ធនឹងច្បាប់ និងនីតិវិធីក្នុងការដោះស្រាយកូដកម្មនិងបាតុកម្ម ការពង្រឹងការ អនុវត្តច្បាប់ស្តីពីសហជីព ការពង្រីកសេវាគាំទ្រ និងប្រឹក្សាយោបល់ផ្នែកច្បាប់ ព្រមទាំងការបង្កើនសមត្ថភាព មន្ត្រីក្នុងការដោះស្រាយវិវាទការងារ កូដកម្ម និងបាតុកម្ម

- វិសាលភាពនៃសេវារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ មិនទាន់ឆ្លើយតបទៅនឹងទំហំតម្រូវការ ហើយការគ្របដណ្តប់មានតែនៅក្នុងរាជធានីភ្នំពេញ ដែលនេះគឺទាមទារ ឱ្យក្រសួង ត្រូវបន្តយកចិត្តទុកដាក់ក្នុងការពង្រឹងក្រុមប្រឹក្សាអាជ្ញាកណ្តាល ពង្រីកសាខាក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅតាមបណ្តាខេត្តផ្សេងៗ ព្រមទាំងបង្កើតក្រុមចល័ត

- កង្វះវិធានការគ្រប់គ្រងសហគ្រាស គ្រឹះស្ថាន នៅពេលបិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូរថៅកែ ថ្មីឬប្តូរស្លាកយីហោថ្មី ដែលនេះទាមទារឱ្យមានកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការទទួលបានព័ ត៌មាន ការផ្តល់ឯកសារ និងភស្តុតាងឱ្យទាន់ពេលវេលា ដើម្បីចាត់វិធានការតាមច្បាប់

- ឧបករណ៍ សម្ភារ និងបរិក្ខារសម្រាប់ធ្វើអធិការកិច្ចការងារនៅមានកម្រិត ធៀបជាមួយនឹងចំនួនទំហំ ដែលកើនឡើងជាលំដាប់ដែលនេះទាមទារការរៀបចំផែនការដោយផ្សារភ្ជាប់ជាមួយនឹងតម្រូវការធនធាន ដោយផ្អែកទៅលើការធ្វើអាទិភាពនៃផែនការសកម្មភាព

- សមត្ថភាពរបស់មន្ត្រីអធិការកិច្ចការងារ និងមន្ត្រីដោះស្រាយវិវាទការងារនៅមានកម្រិត ជាពិសេសទាក់ទងនឹងផ្នែកសុវត្ថិភាព និងសុខភាពការងារ ការប្រើប្រាស់កម្លាំងពលកម្មកុមារ ច្បាប់ស្តីពីការងារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងនីតិវិធីនៃអធិការកិច្ចការងារ ដែលនេះទាមទារឱ្យមានការរៀបចំមានវគ្គវិក្រឹត្យការពង្រឹងសមត្ថភាព ការប្រឡងតេស្តសមត្ថភាព ព្រមទាំងរៀបចំយន្តការតាមដានការអនុវត្តការងាររបស់ក្រុមអធិការកិច្ចការងារ

- ពុំទាន់មានការសិក្សាស្រាវជ្រាវរៀបចំបញ្ជីជំងឺវិជ្ជាជីវៈ ដែលនេះទាមទារឱ្យមានការយកចិត្តទុកដាក់ក្នុងការជ្រើសរើសបន្ថែមនូវមន្ត្រីជំនាញ អ្នកបច្ចេកទេស និងគ្រូពេទ្យឯកទេស ព្រមទាំងបំពាក់សម្ភារ បរិក្ខារវេជ្ជសាស្ត្រ និងមន្ទីរពិសោធន៍សារធាតុពុល និងរូបសាស្ត្រដែលបម្រើដល់ការស្រាវជ្រាវ

- លិខិតបទដ្ឋានគតិយុត្តគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា មិនទាន់បានគ្រប់ជ្រុងជ្រោយស្របតាមស្ថានភាពនៃការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គម ហើយប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នមានវិសាលភាពត្រឹមតែវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលនេះទាមទារឱ្យមានសិក្សាពីលទ្ធភាពបន្ថែមក្នុងការពង្រីកវិសាលភាព តាមដានវាយតម្លៃបម្រែបម្រួលប្រាក់ឈ្នួល ព្រមទាំងរៀបចំគោលនយោបាយប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ។

**២.៣.២. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- ការផ្តល់តម្លៃទៅលើបច្ចេកវិទ្យា ឬវិទ្យាសាស្ត្រសម្រាប់ការអនុវត្ត នៅមិនទាន់ផុសផុលនៅឡើយ ដែលប្រការនេះជាបញ្ហាសម្រាប់ជំរុញទឹកចិត្តយុវជនឱ្យមានក្តីស្រមៃ និងមានមោទនភាព ក្នុងការចាប់យកបច្ចេកទេស ឬវិទ្យាសាស្ត្រក្នុងការសិក្សា ដែលនេះទាមទារការពង្រឹង និងបង្កើនការផ្សព្វផ្សាយ ជាពិសេស ការបន្តរៀបចំទិវា អ.ប.វ និងកម្មវិធីតម្រង់ទិសវិជ្ជាជីវៈ

- កម្មវិធី និងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ដែលនេះត្រូវការការយកចិត្តទុកដាក់បន្ថែម ក្នុងការរៀបចំបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគុណវុឌ្ឍគ្រូបច្ចេកទេស ស្តង់ដាសមត្ថភាពគ្រូបច្ចេកទេស ការធ្វើវិក្រឹត្យការគ្រូ ព្រមទាំងការពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជំរុញការស្រាវជ្រាវនិងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍

- ការទទួលស្គាល់សមត្ថភាពជំនាញស្របតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា (CQF) តាមវិស័យនីមួយៗ នៅមានចំនួនតិចតួច ដែលទាមទារឱ្យមានការកំណត់បន្ថែមនូវវិសាលភាពនៃវិស័យ និងអាទិភាពប្រភេទមុខជំនាញ ព្រមទាំងបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ហើយធ្វើការផ្ទឹងផ្ទងបន្ស៊ីគ្នារវាង CQF និងក្របខ័ណ្ឌគុណវុឌ្ឍយោងអាស៊ាន (AQRF)

- កង្វះខាតការលើកទឹកចិត្តទាំងធនធានហិរញ្ញវត្ថុ និងសម្ភារ ដល់សិក្ខាកាម សិស្ស-និស្សិត ជាពិសេសជនងាយរងគ្រោះ ដែលនេះទាមទារឱ្យមានជាយន្តការក្នុងការផ្តល់ឥណទានដល់សិក្ខាកាម ជាពិសេសស្ត្រី ជនជាតិដើមភាគតិច និងជនចំណាកស្រុក ក្នុងការបង្កើតមុខរបរបន្ទាប់ពីបញ្ចប់ការសិក្សា

- ឧបករណ៍បរិក្ខារបច្ចេកទេស រោងជាង និងបន្ទប់ពិសោធន៍ នៅមានកម្រិត និងមិនទាន់សមស្របតាមតម្រូវការជាក់ស្តែងក្នុងការបណ្តុះបណ្តាល ដែលទាមទារឱ្យមានការវិនិយោគសាងសង់បន្ថែមហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់ឧបករណ៍ បរិក្ខារ សម្ភារបណ្តុះបណ្តាលទៅតាមជំនាញអាទិភាព

- កត្តាបោះបង់ការសិក្សាមុនបញ្ចប់ថ្នាក់ទី ៩ នៅមានចំនួនច្រើន ដែលទាមទារឱ្យពង្រឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងការបណ្តុះបណ្តាលជំនាញបន្ថែមដល់អ្នកដែលស្ថិតនៅក្នុងទីផ្សារការងារ

- ការចូលរួមពីវិស័យឯកជន ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យ អ.ប.វ នៅមានកម្រិត ដែលទាមទារឱ្យពង្រឹងកិច្ចសហការរវាងគ្រឹះស្ថាន អ.ប.វ ទៅនឹងវិស័យឯកជន ការបង្កើតមជ្ឈមណ្ឌល អ.ប.វ នៅតាមតំបន់សេដ្ឋកិច្ចពិសេស ការអនុវត្តមូលនិធិជាតិសម្រាប់អភិវឌ្ឍជំនាញ និងការបង្កើនសិស្សចុះកម្មសិក្សានៅតាមសហគ្រាស គ្រឹះស្ថាន

- ប្រព័ន្ធព័ត៌មានទីផ្សារការងារ ដែលជាប្រភពទិន្នន័យយ៉ាងសំខាន់ក្នុងការតាមដាន វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ មិនទាន់បានដំណើរការពេញលេញ ដែលតម្រូវឱ្យមានការបន្តពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកបញ្ចូលទិន្នន័យ នៅតាមគ្រឹះស្ថាន រៀបចំឱ្យមានមន្ត្រីទទួលបន្ទុកណែនាំអំពីការប្រើប្រាស់ និងរៀបចំការដាក់ទណ្ឌកម្មសម្រាប់គ្រឹះស្ថានណាដែលមិនអនុវត្ត។

### ២.៣.៣. ការអភិវឌ្ឍមុខរបរ និងការងារ

- ការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ទាំងថ្នាក់ជាតិ និងក្រោមជាតិ មិនទាន់បានទូលំទូលាយ ដោយមិនទាន់មានផែនការសកម្មភាពក្នុងការអនុវត្តគោលនយោបាយ ដែលទាមទារឱ្យពង្រឹងលេខាធិការដ្ឋាន និងសមត្ថភាពសមាជិកអនុគណៈកម្មការអន្តរក្រសួងដើម្បីដឹកនាំរៀបចំ អនុវត្ត និងតាមដាន

- វិសាលភាពគ្របដណ្តប់ និងប្រព័ន្ធគ្រប់គ្រងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ មិនទាន់ទូលំទូលាយដែលទាមទារឱ្យពង្រីកមជ្ឈមណ្ឌលការងារបន្ថែម ការពង្រឹងយន្តការវេទិកាការងារ ការពង្រឹងសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវា ការជ្រើសរើសមន្ត្រីបន្ថែមតាមតម្រូវការជំនាញអាទិភាព ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្តល់ និងពង្រឹងគុណភាពសេវា

- ប្រព័ន្ធព័ត៌មានទីផ្សារការងារមិនទាន់មានការអភិវឌ្ឍពេញលេញ ដែលទាមទារឱ្យមានការវិនិយោគបន្ថែមក្នុងការអង្កេត ប្រមូល ចងក្រងពីគ្រប់ប្រភពទិន្នន័យ ព្រមទាំងពង្រឹងសមត្ថភាពមន្ត្រីក្នុងការវិភាគ ស្រាវជ្រាវ និងព្យាករណ៍អំពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម

- ការយល់ដឹងនិងការអនុវត្តច្បាប់ និងបទបញ្ញានានា របស់និយោជក រដ្ឋបាល អ្នកគ្រប់គ្រង និងជនបរទេស នៅតាមសហគ្រាស គ្រឹះស្ថាន នៅមានកម្រិត ជាពិសេសការបំពេញបែបបទក្នុងការចុះបញ្ជីតាមរយៈការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ដែលទាមទារឱ្យបន្តយកចិត្តទុកដាក់បន្ថែមទៀតក្នុងការបង្កើនការផ្សព្វផ្សាយ ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងក្នុងប្រទេស ជាពិសេសធ្វើការសិក្សាទៅលើប្រភេទមុខរបរដែលត្រូវហាមឃាត់ជនបរទេស

- កង្វះខាតការគ្រប់គ្រង និងការផ្តល់ឯកសារស្របច្បាប់ជូនពលករ នីតិវិធី និងការរៀបចំបែបបទបញ្ជូនពលករទៅបរទេសមានរយៈពេលវែង ព្រមទាំងតួនាទីរបស់ទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួន នៅមានកម្រិត ដែលតម្រូវឱ្យបន្តយកចិត្តទុកដាក់ក្នុងការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ព្រមទាំងចុះត្រួតពិនិត្យ គ្រប់គ្រងការអនុវត្តកាតព្វកិច្ចរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិនានាដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករខ្មែរ និងតែងតាំងឱ្យមានទីប្រឹក្សាពលករទទួលបន្ទុកការងារតាមបណ្តាប្រទេសដែលមានពលករខ្មែរ។

## ២.៣.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- សហគ្រាស គ្រឹះស្ថានមួយចំនួន នៅមិនទាន់បានអនុវត្តកាតព្វកិច្ចចុះបញ្ជីសហគ្រាស គ្រឹះស្ថាន ការផ្តល់ឯកសារពាក់ព័ន្ធ ទិន្នន័យចំនួនកម្មករនិយោជិត និងប្រាក់ឈ្នួលរបស់កម្មករនិយោជិត

- លក្ខណវិនិច្ឆ័យសម្រាប់កំណត់ចំណាត់ថ្នាក់កម្រិតហានិភ័យការងារនៅមិនទាន់បានត្រូវកំណត់

- ខ្វះយន្តការតាមដានប្រវត្តិការងាររបស់កម្មករនិយោជិតដែលជាសមាជិករបស់ ប.ស.ស

- មិនទាន់មានបទដ្ឋានរួមសម្រាប់តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់ចំណាត់ថ្នាក់គុណភាពសេវាមូលដ្ឋានសុខាភិបាលរបស់ដៃគូ ប.ស.ស ហើយសេវា Hotline ជាមួយដៃគូ ប.ស.ស នៅតាមបណ្តារាជធានីខេត្ត មួយចំនួនក៏នៅមិនទាន់ដំណើរការពេញលេញ

- ខ្វះបទដ្ឋានរួមក្នុងការបំពាក់ ឧបករណ៍ សម្ភារ បរិក្ខារ នៅតាមសាខា ប.ស.ស ដែលសាងសង់រួច

- ចិរវេលានៃដំណើរការរៀបចំឯកសារដើម្បីទទួលបានគោលរបបឧបត្ថម្ភត្រឹមត្រូវ និងទាន់ពេលវេលា នៅមិនទាន់បានកំណត់ សម្រាប់ការអនុវត្ត

- ដំណើរការជារួមដែលប្រើសម្រាប់ការកំណត់អត្តសញ្ញាណ និងតាមដានកម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលត្រូវធ្វើសមាហរណកម្មចូលជាសមាជិក ប.ស.ស នៅមិនទាន់បានរៀបចំ

- មិនទាន់បានរៀបចំយន្តការគ្រប់គ្រងការផ្ទេរតាវកាលិករបបសន្តិសុខសង្គមពីបណ្តាប្រទេស ដែលមានពលករទេសន្តរប្រវេសន៍ខ្មែរ

- ទីតាំងបច្ចុប្បន្នមានលក្ខណៈតូចចង្អៀត ហើយមិនទាន់ឆ្លើយតបទៅនឹងការកើនឡើង យ៉ាងឆាប់រហ័សនៃតម្រូវការអ្នកប្រើប្រាស់សេវា។

### ២.៣.៥. ការពង្រឹងអភិបាលកិច្ចល្អ

- យុទ្ធសាស្ត្រ កម្មវិធី និងអនុកម្មវិធីមិនទាន់មានសង្គតិភាព អាស្រ័យដោយការមិនទាន់យល់ច្បាស់អំពីការកំណត់សូចនាករគោលដៅ និងការផ្តល់កិច្ចសហការពីគ្រប់អង្គភាពពាក់ព័ន្ធក្នុងការកសាងផែនការ ស្ថិតិ និងនីតិកម្ម ព្រមទាំងយន្តការក្នុងការតាមដាន រាយការណ៍ ការវាយតម្លៃ នៅមានកម្រិត

- ការអនុវត្តចំណូលនៅមានភាពលម្អៀងលើសពីផែនការ តម្រូវការចំណាយធំជាងលទ្ធភាពថវិកា ចំណែកអង្គភាពថវិកាមួយចំនួនមិនទាន់មានភាពម្ចាស់ការលើការអនុវត្តថវិកាកម្មវិធីពេញលេញ អាស្រ័យដោយខ្វះមន្ត្រីហិរញ្ញវត្ថុដែលមានជំនាញច្បាស់លាស់

- ការចូលរួមរបស់មន្ត្រីដែលអនុវត្តផ្ទាល់លើវិស័យការងារ និងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងការកសាងឯកសារគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត នៅមានកម្រិត

- មិនទាន់អនុវត្តបាននូវការកំណត់ច្បាស់លាស់អំពីចរន្តនៃការប្រមូល ចងក្រង ធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានថ្មីៗ និងផ្សព្វផ្សាយដល់អង្គភាពក្រោមឱវាទទាន់ពេលវេលា ក្នុងការអនុវត្តការងារ

- មិនទាន់មានយន្តការច្បាស់លាស់ក្នុងការសម្របសម្រួល ប្រមូល គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ អនុស្សរណៈនៃការយោគយល់គ្នា និងលិខិតូបករណ៍នានាដែលពាក់ព័ន្ធនឹងវិស័យការងារ និងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បទដ្ឋានស្តីពីលំហូរនៃការផ្តល់សេវាសាធារណៈតាមការិយាល័យច្រកចេញ-ចូលតែមួយនៃរាជធានី ខេត្តនៅមិនទាន់បានរៀបចំឱ្យសមស្របតាមតម្រូវការនៃការងារជាក់ស្តែង

- ប្រព័ន្ធស្ថិតិវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅមិនទាន់បានអនុវត្ត

- មិនទាន់បានកំណត់ទម្រង់របាយការណ៍រួមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រ និងប្រព័ន្ធរបាយការណ៍ឌីជីថល សម្រាប់គ្រប់គ្រងស្ថិតិ និងប្រព័ន្ធរបាយការណ៍រួម

- ការយល់ដឹងអំពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងតួនាទី ភារកិច្ចនៃមន្ត្រីរាជការ នៅមានកម្រិត។

# ជំពូកទី ៣

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ: ២០១៩-២០២៣

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ: ២០១៩-២០២៣** នឹងឆ្លើយតបទៅនឹងបញ្ហាទាំងឡាយដែលនៅសេសសល់ពីការអនុវត្តកន្លងមក និងកំណត់នូវយុទ្ធសាស្ត្រគន្លឹះមួយច្បាស់លាស់ ដែលមានការសម្របសម្រួលប្រទាក់ក្រឡា និងបំពេញគ្នាទៅវិញទៅមក ដើម្បីធានានូវប្រសិទ្ធភាព និងភាពជោគជ័យនៃគោលនយោបាយរបស់វិស័យទាំងមូល។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រនេះមានមុខព្រួញលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្សប្រកបដោយសមធម៌ ទាំងបរិមាណ និងគុណភាព ដែលឆ្លើយតបតាមតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាចូលរួមចំណែកក្នុងការសម្រេចជោគជ័យនូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើអាទិភាវូបនីយកម្មនូវមុំអាទិភាពរបស់ខ្លួន ព្រមទាំងកំណត់នូវយុទ្ធសាស្ត្រគន្លឹះចំនួន ៥ ដូចខាងក្រោម ៖

**យុទ្ធសាស្ត្រទី១** ÷ ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ
**យុទ្ធសាស្ត្រទី២** ÷ ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
**យុទ្ធសាស្ត្រទី៣** ÷ ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស
**យុទ្ធសាស្ត្រទី៤** ÷ ការអភិវឌ្ឍរបបសន្តិសុខសង្គម
**យុទ្ធសាស្ត្រទី៥** ÷ ការពង្រឹងសេវាគាំទ្រទូទៅ

### ៣.១- ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ:

ការលើកកម្ពស់លក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ គឺជាយុទ្ធសាស្ត្រមួយ ដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយបានអនុវត្តនូវគោលនយោបាយផ្សាភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារដើម្បីធានាថា សិទ្ធិសេរីភាព និងលក្ខខណ្ឌការងារនៅកម្ពុជាអនុលោមទៅតាមបទដ្ឋានអន្តរជាតិ ដែលផ្តល់នូវសេចក្តីទុកចិត្តដល់បងប្អូនកម្មករនិយោជិត និងនិយោជកពីបរទេសដែលកំពុងដំណើរការវិនិយោគនៅកម្ពុជា ក៏ដូចជានិយោជកបរទេស ដែលមានបំណងមកធ្វើការវិនិយោគបន្ថែមនៅកម្ពុជា។ ក្នុងអាណត្តិថ្មីនេះ ក្រសួងបន្តយកចិត្តទុកដាក់លើការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដោយត្រូវបន្តការលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ការពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ

ការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត និងការពង្រឹងសុខដុមនីយកម្មនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ សំដៅលើកកម្ពស់ការគោរពលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ដោយផ្តោតការយកចិត្តទុកដាក់ក្នុងការអនុវត្តនូវគោលនយោបាយផ្សាភ្ជាប់ពាណិជ្ជកម្ម ធានាសិទ្ធិសេរីភាព និងលក្ខខណ្ឌការងារនៅកម្ពុជាតាមបទដ្ឋានជាតិ និងអន្តរជាតិដែលផ្តល់នូវសេចក្តីទុកចិត្តដល់កម្មករនិយោជិត និងនិយោជកដែលកំពុងវិនិយោគនៅកម្ពុជា។

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រួមមាន÷

- អត្រាសហគ្រាស គ្រឹះស្ថានដែលមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារមានការថយចុះ
- ទម្រង់ធ្ងន់ធ្ងរបំផុតនៃកម្លាំងពលកម្មកុមារនិងការងារដោយបង្ខំ ត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំ
- របាយការណ៍អធិការកិច្ចការងារត្រូវបានទទួលស្គាល់កាន់តែទូលំទូលាយ
- ប្រាក់ឈ្នួលអប្បបរមានិងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតត្រូវបានពិភាក្សា និងកំណត់ជាប្រចាំ
- អត្រាវិវាទការងារធៀបជាមួយនឹងកម្មករនិយោជិត ត្រូវបានថយចុះរៀងរាល់ឆ្នាំ
- អត្រាវិវាទការងារ ដែលផ្សះផ្សាសះជាដោយមន្ត្រីផ្សះផ្សាយ៉ាងតិច ៥០%
- កិច្ចព្រមព្រៀងផ្សះផ្សាវិវាទការងារដោយមន្ត្រីផ្សះផ្សាវិវាទ ត្រូវបានគោរព និងអនុវត្ត
- សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានគោរព និងអនុវត្តភាពអនុលោមតាមនីតិវិធីជាធរមាន
- អត្រានៃកម្មករនិយោជិតដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកើនឡើង
- ស្ថិតិសហជីពធៀបនឹងចំនួនសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជីនៅក្រសួង ត្រូវបានផលិត
- ស្ថិតិកម្មករនិយោជិតជាសមាជិកសហជីពធៀបជាមួយកម្មករនិយោជិត ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត
- អត្រាកម្មករនិយោជិតដែលដួលសន្លប់ធៀបជាមួយកម្មករនិយោជិតក្នុងវិស័យនៅមានការថយចុះ
- កូដកម្ម-បាតុកម្ម ត្រូវបានដោះស្រាយដោយសន្តិវិធី តម្លាភាព និងគណនេយ្យភាពស្របតាមច្បាប់។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

### ៣.១.១. លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីខាងលើនេះ រួមមាន÷

- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌស្នូល ៣១ចំណុច មានការថយចុះ
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌ ៤១ចំណុច មានការថយចុះ
- សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីអធិការកិច្ចការងារ ត្រូវបានពង្រឹង

- តម្លាភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានពង្រឹង
- រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform) ត្រូវបានដាក់ឱ្យអនុវត្ត
- ក្រុមអធិការកិច្ចអន្តរស្ថាប័នដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់សហគ្រាស គ្រឹះស្ថាន ត្រូវបានដាក់ឱ្យអនុវត្ត។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បន្តសិក្សាស្រាវជ្រាវលទ្ធភាពធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិទ្ធិ និងលក្ខខណ្ឌការងារស្របតាមតម្រូវការសង្គម-សេដ្ឋកិច្ច

២. បន្តពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារ ដោយផ្អែកលើហានិភ័យ និងវិធីសាស្ត្រអធិការកិច្ចប្រកបដោយវិជ្ជាជីវៈ ដោយកំណត់ជាគោលការណ៍សហគ្រាស គ្រឹះស្ថាន និងវងអធិការកិច្ចចំនួន ០១ ដង/ឆ្នាំ តាមរយៈ÷

   - ការរៀបចំផែនការធ្វើអធិការកិច្ចការងារឱ្យកាន់តែមានលក្ខណៈយុទ្ធសាស្ត្រឱ្យបានទៀងទាត់យ៉ាងតិច ៥ ០០០លើក ក្នុងមួយឆ្នាំ ដោយកំណត់តាមប្រភេទ សហគ្រាស គ្រឹះស្ថាន ដែលជាគោលដៅអាទិភាព ឬងាយប្រឈមនឹងការរំលោភបំពានលក្ខខណ្ឌការងារ និងមានហានិភ័យដល់កម្មករនិយោជិតដូចជា សហគ្រាស គ្រឹះស្ថានផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សំណង់ ឡឥដ្ឋ សេវាកម្សាន្ត
   - ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់មន្ត្រីអធិការកិច្ចការងារ
   - ការបន្តបំពាក់សម្ភារ បរិក្ខារ និងមធ្យោបាយចាំបាច់ សម្រាប់ក្រុមអធិការកិច្ចការងារបំពេញការងារ
   - ការបន្តចាត់វិធានការចំពោះ សហគ្រាស គ្រឹះស្ថាន ទាំងឡាយដែលប្រព្រឹត្តល្មើសច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យការងារ
   - ការបន្តពង្រឹងលេខាធិការដ្ឋានបញ្ជាការឯកភាពក្រុមអធិការកិច្ចការងារ

៣. ពង្រឹងយន្តការអធិការកិច្ចការងារវិស័យសំណង់ ឡឥដ្ឋ និងសេវាកម្សាន្ត តាមរយៈការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុវត្ថិភាព និងសុខភាពការងារក្នុងវិស័យសំណង់ និងឡឥដ្ឋ, ការបណ្តុះបណ្តាលផ្នែកសុវត្ថិភាព និងសុខភាពការងារដល់មន្ត្រីអធិការកិច្ចការងារ និងការបំពាក់ឧបករណ៍ សម្ភារ បរិក្ខារ សម្រាប់ការធ្វើអធិការកិច្ចការងារក្នុងវិស័យសំណង់ និងឡឥដ្ឋ

៤. ធ្វើទំនើបកម្មការធ្វើអធិការកិច្ចការងារដោយប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធព័ត៌មានវិទ្យា សំដៅរៀបចំលក្ខណៈវិនិច្ឆ័យកម្រិតហានិភ័យលក្ខខណ្ឌការងាររបស់សហគ្រាស គ្រឹះស្ថាន ដើម្បីបង្កើននូវប្រសិទ្ធភាព គុណភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលអាចយកមកធ្វើការវិភាគលើកជាទិសដៅជាយុទ្ធសាស្ត្រសម្រាប់អនុវត្តបន្ត

៥. រៀបចំយន្តការតាមដានការអនុវត្តការងាររបស់ក្រុមអធិការកិច្ចការងារ តាមរយៈការបង្កើតឱ្យមានក្រុមការងារ វាយតម្លៃលើរបាយការណ៍អធិការកិច្ចការងារ ប្រសិទ្ធភាព និងវិធីសាស្ត្រនៃការចុះធ្វើអធិការកិច្ចការងារយ៉ាងតិចឱ្យបាន ២ដងក្នុងមួយឆ្នាំ

៦. បន្តលើកកម្ពស់សិទ្ធិ និងអត្ថប្រយោជន៍របស់កម្មករនិយោជិតជាស្ត្រី

៧. បន្តពង្រឹង និងពង្រីកការសហការជាមួយដៃគូពាក់ព័ន្ធ

៨. ដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិការងារ និងពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ អង្គការវិជ្ជាជីវៈនិយោជក អង្គការវិជ្ជាជីវៈកម្មករនិយោជិត សិស្ស និស្សិត និងអ្នកពាក់ព័ន្ធដទៃទៀត ជាពិសេសបណ្តុះបណ្តាលមន្ត្រីរាជការក្នុងវិស័យការងារឱ្យក្លាយជាអធិការការងារ អធិការពេទ្យការងារ អភិបាលការងារ និងមន្ត្រីផ្សះផ្សាវិវាទការងារ ព្រមទាំងសិក្សាស្រាវជ្រាវអំពីលក្ខខណ្ឌទូទៅនៃវិស័យការងារ ទំនាក់ទំនងវិជ្ជាជីវៈ ផលិតភាពការងារ សុវត្ថិភាព និងសុខភាពការងារ របបសន្តិសុខសង្គម និងទេសន្តរប្រវេសន៍ការងារ ដោយមានកិច្ចសហប្រតិបត្តិជាមួយអង្គការអន្តរជាតិខាងការងារ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានការងារ អគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា បេឡាជាតិរបបសន្តិសុខសង្គម នាយកដ្ឋានអធិការកិច្ចការងារ នាយកដ្ឋានវិវាទការងារ នាយកដ្ឋានពេទ្យការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានការងារកុមារ ក្រុមអធិការកិច្ចការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម វិទ្យាស្ថានជាតិការងារ ក្រុមការងារកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្រុមការងារវាយតម្លៃ វិស័យឯកជន អង្គការវិជ្ជាជីវៈ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងដៃគូ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីបង្កើតឱ្យមានយន្តការ សម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.១.២. ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីខាងលើនេះ រួមមាន÷

- អត្រានៃសហគ្រាសនាំចេញដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដែលអនុលោមតាមស្តង់ដាស្នូលសុវត្ថិភាព និងសុខភាពការងារ មានការកើនឡើងដល់យ៉ាងតិច ៨០% នៅឆ្នាំ២០២៣ (កន្លងទៅបានបំពេញបែបបទ ប៉ុន្តែអនុវត្តមិនគ្រប់តាមស្តង់ដា)

- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលបានបំពេញបែបបទស្របតាមស្តង់ដាសុវត្ថិភាព និងសុខភាពការងារស្ទួលចំនួន៩០% ត្រឹមឆ្នាំ២០២២
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានប្រអប់សង្គ្រោះលើប្រភេទសហគ្រាសដែលត្រូវមានប្រអប់សង្គ្រោះ
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានបន្ទប់រុំរបួស លើប្រភេទសហគ្រាសដែលត្រូវមានបន្ទប់រុំរបួស
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានគិលានដ្ឋាន លើប្រភេទសហគ្រាសដែលត្រូវមានគិលានដ្ឋាន
- អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានរៀបចំកន្លែងហូបបាយ
- ការវាយតម្លៃអំពីមូលដ្ឋានគោលនៃលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ត្រូវបានធ្វើជារៀងរាល់ ២ ឆ្នាំ/ ម្តង ចាប់ផ្តើមពីឆ្នាំ២០២១
- ទម្រង់របាយការណ៍គ្រូពេទ្យសហគ្រាស និងដាក់ឱ្យដំណើរការប្រព័ន្ធរាយការណ៍ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដោយគ្រូពេទ្យសហគ្រាស ត្រូវបានរៀបចំត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បន្តរៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារដោយសហការជាមួយដៃគូអភិវឌ្ឍន៍តាមតម្រូវការសង្គម-សេដ្ឋកិច្ច

២. បន្តពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចផ្នែកសុវត្ថិភាព និងសុខភាពការងារ

៣. ពង្រីកការផ្តល់សេវាសាធារណៈលើវិស័យសុវត្ថិភាព និងសុខភាពការងារ ដោយបង្វិតសេវាកាន់តែកៀកទៅភូមិសាស្ត្រដែលមានកម្មករនិយោជិតរស់នៅច្រើន

៤. សិក្សាស្រាវជ្រាវកំណត់ប្រភេទជំងឺវិជ្ជាជីវៈ

៥. ពង្រឹងសមត្ថភាពមន្ត្រីផ្នែកសុវត្ថិភាព និងសុខភាពការងារ

៦. ជំរុញយុទ្ធនាការ និងបញ្ជ្រាបការយល់ដឹងស្តីពីសុវត្ថិភាព និងសុខភាពការងារ។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានការងារ បេឡាជាតិសន្តិសុខសង្គម នាយកដ្ឋានពេទ្យការងារ នាយកដ្ឋានអធិការកិច្ចការងារ វិទ្យាស្ថានជាតិការងារ គណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងលិខិតបទដ្ឋានគតិយុត្ត ក្រុមការងារអន្តរក្រសួង លេខាធិការដ្ឋាននៃគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងគ្រឿងញៀន លេខាធិការដ្ឋានអាស៊ាន នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម អង្គការវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងដៃគូ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ បង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ សំដៅប្រមូលនូវចំណុច

ប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.១.៣. ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីខាងលើនេះ រួមមាន÷

- ស្ថិតិកុមារអាយុពី១៥ ដល់ ១៧ឆ្នាំ ដែលបានចូលរួមក្នុងពលកម្មកុមារ ត្រូវបានផលិត
- អត្រានៃចំនួនពលកម្មកុមារដែលស្ថិតក្នុងទម្រង់ធ្ងន់ធ្ងរត្រូវបានកាត់បន្ថយ ជាពិសេសក្នុងផ្នែក សំណង់ ឡឥដ្ឋ និងកសិឧស្សាហកម្ម ត្រូវបានកាត់បន្ថយ
- ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ត្រូវបានអនុវត្ត តាមដាន និងវាយតម្លៃ
- និយោជកដែលប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ត្រូវទទួលការពិន័យ និងផ្តន្ទាទោស។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ការកសាងសមត្ថភាពមន្ត្រីអធិការកិច្ចការងារស្តីពីការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ និងការពង្រឹងយន្តការប្រឆាំងពលកម្មកុមារ និងការងារដោយបង្ខំជាពិសេសលើវិស័យ មុខរបរ និងភូមិសាស្ត្រដែលមានហានិភ័យខ្ពស់

២. ពង្រឹងកិច្ចអន្តរាគមន៍ស្នូល ដើម្បីសង្គ្រោះពលកម្មកុមារ និងការហាមឃាត់ការងារដោយបង្ខំ ជាពិសេសនៅផ្នែកសិប្បកម្ម ឡឥដ្ឋ សំណង់ និងកសិឧស្សាហកម្ម

៣. បង្កើនកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ

៤. ពង្រីកការផ្សព្វផ្សាយ និងធ្វើយុទ្ធនាការប្រឆាំងការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ។

ដើម្បីសម្រេចបានសកម្មភាពអាទិភាពខាងលើនេះ អគ្គលេខាធិការដ្ឋាន គ.ជ.ព នាយកដ្ឋានការងារកុមារ វិទ្យាស្ថានជាតិការងារ វិទ្យាស្ថានជាតិស្ថិតិ នាយកដ្ឋានអធិការកិច្ចការងារ ក្រុមអធិការកិច្ចការងារ ក្រុមការងារអន្តរក្រសួង នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងដៃគូ ត្រូវសហការយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ ដែលកើតឡើងដោយសារការវិវឌ្ឍស្ថានភាព

សេដ្ឋកិច្ច- សង្គម និងវឌ្ឍនភាពនៃវិស័យការងារ តាមដាន និងវាយតម្លៃការអនុវត្តផែនការ សកម្មភាពជាតិ និង ស្វែងរកធនធានខាងក្រៅ ដើម្បីសង្គ្រោះពលករកុមារ តាមរយៈយន្តការផ្ទៃក្នុងដែលមានស្រាប់ និងយន្តការនៃ ភាគីពាក់ព័ន្ធ។

### ៣.១.៤. ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីខាងលើនេះ រួមមាន÷

- ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ជាទៀងទាត់ លទ្ធភាពពង្រីកវិសាលភាពនៃប្រាក់ឈ្នួលអប្បបរមា ត្រូវបានសិក្សា
- យន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាត្រូវបានពង្រឹង និងដំណើការដោយរលូន
- អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករត្រូវបានសិក្សា និងកែលម្អតាមការចាំបាច់
- ស្ថិតិសហគ្រាស គ្រឹះស្ថាន ដែលផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗប្រសើរឡើង ធៀបនឹង សហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំលិខិតបទដ្ឋានគតិយុត្ត និងដាក់ឱ្យដំណើរការក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា និងអគ្គ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ប្រកបដោយប្រសិទ្ធភាព ត្រឹមដើមត្រីមាស ទី២ ឆ្នាំ២០១៩

២. សិក្សាស្រាវជ្រាវអំពីគោលនយោបាយប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ តាមបែប វិទ្យាសាស្ត្រ និងផ្អែកលើលក្ខណវិនិច្ឆ័យផ្នែកសេដ្ឋកិច្ច- សង្គម និងភាពប្រកួតប្រជែង ដោយសហការ យ៉ាងជិតស្និទ្ធជាមួយ ILO និងយន្តការត្រីភាគី

៣. រៀបចំកិច្ចប្រជុំពិភាក្សាប្រាក់ឈ្នួលអប្បបរមាក្នុងក្របខ័ណ្ឌយន្តការត្រីភាគីឱ្យបានទៀងទាត់

៤. អង្កេត សិក្សា ស្រាវជ្រាវអំពីការប្រែប្រួលប្រាក់ឈ្នួល និងឥទ្ធិពលនៃប្រាក់ឈ្នួលអប្បបរមាលើសកម្ម ភាពសេដ្ឋកិច្ច និងសង្គម និងលទ្ធភាពពង្រីកវិសាលភាព

៥. ជ្រើសរើសបន្ថែម និងបង្កើនសមត្ថភាពមន្ត្រី ក្នុងការប្រមូលទិន្នន័យ វិភាគ និងព្យាករណ៍

៦. ពង្រឹងការអនុវត្តប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗដូចជា ប្រាក់បំណាច់អតីតភាព

៧. ពង្រឹងយន្តការអន្តរក្រសួងសម្របសម្រួលការដំឡើងថ្លៃប្រាក់ឈ្នួលផ្ទះ ទឹក ភ្លើងដែលមិនសមរម្យ

៨. សិក្សាលទ្ធភាពពង្រីកវិសាលភាព និងដាក់ឱ្យអនុវត្តប្រាក់ឈ្នួលអប្បបរមាលើវិស័យផ្សេងទៀតស្រប តាមស្ថានភាពសេដ្ឋកិច្ច និងសង្គម ដោយសហការជាមួយ ILO និងដៃគូពាក់ព័ន្ធ

៩. បង្កើនការផ្សព្វផ្សាយអំពីយន្តការ នៃការកំណត់ប្រាក់ឈ្នួលអប្បបរមា និងលទ្ធផលនៃការសិក្សាស្រាវជ្រាវនានាពាក់ព័ន្ធជាមួយប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា វិទ្យាស្ថានជាតិការងារ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្រុមអធិការកិច្ចការងារ អង្គការអន្តរជាតិខាងការងារ អង្គការវិជ្ជាជីវៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងដៃគូ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.១.៥. ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងកម្មវិធីខាងលើនេះ រួមមាន÷

- អត្រាដោះស្រាយវិវាទការងារបុគ្គលសះជានៅកម្រិតមន្ត្រីផ្សះផ្សា យ៉ាងតិច ៥០% ចាប់ពីឆ្នាំ២០២០
- អត្រាវិវាទការងាររួមសះជានៅកម្រិតមន្ត្រីផ្សះផ្សា យ៉ាងតិច ៥០% ចាប់ពីឆ្នាំ២០២០
- អត្រាអនុលោមតាមសេចក្តីបង្គាប់ជាប់កាតព្វកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានការកើនឡើងជារៀងរាល់ឆ្នាំ
- ស្ថិតិសហគ្រាស គ្រឹះស្ថានមានវិវាទធៀបនឹងចំនួន សហគ្រាស គ្រឹះស្ថានសរុប ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត
- ស្ថិតិសហគ្រាស គ្រឹះស្ថានដែលមានកូដកម្ម ធៀបនឹងសហគ្រាស គ្រឹះស្ថានសរុប ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត
- ស្ថិតិសហគ្រាស គ្រឹះស្ថានដែលមានបាតុកម្ម ធៀបនឹងសហគ្រាស គ្រឹះស្ថានសរុប ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត
- ស្ថិតិកូដកម្ម បាតុកម្ម ដែលត្រូវបានដោះស្រាយបញ្ចប់ ត្រូវបានផលិត
- មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានធានា
- សេវាក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានពង្រីក
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការវិជ្ជាជីវៈ អនុសញ្ញារួម និងការដោះស្រាយវិវាទការងារគ្រប់ដំណាក់កាលត្រូវបានដាក់ឱ្យដំណើរការពេញលេញត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំថ្មី និងធ្វើវិសោធនកម្មច្បាប់ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយនឹងនីតិវិធីដោះស្រាយវិវាទការងារ អង្គការវិជ្ជាជីវៈ និងចរចាអនុសញ្ញារួម
២. ពង្រឹងយន្តការដោះស្រាយវិវាទការងារនៅគ្រប់ដំណាក់កាល
៣. រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ បែបព័ត៌មានវិទ្យាពាក់ព័ន្ធនឹងអង្គការវិជ្ជាជីវៈ វិវាទការងារ កូដកម្ម និងបាតុកម្ម
៤. ពង្រឹងលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ លេខាធិការដ្ឋានក្រុមការងារទំនាក់ទំនងវិជ្ជាជីវៈ និងលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
៥. បន្តគាំទ្រ ពង្រឹង និងពង្រីកតួនាទី និងសេវារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
៦. លើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈស្របតាមច្បាប់ បទប្បញ្ញត្តិជាធរមាន និងទប់ស្កាត់រាល់ទម្រង់នៃការរើសអើងចំពោះសហជីព
៧. ពង្រឹងយន្តការគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្ម រាជធានី ខេត្ត ស្តីពីបាតុកម្ម កូដកម្ម គ្រប់មុខសញ្ញា
៨. បន្តរៀបចំកម្មវិធីសំណេះសំណាលរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាមួយបងប្អូនកម្មករនិយោជិត ដើម្បីលើកកម្ពស់សុខដុមរមនាទំនាក់ទំនងវិជ្ជាជីវៈ និងបង្កើនផលិតភាពការងារ
៩. យុទ្ធនាការលើកកម្ពស់សិទ្ធិការងារ និងសំវាទសង្គម និងការគ្រប់គ្រងហានិភ័យវិវាទ
១០. រៀបចំយុទ្ធនាការ “រោងចក្រ សហគ្រាស មួយជាសហគមន៍សុខសាន្តមួយ ” ដោយផ្អែកលើលក្ខណវិនិច្ឆ័យ ÷ ១. មានលក្ខខណ្ឌការងារល្អ (ប្រសើរជាងច្បាប់), ២. មានទំនាក់ទំនងវិជ្ជាជីវៈល្អ, ៣. មានសុវត្ថិភាព និងសុខភាពការងារ, ៤. មានកម្មវិធីលើកកម្ពស់ផលិតភាពការងារ និង ៥. មានកម្មវិធីទទួលខុសត្រូវសង្គម
១១. ពង្រឹងភាពជាដៃគូជាមួយអង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធ ជាពិសេសអង្គការ ILO
១២. លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិការងារ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ នីតិវិធីដោះស្រាយវិវាទការងារ និងកូដកម្ម បាតុកម្ម។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា អគ្គនាយកដ្ឋានការងារ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានវិវាទការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខាធិការដ្ឋានក្រុមប្រឹក្សាការងារ បេឡាជាតិរបបសន្តិសុខសង្គម វិទ្យាស្ថានជាតិការងារ គណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ ក្រុមអធិការកិច្ចការងារ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានអធិការកិច្ចការងារ នាយកដ្ឋានផែនការ

ស្ថិតិ និងនីតិកម្ម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ អង្គការអន្តរជាតិខាងការងារ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងដៃគូ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗឬត្រៀមធ្វើជាធាតុចូលក្នុងផែនការយុទ្ធសាស្ត្រនាពេលខាងមុខ។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពខាងលើនេះ អង្គភាពពាក់ព័ន្ធត្រូវ÷

▪ រៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃ ផែនការសកម្មភាពនៃកម្មវិធីនេះ ដើម្បីកំណត់នូវសូចនាករវាស់នូវសមិទ្ធកម្មប្រចាំឆ្នាំ និងកំណត់ផែនការសកម្មភាពប្រចាំឆ្នាំ តាមរយៈកំណត់ឱ្យមានរបាយការណ៍ និងស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយមានបញ្ជាក់ពីការវិវឌ្ឍនៃសូចនាករនីមួយៗ។

▪ រៀបចំអនុវត្តថវិកាតាមកម្មវិធីដើម្បីបន្សុីផែនការសកម្មភាពក្នុងកម្មវិធីនីមួយៗ ទៅនឹងផែនការយុទ្ធសាស្ត្រចំណាយរយៈពេលមធ្យមរបស់ក្រសួងសំដៅបង្កើនប្រសិទ្ធភាពចំណាយថវិកា និងភាពអាចព្យាករណ៍បាននៃប្រភពធនធានថវិកា។

▪ រៀបចំគម្រោងថវិកាជូនរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីស្នើសុំហិរញ្ញប្បទាន និងជំនួយបច្ចេកទេស សម្រាប់ទិញសម្ភារបរិក្ខារ និងមធ្យោបាយ សំដៅលើកស្ទួយសមត្ថភាពអង្គភាពក្នុងការបំពេញភារកិច្ច។

▪ រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលទទួលភារកិច្ចចាត់តាំងឱ្យអនុវត្តសកម្មភាពអាទិភាពក្នុងកម្មវិធីនីមួយៗ។

## ៣.២- ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការអភិវឌ្ឍធនធានមនុស្សផ្នែកបច្ចេកទេសប្រកបដោយគុណភាព ជំនាញ ក្រមសីលធម៌វិជ្ជាជីវៈ និងផលិតភាព គឺជាយន្តការមួយដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការកសាងនូវកម្លាំងពលកម្ម ដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ គំនិតច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ ដែលអាចឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងគោលនយោបាយពិពិធកម្មសេដ្ឋកិច្ចទាំងនៅទីផ្សារការងារក្នុងស្រុក និងទីផ្សារការងារក្រៅប្រទេស។ ក្នុងអាណត្តិថ្មីនេះ ក្រសួងយកចិត្តទុកដាក់ លើការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយបន្តការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការពង្រីកការបណ្តុះបណ្តាលជំនាញ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ការពង្រឹងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការលើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍ សំដៅ

ធានាថា "**យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត**" ក្នុងការលើកកម្ពស់ចំណេះដឹងជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពល្អ និងកាយសម្បទារឹងមាំ តួនាទីស្ត្រី និងកិច្ចគាំពារសង្គម ជាពិសេសដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឱ្យឈានឡើងមួយកម្រិតទៀត។

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រួមមាន÷

- សិស្ស និស្សិត ដែលចូលរៀនក្នុង វិស័យអាទិភាពសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (CQF2) ដល់សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស(CQF5) នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន មានការកើនឡើង យ៉ាងតិចចំនួន ២០%/ឆ្នាំ
- អត្រាសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សា អ.ប.វ មានការកើនឡើង
- អត្រាសិក្ខាកាម សិស្ស និស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលមានការងារធ្វើ មានការកើនឡើងជារៀងរាល់ឆ្នាំ
- សិក្ខាកាមវគ្គខ្លីដែលបញ្ចប់ការបណ្តុះបណ្តាល មានចំណូលកើនឡើងលឿនជាងប្រជាពលរដ្ឋក្នុងសហគមន៍ដែលមិនទទួលបានការបណ្តុះបណ្តាល
- កម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) ត្រូវបានរៀបចំ
- អគារបណ្តុះបណ្តាល និងមន្ទីរពិសោធន៍លើជំនាញអាទិភាពត្រូវ បានសាងសង់ និងធ្វើទំនើបកម្ម
- ស្ថិតិស្នាដៃស្រាវជ្រាវដែលត្រូវបានយកទៅប្រើប្រាស់ក្នុងឧស្សាហកម្ម
- អត្រានៃការពេញចិត្តរបស់និយោជកលើសិក្ខាកាម សិស្ស និស្សិត ចេញពី អ.ប.វ មានការកើនឡើង
- អត្រាសិក្ខាកាម សិស្ស និស្សិតដែលពេញចិត្ត និងវគ្គបណ្តុះបណ្តាលមានការកើនឡើង
- អត្រាវគ្គបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) ធៀបនឹងវគ្គបណ្តុះបណ្តាលសរុបមានការកើនឡើង
- ចំនួនមនុស្សចូលធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL និង RCC) មានការកើនឡើង
- អត្រាយុវជន (អាយុ១៥-២៤ឆ្នាំ)ដែលគ្មានការអប់រំ គ្មានការងារធ្វើ ឬគ្មានការបណ្តុះបណ្តាលមានការថយចុះ
- អត្រាអ្នកចុះឈ្មោះចូលរៀន (អាយុ១៥-២៤ឆ្នាំ) សរុបនៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈមានការកើនឡើង
- ចំនួនយុវជននៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំពុងហាត់ការក្នុងវិស័យការងារ (ការហ្វឹកហ្វឺនកូនជាង/កម្មសិក្សា) មានការកើនឡើង
- រៀបចំផែនការមេសម្រាប់អភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅត្រឹមឆ្នាំ ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

### ៣.២.១. ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- សិស្ស និស្សិតបានចុះទស្សនកិច្ចសិក្សាតាមសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន ១០%/ឆ្នាំ
- លិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័ត យ៉ាងតិចចំនួន ២០ ត្រឹមឆ្នាំ២០២៣
- គ្រូបច្ចេកទេសបានធ្វើវិក្រឹត្យការនៅតាមសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន ១០%/ឆ្នាំ
- កញ្ចប់ស្តង់ដាបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍ យ៉ាងតិច ចំនួន ១៨៥ គុណវុឌ្ឍ នៅត្រឹមឆ្នាំ២០២៣
- អត្រាតម្លាតតម្លៃឯកតាបណ្តុះបណ្តាល (Unit cost) នៃគ្រឹះស្ថាន អ.ប.វ សាធារណៈ និងឯកជន មានការថយចុះ។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាមួយក្របខ័ណ្ឌគុណវុឌ្ឍជាតិ ស្តង់ដា ក្របខ័ណ្ឌគុណវុឌ្ឍគ្រូបច្ចេកទេស ការគ្រប់គ្រងគ្រឹះស្ថានសិក្សា

២. អភិវឌ្ឍ និងអនុវត្តកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាព ស្របតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជាកម្រិត ១ ២ ៣ ៤ លើជំនាញ អគ្គិសនី/អេឡិចត្រូនិក មេកានិករថយន្ត សំណង់ កម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា

៣. រៀបចំ និងការកែលម្អកម្មវិធីសិក្សាតាមក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជាកម្រិត៥ ជាពិសេសលើជំនាញអាទិភាព អគ្គិសនី/អេឡិចត្រូនិក មេកានិករថយន្ត សំណង់ កម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា

៤. រៀបចំជ្រើសរើស និងប្រឡងបញ្ចប់សិស្ស និស្សិត និងគរុនិស្សិត ធ្វើតេស្តសមត្ថភាព ដើម្បីទទួលស្គាល់ជំនាញ និងហ្វឹកហាត់ចូលរួមប្រកួតប្រជែងជំនាញប្រចាំឆ្នាំក្នុង និងក្រៅប្រទេស (ថ្នាក់ភូមិភាគ ថ្នាក់ជាតិ ថ្នាក់អាស៊ាន ថ្នាក់អាស៊ី និងថ្នាក់ពិភពលោក)

៥. ពង្រឹងយន្តការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា (CQF) នៅតាមគ្រឹះស្ថាន អ.ប.វ

៦. លើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេស

៧. ពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៨. សាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់ឧបករណ៍ បរិក្ខារ សម្ភារបណ្តុះបណ្តាលទៅតាមជំនាញអាទិភាព និងបច្ចេកវិទ្យាថ្មីៗ

៩. រៀបចំ និងធ្វើបច្ចុប្បន្នភាពកញ្ចប់ថវិកាតម្លៃឯកតាបណ្តុះបណ្តាលជាប្រចាំតាមការចាំបាច់

១០. ពង្រឹងការគ្រប់គ្រងវិស្វករ និងអភិវឌ្ឍសមត្ថភាពវិស្វករអាជីព។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានព័ត៌មានទីផ្សារការងារ នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា នាយកដ្ឋានធានាគុណភាព នាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា គណៈវិស្វករកម្ពុជា ទីភ្នាក់ងារជាតិមុខរបរ និងការងារ គ្រឹះស្ថាន អ.ប.វ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងអង្គភាពពាក់ព័ន្ធត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗ ឬត្រៀមធ្វើជាធាតុចូលក្នុងផែនការយុទ្ធសាស្ត្រនាពេលខាងមុខ។

### ៣.២.២. ពង្រីកការបណ្តុះបណ្តាលជំនាញ ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- អត្រាសិស្សដែលបានបញ្ចប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ៣ (CQF2 3 4) បានកើនឡើងយ៉ាងតិច ២០%/ឆ្នាំ
- អត្រានិស្សិតដែលបានបញ្ចប់សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស (CQF5) បានកើនឡើង យ៉ាងតិច ២០%/ឆ្នាំ
- អត្រាសិក្ខាកាមដែលបានបញ្ចប់វគ្គខ្លីតាមជំនាញអាទិភាព បានកើនឡើង។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បង្កើនចំនួនសិស្សទទួលបានសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

២. ផ្តល់ឱកាសដល់ស្ត្រី ជនងាយរងគ្រោះ ជនជាតិដើមភាគតិច និងជនចំណាកស្រុក ទទួលបានការបណ្តុះបណ្តាល

៣. រៀបចំយន្តការ និងកម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling)

៤. រៀបចំយន្តការជាមួយដៃគូពាក់ព័ន្ធដើម្បីផ្តល់ឥណទានដល់ សិក្ខាកាម សិស្ស និស្សិត ដែលបញ្ចប់វគ្គបណ្តុះបណ្តាលដើម្បីបង្កើតមុខរបរខ្លួនឯង

៥. ពង្រឹងការហ្វឹកហ្វឺនកូនជាង និងកម្មសិក្សា

៦. ពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

៧. លើកទឹកចិត្ត និងលើកកម្ពស់ការបញ្ចូល និងការអនុវត្តសកម្មភាពអប់រំកាយ កីឡា សិល្បៈ និងវប្បធម៌ទៅក្នុងកម្មវិធីសិក្សា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ នាយកដ្ឋានព័ត៌មានទីផ្សារការងារ នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា គ្រឹះស្ថាន អ.ប.វ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងអង្គភាពពាក់ព័ន្ធ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗទៅតាមស្ថានភាពការងារចាំបាច់។

### ៣.២.៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- គ្រឹះស្ថាន អ.ប.វ បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន ១៥ MoU/ឆ្នាំ
- គោលនយោបាយលើកទឹកចិត្តបន្ថែម ផ្អែកសារពើពន្ធផ្សារភ្ជាប់នឹងការបណ្តុះបណ្តាលធនធានមនុស្សត្រូវបានអនុវត្តត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីសហការជាមួយវិស័យឯកជន ស្របតាមគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០
២. រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញដោយសហការជាមួយស្ថាប័ន និងដៃគូពាក់ព័ន្ធ
៣. ជំរុញការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមតំបន់សេដ្ឋកិច្ចពិសេស និងសួនឧស្សាហកម្ម
៤. បង្កើនចំនួនសិស្ស និងនិស្សិតចុះកម្មសិក្សា ចុះអនុវត្តនៅតាមសហគ្រាស គ្រឹះស្ថានឯកជន។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ នាយកដ្ឋានព័ត៌មានទីផ្សារការងារ នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ព្រមទាំងអង្គភាពពាក់ព័ន្ធត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មី ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗ ឬត្រៀមធ្វើជាធាតុចូលក្នុងផែនការយុទ្ធសាស្ត្រនាពេលខាងមុខ។

### ៣.២.៤. លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- លិខិតបទដ្ឋានគតិយុត្ត ត្រូវបានអភិវឌ្ឍយ៉ាងតិចចំនួន ៥ ត្រឹមឆ្នាំ២០២១
- សមត្ថភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អ.ប.វ មន្ត្រីប្រតិបត្តិ និងមន្ត្រីគ្រឹះស្ថាន អ.ប.វ ត្រូវបានពង្រឹង
- ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ (TVETMIS) ត្រូវបានបញ្ចូលត្រឹមត្រូវពេញលេញ និងប្រើប្រាស់ជាផ្លូវការ
- របាយការណ៍វឌ្ឍនភាព ស្តីពីការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (NTVET) ឆ្នាំ២០១៧-២០២៥ ប្រចាំឆ្នាំត្រូវបានរៀបចំ និងដាក់ជូន រាជរដ្ឋាភិបាល ទៀងទាត់តាមកាលកំណត់។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងគ្រឹះស្ថាន អ.ប.វ
២. បង្កើនប្រសិទ្ធភាពគណៈកម្មាធិការជាតិបណ្តុះបណ្តាល (NTB)
៣. ពង្រឹងយន្តការអន្តរស្ថាប័នដើម្បីជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៤. ពង្រឹងសមត្ថភាព និងភាពដឹកនាំមន្ត្រីអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥
៥. ពង្រឹងការគ្រប់គ្រងស្ថិតិ អ.ប.វ តាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ (TVETMIS)
៦. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវគ្គបណ្តុះបណ្តាល។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានព័ត៌មានទីផ្សារការងារ នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា គ្រឹះស្ថាន អ.ប.វ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.២.៥. ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ចំនួនគម្រោងស្រាវជ្រាវដែលបានបញ្ចប់ដោយជោគជ័យ នៅឆ្នាំ២០២៣

- ចំនួនអ្នកស្រាវជ្រាវដែលចូលរួមមានការកើនឡើង នៅឆ្នាំ២០២៣
- ចំនួនស្នាដៃស្រាវជ្រាវដែលត្រូវបានយកទៅប្រើប្រាស់ក្នុងឧស្សាហកម្ម នៅឆ្នាំ២០២៣។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បង្កើតយន្តការដឹកនាំសម្របសម្រួលជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍

២. បង្កើនមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍

៣. រៀបចំចងក្រង និងជំរុញដំណើរការរបស់បណ្តាញអ្នកស្រាវជ្រាវ និងវិទ្យាសាស្ត្រដើម្បីជំរុញការស្រាវជ្រាវ

៤. កៀរគរមូលនិធិ និងរៀបចំគម្រោងថវិកាសិក្សាស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានព័ត៌មានទីផ្សារការងារ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយសំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពខាងលើនេះ អង្គភាពពាក់ព័ន្ធត្រូវ÷

▪ រៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃផែនការសកម្មភាព នៃកម្មវិធីនេះដើម្បីកំណត់នូវសូចនាករវាស់នូវសមិទ្ធកម្មប្រចាំឆ្នាំ និងកំណត់ផែនការសកម្មភាពប្រចាំឆ្នាំ តាមរយៈកំណត់ឱ្យមានរបាយការណ៍ និងស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដោយមានបញ្ជាក់ពីការវិវឌ្ឍនៃសូចនាករនីមួយៗ

▪ រៀបចំអនុវត្តថវិកាតាមកម្មវិធីដើម្បីបន្សុីផែនការសកម្មភាពក្នុងកម្មវិធីនីមួយៗ ទៅនឹងផែនការយុទ្ធសាស្ត្រចំណាយរយៈពេលមធ្យមរបស់ក្រសួង សំដៅបង្កើនប្រសិទ្ធភាពចំណាយថវិកា និងភាពអាចព្យាករណ៍បាននៃប្រភពធនធានថវិកា

▪ រៀបចំគម្រោងថវិកាជូនរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដើម្បីស្នើសុំហិរញ្ញប្បទាន និងជំនួយបច្ចេកទេសសម្រាប់ទិញសម្ភារ បរិក្ខារ និងមធ្យោបាយសំដៅលើកស្ទួយសមត្ថភាពអង្គភាពក្នុងការបំពេញភារកិច្ច

▪ រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលទទួលភារកិច្ចចាត់តាំងឱ្យអនុវត្តសកម្មភាពអាទិភាពក្នុងកម្មវិធីនីមួយៗ។

### ៣.៣- ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស

ដើម្បីធានាបាននូវការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ស្របតាមការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការអភិវឌ្ឍមុខរបរ និងការងារជាអាទិភាពមួយក្នុងចំណោមអាទិភាពផ្សេងទៀត ព្រោះថាការរីកចម្រើននៃវិស័យការងារ នឹងនាំឱ្យប្រជាពលរដ្ឋ មានឱកាសទទួលបានការងារល្អៗ។ ក្នុងអាណត្តិថ្មីនេះ ក្រសួងបន្តយកចិត្តទុកដាក់ក្នុងការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស ដោយការបង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់ ការពង្រីកយន្តការ វិសាលភាពនិងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយ តបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា ការពង្រឹងយន្តការវេទិកាការងារនិងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ ការបង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ សំដៅពង្រឹងយន្តការវេទិកាការងារ ការផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលធ្វើការ និងការពង្រីកការផ្តល់សេវារកការងារឱ្យធ្វើ និងការផ្សព្វផ្សាយ ព្រមទាំងការបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស ដើម្បីបង្កើនឱកាសការងារប្រកបដោយសមធម៌ និងការកាត់បន្ថយការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន និងការលើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅកម្ពុជា ដោយទទួលស្គាល់ថា ពលករទេសន្តរប្រវេសន៍គឺជាភ្នាក់ងារនៃការច្នៃប្រឌិតថ្មី និងការអភិវឌ្ឍ។

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ រួមមាន÷

- អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជនសរុប(អាយុ ១៥ឆ្នាំឡើង) ត្រូវបានរក្សាមិនឱ្យធ្លាក់ក្រោម ៧៨%
- អត្រាគ្មានការងារធ្វើសរុប (អាយុ ១៥ឆ្នាំឡើង) ត្រូវបានរក្សាមិនឱ្យលើស ២%
- អត្រាគ្មានការងារធ្វើរបស់យុវជន (អាយុពី១៥-២៤ ឆ្នាំ) ត្រូវបានរក្សាមិនឱ្យលើស ៣%
- អត្រាគម្លាតចូលរួមកម្លាំងពលកម្មរវាង ស្ត្រីធៀបនឹងបុរស ត្រូវបានកាត់បន្ថយ
- អត្រាកម្មករ-និយោជិតដែលទទួលបានប្រាក់ឈ្នួលធៀបនឹងអ្នកមានការងារធ្វើសរុប មានការកើនឡើង
- អត្រាអ្នកមានការងារធ្វើក្នុងវិស័យក្រៅពីកសិកម្មធៀបនឹងអ្នកមានការងារធ្វើសរុប មានការកើនឡើង
- ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារត្រូវបានពង្រឹង
- កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា និងកម្មវិធីរបស់ដៃគូ ត្រូវបានធ្វើសមាហរណកម្ម និងអនុវត្ត
- ព័ត៌មានទីផ្សារការងារត្រូវបានផ្សព្វផ្សាយកាន់តែទូលំទូលាយដល់គ្រប់គោលដៅ
- សេវាកម្មស្វែងរកការងារធ្វើសាធារណៈ ត្រូវបានពង្រឹង និងពង្រីក
- ការចូលរួមវេទិកាការងារ និងផលិតភាពការងារត្រូវបានកើនឡើង
- ការគ្រប់គ្រងស្ថិតិ និងចលនាបុគ្គលិក ត្រូវបានពង្រឹង
- ការគ្រប់គ្រងមុខរបរ និងការងាររបស់កម្មករនិយោជិតបរទេសត្រូវបានពង្រឹង

- ការគាំទ្រ និងគាំពារពលករទេសន្តរប្រវេសន៍ខ្មែរ និងក្រុមគ្រួសារ ត្រូវបានពង្រឹង
- ផលិតភាពកម្មករនិយោជិតត្រូវបានបង្កើនចាប់ពីឆ្នាំ២០២០
- សហគ្រាសនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ យ៉ាងតិចចំនួន ៥%/ឆ្នាំ ត្រូវបានចុះបញ្ជី។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

### ៣.៣.១. បង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ (NEP) ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំ និងដាក់ជូនរាជរដ្ឋាភិបាលទៀងទាត់តាមការកំណត់
- លេខាធិការដ្ឋានសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានដំណើរការពេញលេញ
- ខេត្តដែលមានផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ (NEP) ចំនួន ៤ ត្រូវបានជ្រើសរើសក្នុង ឆ្នាំ២០១៩ និងត្រូវបានបង្កើនយ៉ាងតិចចំនួន ១ ខេត្ត/ឆ្នាំ
- របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំលើការអនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័ត
- វេទិកាដៃគូពាណិជ្ជកម្ម-អ្នកបញ្ចូនទិញ ត្រូវបានរៀបចំជារៀងរាល់ឆ្នាំ។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត

២. ពង្រឹងលេខាធិការដ្ឋាន និងសមត្ថភាពសមាជិកអនុគណៈកម្មការអន្តរក្រសួង គណៈកម្មការរាជធានី-ខេត្ត ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

៣. ជំរុញការអនុវត្តកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ដោយសហការជាមួយអង្គការអន្តរជាតិខាងការងារ

៤. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍បន្ថែម ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារ និងកម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋាន

ការងារ វិទ្យាស្ថានជាតិការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ទីភ្នាក់ងារជាតិមុខរបរ និងការងារ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានអធិការកិច្ចការងារ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ លេខាធិការដ្ឋានក្រុមការងារទី៨ លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួល គណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យការងារ លេខាធិការដ្ឋានសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារគណៈកម្មការអន្តរក្រសួងសម្រាប់ដឹកនាំ ត្រួតពិនិត្យ វាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ គ្រប់អង្គភាពពាក់ព័ន្ធ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីផ្តល់នូវព័ត៌មាន និងទិន្នន័យដែលមានស្រាប់សម្រាប់ធ្វើជាធាតុចូលផ្តល់ជូនក្រុមការងារបច្ចេកទេសក្នុងការរៀបចំរបាយការណ៍។

### ៣.៣.២. ពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- សេវាការងារ និងព័ត៌មានទីផ្សារការងារបានគ្របដណ្តប់ទូទាំងប្រទេសនៅត្រឹមឆ្នាំ២០២៣
- អត្រាអ្នកចុះឈ្មោះស្វែងរកការងារធ្វើបានកើនឡើងជាមធ្យមយ៉ាងតិច ០,៥ពិន្ទុភាគរយ ជារៀងរាល់ឆ្នាំធៀបនឹងចំនួនប្រជាជនដល់អាយុចូលធ្វើការ (៣០០ ០០០នាក់/ឆ្នាំ)
- អត្រាអ្នកបានការងារធ្វើ ត្រូវបានបង្កើន ១ពិន្ទុភាគរយ ធៀបនឹងចំនួនអ្នកចុះឈ្មោះស្វែងរកការងារធ្វើ
- ចំនួនវិទ្យាល័យទូទាំងប្រទេសដែលទទួលបានសេវាមគ្គុទេសន៍អាជីព មានការកើនឡើង
- អត្រាការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាមានការកើនឡើងផ្អែកលើការធ្វើអង្កេតជារៀងរាល់ឆ្នាំ
- ប្រព័ន្ធផ្តល់សេវាស្វ័យប្រវត្តិកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ឱ្យដំណើរការត្រឹមឆ្នាំ២០២១។

ដើម្បីសម្រេចនូវសូចនាករខាងលើនេះ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ពង្រីកវិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាការងារ និងមុខរបរ
២. បង្កើនការចុះឈ្មោះអ្នកស្វែងរកការងារ ការផ្គូផ្គងបញ្ជូនទៅនិយោជក និងការទទួលបានការងារ
៣. ពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈ
៤. លើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវា និងសមិទ្ធកម្មក្នុងការបំពេញការងារ
៥. លើកកម្ពស់ និងពង្រីកសមត្ថភាពមន្ត្រីក្នុងការផ្តល់សេវា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ក្រុមការងារពង្រឹង

ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវរៀបចំយន្តការការងារដើម្បីអនុវត្ត សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៣.៣. ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- អត្រានៃចំនួនវេទិកាការងារថ្នាក់ជាតិ/មូលដ្ឋាន មានការកើនឡើង១០%/ឆ្នាំ
- អត្រាយល់ដឹងអំពីសេវាការងារ និងព័ត៌មានទីផ្សារការងារមានការកើនឡើង ផ្អែកលើការអង្កេតជារៀងរាល់ឆ្នាំ
- ស្ថិតិព័ត៌មានទីផ្សារការងារត្រូវបានផលិត និងផ្សព្វផ្សាយជាប្រចាំតាមការកំណត់។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ពង្រីកយន្តការវេទិកាការងារថ្នាក់ជាតិ និងតាមមូលដ្ឋាន
២. ពង្រីកការអង្កេត ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនូវព័ត៌មានស្ថិតិទីផ្សារការងារ
៣. អភិវឌ្ឍប្រព័ន្ធព្យាករណ៍ និងប៉ាន់ប្រមាណស្ថិតិព័ត៌មានទីផ្សារការងារ
៤. កៀរគរធនធានហិរញ្ញវត្ថុបច្ចេកទេស និងការគាំទ្រផ្សេងទៀតពីដៃគូទ្វេភាគី ពហុភាគី ផ្អែកឯកជនសង្គមស៊ីវិល ដើម្បីពង្រីកលទ្ធភាពក្នុងការផ្តល់សេវា
៥. ពង្រឹង និងបង្កើនប្រសិទ្ធភាពការផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹង និងបង្កើនការប្រើប្រាស់សេវាការងារនិងព័ត៌មានទីផ្សារការងារ
៦. ពង្រីកការប្រមូលផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្ម វគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ពីគ្រប់ប្រភព។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវរៀបចំយន្តការការងារដើម្បីអនុវត្ត សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៣.៤. ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ការផ្តល់សេវាប័ណ្ណ សៀវភៅការងារជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ទិន្នន័យកម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន ត្រូវបានគ្រប់គ្រងប្រសើរឡើងតាមរយៈប្រព័ន្ធទិន្នន័យ
- អត្រាអនុលោមតាមច្បាប់របស់សហគ្រាស គ្រឹះស្ថានដែលប្រើប្រាស់កម្លាំងពលកម្មបរទេសមានចំនួនយ៉ាងតិច ៩០% ត្រូវបានកើនឡើងត្រឹមឆ្នាំ២០២៣
- ទិន្នន័យពលករទេសន្តរប្រវេសន៍ខ្មែរត្រូវបានគ្រប់គ្រង និងដំណើរការប្រសើរឡើង តាមរយៈការពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ចំណូលពីអាករ និងកម្រៃសេវាលើប័ណ្ណ សៀវភៅការងារ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស មានការកើនឡើងរៀងរាល់ឆ្នាំ
- ចំណូលពីអាករលើប័ណ្ណ សៀវភៅការងារជនកម្ពុជា មានការកើនឡើងរៀងរាល់ឆ្នាំ
- យន្តការគ្រប់គ្រងគាំទ្រ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍ត្រូវបានពង្រីក
- ប្រាក់បញ្ញើត្រឡប់មកក្នុងប្រទេសរបស់ពលករទេសន្តរប្រវេសន៍ខ្មែរ ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំ
- ប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ ដើម្បីបង្កើនប្រសិទ្ធភាព ការទទួលខុសត្រូវ ការតាមដាន និងគ្រប់គ្រងដំណើរការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ត្រូវបានដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បង្កើនការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស
២. ពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេស
៣. ពង្រឹងការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ខ្មែរ នៅបរទេស
៤. ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី (ក្របខ័ណ្ឌតំបន់ និងអន្តរជាតិ) ដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករទេសន្តរប្រវេសន៍ ព្រមទាំងជំរុញការអនុវត្តលិខិតូបករណ៍នានារបស់អាស៊ាន និងអន្តរជាតិ។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម វិទ្យាស្ថានជាតិការងារ គណៈកម្មការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅបរទេស គណៈកម្មការផ្តល់ភាពស្រប

ច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ទីប្រឹក្សាទទួលបន្ទុកពលករ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ត្រូវរៀបចំយន្តការការងារដើម្បីអនុវត្ត សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៣.៥. បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- អត្រានៃចំនួនវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់ផលិតភាពការងារដល់កម្មករ និយោជិត និយោជក និងអ្នកស្វែងរកការងារ កើនឡើងយ៉ាងតិច៥ភាគរយ/ឆ្នាំ
- អត្រានៃការយល់ដឹងអំពីភាពចាំបាច់ និងសារៈសំខាន់នៃផលិតភាពការងារក្នុងចំណោមកម្មករនិយោជិត និយោជក មានការកើនឡើងផ្អែកលើការអង្កេតជារៀងរាល់ឆ្នាំ

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ធ្វើវិសោធនកម្ម ឬកសាងលិខិតបទដ្ឋានគតិយុត្ត ដើម្បីឱ្យមានទទួលយកនិស្សិតធ្វើកម្មសិក្សាតាមសហគ្រាស គ្រឹះស្ថាន

២. ធ្វើយុទ្ធនាការលើកកម្ពស់ផលិតភាពការងារថ្នាក់ជាតិជារៀងរាល់ឆ្នាំ

៣. ផ្តល់ការបណ្តុះបណ្តាលតម្រង់ទិសមុនចូលបម្រើការងារ ជំនាញទន់ ការលើកកម្ពស់ផលិតភាពការគ្រប់គ្រងធនធានមនុស្ស និងសហគ្រិនភាព

៤. បង្កើនការស្វែងរកកម្មសិក្សាការងារសម្រាប់សិស្ស និស្សិត កម្មករ និយោជិត នៅតាមសហគ្រាស គ្រឹះស្ថានរដ្ឋ និងឯកជននានា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ វិទ្យាស្ថានជាតិការងារ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវរៀបចំយន្តការការងារដើម្បីអនុវត្ត សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពខាងលើនេះ អង្គភាពពាក់ព័ន្ធត្រូវ÷

▪ រៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃផែនការសកម្មភាពនៃកម្មវិធីនេះដើម្បីកំណត់នូវសូចនាករវាស់នូវសមិទ្ធកម្មប្រចាំឆ្នាំ និងកំណត់ផែនការសកម្មភាពប្រចាំឆ្នាំតាមរយៈការកំណត់ឱ្យមានរបាយការណ៍ និងស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដោយមានបញ្ជាក់ពីការវិវឌ្ឍនៃសូចនាករនីមួយៗ

▪ រៀបចំអនុវត្តថវិកាតាមកម្មវិធី ដើម្បីបន្ស៊ីផែនការសកម្មភាពក្នុងកម្មវិធីនីមួយៗទៅនឹងផែនការយុទ្ធសាស្ត្រចំណាយរយៈពេលមធ្យមរបស់ក្រសួង សំដៅបង្កើនប្រសិទ្ធភាពចំណាយថវិកា និងភាពអាចព្យាករណ៍បាននៃប្រភពធនធានថវិកា

▪ រៀបចំគម្រោងថវិកាជូនរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីស្នើសុំហិរញ្ញប្បទាន និងជំនួយបច្ចេកទេសសម្រាប់ទិញសម្ភារ បរិក្ខារ និងមធ្យោបាយសំដៅលើកស្ទួយសមត្ថភាពអង្គភាពក្នុងការបំពេញភារកិច្ច

▪ រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលទទួលភារកិច្ចចាត់តាំងឱ្យអនុវត្តសកម្មភាពអាទិភាពក្នុងកម្មវិធីនីមួយៗ។

## ៣.៤- ការអភិវឌ្ឍរបបសន្តិសុខសង្គម

ដោយឈរលើមូលដ្ឋាននៃស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវឌ្ឍនភាពក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច-សង្គមកិច្ច រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ក្នុងការធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រជាជនសំដៅលើកកម្ពស់សុខមាលភាព និងសាមគ្គីភាពសង្គម ព្រមទាំងកាត់បន្ថយភាពក្រីក្រជាអតិបរមា ជាពិសេសប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ ក្នុងអាណត្តិថ្មីនេះ ក្រសួងបន្តយកចិត្តទុកដាក់លើ ការអភិវឌ្ឍរបបសន្តិសុខសង្គមដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយបន្តការពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ការបន្តពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ការជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបប្រាក់សោធន និងការពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងការអភិវឌ្ឍសមត្ថភាពដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា សំដៅលើកកម្ពស់សុខមាលភាព និងសាមគ្គីភាពសង្គម ព្រមទាំងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រជាអតិបរមា ជាពិសេស ប្រព័ន្ធគាំពារសង្គមសម្រាប់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

សូចនាករដែលត្រូវសម្រេចឱ្យបានក្នុងយុទ្ធសាស្ត្រនេះ រួមមាន÷

- អត្រាចំណាយរដ្ឋបាលធៀបនឹងសមាជិក ប.ស.ស.

- ចំនួនមន្ត្រី ប.ស.ស ធៀបនឹងសមាជិក ប.ស.ស.
- ករណីប្តឹងតវ៉ាពាក់ព័ន្ធនឹងសេវាដៃគូ ប.ស.ស. ធៀបនឹងសមាជិក ប.ស.ស មានការថយចុះ
- ករណីបណ្តឹងតវ៉ាពាក់ព័ន្ធនឹងសេវាដៃគូ ធៀបនឹងចំនួនសេវាដែលបានផ្តល់
- ករណីប្តឹងតវ៉ាពាក់ព័ន្ធនឹងសេវា គាំទ្ររបស់ ប.ស.ស. ធៀបនឹងសមាជិក ប.ស.ស. មានការថយចុះ។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន៥ ដូចខាងក្រោម÷

### ៣.៤.១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- អត្រាសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទាន ប.ស.ស. លើចំនួនសហគ្រាសសរុប យ៉ាងតិចចំនួន ៩៩ភាគរយ ត្រឹមឆ្នាំ២០២៣
- កម្រិតគុណភាពសេវារបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ មានការកើនឡើង
- សុវត្ថិភាពនៃការដឹកជញ្ជូនកម្មករនិយោជិតត្រូវបានពង្រឹង
- កម្មករនិយោជិតថ្មីយ៉ាងតិចចំនួន ៥០ ០០០នាក់/ឆ្នាំ ត្រូវបានចុះបញ្ជី
- ចំនួនមន្ត្រីផ្តល់សេវាផ្នែកហានិភ័យធៀបនឹងសមាជិក ប.ស.ស.
- អត្រាចំណាយរដ្ឋបាលផ្នែកហានិភ័យការងារធៀបនឹងសមាជិក ប.ស.ស.
- ប្រព័ន្ធតាមដានប្រវត្តិកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. ដែលទទួលគ្រោះថ្នាក់ការងារ ត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីសាធារណៈ ដែលជាសមាជិក ប.ស.ស. ផ្នែកហានិភ័យការងារ ត្រូវបានរៀបចំត្រឹមឆ្នាំ ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណាត់ថ្នាក់សេវារបស់ដៃគូ ប.ស.ស. ត្រូវបានរៀបចំត្រឹមឆ្នាំ២០២១។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

២. ពង្រឹងយន្តការនៃកាអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

៣. ពង្រឹងយន្តការទប់ស្កាត់ករណីគ្រោះថ្នាក់ដឹកជញ្ជូនកម្មករនិយោជិត និងករណីដួលសន្លប់របស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន

៤. ពង្រីកសេវារបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ដល់សមាជិក ប.ស.ស.

៥. ពង្រីកសេវាគាំទ្រដល់សមាជិក ប.ស.ស.

៦. រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

៧. បង្កើតការយល់ដឹងអំពីរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងអង្គភាពពាក់ព័ន្ធ ដូចជា ក្រុមកសាងច្បាប់ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវប្រឹក្សាយោបល់ជាមួយគ្នា សំដៅកែលម្អការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នភាពនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៤.២. ពង្រីក និងពង្រឹងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- អត្រាសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទាន ប.ស.ស. លើចំនួនសហគ្រាសសរុប យ៉ាងតិចចំនួន ៩៩% ត្រឹមឆ្នាំ២០២៣
- កម្រិតគុណភាពសេវារបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព មានការកើនឡើង
- កម្មករនិយោជិតថ្មីយ៉ាងតិចចំនួន ៥០ ០០០នាក់/ឆ្នាំ ត្រូវបានចុះបញ្ជី
- ចំនួនមន្ត្រីផ្តល់សេវាផ្នែកថែទាំសុខភាព និងសមាជិក ប.ស.ស.
- អាត្រាចំណាយរដ្ឋបាលផ្នែកថែទាំសុខភាពធៀបនឹងសមាជិក ប.ស.ស.
- ប្រព័ន្ធតាមដានប្រវត្តិកម្មករនិយោជិតដែលជាសមាជិក ប.ស.ស. ដែលទទួលបញ្ហាសុខភាពត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតផ្នែកថែទាំសុខភាព ត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីសាធារណៈ ដែលជាសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពត្រូវបានរៀបចំ ត្រឹមឆ្នាំ ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណាត់ថ្នាក់សេវារបស់ដៃគូ ប.ស.ស. ត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២១។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

២. ពង្រឹងយន្តការនៃកាអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

៣. ពង្រីកសេវារបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដល់សមាជិក ប.ស.ស.

៤. បង្កើនការយល់ដឹងអំពីរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

៥. រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ ក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម និង បេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងអង្គភាពពាក់ព័ន្ធដូចជា ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍វិស័យការងារ ត្រូវប្រឹក្សាយោបល់ជាមួយគ្នា សំដៅកែលម្អការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ និងធ្វើ បច្ចុប្បន្នភាពនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និង ឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៤.៣. ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- និវត្តន៍ជនទទួលបាននូវប្រាក់សោធនតាមច្បាប់កំណត់
- អត្រាចំណាយរដ្ឋបាលផ្នែកប្រាក់សោធនធៀបនឹងសមាជិក ប.ស.ស.
- សមាមាត្រមន្ត្រី ប.ស.ស. ផ្នែកប្រាក់សោធនធៀបនឹងសមាជិក ប.ស.ស.
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យនិវត្តន៍ជនដែលជាសមាជិក ប.ស.ស. ផ្នែកប្រាក់សោធនត្រូវបានរៀបចំ ត្រឹមឆ្នាំ ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យលើ សហគ្រាស គ្រឹះស្ថានផ្នែកប្រាក់សោធនត្រូវបានរៀបចំត្រឹមឆ្នាំ២០២០
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យការទាមទារប្រាក់សោធនត្រូវបានអភិវឌ្ឍត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

២. រៀបចំយន្តការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

៣. សិក្សាសមិទ្ធលទ្ធភាពនៃការពង្រីកវិសាលភាពសម្រាប់របបប្រាក់សោធនស្ម័គ្រចិត្តស្របតាម ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

៤. បង្កើនការយល់ដឹងអំពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន

៥. រៀបចំយន្តការតាមដាន និងវាយតម្លៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គម និងក្រុមការងារ ពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវប្រឹក្សាយោបល់ជាមួយគ្នា សំដៅកែលម្អការធ្វើផែនការ សកម្មភាពប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នភាពនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្តដើម្បីធ្វើ ជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៤.៤. ពង្រីកការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ចំនួនសមាជិក ប.ស.ស. នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះបញ្ជី ត្រូវបានធ្វើបច្ចុប្បន្នភាពទៅជាសមាជិកក្នុងប្រព័ន្ធជារៀងរាល់ឆ្នាំ
- នីតិវិធី និងឯកសារនៃការចុះបញ្ជី ត្រូវបានផ្សព្វផ្សាយ។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. បង្កើនការផ្សព្វផ្សាយអំពីនីតិវិធី និងឯកសារចាំបាច់នានាសម្រាប់ការចុះបញ្ជី

២. ពង្រឹងការចុះបញ្ជី និងការផ្តល់ប័ណ្ណដល់កម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៣. ពង្រឹងយន្តការបើកផ្តល់គោលរបបឧបត្ថម្ភដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុងនិងក្រៅប្រព័ន្ធ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ អនុភូមិ ជំនួយការភូមិជាស្ត្រី ពេលសម្រាលកូន។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គម និងក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវប្រឹក្សាយោបល់ជាមួយគ្នា សំដៅកែលម្អការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នភាពនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៤.៥. អភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ប្រព័ន្ធគ្រប់គ្រង ប.ស.ស. ស្របតាមគោលការណ៍អភិបាលកិច្ចល្អ ត្រូវបានពង្រឹង
- ការគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពការងារ ត្រូវបានពង្រឹង
- ការវិនិយោគ និងនិរន្តរភាពហិរញ្ញវត្ថុរបស់ ប.ស.ស. ត្រូវបានធានាសមត្ថភាពឆ្លើយតបរបស់ ប.ស.ស. ទៅនឹងការកើនឡើងនៃតម្រូវការសេវា ត្រូវបានលើកកម្ពស់។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបេឡាជាតិរបបសន្តិសុខសង្គមដែលស្របតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥

២. ពង្រីកសមត្ថភាព និងលទ្ធភាពផ្តល់សេវាគាំទ្រដល់សមាជិក

៣. សិក្សាសមិទ្ធិលទ្ធភាពនៃការពង្រីកវិសាលភាពកម្មករនិយោជិតក្រៅប្រព័ន្ធ

៤. ពង្រឹងគណៈកម្មការវិនិយោគមូលនិធិសន្តិសុខសង្គម/ក្រុមប្រឹក្សាធនាភិបាល

៥. ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាលើការផ្លាស់ប្តូរតាវកាលិករបបសន្តិសុខសង្គម

៦. បង្កើនសមត្ថភាពមន្ត្រី ប.ស.ស. ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពនៃការដឹកនាំ និងផ្តល់សេវា

៧. ពង្រឹងយន្តការផ្តល់ព័ត៌មានដោយសាធារណជន។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវប្រឹក្សាយោបល់ជាមួយគ្នា សំដៅកែលម្អការធ្វើផែនការសកម្មភាពប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នភាពនូវចំណុចប្រឈមថ្មីៗ ដែលអាចកើតឡើងនាពេលអនុវត្ត ដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពខាងលើនេះអង្គភាពដែលពាក់ព័ន្ធត្រូវ÷

▪ រៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃផែនការសកម្មភាពនៃកម្មវិធីនេះដើម្បីកំណត់នូវសូចនាករវាស់នូវសមិទ្ធកម្មប្រចាំឆ្នាំ និងកំណត់ផែនការសកម្មភាពប្រចាំឆ្នាំតាមរយៈកំណត់ឱ្យមានរបាយការណ៍និងស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដោយមានបញ្ជាក់ពីការវិវឌ្ឍនៃសូចនាករនីមួយៗ។

▪ រៀបចំអនុវត្តថវិកាតាមកម្មវិធីដើម្បីបន្ស៊ីផែនការសកម្មភាពក្នុងកម្មវិធីនីមួយៗទៅនឹងផែនការយុទ្ធសាស្ត្រចំណាយរយៈពេលមធ្យមរបស់ក្រសួង សំដៅបង្កើនប្រសិទ្ធភាពចំណាយថវិកា និងភាពអាចព្យាករណ៍បាននៃប្រភពធនធានថវិកា។

▪ រៀបចំគម្រោងថវិកាជូនរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិដើម្បីស្នើសុំហិរញ្ញប្បទាន និងជំនួយបច្ចេកទេសសម្រាប់ទិញសម្ភារបរិក្ខារ និងមធ្យោបាយសំដៅលើកស្ទួយសមត្ថភាពអង្គភាពក្នុងការបំពេញភារកិច្ច។

▪ រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលទទួលភារកិច្ចចាត់តាំងឱ្យអនុវត្តសកម្មភាពអាទិភាពក្នុងកម្មវិធីនីមួយៗ។

## ៣.៥- ការពង្រឹងសេវាគាំទ្រទូទៅ

ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ លើការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ ការពង្រឹងអភិបាលកិច្ចវិស័យឯកជន និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាគន្លឹះសំខាន់មួយដែលរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ នឹងធ្វើឱ្យការអនុវត្តការងារកាន់តែមានគុណភាព សមត្ថភាព និងផលិតភាព សំដៅពង្រឹងគុណភាពនៃការផ្តល់សេវា

សាធារណៈឱ្យកាន់តែមានភាពល្អប្រសើរ។ ក្នុងអាណត្តិថ្មីនេះ ក្រសួងបន្តយកចិត្តទុកដាក់លើការងារអភិបាលកិច្ចល្អ ដោយបន្តពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីសម្រេចបាននូវការធ្វើទំនើបកម្មស្ថាប័នក្រសួង និងការអភិវឌ្ឍប្រកបដោយភាពបរិយាប័ន្ន ការលើកកម្ពស់ និងការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ ការធានានិរន្តរភាពនៃតួនាទី និងពង្រឹងសមត្ថភាពនៃដំណើរការវិស័យសាធារណៈ ការលើកកម្ពស់គុណាធិបតេយ្យ។

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងយុទ្ធសាស្ត្រនេះ រួមមាន÷

- ប្រព័ន្ធរដ្ឋបាលហិរញ្ញវត្ថុ និងតាមដានវាយតម្លៃត្រូវបានពង្រឹង
- សមត្ថភាពមន្ត្រីក្នុងការឆ្លើយតប តម្រូវការសាធារណៈត្រូវបានពង្រឹង
- ប្រព័ន្ធធ្វើតេស្តសមត្ថភាពមន្ត្រីដោយបច្ចេកទេសព័ត៌មានវិទ្យា ក្រោយពេលវិក្រឹត្យការ ត្រូវបានអនុវត្តត្រឹមត្រីមាសទី ៣ ឆ្នាំ២០១៩
- កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុវត្ត
- តួនាទី និងសមត្ថភាពអង្គភាព ត្រូវបានពង្រឹង
- កិច្ចសហប្រតិបត្តិការគ្រប់ផ្នែក និងគ្រប់ដៃគូជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងពង្រីក
- របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៩-២០២៣ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ត្រូវបានធ្វើទៀងទាត់តាមកាលកំណត់
- ដំណោះស្រាយលើចំណុចប្រឈម និងសំណូមពរត្រូវបានរកឃើញ និងដោះស្រាយទាន់ពេលតាមរយៈយន្តការពិនិត្យ តាមដាន វាយតម្លៃ ប្រចាំឆមាស និងប្រចាំឆ្នាំ
- ការត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រ ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានធ្វើជាទៀងទាត់។

ដើម្បីសម្រេចសូចនាករយុទ្ធសាស្ត្រខាងលើ ក្រសួងបានកំណត់នូវកម្មវិធីអាទិភាពចំនួន ៥ ដូចខាងក្រោម÷

### ៣.៥.១. ពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ប្រសិទ្ធភាពការងាររដ្ឋបាលត្រូវបានពង្រឹង
- សមត្ថភាពស្ថាប័នត្រូវបានពង្រឹង

- ឥរិយាបថ សីលធម៌ វិន័យ ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវរបស់មន្ត្រីត្រូវបានលើកកម្ពស់
- សេវាសាធារណៈក្នុងវិស័យការងារ និងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ត្រឹមឆ្នាំ២០២០
- កម្រងសេវាសាធារណៈទាំងអស់ត្រូវបានបញ្ជូន ទៅច្រកទ្វារ អេឡិចត្រូនិច ផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway) របស់ក្រសួងមុខងារសាធារណៈ
- សេវាសាធារណៈនៅថ្នាក់ជាតិត្រូវ បានផ្តល់តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ជាអតិបរិមា ត្រឹមឆ្នាំ២០២៣។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ដំណើរការប្រព័ន្ធគ្រប់គ្រងឯកសារចេញ ចូលរបស់ក្រសួង ដើម្បីតាមដានលំហូរឯកសារ និងគ្រប់គ្រងឯកសារកាលប្បវត្តិ

២. រៀបចំចងក្រងគំរូលិខិត និងនីតិវិធី ក្នុងការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ប្រើប្រាស់ឱ្យមានការឯកភាពគ្នានៅតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង

៣. បន្តបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ ទាន់ពេលវេលាកំណត់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល

៤. ពង្រឹងយន្តការគ្រប់គ្រងមន្ត្រីរាជការតាមអង្គភាពនានាក្រោមឱវាទក្រសួង ស្របតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា

៥. បន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបនឹងតម្រូវការអ្នកទទួលសេវានៅទីស្តីការក្រសួង

៦. បន្តរៀបចំវិភាគ និងពិពណ៌នាមុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការ ដោយកំណត់តាមតួនាទី ភារកិច្ច និងកម្រិត សញ្ញាបត្រជំនាញ

៧. បន្តអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅបង្កើនប្រសិទ្ធភាពការងារ និងបង្កិតការផ្តល់សេវាឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋ ស្របតាមកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

៨. ធ្វើឱ្យកាន់តែប្រសើរសេវារដ្ឋបាល និងសេវាផ្សេងៗ ជូនដល់មន្ត្រីរាជការរបស់ក្រសួងដើម្បីលើកកម្ពស់ផលិតភាព គុណភាព និងប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ

៩. បង្កើនសាមគ្គីភាពផ្ទៃក្នុងតាមបណ្តាអង្គភាពនានា ដើម្បីលើកកម្ពស់ស្មារតីការងារជាក្រុម និងសុខដុមនីយកម្មក្នុងការបំពេញការងារ

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានីខេត្ត ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ គ្រប់អង្គភាពពាក់ព័ន្ធ និងក្រុមការងារច្រកចេញចូលតែមួយ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗដែលអាចកើតឡើងនាពេលអនុវត្តធ្វើជាមូលដ្ឋាន ដើម្បីកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៥.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- ការគ្រប់គ្រងធនធានដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រនានា ត្រូវបានពង្រឹង
- ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានរៀបចំទាន់ពេល និងគ្រប់ជ្រុងជ្រោយ
- ផែនការថវិកាត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាព
- សិក្សាលទ្ធភាពការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅតាមអង្គភាពថវិកាត្រូវបានពង្រីក។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយផ្សារភ្ជាប់ជាមួយគោលបំណង គោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង និងបន្តកែលម្អគម្រោងថវិកាកម្មវិធី ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២. ពង្រឹងយន្តការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីសេវាសាធារណៈដោយកំណត់កម្រិតលំអៀងកើនឡើងឬថយចុះ ១០ភាគរយ

៣. ពង្រឹងការអនុវត្តចំណាយ ឱ្យកាន់តែមានស័ក្តិសិទ្ធភាព គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពស្របតាមកម្មវិធីអាទិភាពរបស់ក្រសួងដោយកំណត់កម្រិតលំអៀងកើនឡើងឬថយចុះ៥ភាគរយ

៤. ពង្រឹងការអនុវត្តនីតិលទ្ធកម្មសាធារណៈ ឱ្យកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងទាន់ពេលវេលា

៥. ពង្រឹងការរៀបចំបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅគ្រប់អង្គភាពក្រោមឱវាទក្រសួង

៦. ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)

៧. ពង្រឹង និងពង្រីក អង្គភាពថវិកា និងគាំទ្រអង្គភាពហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងប្រកបដោយគណនេយ្យភាព និងតម្លាភាព។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រខាងលើនេះ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ អង្គភាពលទ្ធកម្ម គ្រប់អង្គភាពថវិកា គ្រប់អង្គភាពប្រមូលចំណូលថ្នាក់កណ្តាល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ និងក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការអនុវត្តនូវសកម្មភាពការងារដែលបានដាក់ចេញ សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗដែលអាចកើតឡើងនាពេលអនុវត្តធ្វើជាមូលដ្ឋាន ដើម្បីកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៥.៣. អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- មេរៀន និងម៉ូឌុលសម្រាប់អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់ផ្នែកត្រូវបានចងក្រង និងអនុម័តឱ្យប្រើប្រាស់
- លិខិតបទដ្ឋានគោលនយោបាយ និងកិច្ចព្រមព្រៀងផ្សេងៗ ត្រូវបានរៀបចំស្របតាមទម្រង់ និងនីតិវិធី
- បញ្ជីតម្រូវការលិខិតបទដ្ឋានគតិយុត្តគោលនយោបាយ និងកិច្ចព្រមព្រៀង ត្រូវបានធ្វើការសិក្សា និងចងក្រង
- គុណភាព និងយន្តការគ្រប់គ្រងស្ថិតិត្រូវបានពង្រឹង
- គុណភាពកសាង ផែនការគោលយោបាយ និងផែនការនានារបស់ក្រសួងត្រូវបានពង្រឹង
- ការគ្រប់គ្រងឋាបនភ័ណ្ឌព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធឌីជីថលព័ត៌មានវិទ្យាក្នុងអង្គភាពក្រោមឱវាទក្រសួងត្រូវបានពង្រឹង
- ប្រព័ន្ធតេស្តសមត្ថភាពសិក្ខាកាម ដោយប្រព័ន្ធបច្ចេកវិទ្យាក្រោយពេលវិក្រឹត្យការ ត្រូវបានអភិវឌ្ឍត្រឹមត្រីមាសទី៣ ឆ្នាំ២០២០
- ប្រព័ន្ធរបាយការណ៍ឌីជីថល(Digital Reporting System) ត្រូវបានដាក់ឱ្យប្រើប្រាស់ត្រឹមឆ្នាំ២០២០។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំបង្កើតគណៈកម្មការវិក្រឹត្យការ និងអភិវឌ្ឍសមត្ថភាពមន្ត្រី
២. រៀបចំចងក្រងគ្រូបង្គោលទៅតាមជំនាញ និងតាមវិស័យដើម្បីបណ្តុះបណ្តាលនិងបង្កើនសមត្ថភាពមន្ត្រី
៣. ពង្រឹងសមត្ថភាពថ្នាក់ដឹកនាំអង្គភាព រួមមានអគ្គនាយកដ្ឋាន នាយកដ្ឋាន គ្រឹះស្ថាន អ.ប.វ និងមន្ទីរ
៤. ពង្រឹងសមត្ថភាពមន្ត្រីដែលរងប្រតិបត្តិការ
៥. ពង្រឹងគុណភាព និងយន្តការគ្រប់គ្រងស្ថិតិ
៦. ជំរុញការកសាង និងគ្រប់គ្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
៧. ពង្រឹងគុណភាពកសាងផែនការ គោលនយោបាយ និងផែនការនានារបស់ក្រសួង

៨. ពង្រឹងការប្រមូលផ្តុំ និងគ្រប់គ្រងព័ត៌មាន សៀវភៅ ឯកសារផ្សេងៗពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៩. បន្តពង្រឹងការគ្រប់គ្រងឋាបនភ័ណ្ឌព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធឌីជីថលព័ត៌មានវិទ្យាក្នុងអង្គភាពក្រោមឱវាទក្រសួង។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម នាយកដ្ឋានវិវាទការងារ នាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន ក្រុមការងារកសាងច្បាប់ និងគណៈកម្មការវិក្រឹត្យការគ្រប់អង្គភាពពាក់ព័ន្ធ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត និងក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុង សំដៅប្រមូលនូវចំណុចប្រឈមថ្មីៗ ដែលអាចលេចឡើងនាពេលអនុវត្តដើម្បីធ្វើជាមូលដ្ឋានកែសម្រួល និងឆ្លើយតបភ្លាមៗ ឬត្រៀមធ្វើជាធាតុចូលក្នុងផែនការយុទ្ធសាស្ត្រនាពេលខាងមុខ។

### ៣.៥.៤. ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷
- កិច្ចសហប្រតិបត្តិការជាមួយដៃគូត្រូវបានពង្រឹង និងពង្រីក
- ក្រុមការងារយេនឌ័រ និងសេវាសង្គមត្រូវបានពង្រឹង។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷
១. បន្តកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសហប្រជាជាតិ ដើម្បីលើកកម្ពស់សិទ្ធិ និងលក្ខខណ្ឌការងារ
២. បន្តជំរុញការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ និងអនុសាសន៍របស់អង្គការអន្តរជាតិខាងការងារ
៣. បន្តពង្រឹងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន និងកម្រិតទ្វេភាគី-ពហុភាគី ពាក់ព័ន្ធនឹងវិស័យការងារ និងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៤. ពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទ ពាក់ព័ន្ធនឹងកិច្ចការងារ ILO អាស៊ាន និងបដិសណ្ឋារកិច្ច
៥. ធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ និងកិច្ចប្រជុំជាតិ-អន្តរជាតិនានា
៦. ពង្រឹងយន្តការប្រមូល ចងក្រង និងតាមដានការអនុវត្តសេចក្តីថ្លែងការណ៍ កិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលក្រសួងបានចុះហត្ថលេខា និងលទ្ធផលនៃការអនុវត្ត
៧. លើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៨. ពង្រឹងយន្តការគណៈកម្មការ និងក្រុមការងារសេវាសង្គមផ្សេងៗដែលក្រសួងជាសមាជិក។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ គណៈកម្មការយេនឌ័រ ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងក្រុមការងារផ្សេងៗ ត្រូវសហការគ្នាយ៉ាងជិតស្និទ្ធដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ ដើម្បីកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

### ៣.៥.៥. ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

សូចនាករដែលត្រូវសម្រេចឱ្យបាននៅក្នុងកម្មវិធីនេះ រួមមាន÷

- តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព នៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រនីមួយៗត្រូវបានពង្រឹង
- អភិក្រមទាំង៥ និងបាវចនា២ ត្រូវបានអនុវត្ត
- យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣ ត្រូវបានបង្កើតនៅឆ្នាំ២០១៩។

ដើម្បីសម្រេចនូវសូចនាករខាងលើ ក្រសួងបានកំណត់នូវចង្កោមសកម្មភាពអាទិភាពដូចខាងក្រោម÷

១. រៀបចំឱ្យមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់គ្រប់អង្គភាពក្រោមឱវាទក្រសួង

២. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព

៣. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការផ្តល់សេវាសាធារណៈ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៤. បន្តចុះធ្វើអធិការកិច្ច និងសវនកម្ម ដោយមានពីរប្រតិភូរួមគ្នា ដើម្បីត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផ.យ.អ.ក.ប ២០១៩-២០២៣ របស់ក្រសួង និងពិនិត្យ សម្រុះសម្រួល ដោះស្រាយវិវាទរដ្ឋបាលនានា។

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើនេះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម ក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ និងគ្រប់អង្គភាពពាក់ព័ន្ធត្រូវសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ ដើម្បីកែសម្រួល និងឆ្លើយតបភ្លាមៗតាមស្ថានភាពការងារចាំបាច់។

ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រអាទិភាពខាងលើនេះ អង្គភាពពាក់ព័ន្ធត្រូវ÷

▪ ក្រសួងត្រូវរៀបចំក្រុមការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃ ផែនការសកម្មភាពនៃកម្មវិធីនេះ ដើម្បីកំណត់នូវសូចនាករវាស់នូវសមិទ្ធកម្មប្រចាំឆ្នាំ និងកំណត់ផែនការសកម្មភាពប្រចាំឆ្នាំ តាមរយៈកំណត់ឱ្យមានរបាយការណ៍ និងស្ថិតិប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដោយមានបញ្ជាក់ពីការវិវឌ្ឍន៍នៃសូចនាករនីមួយៗ

▪ រៀបចំអនុវត្តថវិកាតាមកម្មវិធី ដើម្បីបន្សុំផែនការសកម្មភាពក្នុងកម្មវិធីនីមួយៗទៅនឹងផែនការយុទ្ធសាស្ត្រចំណាយរយៈពេលមធ្យមរបស់ក្រសួង សំដៅបង្កើនប្រសិទ្ធភាពចំណាយថវិកា និងភាពអាចព្យាករណ៍បាននៃប្រភពធនធានថវិកា

▪ រៀបចំគម្រោងថវិកាជូនរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ដើម្បីស្នើសុំហិរញ្ញប្បទាន និងជំនួយបច្ចេកទេស សម្រាប់ទិញសម្ភារ បរិក្ខារ និងមធ្យោបាយ សំដៅលើកស្ទួយសមត្ថភាពអង្គភាពក្នុងការបំពេញភារកិច្ច

▪ រៀបចំកែលម្អប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការ ដែលទទួលភារកិច្ចចាត់តាំងឱ្យអនុវត្តសកម្មភាពអាទិភាពក្នុងកម្មវិធីនីមួយៗ។

# ជំពូកទី ៤

## ការគៀរគរប្រភពធនធានហិរញ្ញវត្ថុ

ដើម្បីអាចឱ្យផែនការសកម្មភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចអនុវត្តប្រកបដោយជោគជ័យ និងសម្រេចបានទៅតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ការផ្តល់នូវធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងទាន់ពេលវេលាពីស្ថាប័នជាតិ និងដៃគូអភិវឌ្ឍន៍នានាគឺជាកត្តាចាំបាច់បំផុត។

ចំពោះវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ) ថវិកាជាតិដែលទទួលបានពុំអាចធានាបានតាមតម្រូវការនៃការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ បានទេ ព្រោះតម្រូវការនៃការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញមានការកើនឡើង។ ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃការកសាងកម្លាំងពលកម្មជំនាញដែលប្រកបដោយសមត្ថភាព គុណភាព និងផលិតភាពការងារស្របតាមតម្រូវការនៃទីផ្សារការងារ គឺចាំបាច់ត្រូវមានប្រភពហិរញ្ញវត្ថុគ្រប់គ្រាន់។ ដូចនេះ ក្រៅពីថវិកាជាតិដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលបានកិច្ចសហការពីដៃគូជាតិនិងអន្តរជាតិ ស្ថាប័នពាក់ព័ន្ធ សហគមន៍ មាតាបិតា សមាគមវិជ្ជាជីវៈ អង្គការមិនមែនរដ្ឋាភិបាល និងជាពិសេស គឺវិស័យឯកជនទាំងឡាយ ដែលមានតម្រូវការកម្លាំងពលកម្មជំនាញ ក្នុងការផ្តល់នូវធនធានហិរញ្ញវត្ថុ ជំនួយបច្ចេកទេស និងឱកាសកម្មសិក្សាសម្រាប់សិស្សនិស្សិតនៃវិស័យ អ.ប.វ គឺជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ ក៏ដូចជាការអភិវឌ្ឍកម្លាំងពលកម្មជំនាញសម្រាប់បំពេញតម្រូវការសេដ្ឋកិច្ចកម្ពុជាផងដែរ។

ដោយឡែកយោងតាមអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម ប្រភពធនធាននៃ ប.ស.ស. មាន÷

- ធនធានដំបូងដែលរដ្ឋផ្តល់សម្រាប់ការបង្កើត ប.ស.ស.
- ការផ្ទេរក្នុងលក្ខណៈ ជាអន្តរាគមន៍សាធារណៈដែលមានចែងក្នុងថវិការដ្ឋ ដូចជាឧបត្ថម្ភធនធានសម្រាប់ដំណើរការ និងឧបត្ថម្ភធនធានជាមូលធន
- ភាគទានរបស់សមាជិកនៃ ប.ស.ស. និងនិយោជកដែលទុកសម្រាប់ហិរញ្ញប្បទានលើផ្នែកនីមួយៗ នៃរបបសន្តិសុខសង្គម
- ប្រាក់ពិន័យពីការយឺតយ៉ាវក្នុងការបង់ភាគទាន ឬការផ្តល់តារាងបៀវត្សព្រមទាំងការប្រាក់ពីការយឺតយូរនេះ។
- ផលចំណេញដែលបានមកពីការវិនិយោគ
- អំណោយ និងបច្ច័យទានផ្សេងៗ
- ប្រភពធនធានផ្សេងៗទៀតដែល ប.ស.ស. អាចទទួលបានស្របតាមច្បាប់។

ដោយអនុលោមតាមអនុក្រឹត្យខាងលើនេះ បេឡាជាតិរបបសន្តិសុខសង្គមមានប្រភពធនធានហិរញ្ញវត្ថុមួយដ៏ច្បាស់លាស់ និងមានភាពរឹងមាំ។ តាមរយៈដំណើរការដំបូងចាប់តាំងពីឆ្នាំ២០០៨ រហូតមកដល់ពេលនេះ ប.ស.ស. បានទទួលនូវប្រភពធនធានហិរញ្ញវត្ថុមួយចំនួន រួមមានការឧបត្ថម្ភពីសំណាក់រាជរដ្ឋាភិបាលសម្រាប់កិច្ចដំណើរការដំបូង ប្រាក់ភាគទានពីសមាជិករបស់ ប.ស.ស. ប្រាក់ពិន័យពីការមិនចុះបញ្ជិកា ឬការយឺតយ៉ាវក្នុងការបង់ភាគទាន និងធនធានហិរញ្ញវត្ថុជាជំនួយបច្ចេកទេសរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា។

# ជំពូកទី ៥

## ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រ

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ជាប្រចាំលើសកម្មភាពនានា ដែលអនុវត្តដោយអង្គភាពក្រោមឱវាទក្រសួង គឺជាភារកិច្ចដ៏មានសារៈសំខាន់នៃដំណើរការអនុវត្តផែនការ ដើម្បីធានាការសម្រេចបាននូវគោលដៅ និងចំណុចការងារអាទិភាពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភានេះ។ វិធីសាស្ត្រតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវប្រើប្រាស់ដើម្បីចង្អុលបង្ហាញយកនូវសមិទ្ធកម្មចម្បងៗ បញ្ហាប្រឈមក្នុងការអនុវត្តយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ គឺជាយន្តការផ្តល់ព័ត៌មានដ៏សំខាន់មួយ សម្រាប់ការតម្រង់ទិសអនុវត្តផែនការយុទ្ធសាស្ត្រ និងសម្រាប់ថ្នាក់ដឹកនាំក្រសួងធ្វើការកែតម្រូវឡើងវិញ និងដាក់ចេញនូវវិធានការអន្តរាគមន៍ទៅតាមដំណាក់កាលនីមួយៗ សំដៅសម្រេចបាននូវគោលដៅគោលនយោបាយដែលបានកំណត់។

ការកំណត់នូវសូចនាករ និងចំណុចដៅសំខាន់ៗសម្រាប់តាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ គឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការការងារ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ សូចនាករ និងចំណុចដៅសំខាន់ៗសម្រាប់ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ត្រូវបំពេញលក្ខខណ្ឌវិនិច្ឆ័យចំនួនពីរ គឺ ៖(១) សូចនាករ និងចំណុចដៅដែលស្នើឡើងត្រូវអាចវាស់វែងបាន ហើយត្រូវធានាថា ទិន្នន័យផ្នែកបរិមាណ និងគុណភាពអាចប្រមូលបានតាមពេលកំណត់ និងត្រូវបានវិភាគទាន់ពេលវេលាសម្រាប់យកមកប្រើប្រាស់ (២) អង្គភាពក្រោមឱវាទក្រសួងត្រូវកំណត់ និងយល់ព្រមធ្វើជាអ្នកទទួលខុសត្រូវក្នុងការតាមដាន និងវាយតម្លៃលើការវិវឌ្ឍន៍ប្រែប្រួលនៃសូចនាករ និងចំណុចទាំងនោះ។

ដើម្បីធានាវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមួយនឹងត្រូវបង្កើតឡើង ដើម្បីតាមដានរាល់ការអនុវត្តរបស់គ្រប់អង្គភាពពាក់ព័ន្ធទាំងអស់នៅក្នុងក្រសួង។ ឈរលើមូលដ្ឋាននេះ ក្រសួងនឹងរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃមួយសម្រាប់គាំទ្រដល់ការអនុវត្ត ដែលរួមមាន៖

- ប្រព័ន្ធរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យលើលទ្ធផលនៃការអនុវត្ត បញ្ហាប្រឈម ដោយផ្អែកលើយុទ្ធសាស្ត្រ កម្មវិធី សកម្មភាព និងសូចនាករគោលដៅដែលបានកំណត់ និងធ្វើការសម្រេចចិត្តក្នុងការដាក់ចេញនូវវិធានការបន្ទាន់ចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះមុខដែលកើតឡើងនាពេលអនុវត្ត។
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ អំពីវឌ្ឍនភាពពាក់កណ្តាលអាណត្តិនៅ ឆ្នាំ២០២១ ដើម្បីជាមូលដ្ឋាននៃការកែតម្រូវ និងតម្រង់ទិសការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃវឌ្ឍនភាពអាណត្តិនៅខែធ្នូ នៅឆ្នាំ២០២៣។



ឃ/

# ជំពូកទី ៦

## សេចក្តីសន្និដ្ឋាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការដឹកនាំ និងការតម្រង់ទិសគោលនយោបាយប្រកបដោយគតិបណ្ឌិតរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានរៀបចំ និងដាក់ចេញនូវ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** ដែលជាអភិក្រមដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រកបដោយចីរភាពភាពបរិយាប័ន្ន និងដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយនានារបស់ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ដែលបានរំលេចក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤**។ ការចងក្រងនូវផែនការនេះ ត្រូវបានរៀបចំដោយផ្អែកលើសមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨។ ផែនការយុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់លើទិដ្ឋភាពគ្រប់ជ្រុងជ្រោយ ដោយផ្តោតលើគ្រប់សមាសភាពពាក់ព័ន្ធ ដើម្បីធានាសម្រេចបាននូវចក្ខុវិស័យ បេសកកម្ម គោលបំណង និងគោលដៅគោលនយោបាយដែលខ្លួនបានកំណត់។ យុទ្ធសាស្ត្រអាទិភាពដែលបានដាក់ចេញ នឹងរួមចំណែកដល់ការរក្សាបាននូវស្ថិរភាពសង្គម ការអភិវឌ្ឍ ខណៈពេលដែលកម្ពុជាត្រូវសម្របសម្រួលខ្លួនទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ចតំបន់ និងពិភពលោក ពិសេសនៅក្នុងបរិការណ៍នៃសកលភាវូបនីយកម្ម ការវិវឌ្ឍប្រែប្រួលដោយអវិជ្ជមាននៃកត្តាផលិតកម្មទាំងក្នុង និងក្រៅប្រទេស ព្រមជាមួយគ្នានេះ ក៏ដើម្បីចាប់យកនូវកាលានុវត្តភាពនានានៃសេដ្ឋកិច្ចសកលផងដែរ។ ផែនការយុទ្ធសាស្ត្រនេះ នឹងជំរុញដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យនៃរាជរដ្ឋាភិបាល ក្នុងការកែប្រែកម្ពុជាពីប្រទេសមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។

តាមរយៈនេះ ការដាក់ចេញនូវ ផ.យ.អ.ក.ប ២០១៩-២០២៣ សំដៅផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ និងយន្តការមួយជាក់លាក់សម្រាប់ការចូលរួមចំណែកការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ ការបង្កើតឱកាសការងារប្រកបដោយសមធម៌ និងការពង្រឹងមូលដ្ឋានកំណើនសេដ្ឋកិច្ចថ្មី។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានជំនឿយ៉ាងមុតមាំថា អង្គភាពក្រោមឱវាទក្រសួងទាំងអស់នឹងជំនះនូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយ ដើម្បីឈានទៅអនុវត្តដោយជោគជ័យ នឹងទទួលបាននូវសមិទ្ធផលគួរជាទីមោទនៈថ្មីថែមទៀត ជូនរាជរដ្ឋាភិបាល ប្រជាជាតិ និងប្រជាជនកម្ពុជា។

ជារួម ដើម្បីធានានូវវឌ្ឍនភាព និងប្រសិទ្ធភាពនៃការអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** អង្គភាពគ្រប់កម្រិតក្រោមឱវាទក្រសួងទាំងអស់ ត្រូវច្បិចយកយុទ្ធសាស្ត្រ កម្មវិធី ចង្កោមសកម្មភាព និងសូចនាករដែលបានកំណត់ ទៅរៀបចំជាផែនការសកម្មភាពសម្រាប់ការអនុវត្តប្រចាំរបស់អង្គភាព ដើម្បីធានាថា ការអនុវត្តនឹងត្រូវរត់ទៅតាមទិសដៅមួយជាក់លាក់ដែលក្រសួងបាន



ង

កំណត់ទុកដើម្បីសម្រេចនូវចក្ខុវិស័យ និងគោលបំណងគោលនយោបាយរបស់ក្រសួង។ ជាមួយគ្នានេះ ក្រសួងនឹងបង្កើតនូវយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើផែនការសកម្មភាព ដោយមានការរៀបចំប្រព័ន្ធរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យវឌ្ឍនភាព បញ្ហាប្រឈម ធានាវេទយិតភាព និងដាក់ចេញនូវវិធានការអន្តរាគមន៍ដ៏រស់រវើកចាំបាច់នានាជាបន្ទាន់ ដើម្បីជាមូលដ្ឋានកែតម្រូវ និងតម្រង់ទិសសម្រាប់ការអនុវត្តជំហានបន្ទាប់។

## ឧបសម្ព័ន្ធ ១ ៖ គំនូសបំព្រួញក្របខ័ណ្ឌនៃ ផ.យ.អ.ក.ប ២០១៩-២០២៣



## ឧបសម្ព័ន្ធ ២ ÷ សូចនាករស្តីពីការតាមដានត្រួតពិនិត្យការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ | | | | | | | | | |
| | | ១.ក. អត្រាសហគ្រាស គ្រឹះស្ថាន ដែលមិនអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារមានការថយចុះ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -អគ្គ.ការងារ<br>-ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |
| | | ១.ខ. ទម្រង់ធ្ងន់ធ្ងរបំផុតនៃកម្លាំងពលកម្មកុមារនិងការងារដោយបង្ខំ ត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំ | ទម្រង់ធ្ងន់ធ្ងរ | - | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | -អគ្គ.ការងារ<br>-ន.ការងារកុមារ<br>-មន្ទីរ ក.ប |
| | | ១.គ. របាយការណ៍អធិការកិច្ចការងារត្រូវបានទទួលស្គាល់កាន់តែទូលំទូលាយ | របាយការណ៍ | - | ទទួលស្គាល់ | ទទួលស្គាល់ | ទទួលស្គាល់ | ទទួលស្គាល់ | ទទួលស្គាល់ | -អគ្គ.ការងារ<br>-ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |
| | | ១.ឃ. ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិតត្រូវបានពិភាក្សា និងកំណត់ជាប្រចាំ | ប្រាក់ឈ្នួលអប្បបរមា | កំណត់ | ពិភាក្សានិងកំណត់ | ពិភាក្សានិងកំណត់ | ពិភាក្សានិងកំណត់ | ពិភាក្សានិងកំណត់ | ពិភាក្សានិងកំណត់ | -អ.ក.ជ.ប.អ<br>-មន្ទីរ ក.ប |
| | | ១.ង. អត្រាវិវាទការងារធៀបជាមួយនឹងកម្មករនិយោជិតត្រូវបានថយចុះរៀងរាល់ឆ្នាំ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ន.វិវាទ<br>-មន្ទីរ ក.ប |
| | | ១.ច. អត្រាវិវាទការងារដែលផ្សះផ្សាសះជាដោយមន្ត្រីផ្សះផ្សាយ៉ាងតិច ៥០% | % | ៤៥ | ៥០ | ៥៥ | ៥៥ | ៥៥ | ៥៥ | -ន.វិវាទ |
| | | ១.ឆ. កិច្ចព្រមព្រៀងផ្សះផ្សាវិវាទការងារដោយមន្ត្រីផ្សះផ្សាវិវាទ ត្រូវបានគោរព និងអនុវត្ត | កិច្ចព្រមព្រៀង | - | គោរព និងអនុវត្ត | គោរព និងអនុវត្ត | គោរព និងអនុវត្ត | គោរព និងអនុវត្ត | គោរព និងអនុវត្ត | -ន.វិវាទ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ១. ជ. សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានគោរព និងអនុវត្តអនុលោមតាមនីតិវិធីជាធរមាន | សេចក្តីបង្គាប់ | - | គោរព និង អនុវត្ត | គោរពនិង អនុវត្ត | គោរពនិង អនុវត្ត | គោរពនិង អនុវត្ត | គោរពនិង អនុវត្ត | -ន.វិវាទ<br>-ន.អធិការកិច្ច |
| | | ១. ឈ. អត្រានៃកម្មករនិយោជិតដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.មុខរបរ<br>-ន.អធិការកិច្ច<br>-ប.ស.ស |
| | | ១. ញ. ស្ថិតិសហជីពធៀបនឹងចំនួនសហគ្រាសគ្រឹះស្ថានដែលចុះបញ្ជីនៅក្រសួងត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -ន.វិវាទ |
| | | ១. ដ. ស្ថិតិកម្មករនិយោជិតជាសមាជិកសហជីពធៀបជាមួយកម្មករនិយោជិតដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -ន.វិវាទ |
| | | ១. ឋ. អត្រាកម្មករនិយោជិតដែលដួលសន្លប់ធៀបជាមួយកម្មករនិយោជិតក្នុងវិស័យនៅមានការថយចុះ | អត្រា ដួលសន្លប់ | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ន.អធិការកិច្ច<br>-ន.ពេទ្យការងារ |
| | | ១. ឌ. កូដកម្ម-បាតុកម្ម ត្រូវបានដោះស្រាយដោយសន្តិវិធី តម្លាភាព និងគណនេយ្យភាពស្របតាមច្បាប់ | ករណី កូដកម្ម | - | បាន ដោះស្រាយ | បាន ដោះស្រាយ | បាន ដោះស្រាយ | បាន ដោះស្រាយ | បាន ដោះស្រាយ | -អ.គ.ក.ប |
| **១.១** | **លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង** | | | | | | | | | |
| | | ១.១.១. អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌស្នូល ៣១ ចំណុច មានការថយចុះ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -អគ្គ.ការងារ<br>-ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ១.១.២.អត្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលរំលោភលើលក្ខខណ្ឌ ៤១ចំណុច មានការថយចុះ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |
| | | ១.១.៣.សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ មន្ត្រីអធិការកិច្ចការងារត្រូវបានពង្រឹង | សមត្ថភាព និង ក្រមសីលធម៌ | - | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | -ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |
| | | ១.១.៤.តម្លាភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានពង្រឹង | តម្លាភាព និង ប្រសិទ្ធភាព | - | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | -ក្រុមអធិការកិច្ចការងារ<br>-មន្ទីរ ក.ប |
| | | ១.១.៥ រៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្មការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (IT Platform) ត្រូវបានដាក់ឱ្យនៅត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | - | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ក្រុមអធិការកិច្ចការងារ<br>-ក្រសួងស្ថាប័នពាក់ព័ន្ធ<br>-មន្ទីរ ក.ប |
| | | ១.១.៦ ក្រុមអធិការកិច្ចអន្តរស្ថាប័នដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់សហគ្រាស គ្រឹះស្ថាន ត្រូវបានដាក់ឱ្យនៅត្រឹមឆ្នាំ ២០២០ | សេវា | - | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ក្រុមអធិការកិច្ចការងារ<br>-ក្រសួងស្ថាប័នពាក់ព័ន្ធ<br>-មន្ទីរ ក.ប |
| **១.២** | **ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ** | | | | | | | | | |
| | | ១.២.១.អត្រានៃសហគ្រាសនាំចេញដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអនុលោមតាមស្តង់ដាស្តូលសុវត្ថិភាព និងសុខភាពការងារមានការកើនឡើងយ៉ាងតិច ៨០% នៅឆ្នាំ២០២៣ (កន្លងទៅបានបំពេញបែបបទ ប៉ុន្តែអនុវត្តមិនគ្រប់តាមស្តង់ដា) | % | ៤៦ | យ៉ាងតិច ៦៥ | យ៉ាងតិច ៦៥ | យ៉ាងតិច ៧០ | យ៉ាងតិច ៧៥ | យ៉ាងតិច ៨០ | -ន.ពេទ្យការងារ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ១.២.២.អគ្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលបានបំពេញបែបបទស្របតាមស្តង់ដាសុវត្ថិភាព និងសុខភាព ការងារ ស្ទួលចំនួន ៩០% ត្រឹមឆ្នាំ២០២២ | % | ៦០ | ៨០ | ៨៥ | ៨៥ | ៩០ | ៩០ | -ន.ពេទ្យការងារ |
| | | ១.២.៣.អគ្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានប្រអប់សង្គ្រោះលើប្រភេទសហគ្រាសដែលត្រូវមានប្រអប់សង្គ្រោះ | % | ៩០ | ៩៥ | ៩៦ | ៩៧ | ៩៨ | ៩៨ | -ន.ពេទ្យការងារ |
| | | ១.២.៤.អគ្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានបន្ទប់រំរបួស លើប្រភេទសហគ្រាស ដែលត្រូវមានបន្ទប់រំរបួស | % | ៩០ | ៩៥ | ៩៦ | ៩៧ | ៩៨ | ៩៨ | -ន.ពេទ្យការងារ |
| | | ១.២.៥.អគ្រាសហគ្រាស គ្រឹះស្ថាននាំចេញដែលមានគិលានដ្ឋាន លើប្រភេទសហគ្រាស ដែលត្រូវមានគិលានដ្ឋាន | % | ៨៨ | ៩០ | ៩២ | ៩៤ | ៩៦ | ៩៨ | -ន.ពេទ្យការងារ |
| | | ១.២.៦.អគ្រាសហគ្រាស គ្រឹះស្ថាន នាំចេញដែលមានរៀបចំកន្លែងហូបបាយ | % | ៣៣ | ៤៥ | ៥០ | ៥៥ | ៦០ | ៧០ | -ន.ពេទ្យការងារ |
| | | ១.២.៧.ការវាយតម្លៃអំពីមូលដ្ឋានគោលនៃលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ត្រូវបានធ្វើជារៀងរាល់ ២ឆ្នាំ/ម្តង ចាប់ផ្តើមពីឆ្នាំ២០២១ | ដង | - | សិក្សា រៀបចំ | សិក្សា រៀបចំ | ១ | - | ១ | -ន.ពេទ្យការងារ<br>-ប.ស.ស<br>-ន.ផែនការ |
| | | ១.២.៨ទម្រង់របាយការណ៍គ្រូពេទ្យសហគ្រាស និងដាក់ឱ្យដំណើរការប្រព័ន្ធរាយការណ៍ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មដោយគ្រូពេទ្យសហគ្រាស ត្រូវបានរៀបចំត្រឹមឆ្នាំ ២០២០ | ប្រព័ន្ធ | សិក្សា រៀបចំ | សិក្សា រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.ពេទ្យការងារ<br>-ប.ស.ស<br>-ន.ផែនការ |



ﾐ/

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **១.៣** | **ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ** | | | | | | | | | |
| | | ១.៣.១. ស្ថិតិកុមារអាយុពី ១៥ដល់ ១៧ឆ្នាំ ដែលបានចូលរួមក្នុងពលកម្មកុមារត្រូវបានផលិត | ស្ថិតិ | - | សិក្សា រៀបចំ | ផលិត | ផលិត | ផលិត | ផលិត | -វិ.ជាតិស្ថិតិ<br>-ន.ការងារកុមារ |
| | | ១.៣.២. អត្រានៃចំនួនពលកម្មកុមារដែលស្ថិតក្នុងទម្រង់ធ្ងន់ធ្ងរត្រូវបានកាត់បន្ថយជាពិសេសក្នុងផ្នែក សំណង់ ឡឥដ្ឋ និងកសិឧស្សាហកម្ម ត្រូវបានកាត់បន្ថយ | % | - | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | កាត់បន្ថយ | -ន.ការងារកុមារ |
| | | ១.៣.៣. ផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (២០១៦-២០២៥) ត្រូវបានអនុវត្តតាមដាន និងវាយតម្លៃ | ផែនការ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.ការងារកុមារ |
| | | ១.៣.៤ និយោជកដែលប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារ និងការងារដោយបង្ខំ ត្រូវទទួលការពិន័យ និងផ្តន្ទាទោស | ពិន័យ និង ផ្តន្ទាទោស | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | -ន.ការងារកុមារ |
| **១.៤** | **ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត** | | | | | | | | | |
| | | ១.៤.១. ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ជាទៀងទាត់ | ប្រាក់ឈ្នួល អប្បបរមា | បានកំណត់ | កំណត់ | កំណត់ | កំណត់ | កំណត់ | កំណត់ | -អ.ក.ជ.ប.អ |
| | | ១.៤.២. លទ្ធភាពពង្រីកវិសាលភាពនៃប្រាក់ឈ្នួលអប្បបរមា ត្រូវបានសិក្សា | វិសាលភាព | សិក្សា | សិក្សា | សិក្សា | សិក្សា | បានកំណត់ អត្តសញ្ញាណ | បានកំណត់ អត្តសញ្ញាណ | -អ.ក.ជ.ប.អ<br>-អង្គការ ILO<br>-អង្គការវិជ្ជាជីវៈ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ១.៤.៣. យន្តការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមាត្រូវបានពង្រឹង និងដំណើការដោយរលូន | យន្តការ | បានពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | -អ.ក.ជ.ប.អ |
| | | ១.៤.៤. អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករត្រូវបានសិក្សា និងកែលម្អតាមការចាំបាច់ | អត្ថប្រយោជន៍ផ្សេងៗ | - | សិក្សា | សិក្សា និងកែលម្អ | សិក្សា និងកែលម្អ | សិក្សា | សិក្សា | -អ.ក.ជ.ប.អ |
| | | ១.៤.៥. ស្ថិតិសហគ្រាស គ្រឹះស្ថាន ដែលផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗប្រសើរឡើង ធៀបនឹងសហគ្រាស គ្រឹះស្ថាន ដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -អ.ក.ជ.ប.អ |
| **១.៥** | **ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ** | | | | | | | | | |
| | | ១.៥.១. អត្រាដោះស្រាយវិវាទការងារបុគ្គល សះជានៅកម្រិតមន្ត្រីផ្សះផ្សា យ៉ាងតិច ៥០% ចាប់ពីឆ្នាំ២០២០ | % | ៤៥% | យ៉ាងតិច ៤៨% | យ៉ាងតិច ៥០% | យ៉ាងតិច ៦០% | យ៉ាងតិច ៥៨% | យ៉ាងតិច ៥៨% | -ន.វិវាទ |
| | | ១.៥.២. អត្រាវិវាទការងាររួមសះជានៅកម្រិតមន្ត្រីផ្សះផ្សា យ៉ាងតិច ៥០% ចាប់ពីឆ្នាំ២០២០ | % | ៤៥% | យ៉ាងតិច ៤៨% | យ៉ាងតិច ៥០% | យ៉ាងតិច ៥៥% | យ៉ាងតិច ៥៥% | យ៉ាងតិច ៥៥% | -ន.វិវាទ |
| | | ១.៥.៣. អត្រាអនុលោមតាមសេចក្តីបង្គាប់ជាប់កាតព្វកិច្ចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានការកើនឡើងជារៀងរាល់ឆ្នាំ | % | - | យ៉ាងតិច ៩០% | យ៉ាងតិច ៩០% | យ៉ាងតិច ៩០% | យ៉ាងតិច ៩៥% | យ៉ាងតិច ៩៥% | -ន.វិវាទ<br>-ក្រុមអធិការកិច្ចការងារ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ១.៥.៤. ស្ថិតិសហគ្រាសគ្រឹះស្ថានមានវិវាទធៀបនឹងចំនួន សហគ្រាសគ្រឹះស្ថានសរុប ដែលបានចុះបញ្ជីនៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -ន.វិវាទ |
| | | ១.៥.៥. ស្ថិតិសហគ្រាស គ្រឹះស្ថានដែលមាន កូដកម្ម ធៀបនឹងសហគ្រាស គ្រឹះស្ថានសរុប ដែលបានចុះបញ្ជី នៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -ន.វិវាទ<br>-អ.ត.ក.ប |
| | | ១.៥.៦. ស្ថិតិសហគ្រាស គ្រឹះស្ថានដែលមាន បាតុកម្ម ធៀបនឹងសហគ្រាស គ្រឹះស្ថានសរុប ដែលបានចុះបញ្ជីនៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -អ.ត.ក.ប |
| | | ១.៥.៧. ស្ថិតិកូដកម្ម បាតុកម្ម ដែលត្រូវ បានដោះស្រាយបញ្ចប់ ត្រូវបានផលិត | ស្ថិតិ | - | ផលិត | ផលិត | ផលិត | ផលិត | ផលិត | -អ.ត.ក.ប |
| | | ១.៥.៨. មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានធានា | មូលនិធិ | - | បាន ធានា | បាន ធានា | បាន ធានា | បាន ធានា | បាន ធានា | -អ.ត.ក.ប |
| | | ១.៥.៩. សេវាក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវ បានពង្រីក | សេវា | - | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | -អ.ត.ក.ប |
| | | ១.៥.១០ ប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការ វិជ្ជាជីវៈ អនុសញ្ញារួម និងការដោះស្រាយ វិវាទការងារគ្រប់ដំណាក់កាល ត្រូវបាន ដាក់ឱ្យដំណើរការពេញលេញត្រឹមឆ្នាំ ២០២០ | ប្រព័ន្ធ | សិក្សា រៀបចំ | សិក្សា រៀបចំ | ដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ | -ន.វិវាទ<br>-ន.ផែនការ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ២ | **ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | | | | | | | | | |
| | | ២.ក. សិស្ស និស្សិត ដែលចូលរៀនក្នុងវិស័យអាទិភាពសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (CQF2) ដល់សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស (CQF5) នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជនមានការកើនឡើង យ៉ាងតិច ២០%/ឆ្នាំ | % | - | យ៉ាងតិច ១០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ខ. អត្រាសិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការសិក្សា អ.ប.វ មានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.គ. អត្រាសិក្ខាកាម សិស្ស និស្សិតដែលបញ្ចប់ការបណ្តុះបណ្តាល មានការងារធ្វើមានការកើនឡើងជារៀងរាល់ឆ្នាំ | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ឃ. សិក្ខាកាមវគ្គខ្លី ដែលបញ្ចប់ការបណ្តុះបណ្តាលមានចំណូល កើនឡើងលឿនជាងប្រជាពលរដ្ឋក្នុងសហគមន៍ដែលមិនទទួលបានការបណ្តុះបណ្តាល | ចំណូល | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ<br>-NEA |
| | | ២.ង. កម្មវិធីបណ្តុះបណ្តាលជំនាញឡើងវិញ (Reskilling) ត្រូវបានរៀបចំ | កម្មវិធី | - | សិក្សារៀបចំ | បានរៀបចំ | បានរៀបចំ | បានរៀបចំ | បានរៀបចំ | -អគ្គ.អ.ប.វ<br>-NEA |
| | | ២.ច. អគារបណ្តុះបណ្តាល និងមន្ទីរពិសោធន៍លើជំនាញអាទិភាពត្រូវ បានសាងសង់ និងធ្វើទំនើបកម្ម | អគារ និង មន្ទីរ ពិសោធន៍ | - | - | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | -អគ្គ.អ.ប.វ<br>-អគ្គ.រដ្ឋបាល |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | ២.ធ. ស្ថិតិស្នាដៃស្រាវជ្រាវដែលត្រូវបានយកទៅប្រើប្រាស់ក្នុងឧស្សាហកម្ម | ស្ថិតិ | - | សិក្សារៀបចំ | បានផលិត | បានផលិត | បានផលិត | បានផលិត | -អគ្គ.អ.ប.វ<br>- NEA |
| | | ២.ជ. អត្រានៃការពេញចិត្តរបស់និយោជកលើសិក្ខាកាម សិស្ស និស្សិត ចេញពី អ.ប.វ មានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | - NEA |
| | | ២ឈអត្រាសិក្ខាកាមសិស្សនិស្សិតដែលពេញចិត្តនឹងវគ្គបណ្តុះបណ្តាលមានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | - NEA |
| | | ២.ញ. អត្រាវគ្គបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) ធៀបនឹងវគ្គបណ្តុះបណ្តាលសរុប មានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ដ. ចំនួនមនុស្សចូលធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុន និងសមត្ថភាពបច្ចុប្បន្ន (RPL និង RCC) មានការកើនឡើង | ចំនួន | - | - | - | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.ស្តង់ដា<br>-ន.ធានាគុណភាព<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ឋ. អត្រាយុវជន (អាយុ១៥-២៤ឆ្នាំ) ដែលគ្មានការអប់រំ គ្មានការងារធ្វើ ឬគ្មានការបណ្តុះបណ្តាលមានការថយចុះ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ឌ. អត្រាអ្នកចុះឈ្មោះចូលរៀន (អាយុ ១៥-២៤ឆ្នាំ) សរុបនៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ មានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.ឍ. ចំនួនយុវជននៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំពុងហាត់ការក្នុងវិស័យការងារ (ការហ្វឹកហ្វឺនកូនជាង/កម្មសិក្សា) មានការកើនឡើង | % | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថាន អ.ប.វ<br>-NEA |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ២.ណ រៀបចំផែនការមេសម្រាប់អភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅត្រឹមឆ្នាំ២០២០ | ផែនការ | - | សិក្សា រៀបចំ | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.បណ្តុះបណ្តាល<br>-ន.គ្រប់គ្រង<br>-ន.ហិរញ្ញវត្ថុ<br>-គ្រឹះស្ថាន អ.ប.វ |
| **២.១** | **ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | | | | | | | | | |
| | | ២.១.១. សិស្ស និស្សិតបានចុះទស្សនកិច្ចសិក្សាតាមសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន ១០%/ឆ្នាំ | % | - | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | -ន. ព័ត៌មានទីផ្សារ<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.១.២. លិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័តយ៉ាងតិចចំនួន ២០ ត្រឹមឆ្នាំ២០២៣ | ចំនួន | - | យ៉ាងតិច៥ | យ៉ាងតិច៥ | យ៉ាងតិច៥ | យ៉ាងតិច៥ | យ៉ាងតិច៥ | -អគ្គ.អ.ប.វ<br>-គណៈកម្មការកសាងច្បាប់ |
| | | ២.១.៣. គ្រូបច្ចេកទេសបានធ្វើវិក្រឹត្យការនៅតាមសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន ១០%/ឆ្នាំ | % | - | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | យ៉ាងតិច ១០% | -ន.ធានាគុណភាព<br>-គ្រឹះស្ថាន អ.ប.វ<br>-វិស័យឯកជន |
| | | ២.១.៤. កញ្ចប់ស្តង់ដាបណ្តុះបណ្តាលត្រូវបានអភិវឌ្ឍ យ៉ាងតិចចំនួន១៨៨ គុណវុឌ្ឍិ ត្រឹមឆ្នាំ២០២៣ | ចំនួន គុណវុឌ្ឍិ | ១២ | យ៉ាងតិច ១៦ | យ៉ាងតិច ៣២ | យ៉ាងតិច ៤២ | យ៉ាងតិច ៤៩ | យ៉ាងតិច ៤៩ | -ន.ស្តង់ដា<br>-ន.ធានាគុណភាព<br>-គ្រឹះស្ថាន អ.ប.វ<br>-ដៃគូ<br>-វិស័យឯកជន |
| | | ២.១.៥. អត្រាគំលាតតម្លៃឯកតាបណ្តុះបណ្តាល (Unit cost) នៃគ្រឹះស្ថាន អ.ប.វ សាធារណៈ និងឯកជនមានការថយចុះ | % | - | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ន.ធានាគុណភាព<br>-ន.បណ្តុះបណ្តាល |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ២.២ | ពង្រីកការបណ្តុះបណ្តាលជំនាញដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម | | | | | | | | | |
| | | ២.២.១.អត្រាសិស្សដែលបានបញ្ចប់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ ២ ៣(CQF2 3 4) បានកើនឡើងយ៉ាងតិច ២០%/ឆ្នាំ | % | - | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថានឯកជន |
| | | ២.២.២.អត្រានិស្សិតដែលបានបញ្ចប់សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស (CQF5) បានកើនឡើង យ៉ាងតិច ២០%/ឆ្នាំ | % | - | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | យ៉ាងតិច ២០% | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល<br>-គ្រឹះស្ថានឯកជន |
| | | ២.២.៣.អត្រាសិក្ខាកាមដែលបានបញ្ចប់វគ្គខ្លីតាមជំនាញអាទិភាពបានកើនឡើង | % | - | កើន ឡើង | កើន ឡើង | កើន ឡើង | កើន ឡើង | កើន ឡើង | -ន.ព័ត៌មានទីផ្សារ<br>-ន.បណ្តុះបណ្តាល |
| ២.៣ | ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានា ដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | | | | | | | | |
| | | ២.៣.១.គ្រឹះស្ថាន អ.ប.វ បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសហគ្រាស គ្រឹះស្ថាន យ៉ាងតិចចំនួន១៥MoU/ឆ្នាំ | ចំនួន | - | យ៉ាងតិច ១៥ | យ៉ាងតិច ១៥ | យ៉ាងតិច ១៥ | យ៉ាងតិច ១៥ | យ៉ាងតិច ១៥ | -ន.គ្រប់គ្រង<br>-ដៃគូ |
| | | ២.៣.២.គោលនយោបាយលើកទឹកចិត្តផ្នែកសារពើពន្ធផ្សារភ្ជាប់ និងការបណ្តុះបណ្តាលធនធានមនុស្សត្រូវបានអនុវត្ត ត្រឹមឆ្នាំ២០២០ | គោល នយោបាយ | - | សិក្សា រៀបចំ | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.គោលនយោបាយ<br>-ដៃគូ |
| ២.៤ | លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | | | | | | | | |
| | | ២.៤.១. លិខិតបទដ្ឋានគតិយុត្ត ត្រូវបានអភិវឌ្ឍយ៉ាងតិចចំនួន ៥ ត្រឹមឆ្នាំ២០២១ | ឯកសារ | - | ២ | រៀបចំបន្ថែម ២ និងអនុវត្ត | រៀបចំបន្ថែម ១ និងអនុវត្ត | អនុវត្ត | អនុវត្ត | -ន.គ្រប់គ្រង<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.៤.២. សមត្ថភាពថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន អ.ប.វ មន្ត្រីប្រតិបត្តិ និងមន្ត្រីគ្រឹះស្ថាន អ.ប.វ ត្រូវបានពង្រឹង | សមត្ថភាព | - | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | ត្រូវ បានពង្រឹង | -ខុទ្ទកាល័យ<br>-អគ្គ.អ.ប.វ<br>-វិ.ជាតិការងារ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | ២.៤.៣.ទិន្នន័យប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា អ.ប.វ (TVETMIS) ត្រូវបានបញ្ចូលត្រឹមត្រូវពេញលេញ និងប្រើប្រាស់ជាផ្លូវការ | ទិន្នន័យ | មាន ទិន្នន័យ | មាន ទិន្នន័យ | មាន ទិន្នន័យ | មាន ទិន្នន័យ | មាន ទិន្នន័យ | មាន ទិន្នន័យ | -ន.ព័ត៌មានទីផ្សារ<br>-គ្រឹះស្ថាន អ.ប.វ |
| | | ២.៤.៤. របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តគោល នយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (NTVET) ឆ្នាំ២០១៧-២០២៥ ប្រចាំឆ្នាំត្រូវបានរៀបចំ និងដាក់ជូនរាជរដ្ឋាភិបាលទៀងទាត់តាមការកំណត់ | ចំនួន របាយ ការណ៍ | - | ១ | ១ | ១ | ១ | ១ | -ន.គោលនយោបាយ<br>-គ្រប់អង្គភាព |
| ២.៥ | **ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍** | | | | | | | | | |
| | | ២.៥.១.ចំនួនគម្រោងស្រាវជ្រាវដែលបានបញ្ចប់ដោយជោគជ័យ នៅឆ្នាំ២០២៣ | គម្រោង | - | សិក្សា ស្រាវជ្រាវ | សិក្សា ស្រាវជ្រាវ | មាន គម្រោង | មាន គម្រោង | មាន គម្រោង | -អគ្គ.អ.ប.វ<br>-ដៃគូ |
| | | ២.៥.២.ចំនួនអ្នកស្រាវជ្រាវដែលចូលរួមមានការកើនឡើង នៅឆ្នាំ២០២៣ | នាក់ | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -អគ្គ.អ.ប.វ<br>-ដៃគូ |
| | | ២.៥.៣.ចំនួនស្នាដៃស្រាវជ្រាវដែលត្រូវបានយកទៅប្រើប្រាស់ក្នុងឧស្សាហកម្ម នៅឆ្នាំ២០២៣ | ចំនួន | - | សិក្សា ស្រាវជ្រាវ | សិក្សា ស្រាវជ្រាវ | សិក្សា ស្រាវជ្រាវ | សិក្សា ស្រាវជ្រាវ | ប្រើប្រាស់ | -អគ្គ.អ.ប.វ<br>-ដៃគូ |
| ៣ | **ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុងនិងក្រៅប្រទេស** | | | | | | | | | |
| | | ៣.ក.អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជនសរុប (អាយុ ១៥ឆ្នាំឡើង) ត្រូវបានរក្សាមិនឱ្យធ្លាក់ក្រោម ៧៨% | % | ៨០.៣% | ៧៨% | ៧៨% | ៧៨% | ៧៨% | ៧៨% | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៣.ខ.អត្រាគ្មានការងារធ្វើសរុប (អាយុ ១៥ ឆ្នាំឡើង) ត្រូវបានរក្សាមិនឱ្យលើស ២% | % | ២% | ២% | ២% | ២% | ២% | ២% | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.គ.អត្រាគ្មានការងារធ្វើរបស់យុវជន (អាយុពី១៥-២៤ ឆ្នាំ) ត្រូវបានរក្សាមិនឱ្យលើស ៣% | % | ៣% | ៣% | ៣% | ៣% | ៣% | ៣% | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.ឃ.អត្រាគម្លាតចូលរួមកម្លាំងពលកម្មរវាង ស្ត្រីធៀបនឹងបុរស ត្រូវបានកាត់បន្ថយ | % | - ១០.៤% | គម្លាតថយចុះ | គម្លាតថយចុះ | គម្លាតថយចុះ | គម្លាតថយចុះ | គម្លាតថយចុះ | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.ង.អត្រាកម្មករ-និយោជិត ដែលទទួលបានប្រាក់ឈ្នួលធៀបនឹងអ្នកមានការងារធ្វើសរុប មានការកើនឡើង | % | ៤៩.៧% | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.ច.អត្រាអ្នកមានការងារធ្វើក្នុងវិស័យក្រៅពីកសិកម្មធៀបនឹងអ្នកមានការងារធ្វើសរុប មានការកើនឡើង | % | ៦១.៨% | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -NEA<br>-វិ.ជាតិការងារ<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.ឆ.ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរនិងការងារត្រូវបានពង្រឹង | ប្រសិទ្ធភាព | - | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -លេ.NEP<br>-អគ្គ.ការងារ<br>-គ្រប់អង្គភាព<br>-មន្ទីរ ក.ប |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៣.ជ.កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា និងកម្មវិធីរបស់ដៃគូ ត្រូវបានធ្វើសមាហរណកម្ម និងអនុវត្ត | កម្មវិធី | - | បាន សមាហរណកម្ម | បាន សមាហរណកម្ម | បាន សមាហរណកម្ម | បាន សមាហរណកម្ម | បាន សមាហរណកម្ម | -អគ្គ.ការងារ<br>-អគ្គ.អ.ប.វ<br>-មន្ទីរ ក.ប |
| | | ៣.ឈ.ព័ត៌មានទីផ្សារការងារត្រូវបានផ្សព្វផ្សាយកាន់តែទូលាយដល់គ្រប់គោលដៅ | ព័ត៌មាន | ដល់ គោលដៅ | ដល់ គោលដៅ | ដល់ គោលដៅ | ដល់ គោលដៅ | ដល់ គោលដៅ | ដល់ គោលដៅ | -NEA<br>-ន.មុខរបរ |
| | | ៣.ញ.សេវាកម្មស្វែងរកការងារធ្វើសាធារណៈត្រូវបានពង្រឹង និងពង្រីក | សេវាកម្ម | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | -NEA<br>-ន.មុខរបរ |
| | | ៣.ដ.ការចូលរួមវេទិកាការងារ និងផលិតភាពការងារត្រូវបានកើនឡើង | ការចូលរួម | - | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -NEA |
| | | ៣.ឋ.ការគ្រប់គ្រងស្ថិតិ និងចលនាបុគ្គលិកត្រូវបានពង្រឹង | ការគ្រប់គ្រងស្ថិតិ | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | បាន ពង្រីក | -ន.មុខរបរ<br>-ន.ផែនការ |
| | | ៣.ឌ.ការគ្រប់គ្រងមុខរបរ និងការងាររបស់កម្មករនិយោជិតបរទេសត្រូវបានពង្រឹង | ការ គ្រប់គ្រង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -ន.មុខរបរ |
| | | ៣.ឍ.ការគាំទ្រ និងគាំពារពលករទេសន្តរប្រវេសន៍ខ្មែរ និងក្រុមគ្រួសារ ត្រូវបានពង្រឹង | ការគាំទ្រ និងគាំពារ | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -ន.មុខរបរ |
| | | ៣.ណ.ផលិតភាពកម្មករនិយោជិតត្រូវបានបង្កើនចាប់ពីឆ្នាំ២០២០ | ផលិតភាព | - | - | បង្កើន | បង្កើន | បង្កើន | បង្កើន | -ន.មុខរបរ |
| | | ៣.ត.សហគ្រាសនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធយ៉ាងតិចចំនួន ៥%/ឆ្នាំ ត្រូវបានចុះបញ្ជី | សហគ្រាស ចុះបញ្ជី | - | យ៉ាងតិច ៥% | យ៉ាងតិច ៥% | យ៉ាងតិច ៥% | យ៉ាងតិច ៥% | យ៉ាងតិច ៥% | -ឈ.NEP<br>-ន.អធិការកិច្ច |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៣.១ | បង្កើនឱកាសការងារសមរម្យ និងផលិតភាពការងារខ្ពស់ | | | | | | | | | |
| | | ៣.១.១.របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ (NEP) ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានរៀបចំ និងដាក់ជូនរាជរដ្ឋាភិបាលទៀងទាត់តាមការកំណត់ | របាយការណ៍ | ២ | ២ | ២ | ២ | ២ | ២ | -លេ. NEP<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.១.២.លេខាធិការដ្ឋានសម្រាប់អនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ត្រូវបានដំណើរការពេញលេញ | លេខាធិការដ្ឋាន | ដំណើរការ | កែលម្អដំណើរការ | ដំណើរការពេញលេញ | ដំណើរការពេញលេញ | ដំណើរការពេញលេញ | ដំណើរការពេញលេញ | -លេ. NEP<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.១.៣.ខេត្តដែលមានផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្ត គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ (NEP) ចំនួន ៤ ត្រូវបានជ្រើសរើស ក្នុងឆ្នាំ២០១៩ និងត្រូវបានបង្កើនយ៉ាងតិចចំនួន ១ ខេត្ត/ឆ្នាំ | ខេត្ត | - | ៤ | យ៉ាងតិច ១ | យ៉ាងតិច ១ | យ៉ាងតិច ១ | យ៉ាងតិច ១ | -លេ. NEP<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.១.៤.របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំលើការអនុវត្តកម្មវិធីការងារសមរម្យ សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ ត្រូវបានអនុម័ត | របាយការណ៍ | ១ | ១ | ១ | ១ | ១ | ១ | -លេ. NEP<br>-អគ្គ.ការងារ<br>-ន.ផែនការ |
| | | ៣.១.៥.វេទិកាដៃគូពាណិជ្ជកម្ម-អ្នកបញ្ជាទិញត្រូវបានរៀបចំជារៀងរាល់២ឆ្នាំម្តង | វេទិកា | - | បានរៀបចំ | បានរៀបចំ | បានរៀបចំ | បានរៀបចំ | បានរៀបចំ | -ន.សហប្រតិបត្តិការ<br>-លេ.ក្រុមការងារទី៨<br>-លេ.LAC |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៣.២ | ពង្រីកយន្តការ វិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារ ឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា | | | | | | | | | |
| | | ៣.២.១.សេវាការងារ និងព័ត៌មានទីផ្សារការងារ បានគ្របដណ្តប់ទូទាំងប្រទេសនៅត្រឹមឆ្នាំ២០២៣ | រាជធានី/ខេត្ត | ១៣ | ១៥ | ១៧ | ១៩ | ២១ | ២៤ | -NEA |
| | | ៣.២.២.អត្រាអ្នកចុះឈ្មោះស្វែងរកការងារ បានកើនឡើងជាមធ្យមយ៉ាងតិច 0,៥ ពិន្ទុ% រៀងរាល់ឆ្នាំធៀបនឹងចំនួនប្រជាជនដល់អាយុចូលធ្វើការ (300 000 នាក់/ឆ្នាំ) | % | ៥,៥% | ៦% | ៦,៧% | ៧,៣% | ៨,០% | ៨,៧% | -NEA |
| | | ៣.២.៣.អត្រាអ្នកបានការងារធ្វើ ត្រូវបានបង្កើន ១ពិន្ទុ% ធៀបនឹងចំនួនអ្នកចុះឈ្មោះស្វែងរកការងារធ្វើ | % | ៣៤% | ៣៦% | ៣៦% | ៣៧% | ៣៨% | ៣៩% | -NEA |
| | | ៣.២.៤.ចំនួនវិទ្យាល័យទូទាំងប្រទេស ដែលទទួលបានសេវាមគ្គុទ្ទេសន៍អាជីព មានការកើនឡើង | រាជធានី/ខេត្ត | ១៣ | ១៦ | ១៨ | ២០ | ២២ | ២៤ | -NEA |
| | | ៣.២.៥.អត្រានៃការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាមានការកើនឡើង ផ្អែកលើការធ្វើអង្កេតជារៀងរាល់ឆ្នាំ | % | - | កំណត់មូលដ្ឋានគោល | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -NEA |
| | | ៣.២.៦ ប្រព័ន្ធផ្តល់សេវាស្វ័យប្រវត្តិកម្មតាមប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន ត្រូវបានដាក់ឱ្យដំណើរការត្រឹមឆ្នាំ២០២១ | ប្រព័ន្ធ | - | សិក្សារៀបចំ | សិក្សារៀបចំ | បានដំណើរការ | បានដំណើរការ | បានដំណើរការ | -NEA |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| ៣.៣ | ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ | | | | | | | | | |
| | | ៣.៣.១. អត្រានៃចំនួនវេទិកាការងារថ្នាក់ជាតិ/មូលដ្ឋាន មានការកើនឡើង១០%/ឆ្នាំ | % | ៦០ | ១០% | ១០% | ១០% | ១០% | ១០% | -NEA |
| | | ៣.៣.២. អត្រាយល់ដឹងអំពីសេវាការងារ និងព័ត៌មានទីផ្សារការងារមានការកើនឡើង ផ្អែកលើការអង្កេតជារៀងរាល់ឆ្នាំ | % | - | កំណត់មូលដ្ឋានគោលត្រូវបានធ្វើ | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -NEA |
| | | ៣.៣.៣. ស្ថិតិព័ត៌មានទីផ្សារការងារត្រូវបានផលិតនិងផ្សព្វផ្សាយជាប្រចាំតាមការកំណត់ | ស្ថិតិ | - | ផលិតនិងផ្សព្វផ្សាយ | ផលិតនិងផ្សព្វផ្សាយ | ផលិតនិងផ្សព្វផ្សាយ | ផលិតនិងផ្សព្វផ្សាយ | ផលិតនិងផ្សព្វផ្សាយ | -NEA |
| ៣.៤ | ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ | | | | | | | | | |
| | | ៣.៤.១. ការផ្តល់សេវាប័ណ្ណ សៀវភៅការងារជនកម្ពុជាត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម | ប្រព័ន្ធ | - | បានរៀបចំនិងដាក់ឱ្យដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ | -ន.មុខរបរ |
| | | ៣.៤.២. ទិន្នន័យកម្មករនិយោជិតតាមសហគ្រាស គ្រឹះស្ថាន ត្រូវបានគ្រប់គ្រង ប្រសើរឡើង តាមរយៈប្រព័ន្ធទិន្នន័យ | ប្រព័ន្ធ | - | បានរៀបចំនិងដាក់ឱ្យដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ | ដំណើរការ | -ន.មុខរបរ |
| | | ៣.៤.៣. អត្រាអនុលោមតាមច្បាប់របស់សហគ្រាស គ្រឹះស្ថានដែលប្រើប្រាស់កម្លាំងពលកម្មបរទេសមានចំនួនយ៉ាងតិច ៩០% ត្រូវបានកើនឡើង ត្រឹមឆ្នាំ២០២៣ | % | ៨៥% | បានកើនដល់ ៨៦% | បានកើនដល់ ៨៧% | បានកើនដល់ ៨៨% | បានកើនដល់ ៨៩% | បានកើនដល់ ៩០% | -ន.មុខរបរ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | ៣.៤.៤. ទិន្នន័យពលករទេសន្តរប្រវេសន៍ខ្មែរ ត្រូវបានគ្រប់គ្រង និងដំណើរការប្រសើរឡើងតាមរយៈការពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម | ប្រព័ន្ធ | បាន ដំណើរការ | សិក្សា | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.មុខរបរ |
| | | ៣.៤.៥.ចំណូលពីអាករ និងកម្រៃសេវាលើប័ណ្ណ សៀវភៅការងារ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេសមានការកើនឡើងរៀងរាល់ឆ្នាំ | អាករ | - | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | -ន.មុខរបរ |
| | | ៣.៤.៦.ចំណូលពីអាករលើប័ណ្ណ សៀវភៅការងារជនកម្ពុជាមានការកើនឡើងរៀងរាល់ឆ្នាំ | អាករ | - | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | -ន.មុខរបរ |
| | | ៣.៤.៧.យន្តការគ្រប់គ្រងគាំទ្រ និងសមាហរណកម្មពលករទេសន្តរប្រវេសន៍ខ្មែរត្រូវបានពង្រឹង | យន្តការ | - | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | -ន.មុខរបរ<br>- MTOSB |
| | | ៣.៤.៨.ប្រាក់បញ្ញើត្រឡប់មកក្នុងប្រទេសរបស់ពលករទេសន្តរប្រវេសន៍ខ្មែរ ត្រូវបានកើនឡើងជារៀងរាល់ឆ្នាំ | ប្រាក់បញ្ញើ | - | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | បានកើន ឡើង | -ន.មុខរបរ |
| | | ៣.៤.៩ ប្រព័ន្ធស្វ័យប្រវត្តិកម្មដើម្បីគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ ដើម្បីបង្កើនប្រសិទ្ធភាព ការទទួលខុសត្រូវ ការតាមដាន និងគ្រប់គ្រងដំណើរការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ត្រូវបានដាក់ឱ្យអនុវត្តត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | - | សិក្សា រៀបចំ | សិក្សា រៀបចំ | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | -ន.មុខរបរ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៣.៥ | **បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ** | | | | | | | | | |
| | | ៣.៥.១. អត្រានៃចំនួនវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់ផលិតភាពការងារដល់កម្មករ-និយោជិត និយោជក និងអ្នកស្វែងរកការងារ កើនឡើងយ៉ាងតិច ៥%/ឆ្នាំ | % | ២៣០ | ៥% | ៥% | ៥% | ៥% | ៥% | - វិ.ជាតិការងារ<br>- NEA |
| | | ៣.៥.២. អត្រានៃការយល់ដឹងអំពីភាពចាំបាច់ និងសារៈសំខាន់នៃផលិតភាពការងារក្នុងចំណោម កម្មករ-និយោជិត និយោជក មានការកើនឡើង ផ្អែកលើការធ្វើអង្កេតជារៀងរាល់ឆ្នាំ | % | - | កំណត់មូលដ្ឋានគោល | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -វិ.ជាតិការងារ<br>- NEA |
| ៤ | **ការអភិវឌ្ឍរបបសន្តិសុខសង្គម** | | | | | | | | | |
| | | ៤.ក. អត្រាចំណាយរដ្ឋបាលធៀបនឹងសមាជិក ប.ស.ស | រៀល/នាក់ | ៣០ ៩៩៨ | ៤៥ ៥៣៣ | ៣៣ ៤៨៥ | ៣១ ៧០៨ | ៣០ ០៨២ | ២៨ ៥៩១ | -ប.ស.ស |
| | | ៤.ខ. ចំនួនមន្ត្រី ប.ស.ស ធៀបនឹងសមាជិក ប.ស.ស | មន្ត្រី/សមាជិក | ១/១ ០៤៣ | ១/៩០១ | ១/៨០០ | ១/៧២៣ | ១/៦៦៣ | ១/៦១៥ | -ប.ស.ស |
| | | ៤.គ. ករណីប្តឹងតវ៉ាពាក់ព័ន្ធនឹងសេវាដៃគូ ប.ស.ស ធៀបនឹងសមាជិក ប.ស.ស មានការថយចុះ | ករណី | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ប.ស.ស |
| | | ៤.ឃ. ករណីបណ្តឹងតវ៉ាពាក់ព័ន្ធនឹងសេវាដៃគូ ធៀបនឹងចំនួនសេវាដែលបានផ្តល់ | ករណី | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ប.ស.ស |
| | | ៤.ង. ករណីប្តឹងតវ៉ាពាក់ព័ន្ធនឹងសេវាគាំទ្ររបស់ ប.ស.ស ធៀបនឹងសមាជិក ប.ស.ស មានការថយចុះ | ករណី | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ប.ស.ស |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **៤.១** | **ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ** | | | | | | | | | |
| | | ៤.១.១.អត្រាសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទាន ប.ស.ស លើចំនួនសហគ្រាសសរុប យ៉ាងតិចចំនួន ៩៥% ត្រឹមឆ្នាំ ២០២៣ | % | ៩៦ | ៩៧ | ៩៨ | ៩៩ | ៩៩ | ៩៩ | -ប.ស.ស |
| | | ៤.១.២.កម្រិតគុណភាពសេវារបបសន្តិសុខសង្គមផ្នែកហានិភ័យការងារមានការកើនឡើង | គុណភាព | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ប.ស.ស |
| | | ៤.១.៣.សុវត្ថិភាពនៃការដឹកជញ្ជូនកម្មករនិយោជិតត្រូវបានពង្រឹង | សុវត្ថិភាព | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | -ប.ស.ស |
| | | ៤.១.៤.កម្មករនិយោជិតថ្មីយ៉ាងតិចចំនួន ៥០ ០០០នាក់/ឆ្នាំ ត្រូវបានចុះបញ្ជី | នាក់ | ៣០ ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | -ប.ស.ស |
| | | ៤.១.៥.ចំនួនមន្ត្រីផ្តល់សេវាផ្នែកហានិភ័យធៀបនឹងសមាជិក ប.ស.ស | មន្ត្រី/ សមាជិក | ១/១ ០៤៣ | ១/៩០១ | ១/៨០០ | ១/៧២៣ | ១/៦៦៣ | ១/៦១៥ | -ប.ស.ស |
| | | ៤.១.៦.អត្រាចំណាយរដ្ឋបាលផ្នែកហានិភ័យការងារធៀបនឹងសមាជិក ប.ស.ស | រៀល/ ១នាក់ | ៩ ២៩៩ | ១៥ ៩១៣ | ១១ ៧០២ | ១១ ០៨១ | ១០ ៥១៣ | ៩ ៩៩២ | -ប.ស.ស |
| | | ៤.១.៧ ប្រព័ន្ធតាមដានប្រវត្តិកម្មករនិយោជិតដែលជាសមាជិក ប.ស.ស ដែលទទួលគ្រោះថ្នាក់ការងារ ត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | ៣០% | រៀបចំ | អនុម័ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |
| | | ៤.១.៨ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីសាធារណៈ ដែលជាសមាជិក ប.ស.ស ផ្នែកហានិភ័យការងារ ត្រូវបានរៀបចំត្រឹមឆ្នាំ ២០២០ | ប្រព័ន្ធ | - | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៤.១.៩ ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណាត់ថ្នាក់សេវារបស់ដៃគូ ប.ស.ស ត្រូវបានរៀបចំត្រឹមឆ្នាំ២០២១ | ប្រព័ន្ធ | រៀបចំ | រៀបចំ | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | -ប.ស.ស |
| ៤.២ | ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព | | | | | | | | | |
| | | ៤.២.១.អត្រាសហគ្រាស គ្រឹះស្ថាន ដែលបានបង់ភាគទាន ប.ស.ស លើចំនួនសហគ្រាសសរុបយ៉ាងតិចចំនួន៩៩% ត្រឹមឆ្នាំ ២០២៣ | % | ៩៦ | ៩៧ | ៩៨ | ៩៩ | ៩៩ | ៩៩ | -ប.ស.ស |
| | | ៤.២.២.កម្រិតគុណភាពសេវារបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព មានការកើនឡើង | គុណភាព | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | កើនឡើង | -ប.ស.ស |
| | | ៤.២.៣.កម្មករនិយោជិតថ្មីយ៉ាងតិចចំនួន ៥០ ០០០នាក់/ឆ្នាំ ត្រូវបានចុះបញ្ជី | នាក់ | ៣០ ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | យ៉ាងតិច ៥ម៉ឺន | -ប.ស.ស |
| | | ៤.២.៤.ចំនួនមន្ត្រីផ្តល់សេវាផ្នែកថែទាំសុខភាព និងសមាជិក ប.ស.ស. | មន្ត្រី/សមាជិក | ១/១ ០៤៣ | ១/៩០១ | ១/៨០០ | ១/៧២៣ | ១/៦៦៣ | ១/៦១៥ | -ប.ស.ស |
| | | ៤.២.៥.អត្រាចំណាយរដ្ឋបាលផ្នែកថែទាំសុខភាពធៀបនឹងសមាជិក ប.ស.ស. | រៀល/ ១នាក់ | ១៨ ៥៩៩ | ២៤ ៧០៣ | ១៨ ១៦៧ | ១៧ ២០៣ | ១៦ ៣២១ | ១៥ ៥១២ | -ប.ស.ស |
| | | ៤.២.៦ ប្រព័ន្ធតាមដានប្រវត្តិកម្មករនិយោជិតដែលជាសមាជិក ប.ស.ស.ដែលទទួលបញ្ហាសុខភាពត្រូវបានរៀបចំ ត្រឹមឆ្នាំ ២០២០ | % | ៣០ | ៧០ | ១០០ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៤.២.៧ ប្រព័ន្ធគ្រប់គ្រងទិន្នន័យសហគ្រាស គ្រឹះស្ថាន និងកម្មករ និយោជិតផ្នែកថែទាំសុខភាព ត្រូវបានធ្វើបច្ចុប្បន្នកម្ម ជាប្រចាំ | ប្រព័ន្ធ | បាន បច្ចុប្បន្ន កម្ម | បច្ចុប្បន្ន កម្ម | បច្ចុប្បន្ន កម្ម | បច្ចុប្បន្ន កម្ម | បច្ចុប្បន្ន កម្ម | បច្ចុប្បន្ន កម្ម | -ប.ស.ស |
| | | ៤.២.៨ ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីសាធារណៈ ដែលជាសមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពត្រូវបានរៀបចំត្រឹមឆ្នាំ ២០២០ | ប្រព័ន្ធ | - | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |
| | | ៤.២.៩ ប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណាត់ថ្នាក់សេវារបស់ដៃគូ ប.ស.ស ត្រូវបាន រៀបចំ ត្រឹមឆ្នាំ២០២១ | ប្រព័ន្ធ | រៀបចំ | រៀបចំ | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | -ប.ស.ស |
| ៤.៣ | **ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន** | | | | | | | | | |
| | | ៤.៣.១.និវត្តន៍ជនទទួលបាននូវប្រាក់សោធនតាមច្បាប់កំណត់ | ប្រាក់ សោធន | រៀបចំ | បានទទួល | បានទទួល | បានទទួល | បានទទួល | បានទទួល | -ប.ស.ស |
| | | ៤.៣.២.អត្រាចំណាយរដ្ឋបាលផ្នែកប្រាក់សោធនធៀបនឹងសមាជិក ប.ស.ស | រៀល/ ១នាក់ | ៣ ១០០ | ៤ ៩១៧ | ៣ ៦១៦ | ៣ ៤២៤ | ៣ ២៤៨ | ៣ ០៨៧ | -ប.ស.ស |
| | | ៤.៣.៣.សមាមាត្រមន្ត្រី ប.ស.ស ផ្នែកប្រាក់សោធនធៀបនឹងសមាជិក ប.ស.ស | រៀល/ ១នាក់ | ១ ៥១៧ | ១ ៤៦៨ | ១ ៤២២ | ១ ៣៧៩ | ១ ៣៣៨ | ១ ៣០០ | -ប.ស.ស |
| | | ៤.៣.៤ ប្រព័ន្ធគ្រប់គ្រងទិន្នន័យនិវត្តន៍ជនដែលជាសមាជិក ប.ស.ស ផ្នែកប្រាក់សោធនត្រូវបានរៀបចំ ត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | - | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៤.៣.៥ ប្រព័ន្ធគ្រប់គ្រងទិន្នន័យលើសហគ្រាស គ្រឹះស្ថានផ្ញើកប្រាក់សោធន ត្រូវបានរៀបចំត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | - | រៀបចំ | បញ្ចប់ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |
| | | ៤.៣.៦ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការទាមទារប្រាក់សោធនត្រូវបានអភិវឌ្ឍ ត្រឹមឆ្នាំ២០២០ | % | ៦០ | ៨០ | ១០០ | អនុវត្ត | អនុវត្ត | អនុវត្ត | -ប.ស.ស |
| **៤.៤.** | **ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ** | | | | | | | | | |
| | | ៤.៤.១ ចំនួនសមាជិក ប.ស.ស នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចុះបញ្ជី ត្រូវបានធ្វើបច្ចុប្បន្នភាពទៅជាសមាជិកក្នុងប្រព័ន្ធជារៀងរាល់ឆ្នាំ | នាក់ | ១២ម៉ឺន | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | ថយចុះ | -ប.ស.ស |
| | | ៤.៤.២ នីតិវិធី និងឯកសារនៃការចុះបញ្ជីត្រូវបានផ្សព្វផ្សាយ | នីតិវិធី និងឯកសារ | - | បាន ផ្សព្វផ្សាយ | ផ្សព្វផ្សាយ | ផ្សព្វផ្សាយ | ផ្សព្វផ្សាយ | ផ្សព្វផ្សាយ | -ប.ស.ស |
| **៤.៥** | **អភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា** | | | | | | | | | |
| | | ៤.៥.១. ប្រព័ន្ធគ្រប់គ្រង ប.ស.ស ស្របតាមគោលការណ៍អភិបាលកិច្ចល្អ ត្រូវបានពង្រឹង | ប្រព័ន្ធ | បានពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | -ប.ស.ស |
| | | ៤.៥.២. ការគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពការងារ ត្រូវបានពង្រឹង | ការ គ្រប់គ្រង | បានពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | ពង្រឹង | -ប.ស.ស |
| | | ៤.៥.៣. ការវិនិយោគ និងនិរន្តរភាពហិរញ្ញវត្ថុរបស់ ប.ស.ស ត្រូវបានធានា | ការ វិនិយោគ | បានធានា | បានធានា | បានធានា | បានធានា | បានធានា | បានធានា | -ប.ស.ស |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៤.៥.៤.សមត្ថភាពឆ្លើយតបរបស់ ប.ស.ស ទៅនឹងការកើនឡើងនៃតម្រូវការសេវា ត្រូវបានលើកកម្ពស់ | ការឆ្លើយតប | លើកកម្ពស់ | លើកកម្ពស់ | លើកកម្ពស់ | លើកកម្ពស់ | លើកកម្ពស់ | លើកកម្ពស់ | -ប.ស.ស |
| ៥ | **ការពង្រឹងសេវាគាំទ្រទូទៅ** | | | | | | | | | |
| | | ៥.ក.ប្រព័ន្ធរដ្ឋបាលហិរញ្ញវត្ថុ និងតាមដានវាយតម្លៃត្រូវបានពង្រឹង | ប្រព័ន្ធ | - | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -អគ្គ.រដ្ឋបាល<br>-គ្រប់អង្គភាព<br>-មន្ទីរ ក.ប |
| | | ៥.ខ.សមត្ថភាពមន្ត្រីក្នុងការឆ្លើយតបតម្រូវការសាធារណៈត្រូវបានពង្រឹង | សមត្ថភាព | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -អគ្គ.រដ្ឋបាល<br>-គ្រប់អង្គភាព<br>-មន្ទីរ ក.ប |
| | | ៥.គ.ប្រព័ន្ធធ្វើតេស្តសមត្ថភាពមន្ត្រីដោយបច្ចេកទេសព័ត៌មានវិទ្យាក្រោយពេលវិក្រឹត្យការត្រូវបានអនុវត្តត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩ | ប្រព័ន្ធធ្វើតេស្ត | - | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | -អគ្គ.រដ្ឋបាល |
| | | ៥.ឃ.កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានអនុវត្ត | កម្មវិធី | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -អគ្គ.រដ្ឋបាល<br>-គ្រប់អង្គភាព<br>-មន្ទីរ ក.ប |
| | | ៥.ង.តួនាទី និងសមត្ថភាពអង្គភាព ត្រូវបានពង្រឹង | តួនាទី និង សមត្ថភាព | - | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | -ន.រដ្ឋបាល |
| | | ៥.ច.កិច្ចសហប្រតិបត្តិការគ្រប់ផ្នែក និងគ្រប់ដៃគូជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង និងពង្រីក | កិច្ចសហប្រតិបត្តិការ | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -អគ្គ.រដ្ឋបាល |
| | | ៥.ឆ.របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ | ចំនួនរបាយការណ៍ | ១៤ | ១៤ | ១៤ | ១៤ | ១៤ | - | -ន.ផែនការ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ឆ្នាំអនុវត្ត ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | ត្រីមាស ឆមាស និងឆ្នាំ ត្រូវបាន ធ្វើទៀងទាត់តាមកាលកំណត់ | | | | | | | | |
| | | ៥.ជ. ដំណោះស្រាយលើចំណុចប្រឈម និងសំណូមពរត្រូវបានរកឃើញ និងដោះស្រាយ ទាន់ពេលតាមរយៈយន្តការពិនិត្យតាមដាន វាយតម្លៃ ប្រចាំឆមាស និងប្រចាំឆ្នាំ | ចំនួន ដំណោះស្រាយ ការឆ្លើយតប | ២ | ២ | ២ | ២ | ២ | ២ | -អគ្គ.រដ្ឋបាល<br>-អគ្គាធិការដ្ឋាន<br>-ន.សវនកម្ម |
| | | ៥.ឈ. ការត្រួតពិនិត្យ តាមដាន វាយតម្លៃការអនុវត្ត កម្មវិធី និងយុទ្ធសាស្ត្រ ប្រចាំឆមាស និងប្រចាំឆ្នាំ ត្រូវបានធ្វើជាទៀងទាត់ | ការ វាយតម្លៃ | - | បាន វាយតម្លៃ | បាន វាយតម្លៃ | បាន វាយតម្លៃ | បាន វាយតម្លៃ | បាន វាយតម្លៃ | -ក្រុមការងារតាមដាន និងវាយតម្លៃ |
| **៥.១** | **ពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ** | | | | | | | | | |
| | | ៥.១.១. ប្រសិទ្ធភាពការងាររដ្ឋបាលត្រូវបានពង្រឹង | ប្រសិទ្ធភាព ការងារ រដ្ឋបាល | - | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | -អគ្គ.រដ្ឋបាល |
| | | ៥.១.២. សមត្ថភាពស្ថាប័នត្រូវបានពង្រឹង | សមត្ថភាព មន្ត្រី និងស្ថាប័ន | - | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | បាន ពង្រឹង | -អគ្គ.រដ្ឋបាល |
| | | ៥.១.៣. ឥរិយាបថ សីលធម៌ វិន័យ ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវរបស់មន្ត្រីត្រូវបានលើកកម្ពស់ | ក្រម សីលធម៌ វិន័យ | - | បាន លើកកម្ពស់ | បាន លើកកម្ពស់ | បាន លើកកម្ពស់ | បាន លើកកម្ពស់ | បាន លើកកម្ពស់ | -អគ្គ.រដ្ឋបាល |
| | | ៥.១.៤ សេវាសាធារណៈក្នុងវិស័យការងារ និងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបាន | សេវា | - | សិក្សា រៀបចំ | ដាក់បញ្ចូល | អនុវត្ត | អនុវត្ត | អនុវត្ត | -អគ្គ.រដ្ឋបាល |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ដាក់បញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មត្រឹមឆ្នាំ២០២០ | | | | | | | | |
| | | ៥.១.៥ កម្រងសេវាសាធារណៈទាំងអស់ត្រូវបានបញ្ចូន ទៅច្រកទ្វារ អេឡិចត្រូនិច ផ្តល់ព័ត៌មានសេវាសាធារណៈ(Public Service Gateway) របស់ក្រសួងមុខងារសាធារណៈ | ចំនួនសេវាបានបញ្ចូល | ២៥ | ៥៥ | សេវាថ្មីបានបន្ថែម | សេវាថ្មីបានបន្ថែម | សេវាថ្មីបានបន្ថែម | សេវាថ្មីបានបន្ថែម | -ន.រដ្ឋបាល<br>-គ្រប់អង្គភាព |
| | | ៥.១.៦ សេវាសាធារណៈនៅថ្នាក់ជាតិត្រូវបានផ្តល់តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ជាអតិបរិមា ត្រឹមឆ្នាំ២០២៣ | %នៃចំនួនសេវា | - | ១០ | ២០ | ៧០ | ៨០ | ៩០ | -ន.រដ្ឋបាល<br>-គ្រប់អង្គភាព |
| ៥.២ | **ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន** | | | | | | | | | |
| | | ៥.២.១.ការគ្រប់គ្រងធនធាន ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រនានា ត្រូវបានពង្រឹង | ការគ្រប់គ្រង | - | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -ន.ហិរញ្ញវត្ថុ<br>-គ្រប់អង្គភាព |
| | | ៥.២.២.ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំទាន់ពេល និងគ្រប់ជ្រុងជ្រោយ | ផែនការ | - | ទាន់ពេល | ទាន់ពេល | ទាន់ពេល | ទាន់ពេល | ទាន់ពេល | -ន.ហិរញ្ញវត្ថុ<br>-គ្រប់អង្គភាព |
| | | ៥.២.៣.ផែនការថវិកាត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាព | ផែនការ | - | ទាន់ពេល | ទាន់ពេល | ទាន់ពេល | ទាន់ពេល | ទាន់ពេល | -ន.ហិរញ្ញវត្ថុ<br>-គ្រប់អង្គភាព |
| | | ៥.២.៤. សិក្សាលទ្ធភាពការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) នៅតាមអង្គភាពថវិកាត្រូវបានពង្រីក | ប្រព័ន្ធ FMIS | - | ត្រូវបានពង្រីក | ត្រូវបានពង្រីក | ត្រូវបានពង្រីក | ត្រូវបានពង្រីក | ត្រូវបានពង្រីក | -ន.ហិរញ្ញវត្ថុ<br>-គ្រប់អង្គភាព |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| ៥.៣ | អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | | | | | | | |
| | | ៥.៣.១.មេរៀន និងម៉ូឌុលសម្រាប់អភិវឌ្ឍសមត្ថភាព មន្ត្រីគ្រប់ផ្នែកត្រូវបានចងក្រង និងអនុម័តឱ្យប្រើប្រាស់ | សមត្ថភាព មន្ត្រី | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -អគ្គ.រដ្ឋបាល<br>-ន.រដ្ឋបាល |
| | | ៥.៣.២.លិខិតបទដ្ឋានគោលនយោបាយ និងកិច្ចព្រមព្រៀងផ្សេងៗ ត្រូវបាន រៀបចំស្របតាមទម្រង់ និងនីតិវិធី | គោល នយោបាយ | - | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | -អគ្គ.រដ្ឋបាល<br>-ន.ផែនការ<br>-ន.សហប្រតិបត្តិការ |
| | | ៥.៣.៣.បញ្ជីតម្រូវការលិខិតបទដ្ឋានគតិយុត្តគោលនយោបាយ និងកិច្ចព្រមព្រៀង ត្រូវបានធ្វើការសិក្សា និងចងក្រង | លិខិត បទដ្ឋាន | - | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | បាន អនុវត្ត | -អគ្គ.រដ្ឋបាល<br>-ន.ផែនការ<br>-ន.សហប្រតិបត្តិការ |
| | | ៥.៣.៤. គុណភាព និងយន្តការគ្រប់គ្រងស្ថិតិត្រូវបានពង្រឹង | បានអនុវត្ត និងពង្រឹង | - | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | ត្រូវបាន ពង្រឹង | -អគ្គ.រដ្ឋបាល<br>-ន.ផែនការ |
| | | ៥.៣.៥. គុណភាពកសាង ផែនការគោលនយោបាយ និងផែនការនានារបស់ក្រសួង ត្រូវបានពង្រឹង | ផែនការ | - | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -អគ្គ.រដ្ឋបាល<br>-ន.ផែនការ |
| | | ៥.៣.៦. ការគ្រប់គ្រងឋាបនភ័ណ្ឌព័ត៌មានវិទ្យា និងការប្រើប្រាស់ប្រព័ន្ធឌីជីថលព័ត៌មានវិទ្យាក្នុងអង្គភាពក្រោមឱវាទក្រសួងត្រូវបានពង្រឹង | ប្រព័ន្ធ | - | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -អគ្គ.រដ្ឋបាល<br>-ន.ផែនការ |
| | | ៥.៣.៧ ប្រព័ន្ធតេស្តសមត្ថភាពសិក្ខាកាមដោយប្រព័ន្ធបច្ចេកវិទ្យាក្រោយពេលវិក្រឹតការ ត្រូវបានអភិវឌ្ឍ ត្រឹមត្រីមាសទី៣ ឆ្នាំ២០២០ | ប្រព័ន្ធតេស្ត សមត្ថភាព | - | សិក្សា រៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -គណៈកម្មការវិក្រឹត្យការ<br>-គ្រប់អង្គភាព<br>-វិ.ជាតិការងារ<br>-ន.រដ្ឋបាល<br>-ន.ផែនការ |

| | សកម្មភាព | សូចនាករ | ឯកតា | ឆ្នាំគោល | ឆ្នាំអនុវត្ត | | | | | អង្គភាពប្រតិបត្តិ |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| | | ៥.៣.៨ ប្រព័ន្ធរបាយការណ៍ឌីជីថល (Digital Reporting System) ត្រូវបានដាក់ឱ្យប្រើប្រាស់ត្រឹមឆ្នាំ២០២០ | ប្រព័ន្ធ | - | សិក្សារៀបចំ | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.ផែនការ |
| ៥.៤ | **ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម** | | | | | | | | | |
| | | ៥.៤.១ កិច្ចសហប្រតិបត្តិការជាមួយដៃគូត្រូវបានពង្រឹង និងពង្រីក | កិច្ចសហប្រតិបត្តិការ | - | បានពង្រឹង | បានពង្រឹងនិងពង្រីក | បានពង្រឹងនិងពង្រីក | បានពង្រឹងនិងពង្រីក | បានពង្រឹងនិងពង្រីក | -គ្រប់អង្គភាព<br>-ន.សហប្រតិបត្តិការ |
| | | ៥.៤.២ ក្រុមការងារយេនឌ័រ និងសេវាសង្គមត្រូវបានពង្រឹង | សេវាសង្គម | - | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | បានពង្រឹង | -គ្រប់អង្គភាព<br>-ក្រុមការងារយេនឌ័រ<br>-គណៈកម្មការផ្សេងៗ |
| ៥.៥ | **ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | | | | | |
| | | ៥.៥.១.តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព នៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រនីមួយៗត្រូវបានពង្រឹង | លទ្ធផល | - | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | -គ្រប់អង្គភាព |
| | | ៥.៥.២.អភិក្រមទាំង៥ និងបាវចនា ២ ត្រូវបានអនុវត្ត | អភិក្រម | - | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | បានអនុវត្ត | -អគ្គ.រដ្ឋបាល<br>-អគ្គាធិការដ្ឋាន<br>-ន.សវនកម្ម |
| | | ៥.៥.៣.យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៃការអនុវត្ត ផ.យ.អ.ក.ប ២០១៩-២០២៣ ត្រូវបានបង្កើតនៅត្រឹម ឆ្នាំ២០១៩ | យន្តការ | - | បានបង្កើត | អនុវត្ត | អនុវត្ត | អនុវត្ត | អនុវត្ត | -ន.ផែនការ |

**ឧបសម្ព័ន្ធ ៣ ÷ របាយការណ៍សមិទ្ធផលនៃការអនុវត្ត ផ.យ.អ.ក.ប ២០១៤-២០១៨**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារនៃការអនុវត្តផែនការយុទ្ធសាស្ត្រ
# អភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្តរក្សាសន្តិភាព ស្ថិរភាព និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ បានបន្តកើនឡើងក្នុងរង្វង់៧% ក្នុងមួយឆ្នាំ បានអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណបីដំណាក់កាលរួចមកហើយ ដើម្បី **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** នៅកម្ពុជា ដែលបាននាំមកនូវការអភិវឌ្ឍជាច្រើន ហើយបានធ្វើឱ្យកម្ពុជាឆ្លងកាត់ដោយជោគជ័យ ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីពេលថ្មីៗកន្លងទៅ។ ជាមួយការដាក់ចេញនូវគោលនយោបាយជាអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ខ្លួន ដោយសំដៅបន្តការធានាលក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ ធានាភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ បង្កើតបរិយាកាសការងារ និងបង្កើនឱកាសការងារ ធានាកិច្ចគាំពារសង្គម និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្របទៅតាមតម្រូវការទីផ្សារការងារ។

ជាមួយការប្តេជ្ញាចិត្តដ៏មោះមុតក្នុងការសម្រេចឱ្យបាននូវក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបានដាក់ចេញដោយមាន ការចូលរួមសហការយ៉ាងស្អិតរមួតពីគ្រប់ភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ នាអាណត្តិ ២០១៤-២០១៨ នេះ ក្រសួង សម្រេចបាននូវលទ្ធផលជាអាទិ៍ (១) បានធានាលក្ខខណ្ឌការងារល្អប្រសើរ ដោយបានតភ្ជាប់បណ្តាញអគ្គិសនី និងភ្ជាប់បណ្តាញទឹកស្អាតដែលមានតម្លៃទាប តាមរយៈការអនុវត្តច្បាប់ស្តីពីភតិសន្យាពិសេស ដើម្បីគ្រប់គ្រងថ្លៃជួលផ្ទះ របស់កម្មករនិយោជិត បានដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធឱ្យឡើងដល់ ១,២លានរៀល លើកលែងពន្ធលើអត្ថប្រយោជន៍បន្ថែមដូចជា សោហ៊ុយធ្វើដំណើរ កន្លែងស្នាក់នៅ ប្រាក់ថ្លៃបាយ មូលនិធិបេឡាជាតិរបបសន្តិសុខសង្គម ឬរៀបចំទារកដ្ឋាន ឬបន្ទប់បំបៅកូន និងប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ រួមទាំងផ្តល់អត្ថប្រយោជន៍ផ្សេងៗទៀតដូចជា ការធ្វើដំណើរតាមរថយន្តក្រុង ការធានាសុខមាលភាពកម្មការិនីមុន



ឃ/

និងក្រោយពេលសម្រាលបុត្រនិងការទទួលបានប្រាក់ឈ្នួលក្នុងការឈប់សម្រាក (២) បានដំឡើងប្រាក់ឈ្នួលអប្បបរមាដល់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ចាប់ពី៨០ដុល្លារ អាមេរិក នៅឆ្នាំ២០១៣ ឡើងដល់ ១៨២ដុល្លារអាមេរិក នៅឆ្នាំ២០១៩ ព្រមទាំងបានរៀបចំកសាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា (៣) បានលើកស្ទួយសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈដោយបានបង្កើតច្បាប់ស្តីពីសហជីព (៤) បានពង្រឹងយន្តការដោះស្រាយវិវាទការងារ (៥) បានលើកកម្ពស់ប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារដោយបានធ្វើបច្ចុប្បន្នភាពនៃផែនការមេលើកទី២ស្តីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ២០១៨-២០២២ (៦) បានបន្តជំរុញការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារគ្រប់ប្រភេទ និងដកហូតការប្រើប្រាស់កម្លាំងពលកម្មកុមារដោយបានធ្វើបច្ចុប្បន្នភាពនៃផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ២០១៦-២០២៥ (៧) បានពង្រឹងនិងពង្រីកការអភិវឌ្ឍជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងគុណភាពរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងបានចូលរួមប្រកួតប្រជែងជំនាញនៅថ្នាក់តំបន់ រួមទាំងបានបង្កើតគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ (៨) បានជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង (៩) បានពង្រីកការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារ ដោយបានបង្កើតគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ (១០) បានបើកទូលាយទីផ្សារការងារក្នុងនិងក្រៅប្រទេស ដោយបានបន្តធ្វើបច្ចុប្បន្នភាពនៃគោលនយោបាយទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ (១១) បានអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិតបានផ្តល់តាវកាលិកផ្នែកថែទាំសុខភាពដល់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងកំពុងរៀបចំដាក់ឱ្យដំណើរការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនចាប់ពីឆ្នាំ២០១៩ (១២) បានបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាលសាធារណៈ និង(១៣) បានអនុវត្តកាតព្វកិច្ចក្នុងនាមជាសមាជិកនៃអង្គការអន្តរជាតិខាងការងារ អាស៊ាន និងដៃគូអភិវឌ្ឍន៍។

## ២. សមិទ្ធផលចម្បងៗ នាអាណត្តិឆ្នាំ២០១៤-២០១៨

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវសមិទ្ធផលជាសារវន្តជាច្រើន ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច បើទោះជាត្រូវប្រឈមបញ្ហាធំៗជាច្រើន និងការប្រែប្រួលនៃពាណិជ្ជកម្មនៅក្នុងតំបន់ និងអន្តរជាតិក៏ដោយ។ ដោយការអនុវត្តយ៉ាងខ្ជាប់ខ្ជួនប្រកបដោយភាពប្រយ័ត្នប្រយែងនូវ ***"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨"*** របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា កន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសម្រេចបានលទ្ធផលការងារសំខាន់ៗដូចខាងក្រោម៖

### ២.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

### ២.១.១. បន្តលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង

ក្រសួងបានយកចិត្តទុកដាក់ ក្នុងការរៀបចំសិក្សាស្រាវជ្រាវកសាងច្បាប់ថ្មីៗបន្ថែម ដោយធ្វើវិសោធនកម្មបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងរៀបចំបន្ថែមនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារឱ្យស្របនឹងការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច-សង្គម និងបទដ្ឋានអន្តរជាតិ ដើម្បីធានាបាននូវការអនុវត្តច្បាប់ការងារប្រកបដោយប្រសិទ្ធភាពសំដៅធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ។ ទន្ទឹមនឹងនេះ ក្នុងអាណត្តិទី៥ ក្រសួងបានពង្រឹងយន្តការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាព និងមានតម្លាភាព ដោយក្រសួងបានកែសម្រួលពីការធ្វើអធិការកិច្ចការងារជាច្រើនក្រុមដាច់ដោយឡែកពីគ្នាតាមជំនាញនីមួយៗ, ការប្រើប្រាស់បទដ្ឋានវាយតម្លៃដាច់ដោយឡែកតាមជំនាញនីមួយៗ និងមិនមានឯកសណ្ឋានរួមមួយមកជាក្រុមអធិការកិច្ចការងាររួមតែមួយដែលមាន ឯកសណ្ឋានតែមួយ, ប្រើប្រាស់បទដ្ឋានវាយតម្លៃតែមួយ, និងចុះធ្វើអធិការកិច្ចក្នុងពេលតែមួយ។

ក្នុងន័យកែលម្អជាប្រចាំនូវយន្តការអធិការកិច្ចការងារ និងសិក្សាពីបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាក្នុងវិស័យការងារ ក្រសួងបានអនុវត្តរបាយការណ៍ស្តីពីអធិការកិច្ចការងារដែលបានធ្វើបច្ចុប្បន្នភាព និងកែលម្អឱ្យកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ តម្លាភាព និងអាចជឿទុកចិត្តបានពីគ្រប់ភាគី។ លើសពីនេះ ក្រសួងបានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការការងារជាមួយដៃគូអភិវឌ្ឍន៍ក្នុងការពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារ ជាក់ស្តែងតាមរយៈគម្រោង រោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ជាគម្រោងកម្មវិធីមួយរបស់អង្គការអន្តរជាតិខាងការងារ ក្រសួងបានអនុវត្តការវាយតម្លៃលើលក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ចាប់តាំងពី ឆ្នាំ២០០១ និងតាមរយៈទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា (GIZ) ក្រសួងបានធ្វើការសិក្សាកែសម្រួល និងដាក់ឱ្យប្រើប្រាស់ក្រមសីលធម៌មន្ត្រីអធិការកិច្ចការងារ, រៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងទិន្នន័យតាមព័ត៌មានវិទ្យា និងលើកកម្ពស់ការយល់ដឹងពីប្រព័ន្ធអធិការកិច្ចការងារតាមរយៈការផលិត និងផ្សព្វផ្សាយខិត្តប័ណ្ណ វីដេអូឃ្លីបខ្លីៗ និងតាមបណ្តាញទំនាក់ទំនងសង្គម។

ជាក់ស្តែង ចាប់ពីឆ្នាំ២០១៤-២០១៨ ក្រសួងបានចុះធ្វើអធិការកិច្ចការងារទៅលើសហគ្រាស-គ្រឹះស្ថានសរុបចំនួន ៤៤ ៧៣៩ លើក ដែលកើនឡើង ៣,៦ ដង ពីចំនួនអធិការកិច្ចការងារនាអាណត្តិទី៤ ហើយក្នុងនោះអធិការកិច្ចការងារសាមញ្ញចំនួន ៤០ ៨៨៨ លើក, អធិការកិច្ចការងារពិសេសចំនួន ២ ៤៩៣ លើក, និងការចុះធ្វើអធិការកិច្ចការងារពិសេសក្រៅកម្មវិធីចំនួន ១ ៣៥៨ លើក។ តាមរយៈការងារនេះ ក្រសួងបានដាក់កំហិតចំពោះសហគ្រាស-គ្រឹះស្ថាន ដែលមិនទាន់បានបំពេញបែបបទស្តីពី សហគ្រាស-គ្រឹះស្ថាន និងមិនព្រមកែលម្អលក្ខខណ្ឌទូទៅនៃការងារ សុខភាព និងសុវត្ថិភាពការងារ ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារចំនួន ៤ ២៣៩ សហគ្រាស-គ្រឹះស្ថាន ហើយបានធ្វើការផាកពិន័យចំនួន ៣០២ សហគ្រាស-គ្រឹះស្ថាន និងប្តឹងទៅតុលាការមានចំនួន ៩សហគ្រាស-គ្រឹះស្ថាន។ ជារួម សហគ្រាស-គ្រឹះស្ថានបាននឹងកំពុងអនុវត្តច្បាប់ និង

បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យការងារបានយ៉ាងល្អ ដែលឆ្លុះបញ្ចាំងតាមរយៈ ការថយចុះនៃអនុបាតការដាក់កំហិតធៀបនឹងចំនួនអធិការកិច្ចការងារពី ១៨,២% នៅអាណត្តិទី៤ មកត្រឹមប្រមាណជា ៩,៥% នៅអាណត្តិទី៥។ ទន្ទឹមការចុះធ្វើអធិការកិច្ច ក្រសួងបានកំពុងសិក្សារៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារ ដើម្បីងាយស្រួលធ្វើការតាមដានការអនុវត្តលក្ខខណ្ឌការងារ តាមបណ្តាសហគ្រាស-គ្រឹះស្ថាន ដែលប្រព័ន្ធនេះនឹងត្រូវគ្រោងដាក់ឱ្យដំណើរការនៅក្នុងឆ្នាំខាងមុខ។

**តារាងទី១÷ ការចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសប្រព្រឹត្តល្មើសច្បាប់**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ការចុះអធិការកិច្ច | លើក | **7,191** | **9,339** | **9,142** | **9,717** | **9,350** | **44,739** |
| *ចុះធ្វើអធិការកិច្ចការងារសាមញ្ញ* | លើក | 6,811 | 8,789 | 8,197 | 8,689 | 8,402 | 40,888 |
| *ចុះធ្វើអធិការកិច្ចការងារពិសេស* | លើក | 380 | 333 | 566 | 595 | 619 | 2,493 |
| *ចុះធ្វើអធិការកិច្ចការងារពិសេសក្រៅកម្មវិធី* | លើក | 0 | 217 | 379 | 433 | 329 | 1,358 |
| ដាក់កំហិត | ស.គ | 805 | 648 | 842 | 893 | 1,051 | 4,239 |
| ត្រូវផាកពិន័យ | ស.គ | 0 | 30 | 111 | 61 | 100 | 302 |
| បានចេញលិខិតផាកពិន័យ | ស.គ | 0 | 30 | 60 | 81 | 16 | 187 |
| ប្ដឹងទៅតុលាការ | ស.គ | 0 | 0 | 0 | 5 | 4 | 9 |

*កំណត់សម្គាល់÷ ស.គ: សហគ្រាស-គ្រឹះស្ថាន*

ជាមួយការចុះអធិការកិច្ចនេះ និងដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងវិស័យការងារឱ្យក្លាយជាអធិការការងារ អធិការពេទ្យការងារ និងអភិបាលការងារ ព្រមទាំងផ្តល់វិក្រឹត្យការដល់មន្ត្រីអធិការកិច្ចការងារដើម្បីមាននីតិសម្បទាគ្រប់គ្រាន់ជាមន្ត្រីនគរបាលយុត្តិធម៌។

ក្នុងគោលបំណងជួយសម្រាលបន្ទុកដល់កម្មករនិយោជិតក្នុងការទទួលលំហូរសាច់ប្រាក់ (ប្រាក់ខែ) ក្រសួងបានរៀបចំឱ្យម្ចាស់សហគ្រាស-គ្រឹះស្ថាន បើកប្រាក់ឈ្នួលប្រចាំខែ ការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន២ដងក្នុងមួយខែ ការពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសច្បាប់ស្តីពីការងារ ការកែសម្រួលប្រាក់ឈ្នួលយោងប្រចាំថ្ងៃពី ៨ ០០០រៀល ទៅ ៤០ ០០០រៀល ក្នុងការផាកពិន័យ។ បន្ថែមពីនេះ ដើម្បីជួយសម្រួលដល់កម្មករនិយោជិតជាស្ត្រីមានផ្ទៃពោះ និងជាសាសនិកឥស្លាម ក្រសួងបានចេញសេចក្តីណែនាំឱ្យម្ចាស់រោងចក្រសហគ្រាស-គ្រឹះស្ថាន អនុវត្តការអនុញ្ញាតកម្មការិនីមានផ្ទៃពោះចេញមុនម៉ោងធ្វើការងារយ៉ាងតិច ១៥ នាទី និងអនុញ្ញាតឱ្យបងប្អូនកម្មករនិយោជិតជាស្ត្រីខ្មែរឥស្លាមអាចប្រើប្រាស់សម្លៀកបំពាក់តាមប្រពៃណីឥស្លាម។

ក្រសួងបានរៀបចំបង្កើតវិទ្យាស្ថានជាតិការងារ ដែលនឹងដាក់ដំណើរការនៅឆ្នាំ២០១៩នេះ។ វិទ្យាស្ថាននេះនឹងដើរតួនាទីក្នុងការសិក្សាស្រាវជ្រាវអំពីលក្ខខណ្ឌទូទៅនៃការងារ, ទំនាក់ទំនងវិជ្ជាជីវៈ, ផលិតភាពការងារ, សុខភាពនិងសុវត្ថិភាពការងារ, របបសន្តិសុខសង្គម, និងទេសន្តរប្រវេសន៍ការងារ ក្នុងគោលបំណងដើម្បីលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យការងារឱ្យកាន់តែល្អប្រសើរឡើង។

ឆ្លងតាមការអនុវត្តការងារក្នុងរយៈពេល៥ឆ្នាំមកនេះយើងពិនិត្យឃើញថា ការអនុវត្តច្បាប់របស់សហគ្រាស-គ្រឹះស្ថាន មានការប្រសើរឡើងជាងមុន ដោយលក្ខខណ្ឌស្តីពីការងារសុទ្ធតែត្រូវបានអនុវត្តស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ប៉ុន្តែស្របជាមួយសមិទ្ធផលខាងលើនេះ ក៏នៅមាន សហគ្រាស-គ្រឹះស្ថាន មួយចំនួន មិនទាន់បំពេញបែបបទស្តីពីសហគ្រាស និងមិនទាន់បានបំពេញលក្ខខណ្ឌការងារបានត្រឹមត្រូវនៅឡើយ ជាពិសេសការផ្តល់ការឈប់សម្រាកត្រឹមត្រូវ ការធ្វើការលើសចិរវេលាកំណត់ដោយពុំមានការអនុញ្ញាត និងមិនអនុវត្តឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌការងារដែលទាមទារ ក្រសួងត្រូវបន្តដាក់ចេញនូវវិធានការគន្លឹះបន្ថែមទៀត ដើម្បីឆ្លើយតបនឹងការងារនេះសម្រាប់អាណត្តិខាងមុខ។

**២.១.២. ការផ្សះផ្សាវិវាទនៃទំនាក់ទំនងវិជ្ជាជីវៈ**

ក្នុងការធានាភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ពង្រឹងយន្តការផ្សះផ្សា និងដោះស្រាយវិវាទការងារស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាប្រកបដោយប្រសិទ្ធភាព ក្រសួងបានពង្រឹងគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា (គ.ក.ប) គ្រប់ជាន់ថ្នាក់ និងអគ្គលេខាធិការដ្ឋាន គ.ក.ប ដើម្បីប្រចាំការ ត្រៀមខ្លួនទប់ស្កាត់ អន្តរាគមន៍ ដោះស្រាយ និងផ្សះផ្សាបញ្ហាកូដកម្ម និងបាតុកម្មខុសច្បាប់ ដែលបានកើតមានឡើង ជាពិសេសក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង តាមរយៈការបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី អ.គ.ក.ប និង អាជ្ញាធរពាក់ព័ន្ធនៅថ្នាក់រាជធានី-ខេត្ត សរុបចំនួន ៣ ៦៩៧នាក់ ស្មើនឹង ១៨ វគ្គ និង អន្តរាគមន៍ដោះស្រាយកូដកម្មសរុបចំនួន ១ ០២២ លើ១ ០៤២ ករណី(ស្មើនឹង ៩៨,១%)។ ជាលទ្ធផល ករណីសះជាមានចំនួន ១ ០០៨ករណី(ស្មើនឹង ៩៦,៧% នៃចំនួនកូដកម្មសរុប), ចំនួនករណីកូដកម្មដែលកើតឡើងនៅតាមសហគ្រាស-គ្រឹះស្ថានបានថយចុះជាបន្តបន្ទាប់ពី ៣៤២ ទៅ ៤៧ ឬប្រមាណជា ៨៦,២% ក្នុងចន្លោះឆ្នាំ២០១៤ និង២០១៨ និងអត្រាកូដកម្មដែលឈានទៅដល់ហិង្សាស្ថិតនៅក្នុងកម្រិតទាប និងគ្រប់គ្រងបានប្រមាណជា ៤,១%។ ទន្ទឹមនឹងនេះ បានធ្វើអន្តរាគមន៍បាតុកម្មចំនួន ៥១២ លើ៥១២ ករណី។ ជារួម អត្រាកូដកម្ម និងបាតុកម្មដែលឈានទៅដល់ហិង្សាស្ថិតនៅក្នុងកម្រិតទាប និងគ្រប់គ្រងបានប្រមាណជា ៤,១% និង ៨,៣% រៀងគ្នា។

**តារាងទី២៖ ករណីកូដកម្ម**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ចំនួនកូដករ | នាក់ | 137,708 | 82,458 | 54,978 | 32,133 | 10,890 | 318,167 |
| ចំនួនរោងចក្រ | រោងចក្រ | 321 | 326 | 211 | 97 | 47 | 1,002 |
| ចំនួនកូដកម្ម | ករណី | 342 | 336 | 220 | 97 | 47 | 1,042 |
| បិទផ្លូវ | ករណី | 19 | 8 | 12 | 4 | 6 | 49 |
| ហិង្សា | ករណី | 12 | 18 | 12 | 0 | 1 | 43 |
| អន្តរាគមន៍ | ករណី | 340 | 336 | 220 | 91 | 35 | 1,022 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ការដង្ហែក្បួន | ករណី | 32 | 46 | 62 | 14 | 3 | 157 |
| សះជា | ករណី | 331 | 326 | 214 | 90 | 47 | 1,008 |
| មិនសះជា | ករណី | 11 | 10 | 6 | 7 | 0 | 34 |

**តារាងទី៣÷ ករណីបាតុកម្ម**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ចំនួនបាតុករ | នាក់ | 10,917 | 19,274 | 16,615 | 5,683 | 486 | 52,975 |
| ចំនួនករណបាតុកម្ម | ករណី | 14 | 192 | 212 | 89 | 5 | 512 |
| បាតុកម្មបិទផ្លូវ | ករណី | 7 | 14 | 19 | 6 | 5 | 51 |
| បាតុកម្មហិង្សា | ករណី | 1 | 11 | 29 | 1 | 1 | 43 |
| អន្តរាគមន៍ | ករណី | 14 | 192 | 212 | 89 | 5 | 512 |
| ការដង្ហែក្បួនបាតុកម្ម | ករណី | 6 | 18 | 162 | 81 | 3 | 270 |

ចាប់ពីឆ្នាំ ២០១៤-២០១៨ ក្រសួងបានទទួលដោះស្រាយវិវាទការងារសរុបចំនួន ៤ ២៧២ ករណី ក្នុងនោះ វិវាទបុគ្គលមានចំនួន ១ ៤៥៣ ករណី និងវិវាទការងាររួមមានចំនួន ២ ៨១៩ ករណី។ បើពិនិត្យតាមឆ្នាំ ចំនួនវិវាទសរុបគឺមានការថយចុះគួរឱ្យកត់សម្គាល់ ពោលគឺ ថយពី ១ ០៧០ ករណី នៅឆ្នាំ ២០១៤ មកត្រឹម ៥៨០ ករណី នៅឆ្នាំ២០១៨។ ជារួម យន្តការ និងសមត្ថភាពមន្ត្រីក្នុងដោះស្រាយវិវាទត្រូវបានកែលម្អ និងមានប្រសិទ្ធភាពជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះនៃចំនួនវិវាទរួម ពី ៨៧៥ ករណី នៅឆ្នាំ ២០១៤ មកត្រឹម ១៦៣ ករណី នៅឆ្នាំ២០១៨ ឬពី ៣៧០ មក ១២៥ សហគ្រាស-គ្រឹះស្ថាន ហើយអត្រានៃវិវាទការងាររួមដែលសះជាមានការកើនឡើងពី ៣៥,១% ទៅ៦០,៧% នៅក្នុងរយៈពេលដូចគ្នានេះ។

**តារាងទី៤÷ ការដោះស្រាយវិវាទការងារ**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| **១. វិវាទបុគ្គល** | | | | | | | |
| សហគ្រាស-គ្រឹះស្ថាន | ចំនួន | 113 | 149 | 148 | 303 | 299 | 1,012 |
| ចំនួនវិវាទបុគ្គល | ករណី | 195 | 149 | 216 | 476 | 417 | 1,453 |
| *សះជា* | ករណី | 94 | 102 | 89 | 228 | 197 | 710 |
| *មិនសះជា* | ករណី | 84 | 42 | 123 | 191 | 163 | 603 |
| *មោឃៈ* | ករណី | 17 | 5 | 4 | 57 | 57 | 140 |
| **២. វិវាទការងាររួម** | | | | | | | |
| សហគ្រាស-គ្រឹះស្ថាន | ចំនួន | 370 | 380 | 293 | 101 | 125 | 1,269 |
| កម្មករនិយោជិតចូលរួម | នាក់ | 353,066 | 130,408 | 113,627 | 75,665 | 93,521 | 766,287 |
| ចំនួនវិវាទការងាររួម | ករណី | 875 | 1,017 | 637 | 127 | 163 | 2,819 |
| *សះជា* | ករណី | 307 | 425 | 230 | 56 | 99 | 1,117 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| *មិនសះជា* | ករណី | 562 | 586 | 406 | 70 | 61 | 1,685 |
| *មោឃៈ* | ករណី | 6 | 6 | 1 | 1 | 3 | 17 |
| **៣. ក្រុមប្រឹក្សាអាជ្ញាកណ្តាល** | | | | | | | |
| សំណុំរឿងក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាន | ករណី | 361 | 338 | 248 | 52 | 53 | 1,052 |
| *សំណុំរឿងចេញសេចក្តីបង្គាប់* | ករណី | 227 | 242 | 176 | 47 | 41 | 733 |
| *សំណុំរឿងមិនចេញសេចក្តីបង្គាប់ (កិច្ចព្រមព្រៀង) សះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល* | ករណី | 22 | 17 | 13 | 3 | 12 | 67 |
| *សំណុំរឿងមិនចេញសេចក្តីបង្គាប់ (កិច្ចព្រមព្រៀង) សះជាដោយភាគីទាំងពីរ* | ករណី | 112 | 79 | 59 | 2 | 0 | 252 |

ការថយចុះនៃចំនួនករណីវិវាទរួម និងចំនួនសហគ្រាស-គ្រឹះស្ថាន ដែលកើតវិវាទរួម គឺបណ្តាលមកពីការខិតខំប្រឹងប្រែងរបស់ក្រសួងក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ ការពង្រឹងយន្តការចរចាប្រាក់ឈ្នួលអប្បបរមា យន្តការអធិការកិច្ចការងារ ជាពិសេសការរៀបចំកម្មវិធីជួបសំណេះសំណាលរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី។**

ជាក់ស្តែងចាប់តាំងពីថ្ងៃអាទិត្យ ទី២០ ខែសីហា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះជួបសំណេះសំណាលជាមួយបងប្អូនកម្មករនិយោជិត ប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម ជំនួយការ នៅតាមបណ្តារោងចក្រនានា តំបន់ឧស្សាហកម្ម និងតាមរោងចក្រ សហគ្រាសទូទាំងប្រទេសចំនួន ៦១ លើក ដែលមានកម្មករនិយោជិតចំនួនសរុប ៨៧៥ ១៧៣នាក់។ ទន្ទឹមនឹងនេះ ការយល់ដឹងរបស់ភាគីពាក់ព័ន្ធពិសេស សហជីពនិយោជក កម្មករនិយោជិត កាន់តែល្អប្រសើរជាងមុនក្នុងការបែងចែកបញ្ហាទាមទាររវាងវិវាទការងាររួម និងវិវាទបុគ្គល បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងក្នុងការពន្យល់ និងបកស្រាយឱ្យកាន់តែច្បាស់អំពីនិយមន័យនៃវិវាទទាំងពីរនេះទៅដល់ភាគីពាក់ព័ន្ធ ពិសេសភាគីសហជីពកម្មករនិយោជិត។

ក្រសួងបានបន្តជំរុញអនុវត្តយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ជាពិសេសតាមរយៈយន្តការនាយកដ្ឋានវិវាទការងារ និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយក្នុងកំឡុងឆ្នាំ២០១៤-២០១៨ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដោះស្រាយវិវាទការងាររួមសរុបចំនួន ១ ០៥២ សំណុំរឿង ដែលក្នុងនោះ សំណុំរឿងចំនួន ៧៣៣ ត្រូវបានដោះស្រាយ ដោយចេញសេចក្តីបង្គាប់, សំណុំរឿងចំនួន ៦៧ ត្រូវបានដោះស្រាយសះជាដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលខ្លួនឯងហើយសំណុំរឿងចំនួន២៥២ត្រូវបានសះជាដោយភាគីទាំងពីរ។ ហើយក្រសួងក៏បានដោះស្រាយករណីថៅកែរត់ចោលមិនទូទាត់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករនិយោជិតក្នុងនោះបានចំនួន ៨៦ ករណី មានកម្មករសរុបចំនួន ៣០ ០០៦ នាក់ ក្នុងនោះ ដោះស្រាយក្រៅ

ប្រព័ន្ធតុលាការមានចំនួន ៦៥ ករណី នីតិវិធីក្ស័យធនមានចំនួន ០៣ ករណី និងប្រាក់បុរេប្រទានពី រាជរដ្ឋាភិបាលមានចំនួន ១៨ ករណី។

ជាមួយនឹងការពង្រឹងយន្តការដោះស្រាយវិវាទការងារខាងលើនេះ សេរីភាពនៃអង្គការវិជ្ជាជីវៈ ក៏ត្រូវបានធានា ជាពិសេសបន្ទាប់ពីច្បាប់សហជីពត្រូវប្រកាសឱ្យប្រើនៅឆ្នាំ២០១៦។ ជាក់ស្តែង ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈមានការកើនឡើង ពោលគឺប្រមាណជា ៦៨១ នៅក្នុងឆ្នាំ ២០១៧ ដែលក្នុងនោះសហភាពសហជីពមានចំនួន ៦ សហព័ន្ធសហជីពមានចំនួន ៤០ និងសហជីពមូលដ្ឋានមានចំនួន ៦៣៥ ដែលជាចំនួនមួយច្រើនជាងការចុះបញ្ជីអង្គការវិជ្ជាជីវៈសរុបក្នុងចន្លោះឆ្នាំ២០១៤ និង២០១៦។ ដោយឡែកនៅក្នុងឆ្នាំ ២០១៨ ចំនួននេះក៏នៅតែបន្តកើនឡើងចំនួន ៥៣៣។ នេះបានបង្ហាញពីថាការអនុវត្តសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈត្រូវបានលើកកម្ពស់ គ្មានការរឹតត្បិត ឬរើសអើងចំពោះការចូលរួមដោយសេរី និងស្មើភាពរបស់កម្មករនិយោជិត ដើម្បីចូលរួមក្នុងការលើកកម្ពស់លក្ខខណ្ឌការងារ និងធានាបាននូវសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈនៅតាមសហគ្រាស-គ្រឹះស្ថាន។ ក្នុងអាណត្តិនេះ ក្រសួងបានចេញលិខិតទទួលស្គាល់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈសរុបចំនួន ៥៥៤ នាក់ ដែលរួមមានសហភាពសហជីពចំនួន ២ នាក់, សហព័ន្ធសហជីពចំនួន ២៤ នាក់, សហជីពមូលដ្ឋានចំនួន ៥២៧ នាក់, សមាគមនិយោជកចំនួន ១ ហើយក្រសួងក៏បានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យដើម្បីចងក្រង និងគ្រប់គ្រងទិន្នន័យអង្គការវិជ្ជាជីវៈ សំដៅធានាឱ្យតម្លាភាពនៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ ក៏ដូចជាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ស្តីពីសហជីព។

**តារាងទី៥÷ ការងារផ្នែកអង្គការវិជ្ជាជីវៈ**

| បរិយាយ | | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ចុះបញ្ជិកាអង្គការវិជ្ជាជីវៈ | សហភាពសហព័ន្ធ | សហជីព | 0 | 2 | 2 | 6 | 4 | 14 |
| | សហព័ន្ធសហជីព | សហជីព | 4 | 11 | 5 | 40 | 37 | 97 |
| | សហជីពមូលដ្ឋាន | សហជីព | 107 | 224 | 162 | 635 | 489 | 1,617 |
| | សមាគមនិយោជក | សហជីព | 0 | 1 | 0 | 0 | 3 | 4 |
| ចេញលិខិតទទួលស្គាល់ថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ | សហភាពសហព័ន្ធ | នាក់ | 0 | 2 | 0 | 0 | 0 | 2 |
| | សហព័ន្ធសហជីព | នាក់ | 4 | 8 | 11 | 0 | 1 | 24 |
| | សហជីពមូលដ្ឋាន | នាក់ | 73 | 113 | 95 | 0 | 246 | 527 |
| | សមាគមនិយោជក | នាក់ | 0 | 0 | 0 | 0 | 1 | 1 |
| ចេញលិខិតទទួលស្គាល់ប្រតិភូបុគ្គលិក | | នាក់ | 786 | 1,203 | 1,698 | 1,781 | 1,640 | 7,108 |
| ចេញលិខិតទទួលស្គាល់ប្រតិភូបុគ្គលិកជំនួយទៅជាប្រតិភូពេញសិទ្ធិ | | នាក់ | 37 | 43 | 46 | 33 | 43 | 202 |
| ចេញលិខិតចាត់តាំងបុគ្គលិកទំនាក់ទំនង | | នាក់ | 37 | 45 | 189 | 141 | 115 | 527 |
| ចុះបញ្ជិកាភាពជាតំណាងបំផុតអង្គការវិជ្ជាជីវៈ | | សហជីព | 37 | 43 | 38 | 0 | 4 | 122 |
| ចុះបញ្ជិកាអនុសញ្ញារួម | | ច្បាប់ | 37 | 45 | 40 | 6 | 4 | 132 |

## ២.១.៣.ការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា និង អត្ថប្រយោជន៍របស់កម្មករនិយោជិត

ក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមា ក្រសួងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ ស្តីពី "ការពង្រឹងដំណើរការនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា" នៅថ្ងៃ ២៤-២៥ ខែមេសា ឆ្នាំ២០១៤ ក្រោមជំនួយបច្ចេកទេសរបស់អង្គការ ILO។ ដោយផ្អែកលើលទ្ធផលសិក្ខាសាលានេះ គណៈកម្មការប្រឹក្សាការងារបានសម្រេចកំណត់គោលការណ៍សម្រាប់ការចរចាប្រាក់ឈ្នួលចំនួន ៥ លក្ខណវិនិច្ឆ័យបែបសង្គម និងបែបសេដ្ឋកិច្ច ចំនួន ៧ និងកាលវិភាគច្បាស់លាស់ក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា÷

- **គោលការណ៍ចំនួន ៥ រួមមាន÷** (១) ត្រូវតែធ្វើឡើងជារៀងរាល់ឆ្នាំ (២) ត្រូវតែជាតួលេខឬអត្រាកំណើនដែលអាចព្យាករណ៍បាន (៣) យកគោលការណ៍ឈ្នះ-ឈ្នះ (៤) សម្រេចចិត្តត្រូវធ្វើឡើងដោយមតិជាឯកច្ឆន្ទ បើក្នុងករណីមិនមានការឯកភាពជាឯកច្ឆន្ទនៅក្នុងកិច្ចប្រជុំលើកទី២ នោះត្រូវយកសំឡេងភាគច្រើនតាមរយៈការបោះឆ្នោតជាសម្ងាត់ និង (៥) ត្រូវផ្អែកលើទិន្នន័យផ្លូវការដែលផលិតដោយភ្នាក់ងារ ឬស្ថាប័នជាតិ។
- **លក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ចចំនួន ៧ រួមមាន÷** ស្ថានភាពគ្រួសារ អត្រាអតិផរណា ការចំណាយក្នុងការរស់នៅ ផលិតភាពភាពប្រកួតប្រជែងរបស់ប្រទេស ស្ថានភាពទីផ្សារការងារ និងកម្រិតចំណេញរបស់វិស័យ។
- **កាលវិភាគនៃការចរចា÷** ចាប់ផ្តើមពីខែកក្កដា ដល់ខែតុលា សម្រាប់ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា ហើយប្រាក់ឈ្នួលអប្បបរមាថ្មី ដែលកំណត់បាននឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករានៃឆ្នាំបន្ទាប់។

តាមរយៈនេះ ក្រសួងបានបង្កើតឱ្យមាន "ក្រុមការងារបច្ចេកទេសត្រីភាគី" ដែលមានសមាសភាពមកពីភាគីរាជរដ្ឋាភិបាល ភាគីនិយោជក និងភាគីសហជីព ដែលមានចំនួនស្មើៗគ្នា ដើម្បីពិភាក្សាការងារបច្ចេកទេសលម្អិតលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច និងដើម្បីផ្តល់ជារបាយការណ៍នៃកិច្ចពិភាក្សារបស់ខ្លួនជូនគណៈកម្មការប្រឹក្សាការងារពិនិត្យសម្រេច។ ក្រុមការងារនេះត្រូវបានបង្កើតឡើងដំបូងនៅ ឆ្នាំ២០១៥ ដែលមានសមាសភាព ២៧ រូប ហើយចំនួននៃសមាជិកត្រូវបានបង្កើនបន្ថែមដល់ចំនួន ៤៨ រូប ចាប់ពី ឆ្នាំ២០១៦ ដើម្បីឱ្យការពិភាក្សារបស់ក្រុមកការងារបច្ចេកទេសនេះ ទទួលបានធាតុចូលគ្រប់ជ្រុងជ្រោយ។ ជាមួយគ្នានេះ ក្រសួងក៏បានធ្វើការសិក្សារួមគ្នា ជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ក្នុងការសិក្សាស្រាវជ្រាវទៅលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច ដែលលទ្ធផលនៃការស្រាវជ្រាវនេះបានក្លាយទៅជាឯកសារគោលសម្រាប់ប្រើប្រាស់ក្នុងការចរចាប្រាក់ឈ្នួលអប្បបរមា។

ក្រសួងបានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមារបស់ក្រសួង ដែលចាប់ពី ឆ្នាំ២០១៥ ក្រុមការងារនេះបានធ្វើការសិក្សា និងអង្កេតជារៀងរាល់ឆ្នាំ អំពីស្ថានភាពជីវភាពរស់នៅរបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ដោយផ្តោតសំខាន់ លើចំណូលចំណាយ លក្ខខណ្ឌការងារ

របបអាហារ និងការយល់ដឹងអំពីប្រាក់ឈ្នួលអប្បបរមា។ លទ្ធផលនៃការសិក្សានេះ គឺជាមុខចូលយ៉ាងសំខាន់ សម្រាប់ធ្វើការវាយតម្លៃទៅលើវិបត្តិនៃការដំឡើងប្រាក់ឈ្នួលអប្បបរមា ក៏ដូចជាការចរចាប្រាក់ឈ្នួលអប្បបរមា ជារៀងរាល់ឆ្នាំរបស់គណៈកម្មការប្រឹក្សាការងារ និងបានរៀបចំបង្កើតបណ្តុំសូចនាករតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ផលវិបាកនៃបម្រែបម្រួលប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងអនាគត។

ជាមួយការរៀបចំនូវយន្តការ និងការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងជារៀងរាល់ឆ្នាំ ការដំឡើងប្រាក់ឈ្នួលនេះ ក្រសួងក៏បានរក្សានូវអត្ថប្រយោជន៍ផ្សេងៗ របស់កម្ពុជា ដែលក្នុងនោះ÷

- **ប្រាក់រង្វាន់ធ្វើការទៀងទាត់÷** ត្រូវបានផ្តល់ឱ្យកម្មករនិយោជិតចាប់ពីឆ្នាំ២០០០ ដែលពេលនោះមានចំនួន៥ដុល្លារអាមេរិកក្នុងមួយខែ។ បច្ចុប្បន្នប្រាក់រង្វាន់នេះមានចំនួន ១០ដុល្លារអាមេរិកក្នុងមួយខែ។
- **ប្រាក់សោហ៊ុយធ្វើដំណើរ ឬស្នាក់នៅ÷**ត្រូវបានផ្តល់ឱ្យកម្មករនិយោជិតចាប់ពីឆ្នាំ២០១២ បច្ចុប្បន្នមានចំនួន ៧ដុល្លារអាមេរិកក្នុងមួយខែ ដើម្បីសម្រួលដល់ការចំណាយថ្លៃធ្វើដំណើរ និងស្នាក់នៅរបស់កម្មករនិយោជិត ក្នុងករណីដែលរោងចក្រសហគ្រាសមិនបានផ្តល់ទីកន្លែងស្នាក់នៅ និងមធ្យោបាយធ្វើដំណើរ។
- **ប្រាក់រង្វាន់អតីតភាពការងារ÷** គឺជាប្រាក់រង្វាន់សម្រាប់កម្មករនិយោជិតដែលបានធ្វើការ ក្នុងរោងចក្រសហគ្រាសលើសពីមួយឆ្នាំ ហើយប្រែប្រួលទៅតាមអតីតភាពការងារដូចតារាងខាងក្រោម÷

| អតីតភាពការងារ (ឆ្នាំ) | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រង្វាន់អតីតភាពការងារ(ដុល្លារអាមេរិក/ខែ) | ០ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |

ជាមួយយន្តការនានាដែលបានរៀបចំឡើងខាងលើនេះ ការដំឡើងប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ក្រសួងក៏បានបន្តយកចិត្តទុកដាក់លើការបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីប្រាក់ឈ្នួលអប្បបរមាផងដែរ។ ក្នុងនោះ ចាប់ពី ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សព្វផ្សាយដល់កម្មករ សិស្ស និស្សិត និងសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន សិស្ស និស្សិត អំពីយន្តការ និងលក្ខណវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៣២ លើក និងមានអ្នកចូលរួមប្រមាណ ១ម៉ឺន ៤ពាន់នាក់។ ក្រសួងក៏បានបោះពុម្ពសៀវភៅរបាយការណ៍ប្រាក់ឈ្នួលអប្បបរមាចំនួន ៥ ៥០០ច្បាប់, ខិត្តប័ណ្ណផ្សព្វផ្សាយពីយន្តការ និងលក្ខណវិនិច្ឆ័យចំនួន ៥ ០០០ច្បាប់ និងផលិតវីដេអូ និង ថតចម្លងដាក់ស៊ីឌីពីអត្ថប្រយោជន៍ផ្សេងៗដែលកម្មករទទួលបាន ចំនួន ៤ ០០០ស៊ីឌី ផងដែរ។

ជារួម ក្នុងរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា កន្លងទៅនេះ ការចរចាប្រាក់ឈ្នួលអប្បបរមាត្រូវបានធ្វើឡើងនូវក្នុងបរិយាសកាសមួយប្រកបដោយភាពសុខដុមនៅក្នុងវិស័យការងារ និងប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង បានកើនឡើងជាលំដាប់ ពោលគឺកើនឡើងពី ១០០ ដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ២០១៤ ដល់ ១៧០ ដុល្លារអាមេរិក នៅឆ្នាំ២០១៨ ហើយសម្រាប់ឆ្នាំ២០១៩ ប្រាក់ឈ្នួលអប្បរមា

សម្រាប់កម្មករនិយោជិតក្នុងវិស័យនេះ នឹងកើនឡើងដល់ ១៨២ដុល្លារអាមេរិក ហើយប្រសិនបើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម កម្មករ និយោជិតម្នាក់ អាចទទួលបានប្រាក់ឈ្នួលពី ១៩៩ ទៅ ២១០ដុល្លារអាមេរិក ក្នុងមួយឆ្នាំនៅឆ្នាំ២០១៩។ ប្រសិនបើធ្វើការប្រៀបធៀបជាមួយបណ្តាប្រទេសដែលមានស្ថានភាពសេដ្ឋកិច្ច និងសង្គមប្រហាក់ប្រហែលគ្នា ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨នេះ ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាមានការកើនឡើងជាលំដាប់ប្រមាណជា ១៧% ជាមធ្យមប្រចាំឆ្នាំ ឬកំណើនបានកើនឡើងជិត ០២ (ពីរ) ដង ខណៈដែលបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់មានដូចជាប្រទេសវៀតណាម ថៃ ភូមា បង់ក្លាដែស បានដំឡើងប្រាក់ឈ្នួលអប្បបរមារបស់ខ្លួនក្នុងអត្រាកំណើនទាប ឬមិនទៀងទាត់។

**រូបភាពទី១: ការវិវឌ្ឍប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជានិងប្រទេសក្នុងតំបន់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨**




បន្ថែមលើសមិទ្ធផលនៃការដំឡើងប្រាក់ឈ្នួលអប្បបរមា និងដើម្បីធានាបាននូវយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមាមួយដែលធានាឱ្យបាននូវសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ក៏ដូចជាការលើកកម្ពស់កម្រិតជីវភាពរបស់កម្មករនិយោជិត ព្រមទាំងធានានូវស្ថិរភាព និរន្តរភាព នៃវិស័យពាណិជ្ជកម្ម និងការទាក់ទាញការវិនិយោគបន្ថែម ក្រសួងបានរៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ស្របតាមច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិខាងការងារដែលច្បាប់នេះត្រូវបានរៀបចំសេចក្តីព្រាងដំបូងនៅឆ្នាំ២០១៦ ហើយត្រូវបានរដ្ឋសភាអនុម័ត និងប្រកាសឱ្យប្រើនៅឆ្នាំ២០១៨។

### ២.១.៤. ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

ការងារកំណែទម្រង់ច្បាប់ គឺត្រូវបានចាត់ទុកជាអាទិភាពមួយរបស់រាជរដ្ឋាភិបាលគ្រប់អាណត្តិ ដែលត្រូវបានដាក់ចេញយ៉ាងច្បាស់តាមរយៈយុទ្ធសាស្ត្រចតុកោណ ទាំង៣ដំណាក់កាលកន្លងមក។ ឈរលើមូលដ្ឋាននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងគោលដៅលើកកម្ពស់ការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងគោលដៅដើម្បីពង្រឹងប្រសិទ្ធភាព ការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត ធានាការទុកចិត្តពីសំណាក់វិនិយោគិន និងធុរជន ក្រសួងបានខិតខំក្នុងការរៀបចំកសាង និងធ្វើវិសោធនកម្មនូវ

លិខិតបទដ្ឋានគតិយុត្តរបស់វិស័យឱ្យស្របតាមដំណើរវិវត្តនៃសង្គម និងសេដ្ឋកិច្ចកម្ពុជា ពិសេស ដើម្បីដើរឱ្យស្របតាមភាពរីកចម្រើនរបស់ប្រទេសជាតិ និងសកលលោកក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថលនេះ។

តាមរយៈនេះ ក្នុងគោលដៅការធានាបាននូវភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ក្រសួងបានរៀបចំកសាងច្បាប់ស្តីពីសហជីព ដែលមានគោលបំណង÷ ទី១) ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់បងប្អូនកម្មករនិយោជិត ទី២) ធានានូវសិទ្ធិសេរីភាពនៃអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជក ទី៣) ជំរុញឱ្យមានសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ទី៤) រួមចំណែកក្នុងការបង្កើតការងារសមរម្យ បង្កើនផលិតភាពដើម្បីអភិវឌ្ឍប្រទេសជាតិ និងលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិត។ ជាមួយគ្នានេះ ក្រសួងបានរៀបចំប្រកាសចំនួន ៨ បន្ថែម ដើម្បីអនុវត្តច្បាប់ស្តីពីសហជីពឱ្យកាន់តែប្រសើរ និងគ្រប់ជ្រុងជ្រោយ រួមមានប្រកាសស្តីពីការចុះបញ្ជីសហជីព និងសមាគមនិយោជក, ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារ, ប្រកាសស្តីពីនីតិវិធីនៃការធ្វើឧបាស្រ័យលើចំណាត់ការរបស់មន្ត្រីដែលទទួលបានប្រតិភូកម្មមុខងារ, ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា, ប្រកាសស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទាន សហជីព និងប្រាក់សេវាភ្នាក់ងារ, ប្រកាសស្តីពីបែបបទនៃការថែរក្សាកំណត់ត្រាហិរញ្ញវត្ថុរបស់សហជីព ឬសមាគម និយោជក, ប្រកាសស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស-គ្រឹះស្ថាន, ប្រកាសស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត។

ក្នុងគោលបំណងធានាការការពារអត្ថប្រយោជន៍ជូនបងប្អូនកម្មករនិយោជិត ការសម្រាលបន្ទុកនិយោជកក្នុងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ការជៀសវាងការរក្សាទុកប្រាក់បំណាច់អតីតភាព រហូតដល់ពេលបញ្ចប់កិច្ចសន្យា និងការលើកកម្ពស់ភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការកាត់បន្ថយការតវ៉ាទាមទារក្នុងការទូទាត់ប្រាក់បំណាច់ផ្សេងៗ ក្រសួងបានធ្វើវិសោធនកម្មមាត្រា៨៧ ចំណងជើងចំណុច “គ” ផ្នែកទី៣ នៃជំពូកទី៤ មាត្រា៨៩ មាត្រា៩០ មាត្រា៩១ មាត្រា៩៤ មាត្រា១១០ មាត្រា១២០ និងមាត្រា១២២ នៃច្បាប់ស្តីពីការងារដែលត្រូវបានប្រកាសឱ្យប្រើ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។ យោងតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្រសួងបានចេញប្រកាសស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ ដើម្បីកំណត់អំពីបែបបទ និងការគណនាប្រាក់បំណាច់អតីតភាពការងារ និងការបើករំលឹកប្រាក់បំណាច់អតីតភាពការងារ ជូនកម្មករនិយោជិត ដែលកំពុងបំពេញការងារក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ និងប្រកាសស្តីពីការបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត ក្នុងគោលបំណងពង្រឹងការអនុវត្តបទប្បញ្ញត្តិនៃមាត្រា១១៦ នៃច្បាប់ស្តីពីការងារ។

បន្ថែមលើនេះទៀតដោយមើលឃើញពីភាពចាំបាច់នៃការដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មកនិយោជិតនៅឆ្នាំ២០១៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តួចផ្តើមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដោយប្រែក្លាយគោលការណ៍ដែលបានព្រមព្រៀងរវាងត្រីភាគីកាលពីសិក្ខាសាលាថ្នាក់ជាតិ នាខែមេសា ឆ្នាំ២០១៤ ឱ្យក្លាយជាច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចអនុវត្តបានដោយប្រសិទ្ធភាព។ ដោយ

ផ្អែកលើការអនុវត្តកន្លងមក យន្តការដែលទទួលបានការឯកភាពគ្នានេះបានធ្វើឱ្យការពិភាក្សា ប្រាក់ឈ្នួលអប្បបរមាកាន់តែមានភាពចាស់ទុំជាងមុន ហើយភាគីពាក់ព័ន្ធកាន់តែទទួលបានទំនុកចិត្ត ទៅលើអត្រាកំណើននៃប្រាក់ឈ្នួលអប្បបរមា។ ច្បាប់នេះមានគោលបំណង ***ទី១)*** លើកកម្ពស់ជីវភាពរស់នៅសមរម្យថ្លៃថ្នូរ បង្កើតឱកាសការងារ និងបង្កើនផលិតភាពរបស់កម្មករនិយោជិត និង ***ទី២)*** ជំរុញឱ្យមានបរិយាកាសវិនិយោគ និងធុរកិច្ចកាន់តែប្រសើរប្រកបដោយភាពទាក់ទាញ។ ក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាត្រូវបានបង្កើតឡើងដោយច្បាប់នេះ ដើម្បីជាយន្តការត្រីភាគីសម្រាប់សិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍អំពីប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗរបស់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ជាមួយកម្មវិធីកំណែទម្រង់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជារបស់ក្រសួង ការរៀបចំធ្វើវិសោធនកម្មនូវច្បាប់សំខាន់ៗ ដើម្បីការពារនូវផលប្រយោជន៍ជាមូលដ្ឋានរបស់កម្មករនិយោជិត ដូចបានលើកឡើងខាងលើ ក្រសួងក៏បានរៀបចំពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាច្រើនផ្សេងទៀត ដូចជា នៅក្នុងការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការគ្រប់គ្រងហត្ថពលកម្មខ្មែរ និងបរទេស ការលើកកម្ពស់ប្រសិទ្ធភាពនៃអធិការកិច្ចការងារ ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារការចុះបញ្ជីអង្គការវិជ្ជាជីវៈ ការលើកកម្ពស់អភិបាលកិច្ច សុទ្ធតែត្រូវបានពិនិត្យកែសម្រួលឱ្យស្របតាមស្ថានភាពវិវត្តរបស់វិស័យ និងតម្រូវការរបស់កម្មករនិយោជិត។

### ២.១.៥. ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ

ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ គឺជាការងារអាទិភាពមួយដែលក្រសួងបានផ្តោតយកចិត្តទុកដាក់ក្នុងអាណត្តិរបស់ខ្លួន។ ក្រសួងបានអនុវត្តតាមផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០១៦-២០២៥ និងបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលនយោបាយប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ពលកម្មកុមារដែលផ្តោតទៅលើអភិក្រមគន្លឹះចំនួនពីរ គឺ ១) ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារគ្រប់ប្រភេទ និងការដកហូតការប្រើប្រាស់កម្លាំងពលកម្មកុមារ ២) ការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ និងស្ត្រី។ តាមរយៈនេះ ក្នុងការងារទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្រសួងបានចុះអធិការកិច្ចសហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតវ័យក្មេងស្របតាមគោលការណ៍មានចំនួន ១៤៦ សហគ្រាស-គ្រឹះស្ថាន ចំណែកឯសហគ្រាសដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេងមានចំនួន ៧៧ សហគ្រាស- គ្រឹះស្ថាន ដែលក្នុងនោះកម្មករនិយោជិតវ័យក្មេងចាប់ពីអាយុ១៥ ដល់ក្រោម១៨ឆ្នាំ ចំនួន ២ ៩៩៣នាក់ (ស្រី ២ ៩៩២នាក់) ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់តាមគោលការណ៍របស់ក្រសួង។ ទន្ទឹមនឹងនេះពលកម្មកុមារចំនួន ២៧ ៥៤៩ នាក់ (ស្រីចំនួន ១៤ ៦៩៩នាក់) ត្រូវបានដកហូត ទប់ស្កាត់ និងសមាហរណកម្មទៅក្នុងសង្គមជាតិវិញតាមរយៈសេវាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើតមុខរបរ ។

## ២.១.៦. ការលើកកម្ពស់សុខភាព និងសុវត្ថិភាពនៅកន្លែងការងារ

ដើម្បីបង្កើនប្រសិទ្ធភាពការងារលើវិស័យសុខភាព និងសុវត្ថិភាពការងារ ក្រសួងបានកែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីសុខភាព និងសុវត្ថិភាពការងារបន្ថែម និងបង្កើតគណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ ដើម្បីពិភាក្សាអំពីវិធានការទប់ស្កាត់និងដោះស្រាយករណីដួលសន្លប់ និងដើម្បីដាក់ចេញនូវវិធានការឱ្យគ្រប់សហគ្រាស-គ្រឹះស្ថាន ពិនិត្យលក្ខណៈបច្ចេកទេស និងស្ថានភាពជុំវិញរោងចក្រ សំដៅបង្ការការដួលសន្លប់ដោយកន្លងមកក្រសួងបានចេញសេចក្តីជូនដំណឹងពាក់ព័ន្ធនឹងសុវត្ថិភាពឡចំហាយនិងបរិយាកាសនៅកន្លែងធ្វើការ ដើម្បីបង្ការករណីដួលសន្លប់ និងគ្រោះថ្នាក់ការងារនៅតាមសហគ្រាស-គ្រឹះស្ថាន ឱ្យមានសុវត្ថិភាព មុនពេលចូលធ្វើការ ដើម្បីបង្ការការដួលសន្លប់ ព្រមទាំងបានរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស-គ្រឹះស្ថាន។

ក្រសួងក៏បានផ្តល់សេវាសាធារណៈក្នុងការពិនិត្យកាយសម្បទាជូនមន្ត្រីរាជការ សិស្ស និស្សិត កម្មករនិយោជិតខ្មែរ និងជនបរទេស សរុបចំនួន ១ ៣៦១ ១២៨នាក់ ដែលក្នុងនោះកម្មករនិយោជិតខ្មែរមានចំនួន ១ ២៦៧ ៦៣៣នាក់ បានបញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសសរុបចំនួន ៨១៨នាក់ បានផ្តល់សេវាបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារចំនួន ១០ ៣០៤នាក់ និងបានពិនិត្យសុខភាពពលករខ្មែរដែលទៅធ្វើការនៅបរទេស (សាធារណៈរដ្ឋកូរ៉េ និងជប៉ុន) សរុបចំនួន ៣៨ ៦៤៧នាក់។

**តារាងទី៦÷ ការផ្តល់សេវាសាធារណៈដល់កម្មករនិយោជិតខ្មែរបរទេស**

| បរិយាយ | | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួននិយោជិតខ្មែរបរទេសទទួលសេវាពិនិត្យកាយសម្បទាកម្មករ | សរុប | នាក់ | 234,544 | 243,011 | 245,060 | 297,665 | 340,848 | 1,361,128 |
| | ស្រី | នាក់ | 187,680 | 173,785 | 130,372 | 156,982 | 179,681 | 828,500 |
| *ចំនួនកម្មករនិយោជិតខ្មែរ* | សរុប | នាក់ | 223,409 | 223,154 | 222,878 | 274,383 | 323,809 | 1,267,633 |
| | ស្រី | នាក់ | 180,601 | 160,453 | 118,736 | 144,503 | 171,141 | 775,434 |
| *ចំនួនជនបរទេស* | សរុប | នាក់ | 11,135 | 19,857 | 22,182 | 23,282 | 17,039 | 93,495 |
| | ស្រី | នាក់ | 7,079 | 13,332 | 11,636 | 12,479 | 8,540 | 53,066 |
| បញ្ជាក់លើវិញ្ញាបនបត្រពិនិត្យកាយសម្បទាជូនជនបរទេស* | សរុប | នាក់ | n.a | n.a | n.a | 35,504 | 116,000 | 151,504 |
| បញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេស | សរុប | នាក់ | 119 | 137 | 180 | 269 | 113 | 818 |
| | ស្រី | នាក់ | 77 | 93 | 88 | 114 | 57 | 429 |
| ការផ្តល់សេវាបណ្តុះបណ្តាលស្តីពីសុខភាពនិងសុវត្ថិភាពការងារ | សរុប | នាក់ | 1,322 | 2,245 | 1,228 | 2,252 | 3,257 | 10,304 |
| | ស្រី | នាក់ | 852 | 1,511 | 595 | 1,149 | 1,797 | 5,904 |
| ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការនៅប្រទេសជប៉ុន | សរុប | នាក់ | 54 | 234 | 160 | 135 | 330 | 913 |
| | ស្រី | នាក់ | 36 | 152 | 77 | 64 | 162 | 491 |
| | សរុប | នាក់ | 5,699 | 6,985 | 10,455 | 3,850 | 10,745 | 37,734 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការនៅសាធារណៈរដ្ឋកូរ៉េ | ស្រី | នាក់ | 2,035 | 1,923 | 3,742 | 715 | 3,946 | 12,361 |

កំណត់សម្គាល់÷ *ការបញ្ជាក់លើវិញ្ញាបនបត្រពិនិត្យកាយសម្បទានជូនបរទេសចាប់ផ្តើមអនុវត្តពីឆ្នាំ២០១៧

ក្រសួងបានសហការជាមួយដៃគូពាក់ព័ន្ធរៀបចំទិវាពិភពលោកដើម្បីសុខភាព និងសុវត្ថិភាពការងារជារៀងរាល់ឆ្នាំដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធដែលមានអ្នកចូលរួមសរុប ៦ ៤១៥នាក់។ ជាងនេះទៅទៀត ការបង្ការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ ត្រូវបានជំរុញដោយក្រសួង តាមរយៈការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស-គ្រឹះស្ថានបានចំនួន ៦៤៤ នៅក្នុងនោះ មានគោលនយោបាយអេដស៍ចំនួន ៥៥៧ សហគ្រាស គ្រឹះស្ថាន និងសមាជិកគណៈកម្មការចំនួន ៦ ៣៧៨នាក់។

ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យសុខភាព និងសុវត្ថិភាពការងារ ក្រសួងបានសហការជាមួយដៃគូជាតិ និង អន្តរជាតិនានា រួមមានអង្គការអន្តរជាតិខាងការងារ ទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ និងអង្គការផ្សេងៗទៀតដើម្បីពង្រឹងសមត្ថភាពមន្ត្រី និងលើកកម្ពស់ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារថ្នាក់ជាតិ។ ក្រសួងបានបន្តអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសជាមួយទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ ព្រមទាំងបានចូលរួមកិច្ចប្រជុំកម្រិតសកលស្តីពីសុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ និងបានធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ចំនួន៣ លើក គឺ កិច្ចប្រជុំប្រចាំឆ្នាំលើកទី១៩ របស់បណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន (ASEANOSHNET), ពិធីផ្តល់ពានរង្វាន់អាស៊ានលើកទី២ ជូនដល់សហគ្រាស-គ្រឹះស្ថាន មានស្នាដៃល្អ និងល្អឥតខ្ចោះ (The ASEANOSHNET Award Ceremony for Excellence and Best Practice on OSH) ដែលមានការចូលរួមពីសហគ្រាសទទួលជ័យលាភីសរុបចំនួន ១៩ មកពីបណ្តាប្រទេសសមាជិកអាស៊ានក្នុងនោះមានតំណាងកម្ពុជាចំនួន ២ សហគ្រាស-គ្រឹះស្ថាន, និងបានរៀបចំសន្និសីទលើកទី៥ របស់បណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ានក្រោមប្រធានបទ "សុខភាព និងសុវត្ថិភាពការងារ និងសំណងគ្រោះថ្នាក់ការងារនៅក្នុងកន្លែងធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងនៅតាមជនបទ"។

### ២.២. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ក្រសួងបានបន្តការយកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលវិស័យនេះ គឺជាសសរស្តម្ភដ៏ចាំបាច់ក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្ស ដែលជាមូលដ្ឋានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដោយឈរលើស្មារតីនេះ ក្រសួងបានយកចិត្តទុកដាក់លើការអនុវត្តនូវកម្មវិធីការងារសំខាន់ ដែលរួមមាន គ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETMIS) និងការកសាងស្តង់ដាជាតិសមត្ថភាព និងការធានាគុណភាព។

### ២.២.១. ការគ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ គឺជាវិស័យអាទិភាពចម្បងមួយដែលក្រសួងបានផ្តោតការយកចិត្តទុកដាក់ពីព្រោះការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាដ៏ចាំបាច់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ដោយយល់ឃើញអំពីភាពចាំបាច់នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជំរុញការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា (CQF) និងស្តង់ដាជាតិសមត្ថភាពនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាក់ស្តែងក្នុងអាណត្តិនៃរាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភាកន្លងទៅនេះ ក្រសួងបានដាក់ចេញនូវ **គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥** ដោយបានកំណត់នូវកម្មវិធីអាទិភាពចំនួន៤គឺ ***ទី១*** ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស ***ទី២*** បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ ***ទី៣*** លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋ និង ឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឱ្យចូលរួមក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និង ***ទី៤*** លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

បន្ថែមលើនេះទៀត ដើម្បីគាំទ្រដល់ការលើកកម្ពស់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ រាជរដ្ឋាភិបាលបានបង្កើតទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVETDAY) ព្រមទាំងបានបង្កើតអនុគណៈកម្មការ និងលេខាធិការដ្ឋានសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពី អ.ប.វ ឆ្នាំ២០១៧-២០២៥ និងបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះសម្រាប់វិស័យ អ.ប.វ ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពី អ.ប.វ ឆ្នាំ២០១៧-២០២៥ នៅតាមរាជធានីខេត្ត។ ក្រសួងបានដាក់ឱ្យអនុវត្តស្តង់ដាជាតិសមត្ថភាព កម្រិត២ កម្រិត៣ កម្រិត៤ ចំនួន ៥៦, គោលការណ៍ណែនាំស្តីពីការរៀបចំផែនការ និងថវិកាដោយផ្អែកលើលទ្ធផល, គោលនយោបាយយេនឌ័រ, និងផែនការសកម្មភាពនៃអគ្គនាយកដ្ឋានអ.ប.វ ឆ្នាំ ២០១៧-២០២៥ និងផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ។

ចាប់ពីឆ្នាំ២០១៤ ដល់២០១៨ ការបណ្តុះបណ្តាលសិស្សនិស្សិតដែលស្ថិតនៅក្រោមគ្រឹះស្ថានសាធារណៈមានចំនួនសរុប ១៩២ ៩៧១នាក់ ដែលក្នុងនោះកម្រិតក្រោយឧត្តមចំនួន ៩៩នាក់ កម្រិតឧត្តម ២០ ៦៦៦ នាក់ កម្រិតជាន់ខ្ពស់បច្ចេកទេស/បរិញ្ញាបត្ររង ១២ ៨២៦នាក់ កម្រិតសញ្ញាបត្រ បច្ចេកទេសនិងវិជ្ជាជីវៈរយៈពេលវែង ៧ ៤៩២នាក់ និងកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ ១៥១ ៨៨៨នាក់។ ក្នុងចន្លោះ ឆ្នាំ ២០១៤-២០១៨ យើងសង្កេតឃើញមានកើនឡើងនៃទ្វេដងនៃចំនួនសិក្ខាកាមដែលរៀននៅកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈរយៈពេលវែង និងបច្ចេកទេសជាន់ខ្ពស់/បរិញ្ញាបត្ររង។ ចំនួនសិស្សនិស្សិតសរុបនេះបានកើនឡើងប្រមាណជា ២,៣ដង ឬស្មើនឹង ១២៦% ប្រៀបធៀបនឹងអាណត្តិទី៤ ដែលនេះបានបង្ហាញពីខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកវិសាលភាព អ.ប.វ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍធនធានមនុស្ស។

**តារាងទី៧÷ ចំនួនសិក្ខាកាម សិស្សនិស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានសារណៈក្រោមឱវាទក្រសួង**

| កម្រិត | ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ក្រោយឧត្តម | 48 | 13 | 6 | 0 | | 0 | 18 | 1 | 27 | 2 | 99 | 16 |
| 2 | ឧត្តម | 4,144 | 1,119 | 2,588 | 622 | 2,811 | 709 | 6,427 | 1,860 | 4,696 | 1,830 | 20,666 | 6,140 |
| 3 | ជាន់ខ្ពស់បច្ចេកទេស/ បរិញ្ញាបត្ររង | 1,830 | 413 | 1,650 | 250 | 1,688 | 244 | 3,525 | 906 | 4,133 | 1,020 | 12,826 | 2,833 |
| 4 | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ រយៈពេលវែង | 1,246 | 314 | 714 | 123 | 1,229 | 79 | 2,135 | 599 | 2,168 | 550 | 7,492 | 1,665 |
| 5 | វិញ្ញាបនបត្រវិជ្ជាជីវៈ | 63,034 | 35,697 | 27,686 | 15,605 | 17,800 | 9,612 | 16,233 | 7,755 | 27,135 | 15,932 | 151,888 | 84,601 |
| សរុប I | | 70,302 | 37,556 | 32,644 | 16,600 | 23,528 | 10,644 | 28,338 | 11,121 | 38,159 | 19,334 | 192,971 | 95,255 |

*កំណត់សម្គាល់÷ *ការបណ្តុះបណ្តាលនៅក្នុងគម្រោង TVETSDP មកដល់បច្ចុប្បន្នបានចំនួន ១៤ ២១២ នាក់ (ស្រី ៨ ៧២០ នាក់)*

មជ្ឈមណ្ឌល/វិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈថ្មីចំនួន ២ ត្រូវបានបង្កើតបន្ថែម រួមមាន មជ្ឈមណ្ឌល អ.ប.វ ខេត្តត្បូងឃ្មុំ នៅឆ្នាំ២០១៤ និងវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជាចិន នៅខេត្តព្រះសីហនុ នៅឆ្នាំ២០១៧, ប្រែក្លាយមជ្ឈមណ្ឌល អ.ប.វ ចំនួន ១៣ ទៅជាវិទ្យាស្ថានដែលអាចធ្វើការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/សញ្ញាបត្រវិស្វករ, និងធ្វើការដំឡើងកម្រិតបណ្តុះបណ្តាល មជ្ឈមណ្ឌល/សាលាចំនួន ១៥ ដែលអាចបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់កម្រិតជាន់ខ្ពស់បច្ចេកទេស/បរិញ្ញាបត្ររង។ ជាក់ស្តែងសម្រាប់ការបណ្តុះបណ្តាល សិស្ស និស្សិត គិតមកដល់ឆ្នាំ២០១៨ នេះ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សរុបមានចំនួន ១០៦ ក្នុងនោះគ្រឹះស្ថានសាធារណៈចំនួន ៣៩, គ្រឹះស្ថានឯកជនចំនួន ៤១, និងគ្រឹះស្ថានជាអង្គការ/សមាគមចំនួន ២៦។

បន្ថែមពីការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងក៏បានយកចិត្តទុកដាក់ក្នុងការពង្រឹងជំនាញរបស់អ្នកដែលស្ថិតនៅក្នុងទីផ្សារការងារ តាមរយៈពង្រឹងការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង នៅតាមសហគ្រាស-គ្រឹះស្ថាន។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៤ ទៅ២០១៨ ក្រសួងបានចុះអធិការកិច្ចហ្វឹកហ្វឺនកូនជាងបានចំនួន ៣ ០៨៧ សហគ្រាស-គ្រឹះស្ថាន ដែលចំនួននេះមានការកើនឡើងប្រមាណជា ៦,៩ដង ធៀបនឹងអាណត្តិទី៤។ ជាលទ្ធផល សហគ្រាស-គ្រឹះស្ថានចំនួន ២០០៨ បានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ចំនួន ៩៨ ២១៨ នាក់ (ស្រី ៧២ ១៣០នាក់) ដែលចំនួននេះមានការឡើងប្រមាណជា ៣,៦ដង ធៀបនឹងអាណត្តិទី៤។

**តារាងទី៨÷ ការធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាង**

| ល.រ | ការបរិយាយ | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនសហគ្រាសបានចុះអធិការកិច្ចហ្វឹកហ្វឺនកូនជាង | | 0 | 989 | 1,715 | 0 | 383 | 3,087 |
| ២ | ចំនួនកូនជាងត្រូវបានហ្វឹកហ្វឺន | ស.គ | 209 | 281 | 483 | 504 | 531 | 2,008 |
| | | សរុប | 11,825 | 14,096 | 21,296 | 23,301 | 27,700 | 98,218 |
| | | ស្រី | 8,601 | 10,446 | 14,310 | 18,927 | 19,846 | 72,130 |
| ៣ | ផ្តល់វិញ្ញាបនបត្រ និងប័ណ្ណទទួលស្គាល់ជំនាញ | ស.គ | 209 | 159 | 249 | 433 | 501 | 1,551 |
| | | សរុប | 11,825 | 8,752 | 11,006 | 22,312 | 25,633 | 79,528 |
| | | ស្រី | 8,601 | 6,210 | 8,020 | 18,049 | 19,050 | 59,930 |

កំណត់សម្គាល់÷ ស.គ: សហគ្រាស គ្រឹះស្ថាន

ចំពោះស្ថានភាពបុគ្គលិក សាស្ត្រាចារ្យ បម្រើការនៅតាមគ្រឹះស្ថាន អ.ប.វ សាធារណៈ គិតមកដល់ឆ្នាំ២០១៨ នេះ គឺមានបុគ្គលិកបម្រើការសរុបចំនួន ៤ ៧៤៦ នាក់ គឺកើនឡើងពី ៣ ៧០២ នាក់ នៅឆ្នាំ២០១៥ ពោលគឺកើនឡើងប្រមាណជា ២២% ដែលបង្ហាញពីការពង្រឹង និងពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងទៅតាមភាពរីកចម្រើននៃសេដ្ឋកិច្ចជាតិផងដែរ។

**តារាងទី៩÷ ស្ថានភាពបុគ្គលិក និងសាស្ត្រាចារ្យនៅគ្រឹះស្ថាន TVET សាធារណៈ**

| ឆ្នាំ | ចំនួន | ថ្នាក់ដឹកនាំ | សាស្ត្រាចារ្យ | | | អ្នកជំនាញ/សាស្ត្រាចារ្យបរទេស | បុគ្គលិក | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | | ក្របខ័ណ្ឌគ្រូ | ជាប់កិច្ចសន្យា | ជំនួយ | | ក្របខ័ណ្ឌគ្រូ | ជាប់កិច្ចសន្យា | |
| ២០១៨ | សរុប | 122 | 2,032 | 1,517 | 252 | 49 | 648 | 126 | 4,746 |
| | ស្រី | 19 | 494 | 379 | 70 | 12 | 165 | 45 | 1,184 |
| ២០១៧ | សរុប | 120 | 2,032 | 1,709 | 285 | 46 | 275 | 140 | 4,607 |
| | ស្រី | 19 | 494 | 457 | 77 | 13 | 93 | 51 | 1,204 |
| ២០១៦ | សរុប | 98 | 1,593 | 1,695 | 102 | 42 | 297 | 93 | 3,920 |
| | ស្រី | 13 | 330 | 454 | 23 | 15 | 91 | 31 | 957 |
| ២០១៥ | សរុប | 91 | 1,426 | 1,683 | 78 | 45 | 287 | 92 | 3,702 |
| | ស្រី | 12 | 293 | 469 | 18 | 17 | 76 | 29 | 914 |

ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក្រសួងបានផ្តល់សញ្ញាបត្រដល់សិស្ស និស្សិត ចំនួន ៣៥ ៨៦៥ សន្លឹក និងបញ្ជាក់លើសន្លឹកវិញ្ញាបនបត្របណ្តោះអាសន្ន និងសញ្ញាបត្រ បានចំនួន ២ ២២៤ សន្លឹក ។ ជាមួយគ្នានេះ ក្នុងគោលដៅដើម្បីលើកកម្ពស់ការចូលរួមក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងក៏បាន

ធ្វើការផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយបានរៀបចំវេទិកាទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានអ្នកចូលរួមចំនួន ១៦៩ ៥៩០ នាក់។

**តារាងទី១០÷ ការផ្សព្វផ្សាយពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (អ.ប.វ)**

| ល.រ | បរិយាយ | ឯកតា | 2015 | 2016 | 2017 | 2018 | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនអ្នកចូលរួម វេទិកា ឬទិវាជាតិ អ.ប.វ | សរុប | 4,500 | 5,000 | 9,899 | 27,453 | 46,852 |
| | | ស្រី | 1,800 | 2,000 | 4,101 | 18,690 | 26,591 |
| ២ | ចំនួនអ្នកបានការតម្រង់ទិសវិជ្ជាជីវៈ អ.ប.វ និងវេទិកាផ្សេងៗនៅថ្នាក់ក្រោមជាតិ | សរុប | 6,500 | 30,717 | 38,794 | 46,727 | 122,738 |
| | | ស្រី | 2,800 | 11,407 | 15,809 | 23,587 | 53,603 |

ចំពោះការងារទំនាក់ទំនងឧស្សាហកម្មនាអាណត្តិកន្លងមក ក្រសួងបានធ្វើការទំនាក់ទំនងជាមួយសហគ្រាស-គ្រឹះស្ថានឯកជនក្នុងកិច្ចសហការជាមួយវិស័យ អ.ប.វ បានចំនួន ២ ០០១ ដែលក្នុងនោះបានបញ្ជូនសិស្សនិស្សិតទៅធ្វើកម្មសិក្សាបានចំនួន ៦៥៧នាក់ (ស្រី ១៥៣នាក់) និងបានផ្តល់ឱកាសការងារដល់សិស្សនិស្សិតបានចំនួន១ ៧៦២នាក់(ស្រី ២១៣នាក់)។ ក្រសួងក៏បានពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារទំនាក់ទំនងឧស្សាហកម្មបានចំនួន ៣៧៩នាក់(ស្រី ១៣១នាក់)។

ក្នុងអាណត្តិរាជរដ្ឋាភិបាលកន្លងទៅ គណៈវិស្វករកម្ពុជា បានអនុវត្តការងាររបស់ខ្លួនដោយសម្រេចបានលទ្ធផល សំខាន់ៗជាអាទិ៍÷ ការជ្រើសរើស និងវាយតម្លៃវិស្វករឱ្យទទួលបានគោរម្យងារជាវិស្វករដំបូងចំនួន ១ ៥៦១នាក់(ស្រី៤៧នាក់) ការជ្រើសរើស និងវាយតម្លៃវិស្វករ និងវិស្វករអាជីពជាតិ បញ្ជូនទៅអង្គការ សហព័ន្ធវិស្វកម្មអាស៊ានដើម្បីទទួលបានគោរម្យងារ ជាវិស្វករវ័យក្មេងអាស៊ានចំនួន ១១២នាក់ (ស្រី ០៣នាក់) វិស្វករអាស៊ានចំនួន១៤០នាក់ (ស្រី ០២នាក់) វិស្វករកិត្តិយសអាស៊ានចំនួន ៥៦នាក់(ស្រី ០២នាក់) វិស្វករកិត្តិយសជាន់ខ្ពស់អាស៊ានចំនួន ២៥នាក់(ស្រី ០១នាក់) និង Distinguished Honorary Fellow ចំនួន ០៤នាក់ និងបានជ្រើសរើស និងវាយតម្លៃវិស្វករអាជីពជាតិ បញ្ជូនទៅគណៈកម្មាធិការសម្របសម្រួលវិស្វករអាជីពឆ្មើម អាស៊ាន (ACPECC) ក្របខ័ណ្ឌ MRA ដើម្បីទទួលបានគោរម្យងារជាវិស្វករអាជីពឆ្មើមអាស៊ានចំនួន ៦៧នាក់។

**តារាងទី១១÷ ការចុះបញ្ជី និងវាយតម្លៃវិស្វករ**

| ល.រ | បរិយាយ | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| 1 | វិស្វករចុះបញ្ជី | សរុប | 167 | 310 | 253 | 449 | 382 | 1,561 |
| | | ស្រី | 7 | 7 | 7 | 11 | 15 | 47 |
| 2 | វិស្វករអាជីព | សរុប | 15 | 42 | 53 | 61 | 26 | 197 |
| | | ស្រី | 1 | 0 | 0 | 1 | 1 | 3 |
| 3 | វិស្វករបរទេស | សរុប | 1 | 0 | 2 | 8 | 2 | 13 |
| | | ស្រី | 0 | 0 | 0 | 0 | 0 | 0 |



ឃ/

ជាមួយគ្នានេះ គណៈវិស្វករកម្ពុជា បានប្រមូលចងក្រងឯកសារការងារធ្វើទស្សនាវដ្ដីរបស់ គ.វិ.ក បោះពុម្ពផ្សាយទស្សនាវដ្ដី គណៈវិស្វករកម្ពុជាបានចំនួន ៤លេខ, ចងក្រង និងរៀបចំបោះពុម្ពប្រតិទិនគណៈវិស្វករកម្ពុជាចំនួន ២ លើក, ប្រមូលឯកសារនានាក្នុងការងារធ្វើបច្ចុប្បន្នភាពវេបសាយរបស់គណៈវិស្វករកម្ពុជា និងធ្វើបច្ចុប្បន្នភាព គេហទំព័ររបស់គណៈវិស្វករកម្ពុជា និងបានបើកវគ្គបំប៉នសមត្ថភាពរយៈពេលខ្លីជូនដល់វិស្វករដែលបានចុះបញ្ជីនៅគណៈវិស្វករកម្ពុជា បានចំនួន ១៦ លើក។

**២.២.២. ការកសាងប្រព័ន្ធគ្រប់គ្រងព័ត៌មានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ**

តាមរយៈគម្រោង ***"ការពង្រឹងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*** (STVET)" ក្រសួងបានរៀបចំសូចនាករការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVETMIS) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវដំណើរការការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, គោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, ទីផ្សារការងារ, កាត់បន្ថយនូវភាពមិនស៊ីគ្នារវាងតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្ម, និងបង្កើនប្រសិទ្ធភាពទីផ្សារការងារ តាមរយៈការធ្វើអន្តរាគមដូចជាការអប់រំបណ្តុះបណ្តាលជំនាញ ការផ្តល់ការគាំពារ និងប្រព័ន្ធសុវត្ថិភាពសង្គម និងការផ្តល់នូវព័ត៌មានស្តីពីការផ្គត់ផ្គង់នូវកម្លាំងពលកម្មដល់សាធារណជន។ បច្ចុប្បន្នប្រព័ន្ធនេះស្ថិតនៅក្នុងដំណាក់កាលប្រើសាកល្បង និងប្រមូលទិន្នន័យសិក្ខាកាម សិស្ស និស្សិត ដែលកំពុងសិក្សា និងបញ្ចប់ពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលស្ថិតក្រោមឱវាទក្រសួង ដែលក្រសួងមានផែនការនឹងដាក់ឱ្យដំណើរការ និងប្រើប្រាស់ប្រព័ន្ធនេះជាផ្លូវការនៅក្នុងឆ្នាំ២០១៩។

**២.២.៣. ការកសាងស្តង់ដាជាតិសមត្ថភាព និងការធានាគុណភាព**

ក្នុងការកសាងស្តង់ដាជាតិសមត្ថភាព និងការធានាគុណភាព ក្រសួងសម្រេចបានការអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពគុណវុឌ្ឍិជាតិកម្រិត ១, ២, ៣ និង ៤ សម្រាប់ ៥ វិស័យរួមមាន÷ សំណង់ មេកានិច ធុរកិច្ច/ICT អគ្គិសនី និងកម្មន្តសាល សរុបចំនួន ៣៦ មុខរបរ/១០៣ គុណវុឌ្ឍិ។ ដោយឡែកសម្រាប់កញ្ចប់ស្តង់ដាបណ្តុះបណ្តាលសមត្ថភាពគុណវុឌ្ឍិជាតិ (CQF) កម្រិត៥ ជំនាញអគ្គិសនី បានដាក់ឱ្យអនុវត្តសាកល្បងនៅ វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC), វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (PPI) និងវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេស (NTTI)។ ក្រសួងបានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន ០៤ គឺ ក្រុមប្រឹក្សាជំនាញវិស័យសំណង់ មានទីតាំងនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ, ក្រុមប្រឹក្សាជំនាញវិស័យអគ្គិសនី មានទីតាំងនៅ វិទ្យាស្ថានពហុបច្ចេកទេស ព្រះកុសុមៈ, ក្រុមប្រឹក្សាជំនាញវិស័យមេកានិករថយន្តមានទីតាំងនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង, និងក្រុមប្រឹក្សាជំនាញវិស័យកម្មន្តសាលមានទីតាំងនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា។ ហើយក្រសួងក៏បានអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF Cambodia Qualification Framework) នៅតាមគ្រឹះស្ថាន អ.ប.វ និងធ្វើការផ្ទៀងផ្ទាត់ CQF ជាមួយក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF Asean Qualifications Reference Framework) ដោយបង្កើតគណៈកម្មការសម្របសម្រួលថ្នាក់ជាតិ

(NCC) ដែលមានអនុគណៈកម្មការចំនួន០៣ គឺ÷ អនុគណៈកម្មការក្របខ័ណ្ឌគុណវុឌ្ឍិយោងអាស៊ាន (AQRF), អនុគណៈកម្មការកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក(MRA) និងអនុគណៈកម្មការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមក (MRS)។ ហើយដើម្បីជំរុញដល់ការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រការសិក្សាពេញមួយជីវិត ក្រសួងក៏បានរៀបចំផងដែរនូវគោលនយោបាយ ស្តីពីការវាយតម្លៃសមត្ថភាព និងការផ្តល់គុណវុឌ្ឍិក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធវាយតម្លៃផ្អែកលើសមត្ថភាព និងការផ្តល់គុណវុឌ្ឍិសម្រាប់កម្ពុជានៅឆ្នាំ២០១៧ ដែលរួមបញ្ចូលទាំងការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន។

ក្នុងការចូលរួមកម្មវិធីប្រកួតប្រជែងផ្នែកនវានុវត្តន៍ផ្សេងៗ ក្រសួងបានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ជាតិ ដែលមានបេក្ខជនចំនួន ១៦១រូប និងបានជ្រើសរើស បេក្ខជនចំនួន ៤៤រូប ទៅចូលរួមការប្រកួតប្រជែងជំនាញថ្នាក់ អាស៊ាន និងអន្តរជាតិ នៅក្នុងឆាកអន្តរជាតិយើងទទួលបានពានរង្វាន់ថ្នាក់លេខ១ ចំនួន ១ (China Skills), មេដាយ សំរឹទ្ធិ ចំនួន ២, Medallion of Excllent ចំនួន ១ វិញ្ញាបនបត្រល្អប្រសើរ ចំនួន ៣, និង Best of the Nation ចំនួន ៣។

ចំពោះការពង្រឹងស្តង់ដាសមត្ថភាព ក្រសួងបានយកចិត្តទុកដាក់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគាំទ្រដោយពង្រីក សាងសង់អគាររោងជាង អន្តេវាសិកដ្ឋាន និងជួសជុលអគារនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក្រសួងបានសាងសង់អគារសិក្សាចំនួន ០៩ អគាររោងជាងចំនួន ១៤ អគារអន្តេវាសិកដ្ឋានចំនួន ១០ ជួសជុលអគារចំនួន ២៤ខ្នង និងបានបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Centers of Excellence) ចំនួន ០៤កន្លែង ដោយផ្អែកកម្មន្តសាលនៅ NPIC (ភ្នំពេញ), ផ្នែកអគ្គិសនីនៅ PPI (ភ្នំពេញ), ផ្នែករថយន្តនៅវិទ្យាស្ថានបច្ចេកទេសបាត់ដំបង BIT (បាត់ដំបង), និងផ្នែកសំណង់នៅវិទ្យាស្ថានបច្ចេកទេសអង្គរ (សៀមរាប)។ ទន្ទឹមនឹងនេះ ក្រសួងបានបង្កើតគណៈកម្មការអធិការកិច្ចគ្រូបច្ចេកទេស/ឯកទេសរបស់ក្រសួង, បានរៀបចំប្រកាសស្តីពីការដាក់ឱ្យអនុវត្តលក្ខណវិនិច្ឆ័យទាំង០៦ក្នុងការធានាគុណភាពវិស័យ អ.ប.វ និងបានស្នើសុំវិញ្ញាបនបត្រធានាគុណភាពដល់គ្រឹះស្ថាន អ.ប.វ ដែលទទួលបានចំណាត់ថ្នាក់ល្អបង្គួរ ល្អ និងល្អប្រសើរ។ លើសពីនេះ គ្រឹះស្ថាន អ.ប.វ ចំនួន២០ បានទទួលវិញ្ញាបនបត្រ ISO ៩០០១-២០១៥ ដែលធ្វើការវាយតម្លៃដោយ ក្រុមហ៊ុន GIC របស់ប្រទេសសិង្ហបុរី។ ជាមួយគ្នានេះ ក្រសួងបានរៀបចំការប្រឡងជ្រើសរើស និងបានបែងចែកគរុនិស្សិតនៅតាមគ្រឹះស្ថាន អ.ប.វ រាជធានីខេត្ត ដោយផ្អែកទៅលើតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថាន អ.ប.វ។ បន្ថែមពីនេះ ក្រសួងបានធ្វើការបណ្តុះបណ្តាលបំប៉នសមត្ថភាពគ្រូបច្ចេកទេសចំនួន ២២០ នាក់ លើវិក្រឹត្យការជំនាញបច្ចេកទេស, ៦៣៦ នាក់ លើវិធីសាស្ត្របង្រៀនផ្អែកលើសមត្ថភាព, និងគ្រូបង្គោល (Master Trainers) ចំនួន ៣០ នាក់ លើវិធីសាស្ត្របង្រៀនផ្អែកលើសមត្ថភាពបន្ត (CBT Methodology) ដល់គ្រូបច្ចេកទេស និងបានរៀបចំបទដ្ឋានគតិយុត្តទទួលស្គាល់វគ្គកម្មវិធីបណ្តុះបណ្តាល និងគ្រឹះស្ថាន អ.ប.វ។

ចំពោះការងារគ្រប់គ្រងគ្រឹះស្ថានសិក្សា ចាប់ពីឆ្នាំ២០១៤ ដល់ ២០១៨ ក្រសួងបានធ្វើលិខិតគាំទ្រដល់សកម្មភាពបណ្តុះបណ្តាលរបស់អង្គការសមាគមសរុបចំនួន ២៣ បានដំឡើងកម្រិតបណ្តុះបណ្តាលចំនួន ២៥ និង បានបន្ថែមដេប៉ាតឺម៉ង់បណ្តុះបណ្តាលចំនួន ៤ ។ ជាមួយគ្នានេះចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ ក្រសួងក៏បានធ្វើការចុះពង្រឹងការគ្រប់គ្រងតាមគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួងបានចំនួន ១៨១គ្រឹះស្ថាន។

**២.៣. ការអភិវឌ្ឍមុខរបរ និងការងារ**

ការអភិវឌ្ឍមុខរបរ និងការងារ គឺជាទិសដៅយុទ្ធសាស្ត្រមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនាអាណត្តិកន្លងទៅនេះ។ ក្រសួងបានដាក់ចេញនូវ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ ២០១៥-២០២៥ ដែលជាអភិក្រមដ៏មុតស្រួចផ្សារភ្ជាប់ជាមួយសក្តានុពលនៃការរីកចម្រើនរបស់ប្រទេសជាតិក្នុងតំបន់ និងសកលលោក។ គោលនយោបាយនេះ ត្រូវបានរៀបចំឡើងឱ្យស៊ីចង្វាក់គ្នាទៅនឹងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដោយផ្តោតយ៉ាងមុតស្រួចលើសរសរស្តម្ភអាទិភាពចំនួន បី គឺ ***ទី១*** ការបង្កើតឱកាស ការងារសមរម្យ និងមានផលិតភាពការងារខ្ពស់ ***ទី២*** ជំរុញការអភិវឌ្ឍជំនាញ និងធនធានមនុស្ស និង ***ទី៣*** ការពង្រឹងអភិបាលកិច្ចទីផ្សារការងារ។ ជាលទ្ធផលនៃការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥នេះ ចំនួនអ្នកមានការងារធ្វើសរុប (អាយុ១៥ឆ្នាំ+) បានកើនឡើងពី ៨,៦លាននាក់នៅក្នុងឆ្នាំ ២០១៥ ទៅ ៩,៦ លាននាក់នៅក្នុងឆ្នាំ ២០១៨ ពោលគឺកើនឡើងប្រមាណជា ២,៥% ជាមធ្យមក្នុងមួយឆ្នាំ។ ជាមួយនឹងកំណើនការងារវិជ្ជមាននេះ អនុបាតអ្នកមានការងារធ្វើទៅនឹងប្រជាជន (អាយុ១៥ឆ្នាំ+) ដែលបង្ហាញពីលទ្ធភាពសេដ្ឋកិច្ចក្នុងការផ្តល់ការងារដល់ប្រជាជនដែលស្ថិតនៅក្នុងវ័យធ្វើការ ឬផ្តល់ការងារដល់អ្នកចង់ស្វែងរកការងារ រក្សាបាននូវអត្រាថេរ ក្នុងរង្វង់ប្រមាណជា ៨១% និងអត្រានិកម្មភាព (អាយុ១៥ឆ្នាំ+) ស្ថិតនៅក្នុងអត្រាទាបជាង ១% ក្នុងរយៈពេលដូចគ្នានេះ។ ទន្ទឹមនឹងនេះ គុណភាពនៃការងារក៏ត្រូវបានកែលម្អដែលបង្ហាញតាមរយៈការកើនឡើងនៃបរិមាណភាគច្រើននិយោជិតទទួលប្រាក់ឈ្នួលប្រមាណជា ១,៣ភាគរយពិន្ទុ ពោលគឺ កើនប្រមាណពី ៤៧,៥% នៅក្នុងឆ្នាំ ២០១៥ ទៅប្រមាណជា ៤៨,៨% នៅក្នុងឆ្នាំ២០១៨។ បន្ថែមពីលើនេះ ក្នុងអាណត្តិនេះ សម្រាប់ការអភិវឌ្ឍមុខរបរ និងការងារ ក្រសួងបានសម្រេចសមិទ្ធផលដូចខាងក្រោម÷

**២.៣.១. ការផ្តល់សេវាមុខរបរ និងការងារ**

ក្រសួងបានបន្តយកចិត្តទុកដាក់ក្នុងការងារពង្រឹងយន្តការផ្តល់សេវាមុខរបរ និងការងារឱ្យកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបបានតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា។ ជាក់ស្តែង ចាប់ពីឆ្នាំ២០១៤ ដល់២០១៨ ក្រសួងបាន÷

- ពង្រីកវិសាលភាពសេវាមុខរបរ និងការងារ ដោយបានបង្កើតមជ្ឈមណ្ឌលការងារនៅតាមរាជធានីខេត្តចំនួន ០៨ (តាកែវ កំពង់ចាម កំពង់ធំ ព្រៃវែង ព្រះសីហនុ បន្ទាយមានជ័យ ពោធិ៍សាត់ និងខេត្តស្ទឹងត្រែង) បន្ថែមទៅលើមជ្ឈមណ្ឌលការងារដែលមានស្រាប់ចំនួន ០៥ (រាជធានីភ្នំពេញ បាត់ដំបង កំពត

សៀមរាប និងស្វាយរៀង) សរុបចំនួន ១៣ និងមជ្ឈមណ្ឌលការងារចល័តចំនួន ០១។ផ្តល់សេវាប្រឹក្សាយោបល់មុខរបរ និងការងារ និងមគ្គុទេសក៍អាជីព ដល់សិស្ស និស្សិត និងអ្នកស្វែងរកការងារចំនួន ៩ ៩០៨នាក់

- រៀបចំវគ្គបណ្តុះបណ្តាលត្រៀមលក្ខណសម្បត្តិ ក្នុងការស្វែងរកការងារ និងវគ្គបណ្តុះបណ្តាលជំនាញទន់ដល់អ្នកស្វែងរកងារចំនួន ២៣១ វគ្គ ដោយមានសិក្ខាកាមចំនួន ១៣ ២០៤នាក់
- រៀបចំចងក្រងឯកសារ និងសម្ភារសម្រាប់ធ្វើមគ្គុទេសក៍អាជីព និងការប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈដូចជា÷ (១) សៀវភៅ កម្រងសំណួរស្វែងយល់ពីការរៀបចំផែនការសិក្សា និងអាជីព (២) សៀវភៅណែនាំសម្រាប់អ្នកស្វែងរកការងារធ្វើ (៣) ប័ណ្ណណែនាំស្តីពីការងារ (៤) សៀវភៅ ណែនាំអំពីអាជីពសម្រាប់យុវជនកម្ពុជា (៥) សៀវភៅស្តីពីការពិនិត្យ និងជ្រើសរើសអាជីព ឬការងារ (៦) សៀវភៅចាប់ផ្តើមការងារក្នុងក្តីសុបិនសិក្សានៅ TVET (៧) សៀវភៅណែនាំសិទ្ធិការងារសម្រាប់យុវជន និង (៨) សៀវភៅការស្វែងយល់អំពីការរៀបចំទទួលស្គាល់ទៅវិញទៅមកលើវិជ្ជាជីវៈឯកទេស ផ្នែកសេវាកម្មចំនួន ៨ ក្រោមក្របខ័ណ្ឌចល័តកម្មសេរីកម្លាំងពលកម្មជំនាញនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន
- រៀបចំសិក្ខាសាលាណែនាំអាជីព និងការងារ តាមគ្រឹះស្ថានអប់រំវិជ្ជាជីវៈ និងសាកលវិទ្យាល័យចំនួន ១៤៩សាកលវិទ្យាល័យ (១៧៧ដង) ដែលមាននិស្សិតចំនួន ១៤ ៦៤២ នាក់ និងសិក្ខាសាលាស្តីពីការរៀបចំផែនការអាជីព និងជ្រើសរើសជំនាញសិក្សាដល់សិស្សមធ្យមសិក្សាទុតិយភូមិចំនួន ៤១៣ វិទ្យាល័យ (៨២៤ដង) ដែលមានសិស្សចំនួន ៥២ ១៥៧ នាក់
- បង្កើនសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសចំនួន៩២ នាក់ រួមមាន÷ (១) ជំនាញនៅកន្លែងការងារ (២) ការផ្តល់សេវាទៅដល់អតិថិជន (៣) ការអនុវត្ត(5s) នៅកន្លែងការងារ (៤) ការផ្តល់ប្រឹក្សាយោបល់អំពីអាជីព (៥) សេវាការងារសាធារណៈ (៦) ភាពជាអ្នកដឹកនាំ (៧) ផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរ (៨) ប្រព័ន្ធអប់រំទ្វេ នៅគ្រឹះស្ថានសិក្សា និងសហគ្រាស និងសេវាណែនាំអាជីព (៩) គោលនយោបាយ និងការអនុវត្តមគ្គុទេសក៍អាជីព
- អភិវឌ្ឍន៍ និងជំរុញការប្រើប្រាស់គេហទំព័រការងារ សម្រាប់ផ្តល់សេវាចុះឈ្មោះអ្នកស្វែងរកការងារ និងជ្រើសរើសកម្លាំងពលកម្ម ងាយស្រួល ឆាប់រហ័ស និងគ្រប់ពេលវេលា ដែលចំនួនចូលប្រើប្រាស់គេហទំព័រ NEA បានកើនឡើងប្រមាណពី ៥ ៥០៩ ៧២៤ លើក នៅក្នុងឆ្នាំ២០១៤ ដល់ប្រមាណជា ១៧ ៨០២ ២៣៤ លើក នៅក្នុងឆ្នាំ២០១៨
- បង្កើតកម្មវិធីសម្រាប់រកការងារតាមស្មាតហ្វូន (NEA Job Search) ដែលមានអ្នកទាញយកមកប្រើប្រាស់សរុបចំនួន ៨ ៩២៣ នាក់ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨
- បានចុះឈ្មោះជួយស្វែងរកការងារដល់កម្មករនិយោជិតចំនួន៦ ៨៩៥ នាក់ ដែលរោងចក្របានបិទទ្វារ (ម្ចាស់រត់ចោល) ចំនួន ១៨ រោងចក្រ ដែលក្នុងនោះអ្នកដែលមានការងារធ្វើចំនួន ៤ ៤៦៥ នាក់

- បានចុះផ្សព្វផ្សាយពីសេវា MRC និងបានចុះឈ្មោះអ្នកស្វែងរកការងារដល់ពលករចំណាកស្រុកមកពីប្រទេសថៃ ក្នុងឆ្នាំ២០១៤ ដល់២០១៨ ចំនួន ២លើក សរុបចំនួន ២០ ១៨៦ នាក់
- នៅឆ្នាំ២០១៤NEA បានក្លាយជាសមាជិកសមាគមផ្តល់សេវាការងារសាធារណៈពិភពលោក(WAPES) ដែលមានប្រទេសជាសមាជិក ចំនួន ៩៣
- បានពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដើម្បីស្វែងរកធនធានហិរញ្ញវត្ថុបច្ចេកទេសបន្ថែមពីដៃគូអភិវឌ្ឍន៍រួមមាន÷ KEIS, UNDP, ILO, SIDASPES, JICA, BBC Media Action, Winrock, Finn Church, និងដៃគូសហការដូចជាគ្រួសារថ្មី, ACTED, SwissContact, Caritas Cambodia, IOM, Amcham, CAMFEBA, GMAC, HRINC, CGTI។

ក្នុងការពង្រឹងយន្តការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារដើម្បីពង្រឹងយន្តការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក្រសួងបាន÷

- ពង្រឹង និងពង្រីកយន្តការ “វេទិកាការងារ ” ដែលមានការចូលរួមពីសំណាក់និយោជក អ្នកស្វែងរកការងារធ្វើនិងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាលដោយ÷
  - បានរៀបចំពិព័រណ៌ការងារថ្នាក់ជាតិចំនួន ០៥ ដង និងយុទ្ធនាការផលិតភាពជាតិចំនួន០២ ដង មានអ្នកចូលរួមចំនួន ៩៨១២៥ នាក់ និងនិយោជកចំនួន៥៣៤ ក្រុមហ៊ុន និងពិព័រណ៌ការងារថ្នាក់ខេត្តចំនួន ០២ ដង មានអ្នកចូលរួម ៦ ១០៥ នាក់ និងនិយោជកចំនួន ៩០ ក្រុមហ៊ុន
  - បានរៀបចំវេទិកាផ្សព្វផ្សាយ និងជួយចុះឈ្មោះអ្នកស្វែងរកការងារ និងជ្រើសរើសកម្លាំងពលកម្មងាយស្រួល ឆាប់រហ័យ នៅតាមមូលដ្ឋានរាជធានីខេត្ត ចំនួន ២៤៦ ដង មានអ្នកចូលរួមចំនួន ៤ ១១៤ នាក់ និងសិក្ខាសាលាជាមួយនិយោជក និងសហជីពចំនួន ៤១ ដង មានអ្នកចូលរួមចំនួន ១ ៣០៧ នាក់
  - បានរៀបចំទិវាជ្រើសរើសកម្លាំងពលកម្ម នៅតាមមជ្ឈមណ្ឌលការងារ និងតាមមូលដ្ឋានចំនួន ២៩៥ ដង ដែលមាននិយោជកចំនួន ២២៨ ក្រុមហ៊ុន និងអ្នកស្វែងរកការងារមានចំនួន ៤៨ ៣៨៣ នាក់។
- បានរៀបចំកិច្ចសម្ភាសន៍ការងារប្រចាំខែចំនួន ២៨ ដង ដែលមានអ្នកចូលរួមចំនួន ១ ៧០១នាក់
- រៀបចំពិព័រណ៍ផ្សព្វផ្សាយចល័ត និងចូលរួមពិព័រណ៍ផ្សេងៗចំនួន ៥៣៣ដង ដែលមានអ្នកចូលរួមចំនួន ៧២ ០៦ នាក់។

## តារាងទី១២÷ ការពង្រឹងយន្តការផ្តល់សេវាមុខរបរ និងការងារ

| ល.រ | សកម្មភាព | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | អ្នកចុះឈ្មោះស្វែងរកការងារ | ស្រី | 10,548 | 4,550 | 7,023 | 7,588 | 8,963 | 38,672 |
| | | សរុប | 25,501 | 9,519 | 13,480 | 15,133 | 16,527 | 80,160 |
| ២ | ផ្គូរផ្គង និងបញ្ជូនអ្នកស្វែង រក ការងារ ទៅនិយោជក | ស្រី | 3,789 | 2,622 | 5,681 | 8,350 | 12,810 | 32,252 |
| | | សរុប | 7,402 | 6,129 | 11,281 | 16,072 | 24,452 | 65,336 |
| ៣ | អ្នកទទួលបានការងារធ្វើ | ស្រី | 1,455 | 774 | 1,536 | 1,923 | 3,176 | 8,864 |
| | | សរុប | 2,925 | 1,394 | 2,443 | 3,412 | 5,650 | 15,824 |
| ៤ | ប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈ | នាក់ | n.a | n.a | 2,967 | 2,597 | 4,344 | 9,908 |
| ៥ | វគ្គបណ្តុះបណ្តាលត្រៀមលក្ខណៈសម្បត្តិស្វែងរកការងារធ្វើ និង ជំនាញទន់ | វគ្គ | 135 | 155 | 52 | 62 | 117 | 231 |
| | | អ្នកចូលរួម | 3,374 | 3,677 | 1,332 | 1,603 | 3,217 | 13,204 |
| ៦ | សិក្ខាសាលាណែនាំពីអាជីព ការងារ និងវិជ្ជាជីវៈ នៅតាមសកលវិទ្យាល័យ TVET និង តាមវិទ្យាល័យ | វគ្គ | 56 | 125 | 271 | 306 | 243 | 1,000 |
| | | អ្នកចូលរួម | 8,474 | 11,373 | 16,388 | 17,578 | 12,986 | 66,799 |

ចំណាំ÷ N/A: មិនទាន់អនុវត្ត

ក្នុងការពង្រឹងយន្តការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារដើម្បីពង្រឹងយន្តការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីព័ត៌មានទីផ្សារការងារ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ក្រសួងបាន÷

- ប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៣៥៧ ០៥១ នាក់ តាមរយៈគេហទំព័រមជ្ឈមណ្ឌលការងារ NEA Facebook និងកម្មវិធីនាទី ទីផ្សារការងារ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៤ ដល់២០១៨ បានរៀបចំចងក្រង និងបោះពុម្ពផ្សាយព្រឹត្តិបត្តការងារ ប្រចាំខែចំនួន ៦០លេខ និងផលិតកម្មវិធីទូរទស្សន៍នាទីទីផ្សារការងារ និងមុខរបរចំនួន ២៥៤ វ៉ុល, អ្នកចូលប្រើប្រាស់គេហទំព័រ Facebook ចំនួន ១៤០ ០៥៦ នាក់, និង YouTube ចំនួន ៨៧ ៩៧៤ នាក់
- បានធ្វើការអង្កេត ចងក្រង វិភាគ បោះពុម្ពផ្សាយរបាយការណ៍មានដូចជា (១)តម្រូវការជំនាញរបស់និយោជកក្នុងឆ្នាំ២០១៤ ២០១៥ និងឆ្នាំ២០១៧ (២)របាយការណ៍បឋមស្តីពីជំនាញសម្រាប់ពាណិជ្ជកម្ម និងពិពិធកម្មសេដ្ឋកិច្ច (STED) ក្នុងវិស័យឧស្សាហកម្មធុនស្រាល និងកែច្នៃចំណីអាហារឆ្នាំ២០១៦ (៣)របាយការណ៍ទស្សនៈវិស័យការងារកម្ពុជាឆ្នាំ២០១៨ (៤)របាយការណ៍ស្តីពីស្ថានភាពសិស្ស និស្សិតក្រោយបញ្ចប់ការសិក្សាឆ្នាំ២០១៦ និងឆ្នាំ២០១៨ (៥)របាយការណ៍ប្រចាំឆ្នាំស្តីពី Labour Market Update

- បានពង្រឹងសមត្ថភាពមន្ត្រីក្នុងការវិភាគ និងព្យាករណ៍ព័ត៌មានទីផ្សារការងារ តាមរយៈការបញ្ជូនមន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត ស្តីពីសេដ្ឋកិច្ចការងារ នៅប្រទេសអ៊ីតាលី, មន្ត្រី ០១រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាករណ៍ និងការផ្គូផ្គងជំនាញនៅប្រទេសអ៊ីតាលី, មន្ត្រី ០៨ រូប ចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិភាគព័ត៌មានទីផ្សារការងារ នៅប្រទេសស៊ុយអ៊ែត, និងបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុងចំនួន ០៥ លើក។

**តារាងទី១៣÷ ការពង្រីកយន្តការផ្សព្វផ្សាយ និងអភិវឌ្ឍព័ត៌មានទីផ្សារការងារ**

| ល.រ | សកម្មភាព | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | វេទិកាការងារ | ចំនួនដង | 107 | 174 | 211 | 251 | 230 | 973 |
| | | អ្នកចូលរួម | 47,715 | 34,374 | 38,405 | 37,130 | 92,607 | 250,231 |
| ២ | ប្រមូលព័ត៌ និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្ម | កន្លែង | 67,735 | 49,483 | 62,420 | 88,875 | 83,538 | 357,051 |
| ៣ | សិក្ខាសាលាជាមួយនិយោជក និងសហជីព | ចំនួនដង | n.a | n.a | 12 | 12 | 17 | 41 |
| | | អ្នកចូលរួម | n.a | n.a | 334 | 367 | 606 | 1,307 |
| ៤ | អ្នកចូលប្រើប្រាស់គេហទំព័រ Facebook និង YouTube | នាក់ | n.a | 40,331 | 41,089 | 96,201 | 103,121 | 280,742 |

ចំណាំ÷ N/A: មិនទាន់អនុវត្ត

ដោយផ្អែកលើទិន្នន័យរដ្ឋបាលនៃការចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថាននៅក្រសួង ចំនួនសហគ្រាស-គ្រឹះស្ថានមានការកើនឡើងពី ៦ ៩៦៩ ទៅ ១២ ៧៨៦ ឬកើនប្រមាណជា ៨៣,៦% ក្នុងចន្លោះឆ្នាំ២០១៤ និង២០១៨។ ទន្ទឹមនឹងនេះ ចំនួនការងារក៏បានកើនឡើងប្រមាណពី ៨២៤ ៣៥២ ទៅ ១ ៣២០ ៥៤៧ ឬស្មើនឹង ៦០,១%។ ប្រសិនបើយើងពិនិត្យនៅក្នុងឆ្នាំ ២០១៨ សហគ្រាស-គ្រឹះស្ថានស្ថិតនៅក្នុងវិស័យកាត់ដេរមានចំនួនប្រមាណជា ៩,១% នៃសហគ្រាស-គ្រឹះស្ថានសរុប តែស្រូបយកកម្លាំងពលកម្មរហូតដល់ប្រមាណជា ៦២,៣% នៃការងារសរុប ខណៈដែលវិស័យក្រៅពីកាត់ដេរមានសហគ្រាស-គ្រឹះស្ថានប្រមាណ ៩០,៩% ប៉ុន្តែការស្រូបយកកម្លាំងពលកម្មមានត្រឹមតែ ៣៧,៧% ប៉ុណ្ណោះ។

**តារាងទី១៤÷ ស្ថិតិស្តីពីចំនួនសហគ្រាស គ្រឹះស្ថាន និងចំនួនកម្មករនិយោជិត**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| កាត់ដេរ | សហគ្រាសគ្រឹះស្ថាន | 904 | 1 099 | 1 107 | 1 147 | 1 159 |
| | កម្មករនិយោជិត | 564 822 | 666 883 | 743 615 | 763 820 | 822 007 |
| | ស្រី | 487 663 | 562 574 | 643 714 | 651 485 | 687 952 |
| ក្រៅពីកាត់ដេរ | សហគ្រាសគ្រឹះស្ថាន | 6 065 | 7 193 | 10 061 | 10 250 | 11 637 |
| | កម្មករនិយោជិត | 259 530 | 307 935 | 443 612 | 444 502 | 498 540 |
| | ស្រី | 134 179 | 152 828 | 187 390 | 209 457 | 209 275 |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | សហគ្រាសគ្រឹះស្ថាន | 6 969 | 8 292 | 11 168 | 11 397 | 12 796 |
| | កម្មករនិយោជិត | 824 352 | 974 818 | 1 187 227 | 1 208 322 | 1 320 547 |
| | ស្រី | 621 842 | 715 402 | 831 104 | 860 942 | 897 227 |

### ២.៣.២. ការពង្រឹងការគ្រប់គ្រងកម្លាំងពលកម្មក្នុងប្រទេស

ចាប់ពីឆ្នាំ២០១៤-២០១៨ អ្នករកការងារធ្វើនៅក្នុងស្រុកដោយខ្លួនឯងមានចំនួនសរុប ៥៦៧ ៥៦៧នាក់ (ស្រី ៣៩៩ ៨០០នាក់) ហើយយើងឃើញថាចំនួនអ្នករកការងារដោយខ្លួនឯងនៅក្នុងស្រុកកើនឡើងទ្វេដង ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ ចាប់ពីឆ្នាំ២០១៤-២០១៨ នេះ ក្រសួងបានផ្តល់សៀវភៅការងារបានចំនួនសរុប ១ ១១៧ ២៥០ ក្បាល, ចុះទិដ្ឋាការចូលចំនួន ១៥៦ ៤៧៩ នាក់, ចុះទិដ្ឋាការចេញចំនួន ៣១ ៨០៣ នាក់, និងបានប្រមូលអាករចូលរដ្ឋបានចំនួន ១១ ១៧២,៥ លានរៀល។

**តារាងទី១៥៖ ការងារត្រួតពិនិត្យកម្មករនិយោជិតខ្មែរចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ផ្តល់សៀវភៅការងារ | នាក់ | 166,151 | 200,974 | 221,277 | 247,796 | 281,052 | 1,117,250 |
| ចុះទិដ្ឋាការចូល | នាក់ | 30,550 | 34,240 | 34,264 | 30,577 | 26,848 | 156,479 |
| ចុះទិដ្ឋាការចេញ | នាក់ | 1,990 | 2,539 | 3,114 | 8,095 | 16,065 | 31,803 |
| អាករសរុបប្រមូលបាន | លានរៀល | 1,661.51 | 2,009.74 | 2,212.77 | 2,477.96 | 2,810.52 | 11,172.50 |

### ២.៣.៣. ការគ្រប់គ្រង និងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

ក្រសួងបានរៀបចំ និងអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៥ និង២០១៨ ដែលផ្តោតសំខាន់លើ អភិបាលកិច្ចនៃទេសន្តរប្រវេសន៍, ការការពារនិងការលើកកម្ពស់សិទ្ធរបស់ពលករទេសន្តរប្រវេសន៍, និងការរៀបចំទេសន្តរប្រវេសន៍ការងារដើម្បីអភិវឌ្ឍន៍។

ទន្ទឹមនឹងការខិតខំប្រឹងប្រែងរកការងារក្នុងប្រទេសតាមរយៈនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ក្រសួងក៏បាន ស្វះស្វែងជួយរកការងារនៅក្រៅប្រទេសបន្ថែមសម្រាប់ប្រជាពលរដ្ឋ ដើម្បីធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅ ការទទួលបានមកវិញនូវកម្លាំងពលកម្មជំនាញសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង គិតចាប់ពីការបញ្ជូនពលករទៅធ្វើការនៅបរទេសរហូតមកដល់ឆ្នាំ២០១៨នេះ ពលករកម្ពុជាដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស មានចំនួន ១ ៥០៥ ៧២៣ នាក់ (ស្រី ៦១២ ៨៩៣ នាក់) ហើយបើគិតចន្លោះឆ្នាំ២០១៤-២០១៨ ការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេសមានចំនួន ៧៧៩ ២៨១ នាក់ (ស្រី៣២១ ៣៨៣ នាក់) ហើយបើគិតដល់ឆ្នាំ២០១៨ នេះ ពលករកម្ពុជាដែលកំពុងធ្វើការ និងស្នាក់នៅបរទេសមានចំនួន ១ ២៣៤ ១១១ នាក់ (ស្រី ៤៩៩ ០៧០នាក់) ក្នុងនោះ នៅប្រទេសថៃចំនួន ១ ១៤៦ ៦៨៥ នាក់, កូរ៉េចំនួន ៤៩ ០៩៩ នាក់, ម៉ាឡេស៊ីចំនួន ៣០ ១១៣ នាក់, ជប៉ុនចំនួន ៧ ៣១៣ នាក់, សឹង្ហបុរីចំនួន ៨៣១នាក់, អារ៉ាប់ប៊ីសាអូឌីតចំនួន ១៦នាក់, និងតំបន់រដ្ឋបាល ពិសេសហុងកុង ចំនួនចំនួន ៥៤ នាក់។

**តារាងទី១៦÷ ពលករពលការិនីខ្មែរដែលត្រូវបានបញ្ជូន និងបាននឹងកំពុងស្នាក់នៅ និងធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគណៈកម្មការបណ្តុះបណ្តាល និងបញ្ជូនពលករនៅធ្វើការនៅបរទេស**

| ល.រ | បរិយាយ | | ការបញ្ជូនពលករទៅធ្វើការនៅបរទេសមុនឆ្នាំ២០១៤ | ការបញ្ជូនពលករទៅធ្វើការនៅបរទេសចន្លោះឆ្នាំ២០១៤-២០១៨ | ពលករដែលត្រឡប់មកប្រទេសវិញចន្លោះឆ្នាំ២០១៤-២០១៨ | ពលករដែលកំពុងស្នាក់នៅនិងធ្វើការនៅបរទេសគិតមកដល់ឆ្នាំ២០១៨ |
|---|---|---|---|---|---|---|
| ១ | ថៃ (១.១)+(១.២) | សរុប | 651,945 | 734,754 | 240,014 | 1,146,685 |
| | | ស្រី | 247,235 | 306,607 | 95,815 | 458,027 |
| ១.១ | *តាមរយៈMoU* | សរុប | 83,415 | 307,913 | 67,732 | *323,596* |
| | | ស្រី | 30,841 | 124,844 | 26,934 | *128,751* |
| ១.២ | *តាមរយៈផ្តល់ភាពស្របច្បាប់* | សរុប | 568,530 | 426,841 | 172,282 | *823,089* |
| | | ស្រី | 216,394 | 181,763 | 68,881 | *329,276* |
| ២ | ម៉ាឡេស៊ី | សរុប | 45,141 | 1,480 | 16,508 | 30,113 |
| | | ស្រី | 39,116 | 995 | 14,239 | 25,872 |
| ៣ | អារ៉ាប់ប៊ីសាអូឌីត | សរុប | n.a | 28 | 12 | 16 |
| | | ស្រី | n.a | 28 | 12 | 16 |
| ៤ | ជប៉ុន | សរុប | 418 | 8,777 | 1,882 | 7,313 |
| | | ស្រី | 157 | 4,832 | 1,122 | 3,867 |
| ៥ | សិង្ហបុរី | សរុប | 111 | 809 | 89 | 831 |
| | | ស្រី | 111 | 809 | 89 | 831 |
| ៦ | តំបន់រដ្ឋបាលពិសេសហុងកុង | សរុប | n.a | 59 | 5 | 54 |
| | | ស្រី | n.a | 59 | 5 | 54 |
| ៧ | កូរ៉េ | សរុប | 28,827 | 33,374 | 13,102 | 49,099 |
| | | ស្រី | 4,891 | 8,053 | 2,541 | 10,403 |
| | **សរុប** | **សរុប** | **726,442** | **779,281** | **271,612** | **1,234,111** |
| | | **ស្រី** | **291,510** | **321,383** | **113,823** | **499,070** |

ចំណាំ÷ n.a : មិនទាន់មានសកម្មភាព

ជាមួយការបញ្ជូនពលករកម្ពុជាទៅធ្វើការនៅបរទេសនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសហការជាមួយក្រសួងការងារថៃ បានចាប់ផ្តើមយុទ្ធនាការផ្តល់ភាពស្របច្បាប់ជូនដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដើម្បីមានសិទ្ធិធ្វើការដោយស្របច្បាប់នៅប្រទេសថៃ។ តាមរយៈនេះ គណៈកម្មការ ផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានចាប់ផ្តើម

យុទ្ធនាការបានផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកាន់ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) លិខិតបញ្ជាក់អត្តសញ្ញាណ ដែលចេញដោយអាជ្ញាធរថៃ ដើម្បីយកទៅសុំភាពស្របច្បាប់ពីភាគីថៃ ដោយគិតចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ២០១៨ គណៈកម្មការបានបញ្ជាក់អត្តសញ្ញាណជូនពលករកម្ពុជាបានចំនួន ៤២៦ ៨៤១ នាក់។ ការទទួលបានភាពស្របច្បាប់នេះ បានធ្វើឱ្យបងប្អូនពលករទទួលបាននូវសិទ្ធិសេរីភាពក្នុងការធ្វើដំណើរទាំងនៅក្នុងប្រទេសថៃនិងចេញចូលប្រទេសកំណើតរួចផុតពីការកេងប្រវ័ញ្ចពលកម្មពីសំណាក់ជនខិលខូច និងជាពិសេស ទទួលបានប្រាក់បៀវត្ស និងអត្ថប្រយោជន៍សន្តិសុខសង្គមពេញលេញទៅតាមច្បាប់នៃប្រទេសថៃ។

ក្រសួងបានធ្វើការដោះស្រាយវិវាទផ្នែកទេសន្តប្រវេសន៍សរុបចាប់ពីឆ្នាំ ២០១៤-២០១៨ ចំនួន ២៩៦ ករណី ក្នុងចំណោម ១២៥ សហគ្រាស-គ្រឹះស្ថាន ក្នុងនោះសំណុំរឿងសះជាចំនួន ១៧២ ករណី, សំណុំរឿងមោឃៈ ចំនួន ៧២ ករណី, សំណុំរឿងតាមដានបន្តចំនួន ៤៦ ករណី, សំណុំរឿងមរណៈចំនួន ៤ ករណី, និងសំណុំរឿងបាត់ខ្លួនចំនួន ២ ករណី។

**តារាងទី១៧៖ ការដោះស្រាយវិវាទផ្នែកទេសន្តរប្រវេសន៍**

| បរិយាយ | | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនក្រុមហ៊ុន | | ក្រុមហ៊ុន | 24 | 25 | 28 | 34 | 14 | 125 |
| ចំនួនពលករ | សរុប | នាក់ | 642 | 581 | 187 | 493 | 214 | 2,117 |
| | ស្រី | នាក់ | 396 | 392 | 58 | 187 | 98 | 1,131 |
| ចំនួនសំណុំរឿង | | សំណុំរឿង | 81 | 63 | 54 | 63 | 35 | 296 |
| *សំណុំរឿងសះជា* | | ករណី | 60 | 41 | 19 | 29 | 23 | 172 |
| *សំណុំរឿងមោឃៈ* | | ករណី | 21 | 17 | 13 | 19 | 2 | 72 |
| *សំណុំរឿងតាមដានបន្ត* | | ករណី | 0 | 0 | 21 | 15 | 10 | 46 |
| មរណភាព | | នាក់ | 0 | 4 | 0 | 0 | 0 | 4 |
| បាត់ខ្លួន | | នាក់ | 0 | 1 | 1 | 0 | 0 | 2 |

### ២.៣.៤. ការគ្រប់គ្រងកម្លាំងពលកម្មបរទេស

ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ នេះ ក្រសួងបានចុះធ្វើអធិការកិច្ចហត្ថពលកម្មជនបរទេសបានចំនួន ១២ ៩៦០ សហគ្រាស-គ្រឹះស្ថាន និងពិនិត្យឃើញមានជនបរទេសសរុបចំនួន ៩៧ ៩៧៥នាក់ ក្នុងនោះ ៩២,៧% មានប័ណ្ណការងារ និងសៀវភៅការងារជនបរទេស។ ទន្ទឹមនឹងនេះ ក្រសួងបានចេញសៀវភៅការងារជនបរទេសថ្មី និងចុះទិដ្ឋាការចូលដល់ជនបរទេសសរុបចំនួន ១៩៩ ៣៩៣ នាក់ និងបានពន្យារសុពលភាពលើប័ណ្ណ និងសៀវភៅការងារជនបរទេសសរុបចំនួន ៨៤ ៧៣១ នាក់ ដោយប្រមូលចំណូលមិនមែនសារពើពន្ធតាមរយៈការប្រមូលអាករជនបរទេសបានថវិកាសរុបចំនួនប្រមាណជា ១៣៨ ៩៦៩ លានរៀល។

### តារាងទី១៨÷ ការធ្វើអធិការកិច្ចជនបរទេស

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ចំនួនសហគ្រាសដែលបានធ្វើអធិការកិច្ច | សហគ្រាស | 1,604 | 2,665 | 3,336 | 3,539 | 1,816 | 12,960 |
| ចំនួនជនបរទេសដែលពិនិត្យឃើញ | នាក់ | 12,074 | 18,792 | 24,414 | 30,453 | 12,242 | 97,975 |
| ចំនួនអ្នកមានប័ណ្ណនិងសៀវភៅការងារ | នាក់ | 9,288 | 16,803 | 23,211 | 29,422 | 12,088 | 90,812 |
| ចំនួនអ្នកគ្មានប័ណ្ណនិងសៀវភៅការងារ | នាក់ | 3,176 | 1,989 | 1,609 | 1,031 | 154 | 7,959 |

### តារាងទី១៩÷ ការគ្រប់គ្រងជនបរទេស

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ផ្តល់ប័ណ្ណ សៀវភៅការងារថ្មី និងទិដ្ឋាកាចូល | នាក់ | 10,503 | 22,927 | 15,601 | 56,975 | 93,387 | 199,393 |
| ពន្យារសុពលភាពលើប័ណ្ណ និងសៀវភៅការងារ | នាក់ | 6,404 | 12,985 | 23,528 | 0 | 41,814 | 84,731 |
| អាករសរុបដែលប្រមូលបាន | លាន រៀល | 8,749.96 | 19,989.92 | 18,229.40 | 24,417.12 | 67,582.72 | 138,969 |

## ២.៤. ការអភិវឌ្ឍរបបសន្តិសុខសង្គមដល់កម្មករនិយោជិត និងមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ អតីតយុទ្ធជន

ក្រសួងបានអនុវត្តរបបសន្តិសុខសង្គម÷ ផ្នែកហានិភ័យការងារ, ផ្នែកថែទាំសុខភាព, និងបន្តអនុវត្តផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិត និងការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាមួយនឹងការចាប់ផ្តើមអនុវត្តផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅឆ្នាំ២០១៩។

### ២.៤.១. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ

ក្រសួងបានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនៅចុងឆ្នាំ២០០៨ ដោយរបបធានារ៉ាប់រងផ្នែកហានិភ័យការងារគឺបានកំពុងអនុវត្តចំពោះជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ ស្តីពីការងារ ដោយនិយោជកទទួលបន្ទុកបង់ភាគទានចំនួន ០.៨% នៃប្រាក់បៀវត្សរបស់កម្មករនិយោជិត។

### តារាងទី២០÷ ចំនួនសហគ្រាស-គ្រឹះស្ថាន និងកម្មករនិយោជិត បានចុះបញ្ជិកា

| បរិយាយ | សហគ្រាសចុះបញ្ជិកា និងសមាជិកសរុប | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ២០០៨-២០១៤ | 7,041 | 1,021,588 | 725,327 | 4,299 | 590,111 | 399,690 | 2,742 | 431,477 | 325,637 |
| ២០០៨-២០១៥ | 7,796 | 1,077,079 | 762,013 | 4,687 | 621,537 | 420,330 | 3,109 | 455,542 | 341,683 |
| ២០០៨-២០១៦ | 8,731 | 1,136,271 | 798,027 | 5,113 | 646,506 | 434,755 | 3,618 | 489,765 | 363,272 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២០០៨-២០១៧ | 9,724 | 1,186,453 | 827,746 | 5,570 | 671,089 | 448,690 | 4,154 | 515,364 | 379,056 |
| ២០០៨-២០១៨ | 12,828 | 1,492,144 | 899,786 | 7,282 | 747,547 | 486,701 | 5,546 | 744,597 | 413,085 |
| បរិយាយ | សហគ្រាសចុះបញ្ជិកា និងសមាជិកថ្មី | | | | | | | | |
| | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| ២០១៤ | 934 | 174,413 | 125,605 | 576 | 88,195 | 55,470 | 358 | 86,218 | 70,135 |
| ២០១៥ | 755 | 55,491 | 36,686 | 388 | 31,426 | 20,640 | 367 | 24,065 | 16,046 |
| ២០១៦ | 935 | 59,192 | 36,014 | 426 | 24,969 | 14,425 | 509 | 34,223 | 21,589 |
| ២០១៧ | 993 | 50,182 | 29,719 | 457 | 24,583 | 13,935 | 536 | 25,599 | 15,784 |
| ២០១៨ | 3,104 | 305,691 | 72,040 | 1,712 | 76,458 | 38,011 | 1,392 | 229,233 | 34,029 |
| សរុប | 6,721 | 644,969 | 300,064 | 3,559 | 245,631 | 142,481 | 3,162 | 399,338 | 157,583 |

គិតត្រឹមចុងឆ្នាំ ២០១៨នេះ បេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ប.ស.ស) បានចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថានថ្មីចំនួន ១២ ៨២៨ សហគ្រាស-គ្រឹះស្ថាន ដោយមានកម្មករនិយោជិតចំនួន ១ ៤៩២ ១៤៤នាក់ (ស្រី ៨៩៩ ៧៨៦នាក់)។ សម្រាប់ក្នុងអាណត្តិនេះ (២០១៤-២០១៨) ប.ស.ស បានចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថានថ្មីសរុបចំនួន ៦ ៧២១គ្រឹះស្ថាន ឬកើនឡើងប្រមាណជា ១១០,១% ដោយមានកម្មករនិយោជិតសរុបចំនួន ៦៤៤ ៩៦៩នាក់ ឬ កើនឡើងប្រមាណជា ៧៦,១% ដែលក្នុងនោះ ស្រីមានចំនួន ៣០០ ០៦៤ នាក់ ដែលនេះជាការបង្ហាញឱ្យឃើញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាពនៃការធានារ៉ាប់រងផ្នែកនេះដើម្បីកាត់បន្ថយហានិភ័យ និងការព្រួយបារម្ភរបស់បងប្អូនកម្មករនិយោជិតក៏ដូចជាអ្នកនៅក្នុងបន្ទុកក្នុងការបាត់បង់ចំណូល ដោយសារគ្រោះថ្នាក់ចៃដន្យណាមួយ ដោយគិតចាប់តាំងពីពេលបងប្អូនកម្មករនិយោជិតធ្វើដំណើរចេញពីផ្ទះសំដៅឆ្ពោះទៅកន្លែងការងារ ពេលកំពុងធ្វើការងារ និងពេលចប់ការងារធ្វើដំណើរសំដៅឆ្ពោះទៅផ្ទះវិញ។

គិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ នេះ សហគ្រាស-គ្រឹះស្ថានដែលបានចុះបញ្ជិកា និងបង់ភាគទាននៅ ប.ស.ស បានកើនឡើងពី ៥ ៧៥៨ សហគ្រាស-គ្រឹះស្ថាន នៅឆ្នាំ២០១៤ ដល់ ៨ ៥៩៩ សហគ្រាស-គ្រឹះស្ថាន នៅឆ្នាំ ២០១៨ គឺកើនឡើងប្រមាណ ៤៩,៣% ហើយចំនួនកម្មករនិយោជិតបានកើនឡើងពី ៩០៨ ៥៣៥ នាក់ មកចំនួន ១ ១៦០ ៤៨០ នាក់ គឺកើនឡើងប្រមាណ ២៧,៧%។

**តារាងទី២១: ចំនួនសហគ្រាស-គ្រឹះស្ថាន និងកម្មករនិយោជិត សរុប បានបង់ភាគទាន និងមិនបានបង់ភាគទាន**

| បរិយាយ | សហគ្រាសជាប់ភាគទាន (មធ្យមភាគ) | សហគ្រាសបានបង់ភាគទាន (មធ្យមភាគ) | មានកម្មករនិយោជិត (មធ្យមភាគ) | | ភាគទាន (លានរៀល) | ភាគរយសហគ្រាស បានបង់ភាគទាន |
|---|---|---|---|---|---|---|
| | | | សរុប | ស្រី | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២០១៤ | 5,758 | 4,966 | 908,535 | 635,975 | 57,288.86 | 86.3% |
| ២០១៥ | 6,140 | 5,622 | 1,038,151 | 726,705 | 74,330.93 | 91.6% |
| ២០១៦ | 6,618 | 5,416 | 1,042,143 | 723,312 | 82,696.22 | 81.8% |
| ២០១៧ | 6,919 | 5,592 | 1,101,070 | 742,431 | 90,678.16 | 80.8% |
| ២០១៨ | 8,599 | 6,463 | 1,160,480 | 795,968 | 110,100.92 | 75.2% |

ក្នុងការផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់កម្មករនិយោជិត គិតចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ នេះ ប.ស.ស បានផ្តល់តាវកាលិកចំនួន ៨៣ ៤២៦ នាក់ ស្មើនឹង ១៥៥ ៧០៦ ឯកសារ គិតជាថវិកាអស់ចំនួន ៧៥,២ ប៊ីលានរៀល។

**តារាងទី២២÷ ការផ្តល់តាវកាលិកហានិភ័យការងារ**

| ប្រភេទតាវកាលិក | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប (ប៊ីលានរៀល) |
|---|---|---|---|---|---|---|---|
| តាវកាលិកព្យាបាល | ឯកសារ | 7,958 | 11,402 | 13,881 | 15,017 | 11,558 | 59,816 |
| តាវកាលិកថែទាំ | ឯកសារ | 1,624 | 3,176 | 4,164 | 4,768 | 4,152 | 17,884 |
| តាវកាលិកបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន | ឯកសារ | 7,686 | 12,388 | 16,238 | 17,494 | 13,996 | 67,802 |
| តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ក្រោម ២០% (វិភាជន៍) | ឯកសារ | 22 | 67 | 92 | 124 | 470 | 775 |
| តាវកាលិកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពី ២០% (ធនលាភ) | ឯកសារ | 247 | 451 | 668 | 956 | 744 | 3,066 |
| វិភាជន៍បូជាសព | ឯកសារ | 98 | 180 | 175 | 187 | 204 | 844 |
| តាវកាលិកឧត្តរជីវី | ឯកសារ | 440 | 772 | 1,226 | 1,616 | 621 | 4,675 |
| តាវកាលិកអ្នកចាំថែរក្សា | ឯកសារ | 9 | 26 | 45 | 75 | 581 | 736 |
| សេវាបុននីតិសម្បទា | ឯកសារ | 4 | 10 | 19 | 33 | 42 | 108 |
| **ចំនួនឯកសារសរុប** | **ឯកសារ** | **18,088** | **28,472** | **36,508** | **40,270** | **32,368** | **155,706** |
| **ចំនួនអ្នកទទួលបានតាវកាលិក** | **នាក់** | **10,193** | **15,338** | **19,242** | **21,267** | **17,386** | **83,426** |
| **ចំណាយតាវកាលិកតាវកាលិក** | **លានរៀល** | **7,987.1** | **12,058.4** | **15,814.1** | **19,156.3** | **20,166** | **75,182** |

### ២.៤.២. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព

#### ២.៤.២.១. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់កម្មករនិយោជិត

ការធានារ៉ាប់រងផ្នែកសុខភាពត្រូវបានដាក់ឱ្យអនុវត្ត ចំពោះជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនៅចុងឆ្នាំ២០១៦ ដោយភាគទានចំនួន ១.៣% នៃប្រាក់បៀវត្ស ត្រូវបង់ដោយនិយោជក និង ១.៣% នៃប្រាក់បៀវត្សត្រូវបង់ដោយកម្មករនិយោជិត ប៉ុន្តែដើម្បីលើកស្ទួយកម្ពស់ជីវភាពរស់នៅរបស់បង

ប្អូនកម្មករនិយោជិតឱ្យកាន់តែប្រសើរឡើង រាជរដ្ឋាភិបាលបានកំណត់ចាប់ពីខែមករា ឆ្នាំ២០១៨តទៅ ឱ្យនិយោជកទទួលបន្ទុកបង់ភាគទាននេះជំនួសបងប្អូនកម្មករនិយោជិត១០០%។ ការធានារ៉ាប់រងផ្នែកសុខភាពត្រូវបានដាក់ឱ្យអនុវត្ត ជាដំណាក់កាលដោយផ្តើមចេញពីសហគ្រាស-គ្រឹះស្ថាន ដែលមានចំនួនកម្មករនិយោជិតច្រើន ហើយស្ថិតក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តបន្តបន្ទាប់ស្របទៅតាមស្ថានភាពបច្ចេកទេស និងភូមិសាស្ត្រជាក់ស្តែង។ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០១៨ ប.ស.ស ចុះបញ្ជីសហគ្រាស-គ្រឹះស្ថាន បានចំនួន ៨ ៧៧០ និងមានសមាជិកសរុបចំនួន ១ ៦១៤ ៦៧៨ នាក់និងបានចំណាយថវិកាអស់ប្រមាណ ១៧១ ៥២២ លានរៀល ដែលនេះបានបង្ហាញនូវការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការពង្រីកវិសាលភាពនៃការធានារ៉ាប់រងសុខភាពនេះ ដល់បងប្អូនកម្មករនិយោជិតឱ្យបានលឿនដើម្បីជួយសម្រាលបន្ទុកចំណាយលើសុខភាព។

**តារាងទី២៣៖ កំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញ**

| បរិយាយ | សរុប | | | ថ្នាក់កណ្តាល | | | ថ្នាក់ខេត្ត | | |
|---|---|---|---|---|---|---|---|---|---|
| | សហ | សមាជិក | ស្រី | សហ | សមាជិក | ស្រី | សហ | សមាជិក | ស្រី |
| គិតត្រឹមឆ្នាំ2016 | 510 | 500,607 | 418,881 | 381 | 381,373 | 316,903 | 129 | 119,234 | 101,978 |
| គិតត្រឹមឆ្នាំ2017 | 85,07 | 1,182,849 | 787,547 | 4,435 | 627,637 | 389,029 | 4,072 | 555,212 | 398,518 |
| គិតត្រឹមឆ្នាំ2018 | 8,770 | 1,614,678 | 1,140,829 | 5,257 | 1,206,176 | 702,913 | 3,513 | 408,502 | 437,916 |

**តារាងទី២៤៖ ការចំណាយតាវកាលិកផ្នែកថែទាំសុខភាព**

| ល.រ | បរិយាយ | ការចំណាយតាវកាលិក | | | សរុប |
|---|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ | |
| | | (លានរៀល) | (លានរៀល) | (លានរៀល) | (លានរៀល) |
| | **ការចំណាយតាមប្រភេទតាវកាលិក (1)** | **0** | 6,477.7 | 84,582.2 | **91,059.9** |
| 1 | តាវកាលិកប្រាក់បំណាច់ប្រចាំថ្ងៃ | 0 | 827.8 | 3,627.5 | **4,455.3** |
| 2 | តាវកាលិកសេវាព្យាបាល និងថែទាំ វេជ្ជសាស្ត្រ (ករណីសង្គ្រោះបន្ទាន់) | 0 | 55.9 | 300.8 | **356.7** |
| 3 | តាវកាលិកលំហែមាតុភាព | 0 | 5,594.0 | 80,653.9 | **86,247.9** |
| | **មន្ទីរពេទ្យផ្លូវការ (2)** | 0 | 12,296.4 | 68,165.7 | **80,462.1** |
| | **សរុប(1)+(2)** | **0** | **18,774.1** | **152,747.9** | **171,522.0** |

ដើម្បីបង្កិតសេវាឱ្យកៀកដល់សមាជិក ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាល ទូទាំង២៥ រាជធានី/ខេត្ត សរុបចំនួន ១ ៣៣៥ (ក្នុងនោះមន្ទីរពេទ្យថ្នាក់ជាតិចំនួន ៥ មន្ទីរពេទ្យបង្អែកចំនួន ១០៩ មណ្ឌលសុខភាពចំនួន ១ ១៧៨ និងមន្ទីរពេទ្យឯកជនចំនួន ៤៣)។

ចំពោះការលំហែមាតុភាពរបស់កម្មករនិយោជិតជាស្ត្រី ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំនួន ១២០% រយៈពេល៣ខែ ក្នុងពេលសម្រាកលំហែមាតុភាព (ចំនួន៥០%ផ្តល់ដោយនិយោជកតាមច្បាប់ស្តីពីការងារ និង ចំនួន ៧០%ផ្តល់ដោយ ប.ស.ស)។ អនុលោមតាមប្រកាសលេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករ និយោជិត ក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនកម្មករ និយោជិត ជាស្ត្រី ទាំងក្នុង និងក្រៅប្រព័ន្ធទទួលបានគោលរបបឧបត្ថម្ភពីរាជរដ្ឋាភិបាលនៅពេលសម្រាលកូន (បើសម្រាលបានកូនម្នាក់ ទទួលបាន ៤០ម៉ឺនរៀល សម្រាលបានកូនភ្លោះពីរនាក់ទទួលបាន ៨០ម៉ឺនរៀល និង សម្រាល បានកូនភ្លោះបីនាក់ទទួល បាន ១លាន២០ ម៉ឺនរៀល ព្រមទាំងទទួលបានថវិកាឧបត្ថម្ភដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ចំនួន ៥លានរៀលបន្ថែមទៀត ទោះបីទារករស់ ឬស្លាប់ក៏ដោយ)។ រាជរដ្ឋាភិបាល បានផ្តល់នូវគោលរបបឧបត្ថម្ភជូនដល់កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធពេលសម្រាលកូន តាមរយៈ ប.ស.ស ក្នុងឆ្នាំ២០១៨ បានចំនួន ៦៥ ៤៨៤ នាក់ កូនសរុបចំនួន ៦៥ ៩៦៥ នាក់ ចំណាយទឹកប្រាក់សរុប ចំនួន ២៦ ៣៨៦ លានរៀល។

**២.៤.២.២.ការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន**

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកត/០២១៧/០៧៨ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែក ហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧។ ក្នុងឆ្នាំ២០១៨នេះ ប.ស.ស បានចុះបញ្ជីមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនបានចំនួន ៣៦ ក្រសួង/ស្ថាប័ន ដែលមានសមាជិកសរុប ៣១២ ៣០៦ នាក់ (ស្រី ៩៧ ៧០៤ នាក់)។ នៅក្នុងឆ្នាំដដែលនេះ មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន បានទៅ ទទួលសេវាចំនួន ២៥ ៨៥១ដង ដែលបានចំណាយថវិកាអស់ចំនួន ២,៥ ប៊ីលានរៀល។

ចំពោះមន្ត្រីរាជការស៊ីវិលជាស្ត្រីក៏ទទួលបានប្រាក់ខែចំនួន ១០០% រយៈពេល៣ខែ ក្នុងរយៈពេលសម្រាក លំហែមាតុភាព អនុលោមតាមអនុក្រឹត្យលេខ ១៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកែប្រែ និងដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និង ប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសពមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលបានទទួល

មរណភាព។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានផ្តល់គោលរបបឧបត្ថម្ភដល់មន្ត្រីរាជការស៊ីវិលជាស្ត្រីពេលសម្រាលបានកូនម្នាក់ទទួលបាន ៨០ម៉ឺនរៀល ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបង្កើនទ្វេគុណ ឬត្រីគុណ ឬច្រើនជាងនេះ ជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីតាមចំនួនកូនដែលសម្រាលបានកូនភ្លោះពីរនាក់ទទួលបាន ១លាន ៦០ម៉ឺនរៀល និងសម្រាលបានកូនភ្លោះបីនាក់ទទួលបាន ២លាន ៤០ម៉ឺនរៀល ទោះទារកនោះសម្រាលមកស្លាប់ក៏ទទួលបានដែរ។

**២.៤.២.៣. ការអនុវត្តផ្នែកថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល**

ដើម្បីលើកកម្ពស់សុខមាលភាពរបស់កម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ រាជរដ្ឋាភិបាលបានផ្តល់ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់សុខភាពកម្មករនិយោជិតក្រៅប្រព័ន្ធតាមរយៈ ការផ្តល់សេវាមូលនិធិសមធម៌សុខាភិបាល។ គិតត្រឹមចុងឆ្នាំ២០១៨ ប.ស.ស បានចុះបញ្ជី និងផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាលជូនដល់កម្មករនិយោជិតនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងគោលដៅផ្សេងៗទៀត បានចំនួន ១២៤ ៩៤៦ នាក់ (ក្នុងនោះមានកម្មករនិយោជិតក្រៅប្រព័ន្ធ ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានភូមិ អនុប្រធានភូមិ សមាជិកភូមិ កីឡាករ កីឡាការិនី សិល្បៈករ សិល្បៈការិនី បុគ្គលិក កម្មករនិយោជិត នៃអង្គការ សមាគម)។

**២.៤.៣. ការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន**

ដើម្បីអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់ សោធន ដល់កម្មករនិយោជិតក្នុងវិស័យឯកជននៅឆ្នាំ២០១៩ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីធ្វើការសិក្សា និងវិភាគហិរញ្ញវត្ថុសម្រាប់ផ្នែកប្រាក់សោធន។ ជាមួយគ្នានេះផងដែរ ក្រសួងបានរៀបចំសេចក្តី ព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម និងលិខិតបទដ្ឋានគតិយុត្តដើម្បីត្រៀមអនុវត្ត។ លើសពីនេះក្រសួងបានកំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធននិវត្តន៍ ដោយពលករអាចផ្ទេរសមាជិកភាព, អតីតភាពការងារ, និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយបន្ទាប់ពីចប់កិច្ចសន្យាការងារ។

**២.៤.៤. សេវាគាំទ្រ**

**២.៤.៤.១. កំណែទម្រង់សេវាសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តរបបសន្តិសុខសង្គម ប្រកបដោយតម្លាភាព និងគណនេយ្យភាព ប.ស.ស បានធ្វើការកំណែទម្រង់សេវាសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការបង្កើតអង្គភាពជំនាញចំណុះឱ្យក្រសួងអាណាព្យាបាល និង ប.ស.ស រួមមានការបង្កើតក្រុមប្រឹក្សាបច្ចេកទេសរបបសន្តិសុខសង្គម ក្រុមប្រឹក្សាភិបាល គណៈកម្មការវេជ្ជសាស្ត្រ គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង គណៈកម្មការវិនិយោគ ក្រុមការងារស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ក្រុមការងារសិក្សាស្រាវជ្រាវទប់ស្កាត់ករណីដួលសន្លប់ ក្រុមការងារ ក.ស.ថ.ម ក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា។ ក្នុងនោះផងដែរ ប.ស.ស ក៏មានសេវាគាំទ្រមួយចំនួនក្នុងការសម្របសម្រួលទាក់ទង កិច្ចការរដ្ឋបាល (ទទួលបន្ទុកគ្រប់គ្រង

ការងាររដ្ឋបាលទូទៅ និងការអភិវឌ្ឍធនធានមនុស្ស) កិច្ចការហិរញ្ញវត្ថុ និងកិច្ចការគណនេយ្យ (ការគ្រប់គ្រងការងារគណនេយ្យស្របតាមគោលការណ៍ គណនេយ្យសាធារណៈ និងវិធានគណនេយ្យ) ការងារព័ត៌មានវិទ្យា (ការងារដំណើរការ Hardware និង Software នៃប្រព័ន្ធកុំព្យូទ័រឱ្យបានល្អត្រឹមត្រូវ ដើម្បីធានាគាំទ្រចំពោះគ្រប់តម្រូវការទិន្នន័យ)។

ស្របគ្នានេះដែរ ប.ស.ស បានយកចិត្តទុកដាក់ទៅលើចំនុចមួយចំនួនមានជាអាទិ៍ ការបង្កើនប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈ ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ពង្រឹង និងពង្រីកកិច្ចសហការប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍពាក់ព័ន្ធនានា និងលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសន្តិសុខសង្គម។

**២.៤.៤.២ ការផ្សព្វផ្សាយអប់រំ និងបង្ការ**

ដើម្បីពង្រឹងគុណភាពក្នុងការផ្តល់សេវារបស់មូលដ្ឋានសុខាភិបាល សេវាផ្តល់តាវកាលិក ប.ស.ស បានពង្រឹងសមត្ថភាព យល់ដឹង ដល់និយោជក និងកម្មករនិយោជិត តាមរយៈការធ្វើសិក្ខាសាលា ការប្រជុំពិគ្រោះយោបល់ត្រីភាគី និងវគ្គបណ្តុះបណ្តាលនានាដែលពាក់ព័ន្ធនឹងការអនុវត្តរបបសន្តិសុខសង្គម។ តាមរយៈនេះ ដោយគិតចាប់ពីឆ្នាំ២០១៦ មក ប.ស.ស បានធ្វើការផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ បានចំនួន ១ ៦០០ លើក/សហគ្រាស-គ្រឹះស្ថាន និងមានកម្មករនិយោជិតចំនួន ៣៤៩ ២១០ នាក់ (ស្រី ៣០៦ ៩៨៤ នាក់) បានចូលរួម។

**តារាងទី២៥÷ ផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍វិស័យការងារ**

| បរិយាយ | សហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | កម្មករនិយោជិតចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|
| | សហគ្រាស-គ្រឹះស្ថាន | លើក | សរុប | ស្រី |
| ២០១៦ | 91 | 91 | 8,728 | 7,371 |
| ២០១៧ | 642 | 642 | 123,255 | 106,375 |
| ២០១៨ | 867 | 867 | 217,227 | 193,238 |
| **សរុប** | **1,600** | **1,600** | **349,210** | **306,984** |

ការផ្សព្វផ្សាយស្តីពីសុវត្ថិភាពចរាចរដល់កម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត ចាប់តាំងពីឆ្នាំ២០១៤-២០១៨ ប.ស.ស. បានធ្វើចុះធ្វើការផ្សព្វផ្សាយនៅតាមសហគ្រាស-គ្រឹះស្ថាន ចំនួន ២ ០៤៣ ត្រូវជា ១ ៧៣២ លើកដោយមានកម្មករនិយោជិតចូលរួមចំនួន ២១២ ៧៨៥ នាក់ និង អ្នកបើកបរចូលរួមសរុបចំនួន ៨១ ៥១៤ នាក់។

**តារាងទី២៦÷ ផ្សព្វផ្សាយសុវត្ថិភាពចរាចរណ៍ដល់ កម្មករនិយោជិត និងអ្នកបើកបរយានយន្តដឹកកម្មករនិយោជិត**

| បរិយាយ | សហគ្រាស | | កម្មករនិយោជិត | | | |
|---|---|---|---|---|---|---|
| | រោងចក្រ | លើក | កម្មករ | អ្នកបើកបរ | សរុបរួម | ស្រី |
| ២០១៤ | 123 | 22 | 2,675 | 1,600 | 4,275 | 2,565 |
| ២០១៥ | 307 | 103 | 17,776 | 3,591 | 21,367 | 12,820 |
| ២០១៦ | 154 | 137 | 24,922 | 1,488 | 26,410 | 15,794 |
| ២០១៧ | 610 | 621 | 55,295 | 26,360 | 81,655 | 49,980 |
| ២០១៨ | 849 | 849 | 112,117 | 48,475 | 156,765 | 100,999 |
| **សរុប** | **2,043** | **1,732** | **212,785** | **81,514** | **290,472** | **182,158** |

ការផ្សព្វផ្សាយគោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គមដល់កម្មករនិយោជក និងកម្មករនិយោជិត ចាប់តាំងពីឆ្នាំ២០១៤-២០១៨ ប.ស.ស. បានចុះធ្វើការផ្សព្វផ្សាយទៅដល់និយោជក សហជីព ជនរងគ្រោះ និងអាជ្ញាធរចំនួន ១១៨ ០៥៣ ស្មើនឹង ៨៥៩លើក ដោយមានកម្មករនិយោជិតចំនួន ១២៧ ៩០១នាក់ (ស្រី៩៥ ៤២៨នាក់) បានចូលរួម។

**តារាងទី២៧÷ ផ្សព្វផ្សាយគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់និយោជក និងកម្មករនិយោជិត**

| បរិយាយ | ស្ថានភាពផ្សព្វផ្សាយ | | | អ្នកចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|---|
| | លើក | និយោជក/ សហជីព/ ជនរងគ្រោះ/អាជ្ញាធរ | រាជធានីខេត្ត | សរុប | ស្រី |
| ២០១៤ | 23 | 2,907 | 0 | 1,682 | 673 |
| ២០១៥ | 46 | 4,841 | 24 | 6,188 | 2,475 |
| ២០១៦ | 74 | 12,868 | 25 | 12,868 | 5,274 |
| ២០១៧ | 404 | 43,768 | 25 | 52,088 | 41,306 |
| ២០១៨ | 312 | 53,669 | 24 | 55,075 | 45,699 |
| **សរុប** | **859** | **118,053** | **98** | **127,901** | **95,427** |

ការផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ករណីជួលសន្លប់របស់កម្មករនិយោជិត និងនិយោជក ចាប់តាំងពីឆ្នាំ២០១៤-២០១៨ ប.ស.ស. បានចុះធ្វើការផ្សព្វផ្សាយនៅតាមសហគ្រាស គ្រឹះស្ថានទូទាំងរាជធានីខេត្ត ចំនួន ៣៨៧ សហគ្រាស-គ្រឹះស្ថាន ដោយមានកម្មករនិយោជិតសរុបចំនួន ៥៧ ៦៩០ នាក់ (ស្រី ៤៧ ៥៧៨ នាក់) បានចូលរួម។

**តារាងទី២៨៖ ផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ករណីជួលសន្លប់ដល់កម្មករនិយោជិត និងនិយោជក**

| បរិយាយ | សហគ្រាសបានទទួលការផ្សព្វផ្សាយអប់រំ | | កម្មករនិយោជិតចូលរួមប្រជុំផ្សព្វផ្សាយ | |
|---|---|---|---|---|
| | រោងចក្រ | លើក | សរុប | ស្រី |
| ២០១៤ | 27 | 19 | 3,100 | 2,790 |
| ២០១៥ | 90 | 90 | 13,450 | 12,105 |
| ២០១៦ | 77 | 77 | 13,042 | 11,738 |
| ២០១៧ | 88 | 88 | 7,296 | 5,129 |
| ២០១៨ | 105 | 105 | 20,802 | 15,816 |
| **សរុប** | **387** | **379** | **57,690** | **47,578** |

## ២.៥. ការពង្រឹងអភិបាលកិច្ចល្អ

ការបន្តកំណែទម្រង់អភិបាលកិច្ចល្អ គឺជាយុទ្ធសាស្ត្រអាទិភាពមួយដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ហើយចាត់ទុកថាឆ្អឹងខ្នងមួយនៃភាពជោគជ័យនៃការអភិវឌ្ឍវិស័យទាំងមូល។ នារយៈពេល៥ឆ្នាំ កន្លងមកនេះ ក្រសួងបានខិតខំយ៉ាងយកចិត្តទុកដាក់លើការលើកកម្ពស់ការងាររដ្ឋបាល, ការផ្តល់សេវាសាធារណៈ, ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋប្រកបដោយតម្លាភាព, ប្រសិទ្ធភាព និងគណនេយ្យភាព, ការពង្រឹងយន្តការផែនការ ស្ថិតិ និងនីតិកម្ម, កិច្ចសហប្រតិបត្តិការអន្តរជាតិ, ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ព្រមជាមួយការលើកកម្ពស់សមភាពយេនឌ័រផងដែរ។

### ២.៥.១. ការងាររដ្ឋបាល និងការគ្រប់គ្រងលិខិត

*"អភិបាលកិច្ចល្អ"* គឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់ដើម្បីសម្រេចបានល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ហើយដែលត្រូវបានរាជរដ្ឋាភិបាលគ្រប់នីតិកាលផ្តោតការយកចិត្តទុកដាក់ និងចាត់ទុកជាចំណុចស៊ីបនៃកំណែទម្រង់ ជាពិសេសត្រូវបានចាត់ទុកជាចំណុចស្នូលនៃ យុទ្ធសាស្ត្រចតុកោណ ទាំង៤ដំណាក់កាល។ ជាមួយគ្នានេះផងដែរក្រសួង ក៏បានចូលរួមចំណែកនឹងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព មានភាពសាមញ្ញ ប្រសិទ្ធភាពដែលអាចជឿទុកចិត្តបានពីអ្នកទទួលសេវា។

ក្នុងការគ្រប់គ្រងចរាចរលិខិតស្នាមរដ្ឋបាល ចាប់តាំងពីឆ្នាំ២០១៤-២០១៨ នេះ ក្រសួងបានទទួលលិខិតចូលចំនួន ៣៤ ៨១៩ និងលិខិតចេញចំនួន ៤០ ៩៦៦ ។ ចំណែកការចុះបេសកកម្មនានា គឺមានចំនួនសរុប ៥៥ ៩៩៤ ដែលក្នុងនោះ បេសកកម្មក្នុងប្រទេសមានចំនួន ៥២ ៣០០ លើក និងបេសកកម្មក្រៅប្រទេសមានចំនួន ៣ ៦៩៤ លើក។

**តារាងទី២៩៖ ការគ្រប់គ្រងលិខិតចេញចូល ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**

| ការចរាចរលិខិតចេញចូល | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| លិខិតចូល | លិខិត | 5,891 | 6,952 | 7,879 | 7,591 | 6,506 | 34,819 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| លិខិតចេញ | លិខិត | 5,977 | 7,383 | 8,712 | 9,670 | 9,224 | 40,966 |

**តារាងទី៣០÷ ចំនួនបេសកកម្មក្នុង និងក្រៅប្រទេស ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**

| បរិយាយ | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| បេសកកម្មក្នុងប្រទេស | សរុប | 7,929 | 9,565 | 9,574 | 11,725 | 13,507 | 52,300 |
| | ស្រី | 1,720 | 2,114 | 2,158 | 2,490 | 2,923 | 11,405 |
| បេសកកម្មក្រៅប្រទេស | សរុប | 471 | 601 | 861 | 986 | 775 | 3,694 |
| | ស្រី | 37 | 70 | 82 | 108 | 154 | 451 |
| **សរុប** | **សរុប** | **8,400** | **10,166** | **10,435** | **12,711** | **14,282** | **55,994** |
| | **ស្រី** | **1,757** | **2,184** | **2,240** | **2,598** | **3,077** | **11,856** |

មន្ត្រីរាជការកំពុងបម្រើការងារនៅក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនសរុប ៤ ៥ ១២នាក់ (ស្រី ១ ២០០នាក់) ក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្តាលមានចំនួន ៣ ១៧៤នាក់ (ស្រី៨៥១នាក់ និងមន្ត្រីបម្រើការងារនៅរាជធានីខេត្តមានចំនួន ១ ៣៣៨នាក់ (ស្រី ៣៤៩នាក់)។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការបន្ថែមនៃការបម្រើសេវាធារណៈ ស្របទៅនឹងគោលនយោបាយជាតិស្តីពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងយុទ្ធសាស្ត្ររបស់ក្រសួង ក្រសួងបានធ្វើការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌគ្រូបច្ចេកទេសចំនួន ១ ១៥៤នាក់ និងមន្ត្រីរាជការក្របខ័ណ្ឌរដ្ឋបាលទូទៅ ៥៨២ នាក់។ ជាមួយគ្នានេះក្រសួងក៏បានគោរពយ៉ាងត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមានក្នុងការ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការផ្តល់គ្រឿងឥស្សរយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ក្រសួងថែមទៀតផង។

**តារាងទី៣១÷ ចំនួនមន្ត្រីរាជការសរុបរបស់ក្រសួង ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**

| បរិយាយ | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សរុបរួម | 3,564 | 802 | 3,823 | 871 | 4,045 | 947 | 4,536 | 1,126 | 4,512 | 1,200 |
| សរុបថ្នាក់កណ្តាល | 2,089 | 476 | 2,346 | 527 | 2,603 | 606 | 3,022 | 744 | 3,174 | 851 |
| សរុបរាជធានីខេត្ត | 1,475 | 326 | 1,477 | 344 | 1,442 | 341 | 1,514 | 382 | 1,338 | 349 |

**តារាងទី៣២÷ ចំនួនបម្រែបម្រួលមន្ត្រីរាជការសរុបរបស់ក្រសួង ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ក្របខ័ណ្ឌថ្មី (គ្រូបង្រៀន) | នាក់ | 294 | 274 | 276 | 306 | 4 | **1,154** |
| ក្របខ័ណ្ឌថ្មី (រដ្ឋបាល) | នាក់ | 125 | 43 | 26 | 151 | 237 | **582** |
| ការផ្ទេរចូល | នាក់ | 60 | 10 | 22 | 33 | 22 | **147** |
| ការផ្ទេរចេញ | នាក់ | 39 | 32 | 46 | 45 | 60 | **222** |
| ទំនេរគ្មានបៀវត្សដោយស្ម័គ្រចិត្ត | នាក់ | 285 | 59 | 79 | 87 | 71 | **581** |
| ឈប់ដោយស្ម័គ្រចិត្ត | នាក់ | 50 | 14 | 38 | 24 | 29 | **155** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឈប់ដោយបោះបង់ | នាក់ | 11 | 34 | 45 | 14 | 18 | **122** |
| ចូលនិវត្តន៍ | នាក់ | 9 | 22 | 20 | 10 | 19 | **80** |
| មរណភាព | នាក់ | 1 | 2 | 0 | 1 | 2 | **6** |
| មន្ត្រីជាប់កិច្ចសន្យា | នាក់ | 568 | 383 | 179 | 368 | 252 | **1,750** |

## តារាងទី៣៣÷ ការតែងតាំង និងដំឡើងឋានៈ ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨

| ការតែងតាំង និងការដំឡើងឋានៈ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ថ្នាក់កណ្តាល | សរុប | 148 | 238 | 229 | 312 | 218 | 1,145 |
| | ស្រី | 20 | 37 | 67 | 75 | 53 | 252 |
| រាជធានីខេត្ត | សរុប | 11 | 40 | 43 | 52 | 64 | 210 |
| | ស្រី | 2 | 7 | 10 | 18 | 19 | 56 |
| **សរុបរួម** | **សរុប** | **159** | **278** | **272** | **364** | **282** | **1,355** |
| | **ស្រី** | **22** | **44** | **77** | **93** | **72** | **308** |

## តារាងទី៣៤÷ ការផ្តល់គ្រឿងឥស្សរិយយស និងបណ្ណសរសើរ ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨

| ប្រភេទគ្រឿងឥស្សរិយស | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់ជាតូបការ | គ្រឿង | 8 | 2 | 0 | 4 | 0 | 14 |
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេរីវឌ្ឍន៍ | គ្រឿង | 2 | 1 | 2 | 5 | 4 | 14 |
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេនា | គ្រឿង | 1 | 1 | 4 | 2 | 1 | 9 |
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់ ធិបឌិន្ទ | គ្រឿង | 1 | 0 | 0 | 0 | 0 | 1 |
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់ សេនា | គ្រឿង | 2 | 2 | 0 | 3 | 0 | 7 |
| ព្រះរាជាណាចក្រកម្ពុជាថ្នាក់ អស្សឫទ្ធិ | គ្រឿង | 0 | 1 | 3 | 3 | 1 | 8 |
| មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេរីវឌ្ឍន៍ | គ្រឿង | 1 | 1 | 1 | 6 | 3 | 12 |
| មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេនា | គ្រឿង | 3 | 6 | 0 | 11 | 6 | 26 |
| មេដាយមុនីសារាភ័ណ្ឌថ្នាក់ ធិបឌិន្ទ | គ្រឿង | 1 | 7 | 9 | 4 | 8 | 29 |
| មេដាយមុនីសារាភ័ណ្ឌថ្នាក់ សេនា | គ្រឿង | 2 | 13 | 11 | 11 | 10 | 47 |
| មេដាយមុនីសារាភ័ណ្ឌថ្នាក់ អស្សឫទ្ធិ | គ្រឿង | 7 | 19 | 39 | 50 | 51 | 166 |
| មេដាយមាស | គ្រឿង | 46 | 68 | 58 | 73 | 73 | 318 |
| មេដាយប្រាក់ | គ្រឿង | 85 | 91 | 124 | 157 | 120 | 577 |
| មេដាយសំរិទ្ធ | គ្រឿង | 186 | 168 | 260 | 276 | 161 | 1,051 |
| បណ្ណសរសើរ | សន្លឹក | 0 | 1,032 | 660 | 382 | 401 | 2,475 |
| សរុប | | 345 | 1,412 | 1,171 | 987 | 839 | 4,754 |

ការគ្រប់គ្រង និងអភិវឌ្ឍមន្ត្រីរាជការស៊ីវិលកន្លងមកនេះ ក្រសួងបាននឹងកំពុងអនុវត្តជាប្រចាំទៅលើការកសាងសមត្ថភាពដោយផ្តោតទៅលើការបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សាក្នុងក្រៅប្រទេស ជូនដល់មន្ត្រីរាជការទាំងថ្នាក់ជាតិ និងក្រោមជាតិ មានចំនួនសរុប ៥ ៦៧៧ នាក់ ។ ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការងារ រដ្ឋបាល ហិរញ្ញវត្ថុ និងផែនការ ដែលមានសិក្ខាកាមសរុបចំនួន ៧៤៩ នាក់។ បញ្ជូនមន្ត្រីទៅទស្សនកិច្ចក្នុងប្រទេសសរុបចំនួន១៤០ នាក់, ទស្សនកិច្ចក្រៅប្រទេសសរុបចំនួន ៣ ៣៨ នាក់, បណ្តុះបណ្តាលក្នុងប្រទេសសរុបចំនួន ៣ ១៥៧នាក់, និងបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ១ ២៩៣ នាក់។

**តារាងទី៣៥÷ ការបណ្តុះបណ្តាលវគ្គរដ្ឋបាល ហិរញ្ញវត្ថុ និងផែនការ ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ការបណ្តុះបណ្តាលវគ្គរដ្ឋបាល ហិរញ្ញវត្ថុ និងផែនការ | នាក់ | 150 | 186 | 206 | 207 | 0 | 749 |
| ចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេស | នាក់ | 504 | 762 | 275 | 636 | 980 | 3,157 |
| ចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស | នាក់ | 177 | 245 | 286 | 255 | 330 | 1,293 |
| ចូលរួមទស្សនកិច្ចសិក្សាក្នុងប្រទេស | នាក់ | 0 | 0 | 0 | 136 | 4 | 140 |
| ចូលរួមទស្សនកិច្ចសិក្សាក្រៅប្រទេស | នាក់ | 9 | 57 | 89 | 86 | 97 | 338 |
| **សរុបរួម** | **នាក់** | **840** | **1,250** | **856** | **1,320** | **1,411** | **5,677** |

### ២.៥.២. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ

ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងបានចូលរួមអនុវត្តដោយការយកចិត្តទុកដាក់លើកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ដោយផ្អែកលើទស្សនទាន ***"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណង គោលនយោបាយ"*** ព្រមទាំងអនុវត្តតាមក្របខ័ណ្ឌនៃកំណែទម្រង់ និងគោលនយោបាយផ្សេងៗ ទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញ។ តាមរយៈកម្មវិធីកំណែទម្រង់ទាំងនេះ ក្រសួងបានរៀបចំអនុវត្តថវិកាកម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាព និងកំណែទម្រង់ទាំង៥ នៃការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ សំដៅលើកកម្ពស់សមត្ថភាព ប្រសិទ្ធភាពការងារ និងពង្រឹងការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ ក្រសួងបានខិតខំបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈដោយការខិតខំពង្រឹងយន្តការគ្រប់គ្រងការផ្តល់សេវា ការចរាចរលិខិតឯកសារ និងរៀបចំការិយាល័យច្រកចេញចូលតែមួយ ការសម្រួលការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលាជាទៀងទាត់តាមប្រព័ន្ធធនាគារ តាមគោលការណ៍របស់រាជរដ្ឋាភិបាល។

បន្ថែមលើនេះ ក្រសួងបានពង្រឹងការគ្រប់គ្រងការអនុវត្តថវិកាកាន់តែមានប្រសិទ្ធភាព ហ្មត់ចត់ និងម៉ឺងម៉ាត់តាមរយៈការគ្រប់គ្រងការអនុវត្តចំណាយ ដែលអនុលោមទៅតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយបានអនុវត្តការបើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការបានទាន់ពេល និងតាមប្រព័ន្ធធនាគារ ១០០% និងអនុវត្តចំណាយក្នុងកម្រិតលំអៀង ៥% នៃផែនការថវិកាជាតិ ។

ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ២០១៣ និងឆ្នាំ២០១៤ ក្រសួងបានចូលរួមអនុវត្តតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយការអនុវត្តថវិកាកម្មវិធីសាកល្បងថវិកាកម្មវិធី និងមិនមែនកម្មវិធីដោយស្ម័គ្រចិត្ត។ នៅឆ្នាំ២០១៥ ក្រសួងបានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ ដោយបានរៀបចំអង្គភាពថវិកាចំនួន ០៧ អង្គភាព (កម្រិតទី២) នៅរដ្ឋបាលកណ្តាល និង ២៥ អង្គភាព នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត។ ក្រសួងបានអនុវត្តតាមផែនការសកម្មភាពកំណែទម្រង់ហិរញ្ញវត្ថុជំហានទី៣ របស់ខ្លួន (MAP3) ប្រចាំត្រីមាស និងអនុវត្តសម្រេចបានតាមគោលដៅសូចនាករ ដោយទទួលបានចំណាត់ថ្នាក់ខ្ពស់ពីការវាយតម្លៃរបស់គណៈកម្មការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បន្ថែមពីនេះនៅឆ្នាំ២០១៧ ក្រសួងបានស្ម័គ្រចិត្តចូលរួមអនុវត្តសាកល្បងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។

## តារាងទី៣៦៖ ប្រៀបធៀបច្បាប់ថវិកា និងការអនុវត្តចំណូលសរុប

*ឯកតាលានរៀល*

| ឆ្នាំ | ច្បាប់ថវិកា | | | អនុវត្ត | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | ថ្នាក់កណ្តាល | រាជធានីខេត្ត | សរុប | ភាគរយ | ថ្នាក់កណ្តាល | ភាគរយ | រាជធានីខេត្ត | ភាគរយ |
| | 1=2+3 | 2 | 3 | 4=6+8 | 5=4/1 | 6 | 7=6/2 | 8 | 9=8/3 |
| **2014** | **9,175.7** | 6,957.2 | 2,218.5 | **19,380.2** | **211.2%** | 12,912.0 | **185.6%** | 6,468.1 | **291.6%** |
| **2015** | **10,827.0** | 7,878.4 | 2,948.6 | **32,179.6** | **297.2%** | 18,387.8 | **233.4%** | 13,791.9 | **467.7%** |
| **2016** | **21,373.2** | 13,612.6 | 7,760.6 | **33,024.5** | **154.5%** | 18,959.7 | **139.3%** | 14,064.8 | **181.2%** |
| **2017** | **26,775.3** | 15,862.7 | 10,912.6 | **39,435.8** | **147.3%** | 20,044.5 | **126.4%** | 19,391.3 | **177.7%** |
| **2018** | **29,336.6** | 17,572.2 | 11,764.4 | **83,986.6** | **286.3%** | 42,322.6 | **240.8%** | 41,664.0 | **354.2%** |
| **សរុបរួម** | **97,487.8** | **61,883.1** | **35,604.7** | **208,006.7** | **213.4%** | **112,626.6** | **182.0%** | **95,380.1** | **267.9%** |
| **កំណើន 2018/2014** | **20,160.9** | **10,615.0** | **9,545.9** | **64,606.5** | **320.5%** | **29,410.6** | **277.1%** | **88,9112.0** | **931.4%** |

## តារាងទី៣៧÷ ការប្រៀបធៀបការអនុវត្តចំណាយ និងច្បាប់ថវិកា

*ឯកតាលានរៀល*

| ឆ្នាំ | ច្បាប់ថវិកា | | | អនុវត្ត | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ថ្នាក់កណ្តាល | | | | រាជធានីខេត្ត | | | | សរុបរួម | % |
| | ថ្នាក់កណ្តាល | រាជធានីខេត្ត | សរុប | កម្មវិធី | មិនមែនកម្មវិធី | សរុប | % | កម្មវិធី | មិនមែនកម្មវិធី | សរុប | % | | |
| | 1 | 2 | 3=1+2 | 4 | 5 | 6=4+5 | 7=6/1 | 8 | 9 | 10=8+9 | 11=10/2 | 12=6+10 | 13=12/3 |
| **2014** | 129,494.6 | 58,305.7 | **187,800.2** | 67,061.1 | 54,290.7 | **121,351.7** | **93.7%** | 26,399.0 | 26,399.0 | **52,797.9** | **90.6%** | **174,149.7** | **92.7%** |
| **2015** | 88,074.6 | 36,883.2 | **124,957.8** | 84,252.1 | 0 | **84,252.1** | **95.7%** | 31,848.8 | 0 | **31,848.8** | **86.4%** | **116,100.9** | **92.9%** |
| **2016** | 130,492.8 | 46,273.5 | **176,766.2** | 126,735.1 | 0 | **126,735.1** | **97.1%** | 40,271.1 | 0 | **40,271.1** | **87.0%** | **167,006.2** | **94.5%** |
| **2017** | 183,747.9 | 53,777.9 | **237,525.8** | 180,358.8 | 0 | **180,358.8** | **98.2%** | 48,615.7 | 0 | **48,615.7** | **90.4%** | **228,974.5** | **96.4%** |
| **2018** | 243,258.6 | 64,461.6 | **307,720.1** | 241,711.9 | 0 | **241,711.9** | **99.4%** | 57,837.0 | 0 | **57,837.0** | **89.7%** | **299,548.9** | **97.3%** |
| **សរុបរួម** | **775,068.4** | **259,701.8** | **1,147,297.8** | **700,119.0** | **54,290.7** | **754,409.7** | **97.3%** | **204,971.6** | **26,399.0** | **231,370.5** | **89.1%** | **985,780.2** | **85.9%** |
| **កំណើន ២០១៤/ ២០១៨** | **113,764.0** | **6,155.9** | **119,919.9** | **174,650.8** | **0** | **120,360.1** | **49.8%** | **31,438.0** | **0** | **5,039.1** | **8.7%** | **125,399.2** | **41.9%** |

សំគាល់÷ ឆ្នាំ២០១៤ក្រសួងបានអនុវត្តថវិកាកម្មវិធីសាកល្បង(ថវិកាកម្មវិធី និងមិនមែនកម្មវិធី) ពីឆ្នាំ ២០១៥ ក្រសួងបានអនុវត្តថវិកាកម្មវិធីពេញលេញស្របតាមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣

## តារាងទី៣៨÷ ការអនុវត្តលទ្ធកម្ម

ឯកតាលានរៀល

| ល.រ | បរិយាយ | | 2014 | | | 2015 | | | 2016 | | | 2017 | | | 2018 | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ផែនការ | អនុវត្ត | % | ផែនការ | អនុវត្ត | % | ផែនការ | អនុវត្ត | % | ផែនការ | អនុវត្ត | % | ផែនការ | អនុវត្ត | % | |
| | | | 4 | 5 | 6=5/4 | 7 | 8 | 9=8/7 | 10 | 11 | 12=11/10 | 13 | 14 | 15=14/13 | 16 | 17 | 18=17/16 | 19=2+5+8+11+14+17 |
| ១ | ទំនិញ | ចំនួន | 14 | 14 | 100% | 16 | 16 | 100% | 24 | 24 | 100% | 22 | 22 | 100% | 18 | 18 | 100% | 91 |
| | | តម្លៃ | 8,772 | 8,480 | 97% | 11,825 | 10,857 | 92% | 24,551 | 23,764 | 97% | 21,814 | 21,647 | 99% | 14,579 | 14,291 | 98% | 73,447 |
| ២ | សំណង់ | ចំនួន | 4 | 4 | 100% | 6 | 6 | 100% | 3 | 3 | 100% | 7 | 7 | 100% | 7 | 7 | 100% | 27 |
| | | តម្លៃ | 3,435 | 3,225 | 94% | 6,683 | 6,007 | 90% | 2,400 | 2,373 | 99% | 16,650 | 16,575 | 100% | 26,878 | 26,828 | 100% | 41,050 |
| ៣ | សេវា | ចំនួន | 0 | 0 | 0 | 0 | 0 | 0% | 2 | 2 | 100% | 2 | 2 | 100% | 2 | 2 | 100% | 4 |
| | | តម្លៃ | 0 | 0 | 0 | 0 | 0 | 0% | 360 | 344 | 96% | 460 | 448 | 97% | 490 | 481 | 98% | 792 |
| សរុប | | ចំនួន | 18 | 18 | 100% | 22 | 22 | 100% | 29 | 29 | 100% | 31 | 31 | 100% | 27 | 27 | 100% | 122 |
| | | តម្លៃ | 12,207 | 11,705 | 96% | 18,508 | 16,864 | 91% | 27,311 | 26,481 | 97% | 38,924 | 38,671 | 99% | 41,947 | 41,600 | 99% | 115,289 |

### តារាងទី៣៩÷ ការគ្រប់គ្រងសម្ភារ និងប្រេងឥន្ធនៈ

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|---|---|
| | | បានបើកផ្តល់ | បានបើកផ្តល់ | បានបើកផ្តល់ | បានបើកផ្តល់ | បានបើកផ្តល់ |
| ផ្គត់ផ្គង់សម្ភារសម្អាត និងអនាម័យ | ទំនិញ | 7,200 | 6,172 | 5,930 | 5,900 | 14,650 |
| ផ្គត់ផ្គង់សម្ភារថែទាំអគារ | ទំនិញ | 1,260 | 3,058 | 1,516 | 1,516 | 3,835 |
| ផ្គត់ផ្គង់គ្រឿងបន្លាស់រថយន្ត | គ្រឿង | 85 | 86 | 84 | 75 | 185 |
| ផ្គត់ផ្គង់ប្រេងឥន្ធនៈ | លីត្រ | 95,831 | 157,465 | 158,663 | 172,773 | 118,690 |
| ផ្គត់ផ្គង់សម្ភារការិយាល័យសម្រាប់គ្រឹះស្ថានសិក្សា | ទំនិញ | 3,274 | - | 8,803 | 7,060 | 5,220 |
| ផ្គត់ផ្គង់សម្ភារការិយាល័យសម្រាប់ថ្នាក់កណ្តាល | ទំនិញ | 17,580 | 4,960 | 12,151 | 10,890 | 10,956 |
| ផ្គត់ផ្គង់សម្ភារប្រឡង | ទំនិញ | 2,401 | 3,945 | 3,932 | 3,439 | 3,180 |

### ២.៥.៣. ការងារផែនការស្ថិតិ និងនីតិកម្ម

### តារាងទី៤០÷ រៀបចំកសាងផែនការ ចងក្រងសមិទ្ធផលក្រសួង

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ប្រជុំ និងសិក្ខាសាលាផ្ទៃក្នុងក្រសួង | ដង | 43 | 105 | 80 | 84 | 85 | 397 |
| ប្រជុំ និងសិក្ខាសាលាអន្តរក្រសួង ពាក់ព័ន្ធនឹងការងារកសាងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានា | ដង | 67 | 102 | 176 | 182 | 186 | 713 |
| ប្រជុំ និងសិក្ខាសាលាអន្តរក្រសួង ពាក់ព័ន្ធនឹងការងារកសាងបទដ្ឋានគតិយុត្ត | ដង | 27 | 42 | 44 | 32 | 30 | 175 |
| ប្រជុំ និងសិក្ខាសាលាអន្តរក្រសួង ពាក់ព័ន្ធនឹងការងារផ្សេងៗ | ដង | 12 | 16 | 23 | 45 | 40 | 136 |
| ការចូលរួមប្រជុំពិភាក្សាជាប្រចាំជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដើម្បីវិភាគពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ដង | 11 | 11 | 11 | 11 | 11 | 55 |
| បានចុះតាមដានការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួង | អង្គភាព | 23 | 20 | 6 | 0 | 0 | 49 |
| ការកសាងរបាយការណ៍ស្តីពីសមិទ្ធផលការងារ និងទិសដៅការងារផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី | ដង | 20 | 22 | 20 | 22 | 22 | 106 |
| ការផ្ញើការបែងចែករបាយការណ៍សមិទ្ធិផលក្រសួងទៅដល់ថ្នាក់ដឹកនាំក្រសួង និងស្ថាប័នពាក់ព័ន្ធ | ក្បាល | 835 | 905 | 1,130 | 1,068 | 1,400 | 5,338 |

### ២.៥.៤. ការងារនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

តាមរយៈកិច្ចសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ក្រសួងបានបង្កើតគណៈកម្មការជាតិ និងលេខាធិការដ្ឋាននៃគណៈកម្មការជាតិត្រួតពិនិត្យការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន ព្រមទាំងបានបង្កើតក្រុមការងារអន្តរជាតិ និងលេខាធិការដ្ឋានក្រុមការងារអន្តរជាតិ ដើម្បីជួយសម្របសម្រួលប្រមូល និងផ្តល់ធាតុចូល សម្រាប់ធ្វើរបាយការណ៍ឆ្លើយតបជូនអង្គការអន្តរជាតិខាងការងារ (ILO) ឱ្យបានទាន់តាមកាលកំណត់។ ទន្ទឹមនឹងនេះ ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ក្រោមកិច្ចសហការត្រីភាគី និងជំនួយបច្ចេកទេសពីអង្គការ ILO ក្រសួងបានអនុម័តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការ ILO ពាក់ព័ន្ធនឹងសេរីភាពសមាគម និងបានផ្សព្វផ្សាយដល់គ្រប់សមាជិកនៃគណៈកម្មការជាតិនេះ។

**តារាងទី៤១÷ កិច្ចប្រជុំ និងសិក្ខាសាលា ក្នុងតំបន់អាស៊ាន និងអឺរ៉ុប**

| បរិយាយ | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| កិច្ចប្រជុំ និង សិក្ខាសាលា | អាស៊ាន | 83 | 144 | 162 | 145 | 105 | 639 |
| | អឺរ៉ុប | 10 | 22 | 16 | 10 | 9 | 67 |
| | តំបន់ផ្សេងៗ | 38 | 47 | 66 | 59 | 97 | 307 |
| **សរុបរួម** | | **131** | **213** | **244** | **214** | **211** | **1,013** |

ក្រសួងបានបង្កើនវត្តមាននៅលើឆាកអន្តរជាតិតាមរយៈការចូលរួមកិច្ចប្រជុំសំខាន់ៗក្នុងតំបន់អាស៊ាន និងអឺរ៉ុប រួមមាន÷ កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍ សង្គមវប្បធម៌អាស៊ាន កិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រី និងថ្នាក់រដ្ឋមន្ត្រីការងារអាស៊ាន និងកិច្ចប្រជុំសំខាន់ៗ ដែលមាននៅក្នុងគម្រោងផែនការរបស់លេខាធិការដ្ឋានអាស៊ាន។ ក្នុងនោះ ក្រសួងក៏បានចូលរួមអនុម័តលើឯកច្ឆន្ទភាពអាស៊ានស្តីពីការការពារ និងលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសន៍ សេចក្តីថ្លែងការណ៍វៀងចន្ទន៍ ស្តីពីការផ្លាស់ប្តូរ ការងារក្រៅប្រព័ន្ធទៅជាការងារក្នុងប្រព័ន្ធ ដើម្បីឆ្ពោះទៅរកការងារសមរម្យក្នុងក្របខ័ណ្ឌអាស៊ាន និងសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការងារបៃតង ដើម្បីសមធម៌ និងការរីកចម្រើនរួមរបស់អាស៊ាន។

**តារាងទី៤២÷ ភាគព្វកិច្ចអនុវត្តអនុសញ្ញា និងការងារសម្របសម្រួលកិច្ចការអន្តរជាតិ**

| បរិយាយ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|
| ការធ្វើរបាយការណ៍ឆ្លើយតបជាមួយអង្គការ ILO | 11 | 13 | 21 | 11 | 11 | 67 |
| ការធ្វើរបាយការណ៍ឆ្លើយតបពាក់ព័ន្ធកិច្ចការអាស៊ាន | 5 | 6 | 14 | 10 | 12 | 47 |
| ការបកប្រែឯកសារពាក់ព័ន្ធនឹងវិស័យការងារ | 4 | 8 | 0 | 1 | 1 | 14 |
| ការរៀបចំឯកសារជំនួយស្មារតី និងកំណត់បង្ហាញលើកិច្ចការងារអាស៊ាន និង ILO ជូនថ្នាក់ដឹកនាំ | 92 | 104 | 34 | 48 | 39 | 317 |

| | | | | | | |
|---|---|---|---|---|---|---|
| ការប្រមូលចងក្រងអនុស្សរណៈនៃការយោគយល់គ្នា (MoU) និងកិច្ចព្រមព្រៀងរវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយដៃគូពាក់ព័ន្ធនានា | 0 | 0 | 0 | 33 | 35 | 68 |

បន្ថែមលើនេះ ដើម្បីបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ជាមួយដៃគូនានាឱ្យកាន់តែប្រសើរ ក្រសួងក៏បានបន្តចុះអនុស្សរណៈ នៃការយោគយល់គ្នា (MoU) ជាមួយអង្គការ ស្ថាប័នជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក។ ទន្ទឹមនឹងនេះក្រសួងក៏បានសហការជាមួយអ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងការបង្កើត គណៈប្រឹក្សាភិបាល នៃកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិ "រួមគ្នាដើម្បីមុខរបរ និងការងាររបស់យុវជននៅកម្ពុជា (Steering Committee of United Nation Joint Programme "UNited for Youth Employment in Cambodia") ដើម្បីលើកកម្ពស់ចំណេះដឹង និងជំនាញរបស់យុវជនកម្ពុជា ។

**តារាងទី៤៣៖ ការប្រមូលចងក្រងអនុស្សរណៈជាមួយដៃគូពាក់ព័ន្ធនានា**

| បរិយាយ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|
| អនុស្សរណៈនៃការយោគយល់គ្នា(MoU) និងកិច្ចព្រមព្រៀងរវាងក្រសួង ជាមួយដៃគូពាក់ព័ន្ធនានា | 0 | 0 | 0 | 33 | 28 | 61 |

### ២.៥.៥. ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

អង្គភាពអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងស្ថិតក្នុងយុទ្ធសាស្ត្រទី៥ គឺការពង្រឹងអភិបាលកិច្ចល្អ។ ក្នុងនោះដែរ អង្គភាពទាំងពីរបានបំពេញតួនាទីភារកិច្ចស្របតាមផែនការយុទ្ធសាស្ត្រក៏ដូចជាលិខិតបទដ្ឋាននានា ហើយ ក្នុងនោះបានចុះអធិការកិច្ច និងសវនកម្ម ដើម្បីតាមដានលើគ្រប់បណ្តាអង្គភាពក្រោមឱវាទក្រសួង ដើម្បីតាមដានការអនុវត្តលើផែនការយុទ្ធសាស្ត្រក្រសួង២០១៤-២០១៨ និងលិខិតបទដ្ឋាននានា ដែលអង្គភាពទាំងនោះត្រូវអនុវត្ត តាមនីតិវិធី ត្រួតពិនិត្យលើការអនុវត្តចំណូលចំណាយថវិកា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោះស្រាយលើវិវាទរដ្ឋបាល។

ក្រសួងបានរៀបចំផែនការ កម្មវិធីការងារ និងការចាត់តាំងអនុវត្តឱ្យស្របតាមគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួង និងបានចុះធ្វើអធិការកិច្ច និងសវនកម្មនៅតាមបណ្តាអង្គភាព រាជធានីខេត្ត និងអង្គភាពថ្នាក់កណ្តាល ព្រមទាំងបានធ្វើរបាយការណ៍អធិការកិច្ច និងសវនកម្ម ស្តីពីចំណុចខ្វះខាត និងបញ្ហាប្រឈម របស់អង្គភាពរងអធិការកិច្ច និងសវនដ្ឋាន ដើម្បីជូនថ្នាក់ដឹកនាំជ្រាប និងផ្តល់អនុសាសន៍។ ជាមួយគ្នានេះ បានទទួលពាក្យបណ្តឹង និងចុះអង្កេតស្រាវជ្រាវ សម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាលតាមរយៈការប្រមូលសំណុំរឿងឯកសារពាក់ព័ន្ធ សាក្សី និងភស្តុតាងផ្សេងៗ ទៅតាមករណីនៃពាក្យបណ្តឹងជាមួយអង្គភាពពាក់ព័ន្ធ។ បន្ថែមលើនេះទៀត, ក្រសួងក៏បានចូលរួមប្រជុំពិភាក្សាធ្វើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចជាមួយ

ក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច និងបណ្តាស្ថាប័នដទៃទៀត ហើយបានចូលរួមពិនិត្យ និងពិភាក្សាលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**តារាងទី៤៤÷ ការងារអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង**

| ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | លទ្ធផលនៃការអនុវត្ត (គិតជាដង) | | | | | សរុប |
|---|---|---|---|---|---|---|
| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | |
| ការរៀបចំកាលវិភាគ សមាសភាពអធិការកិច្ច និងសវនកម្មសម្រាប់ការិយបរិច្ឆេទ ២០១៨ | 25 | 30 | 53 | 49 | 58 | 215 |
| ការពង្រឹងយន្តការអធិការកិច្ច និងសវនកម្ម ទាំងមុខសញ្ញាថ្មី ការិយបរិច្ឆេទថ្មី និងមុខសញ្ញាចាស់ការិយបរិច្ឆេទចាស់ | 25 | 30 | 53 | 49 | 58 | 215 |
| ការបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ច និងសវនកម្ម | 0 | 0 | 1 | 1 | 1 | 3 |
| ការប្រជុំផ្សព្វផ្សាយស្តីពីលទ្ធផលធ្វើសវនកម្មនូវចំណុចខ្វះខាត ឬចំណុចអសកម្មរួម | 0 | 1 | 1 | 0 | 0 | 2 |
| ការពិនិត្យតាមដានការអនុវត្តបេសកកម្ម និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងក៏ដូចជាគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តរាជរដ្ឋាភិបាល | 25 | 30 | 53 | 49 | 58 | 215 |
| ការចុះដោះស្រាយពាក្យបណ្តឹងជូនគ្រប់បណ្តាអង្គភាពស្ថិតក្រោមចំណុះក្រសួង | 1 | 2 | 5 | 1 | 1 | 10 |

### ២.៥.៦. គណៈកម្មការទទួលបន្ទុកការងារយេនឌ័រ

ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងបានអនុវត្តតាមអនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាឱ្យមានសង្គតិភាពទៅនឹងផែនការយុទ្ធសាស្ត្រស្តីពីនារីរតនៈទី៤ ក្រសួងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ក្នុងការយកចិត្តទុកដាក់ខ្ពស់លើការអប់រំអំពីសិទ្ធិកម្មករក្នុងក្របខ័ណ្ឌច្បាប់ ស្តីពីការងារក្នុងចំណោមនិយោជក និងកម្មករនិយោជិត ជាពិសេសកម្មករកម្មការិនីក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង ការអប់រំជាមូលដ្ឋានអំពីច្បាប់ ស្តីពីការងារ ច្បាប់ទេសន្តរប្រវេសន៍ ច្បាប់ពាក់ព័ន្ធនឹងប្រពៃណីវប្បធម៌ប្រទេសគោលដៅដល់ពលករកម្ពុជាចំណាកស្រុកទាំងពីរភេទ, ការផ្សព្វផ្សាយបទដ្ឋានគតិយុត្ត ស្តីពីសុខភាព និងសុវត្ថិភាពការងារដល់កម្មករ កម្មការិនីក្នុងវិស័យវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង និងបានផ្សព្វផ្សាយព័ត៌មានឱកាសការងារក្នុង និងក្រៅប្រទេស ផ្តល់សេវាពិគ្រោះយោបល់ និងតម្រង់ទិសវិជ្ជាជីវៈដល់ស្ត្រី។ ក្រសួងបានផ្តល់ឱកាស និងជំរុញលើកទឹកចិត្តនារី មានលទ្ធភាពទទួលបានការបណ្តុះបណ្តាល ពង្រឹងសមត្ថភាព និងផ្តល់អាទិភាពឱ្យទទួលបានតួនាទីសមស្របក្នុង

ការងារដឹកនាំ ក្នុងស្ថាប័ន ដោយឡែកក្រសួងបានចុះផ្សព្វផ្សាយបច្ចុប្បន្នភាពអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ (ស៊ី-ដ) និងឱកាសការងារស្ត្រីនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈការចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ GMAP តាមបណ្តាខេត្តគោលដៅ។

ជាសេនាធិការក្នុងការលើកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ក្រសួង គណៈកម្មការទទួលបន្ទុកការងារយេនឌ័រ បានពង្រឹងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ តាមរយៈការផ្សព្វផ្សាយ និងរៀបចំប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ដល់មន្ត្រីរាជការថ្នាក់កណ្តាលជារៀងរាល់ឆ្នាំ ដោយគិតចាប់ពីឆ្នាំ២០១៤មក បានធ្វើការផ្សព្វផ្សាយ ដល់មន្ត្រីជាស្ត្រី ២ ៥៤៦នាក់ (នៃចំនួនសរុប ២ ៧៧២នាក់) និងបានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ជនបង្គោលយេនឌ័រ គ្រប់អង្គភាពក្រោមឱវាទក្រសួង គិតមកត្រឹមឆ្នាំ២០១៨ មានចំនួនសរុប ៦២៥នាក់ (ស្រី ៥០៤នាក់) បានចុះផ្សព្វផ្សាយបច្ចុប្បន្នភាពអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ) និងអនុសាសន៍ ១១ចំណុចរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ និង មន្ត្រីនៃវិទ្យាស្ថានក្រោមឱវាទមន្ទីរ និងបានចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការ GMAP តាមបណ្តាខេត្តគោលដៅ ចំនួន ១០ ទៅ ១១ រាជធានី ខេត្ត ជារៀងរាល់ឆ្នាំ គិតចាប់ពីឆ្នាំ២០១៦ មក។

## តារាងទី៤៥៖ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការជាស្ត្រី

| ល.រ | ឋានៈតួនាទី | ២០១៤ | | ២០១៥ | | ២០១៦ | | ២០១៧ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី | សរុប | ស្ត្រី |
| **១. ថ្នាក់ជាតិ** | | | | | | | | | | | |
| ១ | រដ្ឋលេខាធិការ/ ថ្នាក់ស្មើ | 7 | 2 | 7 | 2 | 7 | 2 | 14 | 1 | 9 | 1 |
| ២ | អនុរដ្ឋលេខាធិការ/ ថ្នាក់ស្មើ | 9 | 2 | 9 | 2 | 7 | 2 | 35 | 2 | 12 | 3 |
| ៣ | អគ្គលេខាធិការ | | | | | | | 0 | 0 | 3 | 0 |
| ៤ | អគ្គនាយក/ ថ្នាក់ស្មើ | 7 | 0 | 7 | 0 | 40 | 4 | 61 | 8 | 9 | 0 |
| ៥ | អគ្គលេខាធិការរង | | | | | | | 0 | 0 | 18 | 3 |
| ៦ | អគ្គនាយករង/ ថ្នាក់ស្មើ | 29 | 5 | 25 | 4 | 26 | 4 | 127 | 16 | 40 | 6 |
| ៧ | ប្រធាននាយកដ្ឋាន/ ថ្នាក់ស្មើ | 38 | 5 | 48 | 7 | 46 | 9 | 83 | 8 | 120 | 15 |
| ៨ | អនុប្រធាននាយកដ្ឋាន/ថ្នាក់ស្មើ | 133 | 29 | 142 | 30 | 144 | 35 | 168 | 46 | 161 | 33 |
| ៩ | ប្រធានការិយាល័យ | 124 | 20 | 236 | 34 | 256 | 38 | 236 | 41 | 251 | 44 |
| ១០ | អនុប្រធានការិយាល័យ | 262 | 56 | 265 | 55 | 431 | 104 | 234 | 116 | 512 | 125 |
| សរុប (១) | | 609 | 119 | 739 | 134 | 957 | 198 | 958 | 238 | 1,135 | 230 |
| **២. ថ្នាក់ក្រោមជាតិ** | | | | | | | | | | | |
| ១ | ប្រធានមន្ទីរ | 25 | 0 | 24 | 0 | 25 | 0 | 25 | 0 | 25 | 0 |
| ២ | អនុប្រធានមន្ទីរ | 61 | 9 | 54 | 10 | 61 | 14 | 64 | 14 | 70 | 17 |
| ៣ | ប្រធានការិយាល័យថ្នាក់រាជធានី ខេត្ត | 120 | 20 | 122 | 18 | 120 | 18 | 89 | 17 | 97 | 17 |
| ៤ | អនុប្រធានការិយាល័យថ្នាក់រាជធានី ខេត្ត | 170 | 44 | 174 | 47 | 130 | 36 | 119 | 39 | 155 | 48 |
| ៥ | នាយកមជ្ឈមណ្ឌល | 20 | 1 | 20 | 1 | 20 | 1 | 22 | 1 | 18 | 0 |
| ៦ | នាយករងមជ្ឈមណ្ឌល | 20 | 1 | 20 | 1 | 18 | 2 | 30 | 5 | 22 | 2 |
| ៧ | ប្រធានការិយាល័យថ្នាក់ក្រុង ខណ្ឌ ស្រុក | 18 | 1 | 17 | 1 | 7 | 2 | 12 | 1 | 19 | 1 |
| ៨ | អនុប្រធានការិយាល័យថ្នាក់ក្រុងខណ្ឌ ស្រុក | 5 | 0 | 5 | 2 | 2 | 1 | 11 | 0 | 0 | 0 |
| សរុប (២) | | 439 | 76 | 436 | 80 | 383 | 74 | 362 | 77 | 406 | 85 |
| **សរុបរួម (១) + (២)** | | 1,048 | 195 | 1,175 | 214 | 1,340 | 272 | 1,320 | 315 | 1,541 | 315 |

ជាមួយគ្នានេះ ក្រសួងតាមរយៈគណៈកម្មការ ទទួលបន្ទុកការងារយេនឌ័រ ក្នុងសកម្មភាពបង្កើនឱកាសការងារសមស្រប និងការងារដែលមានកម្រៃទាំងក្នុង និងក្រៅប្រទេសដល់ស្ត្រី ក្រសួងបានចុះអប់រំអំពីច្បាប់នានា ជាអាទិ៍ ការអប់រំអំពីសិទ្ធិកម្មករក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការងារក្នុងចំណោមនិយោជក និងកម្មករនិយោជិត

ពិសេសកម្មការិនីក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានចំនួន ៥៧,៦% ការអប់រំជាមូលដ្ឋានអំពីច្បាប់ស្តីពីការងារ ច្បាប់ទេសន្តរប្រវេសន៍ ច្បាប់ពាក់ព័ន្ធជាមួយប្រពៃណី វប្បធម៌ប្រទេសគោលដៅ ដល់ពលករកម្ពុជាចំណាកស្រុកមានចំនួន ៥ ៤៩៩ នាក់ ក្នុងនោះស្ត្រី ៤៤,៥%។ ក្រសួងបានបន្តការផ្សព្វផ្សាយព័ត៌មានស្តីពីឱកាសការងារក្នុងស្រុក និងក្រៅប្រទេស សេវាពិគ្រោះយោបល់ និងតម្រង់ទិសវិជ្ជាជីវៈ បានចំនួន ៩១ ៥៩៤ នាក់ (ស្ត្រី ៣៩,៤%) ផ្សព្វផ្សាយអំពីសេវា ទ.ជ.ម.ក ដល់អ្នកស្វែងរកការងារធ្វើជាស្ត្រី ចំនួន ៥៥ ៤៧៤ នាក់(ស្ត្រី ៣៦,៧%) ព្រមទាំងអភិវឌ្ឍសមត្ថភាពជំនាញដល់ស្ត្រីជាមន្ត្រីនៅ ទ.ជ.ម.ក បានចំនួន ៩៥១ នាក់ (ស្រី ៣២,៧%) បានទទួលការអភិវឌ្ឍសមត្ថភាព។

ស្ត្រីទទួលបានការបណ្តុះបណ្តាលកម្រិតឧត្តម ចំនួន ៣ ៦៩៥ នាក់ កម្រិតជាន់ខ្ពស់បច្ចេកទេស/បរិញ្ញាបត្ររង ចំនួន ១ ៧៣១ នាក់ កម្រិតសញ្ញាបត្ររយៈពេលវែង ចំនួន ១ ១៥៣ នាក់។ ជាមួយគ្នានេះ ក្រសួងក៏បានផ្តល់អាហារូបករណ៍ដល់សិស្សស្ត្រីបានចំនួន ៨៨៦នាក់ ការបណ្តុះបណ្តាលស្ត្រីតាមរយៈមូលនិធិកាត់បន្ថយភាពក្រីក្រ បានចំនួន ៤៩ ៨៨៥ នាក់ ការហ្វឹកហ្វឺនកូនជាងនៅតាមសហគ្រាស-គ្រឹះស្ថាន ដល់កម្មការិនីបានចំនួន ៦៣ ៩៣៩ នាក់។

**តារាងទី៤៦÷ ស្ថានភាពស្ត្រីទទួលបានសេវាបណ្តុះបណ្តាល**

| បរិយាយ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| ចំនួនស្ត្រីទទួលសេវាបណ្តុះបណ្តាលតាមរយៈថវិកាទ្រទ្រង់គ្រឹះស្ថានសិក្សា | ស្រី | 1,423 | 2,875 | 2,469 | 2,133 | 6,273 | 15,173 |
| ចំនួនស្ត្រីដែលទទួលការបណ្តុះបណ្តាលតាមរយៈកម្មវិធីស្ពានចម្លងបន្តជំនាញ | ស្រី | 8,923 | 17,104 | 9,818 | 80 | 802 | 36,727 |
| ចំនួនស្ត្រីទទួលបានការបណ្តុះបណ្តាលកំរិតឧត្តម | ស្រី | 1,119 | 622 | 709 | 718 | 527 | 3,695 |
| ចំនួនស្ត្រីទទួលបានការបណ្តុះបណ្តាលកំរិតជាន់ខ្ពស់បច្ចេកទេស/ បរិញ្ញាបត្ររង | ស្រី | 413 | 250 | 244 | 412 | 412 | 1,731 |
| ចំនួនស្ត្រីទទួលបានការបណ្តុះបណ្តាលកំរិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈរយៈពេលវែង | ស្រី | 314 | 123 | 232 | 237 | 247 | 1,153 |
| ចំនួនខេត្តបានសិក្សាស្រាវជ្រាវបញ្ហាយេនឌ័រលើមុខជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ | ស្រី | 0 | 9 | 10 | 6 | 8 | 33 |
| ចំនួនខិតប័ណ្ណ Leaflet ជំនាញសំណង់ មេកានិច រថយន្ត ព័ត៌មានវិទ្យា/ ធុរកិច្ចដែលបានចែកដល់ក្មេងស្រី និងសិស្សតាមរាជធានីខេត្ត | ស្រី | 0 | 10 | N/A | 4 | 0 | 14 |
| អន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី តាមគ្រឹះស្ថាន អ.ប.វ | ស្រី | 0 | 0 | N/A | 0 | 0 | 0 |
| ការផ្តល់អាហារូបករណ៍ដល់សិស្សស្រី | ស្រី | 0 | 0 | 0 | 446 | 440 | 886 |
| ការបណ្តុះបណ្តាលសហគ្រិនភាព ក្នុងបណ្តាគ្រឹះស្ថាន អ.ប.វ | ស្រី | 0 | 0 | N/A | 16 | 0 | 16 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ចំនួនសិក្ខាកាម សិស្ស និស្សិតជាស្ត្រី ទទួលបានការបញ្ជាបយេនឌ័រក្នុងកម្មវិធីសិក្សា តាមគ្រឹះស្ថាន អ.ប.វ | ស្រី | 0 | 912 | 1,321 | 2,127 | 3,069 | 7,429 |
| ការបណ្ដុះបណ្ដាលជំនាញដល់ស្ត្រីតាមរយៈមូលនិធិជាតិបណ្ដុះបណ្ដាលដើម្បីកាត់បន្ថយភាពក្រីក្រ | ស្រី | 8,923 | 17,104 | 9,818 | 9,056 | 4,984 | 49,885 |
| ហ្វឹកហ្វឺនកូនជាងតាមរោងចក្រ សហគ្រាស ដល់កម្មករិនី | ស្រី | 8,601 | 10,446 | 14,310 | 10,736 | 19,846 | 63,939 |
| ចំនួននាយិកា នាយិការង ជាស្ត្រី | ស្រី | 0 | 0 | 18 | 19 | 19 | 56 |
| ចំនួនគ្រូបច្ចេកទេសដែលចូលវគ្គបណ្ដុះបណ្ដាលបង្កើនសមត្ថភាពនានា | ស្រី | 0 | 0 | 469 | 493 | 0 | 962 |

## ៣. បញ្ហាប្រឈម

ក្រៅពីសមិទ្ធផលធំៗគួរជាទីមោទកភាពខាងលើនេះ ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៤-២០១៨ កន្លងមក ក្រសួងជួបបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តយកចិត្តទុកដាក់ និងដោះស្រាយ រួមមាន÷

### ៣.១. ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

– សមត្ថភាពមន្ត្រីអធិការកិច្ចការងារអំពីច្បាប់ស្តីពីការងារ, លិខិតបទដ្ឋានពាក់ព័ន្ធនានា, នីតិវិធីនៃអធិការកិច្ចការងារនៅមានកម្រិត មិនទាន់មានវគ្គវិក្រឹត្យការពង្រឹងសមត្ថភាព ការប្រឡងតេស្តសមត្ថភាពមន្ត្រីអធិការកិច្ចការធ្វើអធិការកិច្ចការងារនៅមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងផែនការអធិការកិច្ចការងារ ទម្រង់របាយការណ៍អធិការកិច្ចការងារ (Check List) មិនទាន់ឆ្លើយតបនឹងការអនុវត្តជាក់ស្តែង ហើយការផ្តល់របាយការណ៍មានភាពយឺតយ៉ាវមិនទាន់គ្រប់ជ្រុងជ្រោយ

– ស្ថិតិសហគ្រាស-គ្រឹះស្ថាន មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ការគ្រប់គ្រងស្ថិតិមិនមានជាលក្ខណៈជាប្រព័ន្ធព័ត៌មានវិទ្យា បូករួមទាំងខ្វះការជូនដំណឹងមកក្រសួងតាមនីតិវិធីពីម្ចាស់សហគ្រាស-គ្រឹះស្ថាន នៅពេលសហគ្រាស-គ្រឹះស្ថានបិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូរថៅកែថ្មី ឬប្តូរស្លាកយីហោថ្មី

– ការពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅមានកម្រិត សហគ្រាស-គ្រឹះស្ថានមួយចំនួននៅមិនទាន់បានរៀបចំប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ ហើយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅមិនទាន់មានគ្រប់គ្រាន់ ខ្លះមិនទាន់បានធ្វើបច្ចុប្បន្នភាព និងមិនទាន់មានច្បាប់ស្តីពីសុខភាព និងសុវត្ថិភាពការងារ

– សមត្ថភាពមន្ត្រីអធិការកិច្ចការងារក្នុងវិស័យ រ៉ែ សំណង់ សេវាកម្សាន្ត និងសហគ្រាសខ្នាតតូចនៅមានកម្រិត, កង្វះអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ គ្រូពេទ្យឯកទេសផ្នែកជំងឺវិជ្ជាជីវៈ សម្ភារបរិក្ខារ អគារមន្ទីរពិសោធន៍ សហគ្រាស-គ្រឹះស្ថានមួយចំនួននៅមិនទាន់គោរព និងអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋាន

ស្តីពីសុខភាព និងសុវត្ថិភាពការងារ ជាមួយគ្នានេះការយល់ដឹងរបស់និយោជក និងកម្មករនិយោជិតស្តីពីសុខភាព និងសុវត្ថិភាពការងារក៏នៅមិនទាន់ទូលំទូលាយនៅឡើយ

– ក្នុងការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ប្រសិទ្ធភាព នៃយន្តការទប់ស្កាត់បញ្ហាកូដកម្ម បាតុកម្ម នៅមិនទាន់ឆ្លើយតបនឹងការងារ មានជួបបញ្ហាដូចជា ការបិទរោងចក្រដោយមិនជូនដំណឹង (ថៅកែរត់ចោល) ប៉ះពាល់ដល់កម្មករនិយោជិតដែលមានអតីតភាពយូរ

– សមត្ថភាពមន្ត្រី គ.ក.ប គ្រប់ថ្នាក់នៅមានកម្រិត ការអនុវត្តច្បាប់ចំពោះជនល្មើស និងជនដៃដល់ក្នុងសកម្មភាពកូដកម្ម បាតុកម្ម នៅមិនទាន់បានគ្រប់ជ្រុងជ្រោយ ការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ឯកសារ និងភស្តុតាងមិនទាន់ឆ្លើយតបទាន់ពេលវេលា កង្វះបន្ទប់ផ្សះផ្សាមិនគ្រប់គ្រាន់ខ្វះបន្ទប់តម្កល់ឯកសារ និងខ្វះខាតមធ្យោបាយធ្វើដំណើរក្នុងការបំពេញភារកិច្ច

– ការកំណត់ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ននៅមានកម្រិតត្រឹមតែវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង មិនទាន់អាចពង្រីកទៅដល់វិស័យផ្សេង

– ការសិក្សាស្រាវជ្រាវអំពីវិសាលភាពនៃប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗមិនទាន់បានទូលំទូលាយ ដោយសារមិនទាន់មានអង្គភាពប្រតិបត្តិច្បាស់លាស់ សមត្ថភាពមន្ត្រីមានកម្រិត និងមិនទាន់គ្រប់គ្រាន់ ចំណែកប្រព័ន្ធគ្រប់គ្រងទិន្នន័យមិនទាន់មានដែលនាំឱ្យកើតមាននូវការវិភាគខ្វះចន្លោះ និងមិនទាន់ពេលវេលា

– មិនទាន់មានយន្តការច្បាស់លាស់ក្នុងការសិក្សាតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ប្រាក់ឈ្នួលអប្បបរមាដោយប្រើប្រាស់វិធីសាស្ត្រ និងម៉ូឌែល

– យន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា ច្បាប់ប្រាក់ឈ្នួលអប្បបរមា និងឯកសារពាកព័ន្ធ មិនទាន់បានធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ

– ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារមិនទាន់ឆ្លើយតបទៅនឹងគោលដៅ នៃផែនការសកម្មភាពជាតិ ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងសហគ្រាស-គ្រឹះស្ថាន មួយចំនួនស្តីពីផលវិបាកនៃបញ្ហាពលកម្មកុមារនៅមានកម្រិត, គណៈកម្មការពលកម្មកុមាររាជធានីខេត្ត មិនទាន់បានដំណើរការឱ្យបានពេញលេញ ហើយសមត្ថភាពមន្ត្រីអធិការកិច្ចការងារកុមារ និងធនធានសម្រាប់ការងារអធិការកិច្ចកុមារមិនគ្រប់គ្រាន់។

**៣.២. ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

– ការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជា និងស្តង់ដាសមត្ថភាពតាមវិស័យអាទិភាព នៅមិនទាន់ត្រូវបានអនុវត្តទូលំទូលាយ ពុំទាន់មានមជ្ឈមណ្ឌលធ្វើតេស្ត និងទទួលស្គាល់ជំនាញ ហើយកម្មវិធីសិក្សា អ.ប.វ មិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ រីឯការចូលរួមរបស់វិស័យឯកជនក្នុងប្រព័ន្ធ អ.ប.វ ក៏នៅមានកម្រិត

-លក្ខណវិនិច្ឆ័យ និងការវាយតម្លៃទទួលស្គាល់គុណភាពគ្រឹះស្ថាន អ.ប.វ មិនទាន់បានអនុវត្តពេញលេញ ជំនាញដែលដាក់ចូលរួមប្រកួតប្រជែងជំនាញ ថ្នាក់ជាតិអាស៊ាន និងអន្តរជាតិនៅមានចំនួនតិច ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍ និងសម្ភារបណ្តុះបណ្តាល ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សមត្ថភាពមន្ត្រីគ្រប់គ្រងនៅមានកម្រិត ហើយគ្រូបច្ចេកទេស និងគ្រូឯកទេសនៅខ្វះបទពិសោធន៍អនុវត្តជាក់ស្តែង

-សាធារណជន និងសិស្សនិស្សិតមិនទាន់បានយល់ដឹងច្បាស់អំពីអត្ថប្រយោជន៍នៃវិស័យ អ.ប.វ កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី មិនទាន់ឆ្លើយតបទៅនឹងតម្រូវការបណ្តុះបណ្តាល រីឯគ្រឹះស្ថាន អ.ប.វ មួយចំនួនមិនទាន់មានលទ្ធភាព ផ្តល់ការបណ្តុះបណ្តាលរយៈពេលវែងនៅឡើយ ហើយចំពោះគុណភាពនៃការបណ្តុះបណ្តាលមិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារ ថវិកាសម្រាប់ប្រព័ន្ធ អ.ប.វ មានកម្រិត ជំនាញមូលដ្ឋាន និងជំនាញទន់មិនទាន់មានការបណ្តុះបណ្តាលទូលំទូលាយនៅឡើយ

-ការគ្រប់គ្រងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រឹះស្ថាន អ.ប.វ មួយចំនួនពុំទាន់បានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការគ្រប់គ្រង និងប្រមូលស្ថិតិគ្រឹះស្ថាននៅមិនទាន់មានប្រសិទ្ធភាព និង កង្វះខាតលំហូរព័ត៌មានទីផ្សារការងារ និងព័ត៌មានរវាងភាគីពាក់ព័ន្ធ

-ការទទួលស្គាល់កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្លងប្រព័ន្ធ មិនទាន់ទូលំទូលាយទោះបីជាក្របខ័ណ្ឌគុណវុឌ្ឍជាតិកម្ពុជាត្រូវបានអនុម័ត ការផ្សាភ្ជាប់រវាងកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅមានកម្រិត កង្វះការខិតខំប្រឹងប្រែងរួមគ្នានៅក្នុងការបណ្តុះបណ្តាលគ្រូបច្ចេកទេស និងការចែករំលែកសម្ភារសិក្សាក្នុងចំណោមក្រសួងពាក់ព័ន្ធ កម្មវិធីស្ពានចម្លងបន្តជំនាញព្រមទាំងការផ្តល់វិញ្ញាបនបត្រឆ្លងក្រសួង និងគ្រឹះស្ថានបណ្តុះបណ្តាលដែលពាក់ព័ន្ធ នៅមិនទាន់អនុវត្តបានទូលំទូលាយ។

### ៣.៣. ការអភិវឌ្ឍមុខរបរ និងការងារ

-ក្នុងការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស ការយល់ដឹងរបស់សហគ្រាស-គ្រឹះស្ថាន និងជនបរទេសមួយចំនួនក្នុងការបំពេញបែបបទ និងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនៅមានកម្រិត រីឯនីតិវិធីនៃការអនុវត្តការងារក្នុងការចុះធ្វើអធិការកិច្ចនៅមានភាពស្មុគស្មាញ និងចំណាយពេលច្រើន

-ការយល់ដឹងរបស់និយោជក រដ្ឋបាល អ្នកគ្រប់គ្រង និងជនបរទេស នៅតាមបណ្តាសហគ្រាស-គ្រឹះស្ថានមួយចំនួនអំពីច្បាប់ និងបទបញ្ញាជាធរមាននៅមានកម្រិតដែលនៅជាឧបសគ្គក្នុងការធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងជនបរទេសដែលចូលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការគ្រប់គ្រង និងការផ្តល់សេវាជូនកម្មករនិយោជិតខ្មែរ

-ទាក់ទងនឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ នៅមានបញ្ហាប្រឈមលើការពង្រឹងយន្តការគ្រប់គ្រង និងការពារពលករទេសន្តរប្រវេសន៍ ដោយទីភ្នាក់ងារជ្រើសរើសឯកជនមួយចំនួនបានផ្សព្វផ្សាយពីការជ្រើសរើសពលករទៅធ្វើការនៅបរទេសដោយគ្មានការអនុញ្ញាតពីក្រសួង ហើយមួយចំនួនតូចលក់អាជ្ញាបណ្ណរបស់ខ្លួនទៅ

ក្រុមហ៊ុន ឬបុគ្គលិកផ្សេងទៀតដែលច្បាប់បានហាមឃាត់។ មិនតែប៉ុណ្ណោះសមត្ថភាពបុគ្គលិករបស់ទីភ្នាក់ងារជ្រើសរើសឯកជន ពាក់ព័ន្ធនឹងច្បាប់ និងបទប្បញ្ញត្តិនានាក៏នៅមានកម្រិតនៅឡើយដែរ

– ខ្វះមន្ត្រីបម្រើការងារ និងសមត្ថភាពមន្ត្រីផ្នែកសេវាការងារនិងព័ត៌មានទីផ្សារការងារនៅមានកម្រិត

– ធនធានហិរញ្ញវត្ថុដែលទទួលបាននៅមានកម្រិត

– វិសាលភាពគ្របដណ្តប់ និងប្រព័ន្ធគ្រប់គ្រងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារនៅមានកម្រិត

– កម្លាំងពលកម្មជាច្រើនមានបំណងធ្វើទេសន្តរប្រវេសន៍ទៅធ្វើការក្រៅប្រទេស

– ប្រព័ន្ធព័ត៌មានទីផ្សារការងារមិនទាន់មានការអភិវឌ្ឍពេញលេញដែលនាំឱ្យកើតឡើងនូវកង្វះជំនាញ (Skill Shortage) និងភាពមិនស៊ីគ្នានៃជំនាញ (Skill Mismatch) ក្នុងទីផ្សារការងារ។

### ៣.៤. ការពាក់ព័ន្ធការអនុវត្តរបបសន្តិសុខសង្គមដល់ កម្មករនិយោជិត និងមន្ត្រី សាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

– ធនធានមនុស្ស និងអគាររដ្ឋបាល របស់ ប.ស.ស. នៅមិនទាន់ឆ្លើយតបទៅនឹងទំហំការងារជាក់ស្តែង

– សហគ្រាស-គ្រឹះស្ថានមួយចំនួនមិនបានបំពេញកាតព្វកិច្ចមកចុះបញ្ជីសហគ្រាស និងផ្តល់ទិន្នន័យអំពីចំនួនកម្មករនិយោជិត និងប្រាក់ខែកម្មករនិយោជិតមិនទាន់ត្រឹមត្រូវនៅឡើយ

– កម្មករនិយោជិតមួយចំនួនមិនមានឯកសារគ្រប់គ្រាន់សម្រាប់បំពេញបែបបទចុះបញ្ជី និងទទួលសេវា (ខ្វះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ខុសឈ្មោះ ខ្ចីឈ្មោះអ្នកផ្សេងប្រើ គ្មានសំបុត្រអាពាហ៍ពិពាហ៍ គ្មានសំបុត្រកំណើត គ្មានសៀវភៅគ្រួសារ) ដែលធ្វើឱ្យមានការលំបាកក្នុងការចុះបញ្ជី និងផ្តល់តាវកាលិក

– គុណភាពសេវារបស់មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. មិនទាន់ឆ្លើយតបទៅនឹងការរំពឹងទុករបស់សមាជិក ប.ស.ស.

– ការផ្តល់សេវាស្តារនីតិសម្បទានៅមានកម្រិត។

### ៣.៥. ការពាក់ព័ន្ធការពង្រឹងអភិបាលកិច្ចល្អ

– ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង នៅពុំទាន់ទទួលបានការឆ្លើយតបពេញលេញនឹងតម្រូវការរបស់អ្នកប្រើប្រាស់សេវា

– ការព្យាករណ៍ និងការអនុវត្តចំណូលនៅមានភាពលំអៀងលើសពីផែនការ ដោយសារតម្រូវការចំណាយរបស់ក្រសួងធំជាងលទ្ធភាពថវិកា, ផែនការបេសកកម្មក្នុង និងក្រៅប្រទេសមិនទាន់រៀបចំបានល្អប្រសើរនាំឱ្យខ្វះឥណទានរៀងរាល់ឆ្នាំ

– ការគ្រប់គ្រងចំណាយដែលអនុវត្តទៅតាមកម្មវិធី អនុកម្មវិធី សកម្មភាព និងជំពូកមាតិកាថវិកាមានលក្ខណៈ ស្មុគស្មាញ រីឯអង្គភាពថវិកាមួយចំនួននៅមិនទាន់មានភាពជាម្ចាស់ និងមិនមានមន្ត្រីជំនាញហិរញ្ញវត្ថុច្បាស់លាស់ នីតិវិធីលទ្ធកម្មមានរយៈពេលវែងធ្វើឱ្យការផ្គត់ផ្គង់សម្ភារលទ្ធកម្មមានការយឺតយ៉ាវ និងមិនទាន់តាមតម្រូវការ និងសភាពការណ៍ជាក់ស្តែង

– ការងារកសាងផែនការ ស្ថិតិ និងនីតិកម្ម នៅពុំទាន់មានដំណើរការល្អនៅឡើយដោយសារសមត្ថភាពមន្ត្រីនៅមានកម្រិត ការប្រមូលសរុបស្ថិតិអន្តរអង្គភាពនៅមិនទាន់មានសង្គតិភាពទៅនឹងយុទ្ធសាស្ត្រ កម្មវិធី និងអនុកម្មវិធីនីមួយៗ ពិបាកវាយតម្លៃសូចនាករដែលបានដាក់ចេញ និងពុំទាន់មានប្រព័ន្ធស្ថិតិស្តីពីវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

– ការអនុវត្តផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទ នៅមិនទាន់មានសង្គតិភាពទៅនឹងយុទ្ធសាស្ត្រ កម្មវិធី និងអនុកម្មវិធីនីមួយៗ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានាមិនទាន់មានដំណើរការល្អ

– សមត្ថភាពមន្ត្រីផ្នែកសហប្រតិបត្តិការអន្តរជាតិនៅមានកម្រិត ចំនួនមន្ត្រីមានជំនាញបច្ចេកទេសទៅតាមផ្នែកនីមួយៗ ដូចជាភាសាបរទេស ច្បាប់ ព័ត៌មានវិទ្យា រៀបចំគម្រោង និងពិធីការ មិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងព្រមជាមួយគ្នានេះកិច្ចសហការពីស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការផ្តល់ធាតុចូល ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍ និងពាក្យបណ្តឹងនានាមិនទាន់មានភាពរលូន

– មិនទាន់មានយន្តការច្បាស់លាស់ក្នុងការសម្របសម្រួល ប្រមូល គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត អនុស្សរណៈនៃការយោគយល់គ្នា (MoU) និងលិខិតូបករណ៍នានា។ មិនទាន់មានយន្តការច្បាស់លាស់ក្នុងការគ្រប់គ្រងរបាយការណ៍ និងទិន្នន័យបេសកកម្មក្រៅប្រទេស ហើយការស្វែងរកកិច្ចសហ-ប្រតិបត្តិការ និងការគាំទ្រផ្នែកបច្ចេកទេស ពីសំណាក់ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិនៅមានកម្រិត

– ការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង អង្គភាពរងអធិការកិច្ច និងសវនដ្ឋាន ថ្នាក់ក្រោមជាតិមួយចំនួនមិនបានសហការក្នុងការផ្តល់ឯកសារ និងការឆ្លើយនូវសំណួរពាក់ព័ន្ធឱ្យបានគ្រប់ជ្រុងជ្រោយ ហើយមួយចំនួនពុំបានអនុវត្តតាមអនុសាសន៍របស់ប្រតិភូ រីឯយន្តការនៃការទទួលពាក្យបណ្តឹងពីមន្ត្រីរាជការ និងសាធារណជនទាំងឡាយ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារមិនទាន់បានអនុវត្ត

– មន្ត្រីអធិការកិច្ច និងសវនកម្មួយចំនួន សមត្ថភាពនៅមានកម្រិតក្នុងការបំពេញការងារ។ លិខិតបទដ្ឋានថ្មីៗ អង្គភាពអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង មិនបានទទួលឱ្យទាន់ពេលវេលាដើម្បីធ្វើជាមូលដ្ឋានក្នុងការចុះធ្វើអធិការកិច្ច និងសវនកម្ម។ យន្តការមួយចំនួនដែលទាក់ទងទៅនឹងចំណុចខ្វះខាតដែលអង្គភាព អគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុងបានរកឃើញមិនបានដោះស្រាយឱ្យទាន់ពេលវេលានៅឡើយ។

## ៤. សេចក្តីសន្និដ្ឋាន

ការអនុវត្តការងារឆ្នាំ២០១៤-២០១៨កន្លងមកនេះ ទទួលបានសមិទ្ធផលគួរជាទីមោទនៈ តាមការចង្អុលទិសក្រោមការដឹកនាំដ៏ឆ្លាតវៃរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមទាំងថ្នាក់ដឹកនាំរបស់ក្រសួង។ ជាមួយនឹងយុទ្ធសាស្ត្រកែទម្រង់ដ៏ត្រឹមត្រូវដែលបានដាក់ចេញ គ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានជំនះនូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយ

ដោយបានឈានទៅអនុវត្តប្រកបដោយភាពជោគជ័យនូវសមិទ្ធផលសំខាន់ៗជាច្រើនជូនរាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនកម្ពុជា។

ការសម្រេចបាននូវសមិទ្ធផលខាងលើនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរួមចំណែកលើការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ ព្រមទាំងផែនការជាតិនានាដែលអាចជះឥទ្ធិពលមកលើសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាស្របតាមការវិវត្តនៃសេដ្ឋកិច្ចតំបន់ និងពិភពលោក ជាពិសេសនៅក្នុងបរិបទអាស៊ាន និងសកលភាវូបនីយកម្ម ដែលវិស័យការងារបានបន្តអភិវឌ្ឍរីកចម្រើន ដោយអត្រាមានការងារធ្វើ ៩៩,៣% បរិមាណការងារសរុបមានប្រមាណជិត១០លាននាក់។ សហគ្រាស-គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធដែលមានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ១២ ៧៩៦ សហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចំនួន ១ ៤២០ ៥៤៧នាក់ ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមជិត ៣ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ សហគ្រាស-គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានចំនួនប្រមាណជិត៦សែន មានកម្មករចំនួនជាង ២លាន៤សែននាក់ វិស័យកសិកម្មប្រមាណជាង៤លាននាក់ ពលករធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណ១លាន២សែននាក់ និងមន្ត្រីសាធារណៈចំនួនប្រមាណជាង ៥សែននាក់។ ចាប់ពីឆ្នាំ២០១៨ និយោជកបានអនុវត្តកាតព្វកិច្ចបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ១០០% ជំនួសកម្មករនិយោជិត។ រដ្ឋបាលថ្នាក់ក្រោមជាតិបានត្រួតពិនិត្យជាប្រចាំនូវថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនី នៅតាមផ្ទះជួល និងកំពុងបន្តជំរុញការតភ្ជាប់បណ្តាញអគ្គិសនី និងទឹកស្អាតនៅតាមតំបន់ផ្ទះជួលរបស់កម្មករនិយោជិត។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបាននឹងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននឹងកំពុងដោះស្រាយបើកផ្តល់អត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត ដែលរោងចក្របិទទ្វារ និងកំពុងរៀបចំបទប្បញ្ញត្តិ ដើម្បីដោះស្រាយករណីនេះជូនកម្មករនិយោជិត រួមទាំងបាននឹងកំពុងយកចិត្តទុកដាក់ដល់ពលករដែលកំពុងធ្វើការនៅក្រៅប្រទេសដោយបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសទទួលផ្សេងៗទៀត ដើម្បីបន្តផ្តល់ឱកាសការងារជូនពលករ, ការពារសិទ្ធិ និងផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

ផ្អែកលើសមិទ្ធផលការងារ បទពិសោធន៍ និងយន្តការដែលមានកន្លងមក ព្រមទាំងការដឹកនាំដ៏ឈ្លាសវៃរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងថ្នាក់ដឹកនាំទាំងអស់ក្រសួងមានជំនឿយ៉ាងមុតមាំថា គ្រប់អង្គភាពក្រោមឱវាទទាំងអស់នឹងជំនះនូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយ ដើម្បីឈានទៅអនុវត្តប្រកបដោយជោគជ័យ និងទទួលបាននូវសមិទ្ធផលគួរជាទីមោទកៈថ្មីថែមទៀតជូនរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៦នៃនីតិកាលរដ្ឋសភា ក៏ដូចជាប្រជាជនកម្ពុជា ក្នុងនោះក៏ត្រូវធ្វើការ

ត្រួតពិនិត្យឡើងវិញនូវផែនការសកម្មភាពទាំងឡាយរបស់ខ្លួនដែលមានភាពទន់ភ្លន់ បត់បែនទៅតាមសភាពការណ៍ និងស្ថានភាពជាក់ស្តែងដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តតាមបេសកកម្មដែលរាជរដ្ឋាភិបាលប្រគល់ជូនឱ្យទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា និងប្រកបដោយចីរភាព៕

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣** ត្រូវបានរៀបចំ និងចងក្រងក្រោមការណែនាំ និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដោយ÷

| ល.រ | គោត្តនាម-នាម | តួនាទី |
|---|---|---|
| ១ | ឯកឧត្តម **ហេង សួរ** | រដ្ឋលេខាធិការ |
| ២ | ឯកឧត្តម **ខុយ រិទ្ធ** | អនុរដ្ឋលេខាធិការ |
| ៣ | លោកជំទាវ **សុវណ្ណ វណ្ណារតន៍** | អនុរដ្ឋលេខាធិការ |
| ៤ | ឯកឧត្តម **សេង សក្ដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកការងារ |
| ៥ | ឯកឧត្តម **ឡៅ ហ៊ឹម** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| ៦ | ឯកឧត្តម **អ៊ុក សមវិទ្យា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិរបបសន្តិសុខសង្គម |
| ៧ | ឯកឧត្តម **ប្រាក់ ចាន់ធឿន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គលេខាធិការ អ.គ.ក.ប |
| ៨ | ឯកឧត្តម **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ៩ | ឯកឧត្តម **ជិត គន្ធល** | អគ្គាធិការ |
| ១០ | ឯកឧត្តម **ហាំង តុលា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ |
| ១១ | ឯកឧត្តម **ទី ស៊ីម៉ាណែត** | ទីប្រឹក្សាក្រសួងនិងជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ |
| ១២ | ឯកឧត្តម **វ៉េង ហៀង** | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ព និងជាប្រធាននាយកដ្ឋានការងារកុមារ |
| ១៣ | ឯកឧត្តម **កុយ ទេពដារាវុធ** | ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានវិវាទការងារ |
| ១៤ | ឯកឧត្តម **ហ៊ុង ស៊ីដេត** | ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| ១៥ | ឯកឧត្តម **អ៊ុក ចាន់ធូ** | ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានអធិការកិច្ចការងារ |
| ១៦ | ឯកឧត្តម **ឡេង តុង** | ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានពេទ្យការងារ |
| ១៧ | ឯកឧត្តម **គួច សុមាន** | ទីប្រឹក្សាក្រសួង និងជាអនុប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ |
| ១៨ | ឯកឧត្តម **ឡូ សុភារិទ្ធ** | ទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១៩ | លោក **អុល ពេជ្រចរិយា** | ទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២០ | លោក **ឃុន ចាន់ណារិទ្ធ** | ទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២១ | លោក **សេង សុខហេង** | នាយករងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា |
| ២២ | លោក **គង់ ឆារ័ត្ន** | ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |

| | | |
|---|---|---|
| ២៣ | លោក **គីម កែវរស្មី** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ |
| ២៤ | លោក **ហង្ស កក្កដារាស្សី** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ២៥ | លោកស្រី **ស្រេង សុកសេរីវឌ្ឍនី** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ |
| ២៦ | លោក **ខៀវ ឆិត្យាកោមល** | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| ២៧ | លោកស្រី **សៅ សុគន្ធកេត្យា** | ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ |
| ២៨ | លោក **ឆាង សាក់** | ប្រធាននាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា |
| ២៩ | លោក **សាន សេង** | ប្រធាននាយកដ្ឋានធានាគុណភាព |
| ៣០ | លោកស្រី **នង កណ្ណិកា** | ប្រធាននាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ |
| ៣១ | លោក **តាន់ សម្បត្តិ** | ប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា |
| ៣២ | លោក **ជៀប ចាន់ថន** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៣៣ | លោក **ស្រ៊ុន ចន្ទុល** | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ |
| ៣៤ | លោក **ប៉ូ ចាន់ផល** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣៥ | លោក **ជុំ មុំ** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣៦ | លោក **រឿន រ៉ាឌី** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣៧ | លោក **យិន វណ្ណៈ** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣៨ | លោក **ជុំ សម្ផស្ស** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៣៩ | លោក **ម៉ិច សុចិត្រា** | ប្រធានការិ.នៃនាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៤០ | លោក **ឡេះ រ៉ានី** | ប្រធានការិ.នៃនាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |
| ៤១ | លោក **មាន ឈាវិមន្ត** | មន្ត្រី |
| ៤២ | លោក **ឌួន សន្ធី** | មន្ត្រី |
| ៤៣ | ថ្នាក់ដឹកនាំ និងមន្ត្រី | គ្រប់អង្គភាពដែលបានសហការផ្តល់នូវស្ថិតិ និងរបាយការណ៍នានា |

# ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

*កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា*

*យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤*

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣

### យុទ្ធសាស្ត្រទី ១

*ការអភិវឌ្ឍ លក្ខខណ្ឌការងារ និងសុខដុមនីយកម្ម នៃទំនាក់ទំនងវិជ្ជាជីវៈ*

**កម្មវិធី**

១. លើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង
២. ពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ
៣. ទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ
៤. ពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ របស់កម្មករនិយោជិត
៥. ពង្រឹងភាពសុខដុមរមនានៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ

### យុទ្ធសាស្ត្រទី ២

*ការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*

**កម្មវិធី**

១. ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
២. ពង្រីកការបណ្តុះបណ្តាលជំនាញដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម
៣. ពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងដៃគូនានាដើម្បីធានានិរន្តរភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៤. លើកកម្ពស់ប្រព័ន្ធអភិបាលកិច្ចវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
៥. ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍បច្ចេកវិទ្យាអនុវត្តន៍

### យុទ្ធសាស្ត្រទី ៣

*ការរក្សា និងបង្កើនមុខរបរ និងការងារនៅក្នុង និងក្រៅប្រទេស*

**កម្មវិធី**

១. បង្កើនឱកាសការងារសមរម្យ និងផលិតភាពខ្ពស់
២. ពង្រីកយន្តការវិសាលភាព និងប្រសិទ្ធភាពការផ្តល់សេវាមុខរបរ និងការងារឱ្យឆ្លើយតបកាន់តែប្រសើរតាមតម្រូវការអ្នកប្រើប្រាស់សេវា
៣. ពង្រឹងយន្តការវេទិកាការងារ និងបង្កើនការប្រមូលផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មានទីផ្សារការងារ
៤. ពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស និងការពារពលករទេសន្តរប្រវេសន៍ខ្មែរ
៥. បង្កើនផលិតភាពកម្លាំងពលកម្មដែលកំពុងស្ថិតក្នុងទីផ្សារការងារ

### យុទ្ធសាស្ត្រទី ៤

*ការអភិវឌ្ឍ របបសន្តិសុខសង្គម*

**កម្មវិធី**

១. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ
២. ពង្រឹង និងពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
៣. ជំរុញការរៀបចំ និងដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន
៤. ពង្រឹងការអនុវត្តរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ
៥. អភិវឌ្ឍសមត្ថភាពស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាពការផ្តល់សេវា

## យុទ្ធសាស្ត្រទី ៥ ÷ ការពង្រឹងសេវាគាំទ្រទូទៅ

១. ពង្រឹងការងាររដ្ឋបាល វិមជ្ឈការ និងវិសហមជ្ឈការដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ
២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធាន
៣. អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ និងកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
៤. ពង្រឹងកិច្ចសហប្រតិបត្តិការ សមភាពយេនឌ័រ និងសេវាសង្គម
៥. ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង និងគោលនយោបាយនានាពាក់ព័ន្ធនឹងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ